# ផ្លូវដែលដើរឆ្លងកាត់



# អារម្ភកថា

សៀវភៅដ៏តូចនេះគឺជាសៀវភៅដែលបង្ហាញអំពីកម្រងជីវិតរបស់ខ្ញុំ។

ជាទូទៅ មនុស្សយើងគ្រប់រូបតែងមានប្រវត្តិផ្ទាល់ខ្លួនប្លែកៗពីគ្នា ដោយសារការឆ្លងកាត់ច្រើនសម័យកាល ឆ្លងកាត់បរិយាកាសសង្គមដែលមានរូបភាពប្លែកៗច្រើនអនេកប្បការ និងការជួបប្រទះនឹងព្រឹត្តិការណ៍ផ្សេងៗគ្នា ។ល។ ជួនកាល ភាពរំភើបសប្បាយធ្វើឲ្យគេលង់លក់ក្នុងអារម្មណ៍ត្រេកត្រអាលសព្វបែបយ៉ាង ជួនកាលក៏មានហេតុការណ៍ខ្លះៗទៀតមកញាំញីសតិអារម្មណ៍ឲ្យក្តុកក្តួល ឈឺចាប់ កំសត់ ព្រាត់ប្រាស សោកសង្រេង ឥតល្ហែល្ហើយដែរ។ ទាំងអស់នេះ គឺជារឿងធម្មតារបស់ជីវិតមនុស្សលោកយើងនេះ។ ក៏ប៉ុន្តែអ្វីដែលមិនធម្មតា ហើយក៏មិនទូទៅដែរនោះ គឺជីវិតខ្លះជួបបញ្ហានេះបន្តិចនោះបន្តិច រីឯជីវិតខ្លះទៀតជួបប្រទះបញ្ហាអាក្រក់ៗច្រើន ហាក់បីដូចជាប្រមូលបញ្ហាមិនល្អទាំងនោះមកផ្ទុកក្នុងខ្លួនធ្វើឲ្យជីវិតផុងកប់ជ្រៅទៅក្នុងវិបត្តិផ្សេងៗ អស់ពេញមួយជីវិតក៏សឹងមាន។

ចំពោះជីវិតរបស់ខ្ញុំវិញ ខ្ញុំពុំអាចកំណត់បានថា វាឋិតនៅក្នុងប្រភេទនៃជីវិតណាមួយនោះទេ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំបានឆ្លងកាត់ក្នុងពេលកន្លងមកនេះ គឺវាធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ជីវិតរបស់ខ្ញុំតែងទទួលការបែកបាក់ ព្រាត់ប្រាសញឹកញាប់ពេកកន្លងហើយ! ប្រៀបបាននឹងដែកឆក់ ឬជ័រស្អិតម្យ៉ាង ( ដែលពាក្យបាលីហៅថា សិនេហ > ស្នេហ ) គឺស្នេហាដែលជាប់ស្អិតតែនឹងបញ្ហា " ការព្រាត់ប្រាស " នេះតែម្តង ។ ខ្ញុំតែងនឹកគិតថា ជីវិតរបស់ខ្ញុំជាជីវិតដែលពោរពេញទៅដោយការព្រាត់ប្រាសគឺ "ជួបហើយព្រាត់ ព្រាត់ហើយជួបៗៗៗ "។

ខ្ញុំយល់ថា ពុំមាននរណាមួយចង់ជួបការព្រាត់ប្រាសនេះទេ! វាពិបាកនឹងទទួលអារម្មណដែលពោរពេញទៅដោយភាពក្តុកក្តួល តក់ស្លុត សោក

សព្រេង ឬឈើចាប់នេះណាស់។ ទោះបីជាមានពេលខ្លះ ការព្រាត់ប្រាស បានទៅដល់ទីអស្តង្គត ហើយដែលអារម្មណ៍ព្រាត់ប្រាសនេះប្រែទៅជាធម្មតាវិញ ហើយក៏ដោយ ក៏ស្ត្រីដែលបាត់បង់ស្វាមីហើយដែលមានកូនសូវនាំកេឪពុក តើស្ត្រីនោះត្រូវប្រើទឹកមុខ និងដាក់អារម្មណ៍យ៉ាងណានៅក្នុងគ្រាដ៏លំបាកនោះទៅ? ។ តើបញ្ហាសេដ្ឋកិច្ចគ្រួសារ បញ្ហាសុវត្ថិភាពក្នុងលំនៅដ្ឋាន បញ្ហាទំនាក់ទំនងសង្គម ។ល។ វាចោទយ៉ាងដូចម្តេចៈទៅហ្ន៎ ? វាពិតជាពិបាកនឹង ប្រឈមមុខណាស់ ជាពិសេសក្នុងសម័យកាលនៃសង្គមបរិយាកាសដ៏ស្មុគស្មាញ។ ក៏ប៉ុន្តែ ខ្ញុំត្រូវតែបន្សល់ទុកនូវអ្វីដែលខ្លួនខ្ញុំផ្ទាល់ និងជីវិតរបស់ខ្ញុំជាមួយប្តីខ្ញុំ ឲ្យកូនចៅ និងញាតិមិត្តអ្នកអានបានដឹងគ្រាន់ជាការកំសាន្ត ឬជាការដកពិសោធន៍សំរាប់ជីវិតទៅចុះ!។

សូមបញ្ជាក់ជូនមិត្តអ្នកអានជ្រាបថាអ្វីៗដែលខ្ញុំបានរៀបរាប់ទាំងអម្បាលមានគឺសុទ្ធតែជាការពិត ឥតមានបញ្ចេញបញ្ចូល ឬកាច្បៃបំភ្លើសអ្វីឡើយ។ យ៉ាងណាមិញ អាចមានរឿងខ្លះឃ្លាតឆ្ងាយចាកពីការពិត ឬខុសតែបញ្ហានេះក៏មិនមែនជាចេតនារបស់ខ្ញុំទេ វាអាចជាការចងចាំមិនច្បាស់លាស់ ឬវាជាការភាន់ច្រឡំ សូមអធ្យាស្រ័យ!។ ម្យ៉ាងវិញទៀត ការចងក្រងសៀវភៅប្រវត្តិផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងពេលនេះ គឺពិតជាការសម្រេចចិត្តយ៉ាងលំបាក ពីព្រោះកន្លែងខ្លះ វាធ្វើឲ្យខ្ញុំអៀនខ្លួនក្នុងការដែលបានលាតត្រដាងអារម្មណ៍ទន់ជ្រាយរបស់ខ្លួន និងហែករឿងមិនល្អក្នុងគ្រួសារឲ្យគេដឹង។ ក៏ប៉ុន្តែ ខ្ញុំតាំងចិត្តជំនះ "អារម្មណ៍មិនទាន់សម័យ" របស់ខ្ញុំ ពីព្រោះខ្ញុំពុំអាចបង្កប់បោលនូវអ្វីដែលខ្ញុំបានទទួល ហើយចំណាយថាមពលអស់ពីវិញ្ញាណក្នុងការតស៊ូទប់ទល់នឹងបញ្ហាលំបាកដែលមកប៉ះទង្គិចជីវិតខ្ញុំបានឡើយ ហើយសង្ឃឹម ទុកក្នុងចិត្តថា កម្រងជីវិតនេះ ជាចំណីអារម្មណ៍ដែលបង្កប់ដោយបទពិសោធន៍ ក្នុងជីវិត និងភាពតស៊ូ និងជាពត៌មានដ៏មានសារៈសំខាន់ដែលទាក់ទងនឹងព្រឹត្តិការណ៍សង្គម ឆាកនយោបាយដ៏មានភាព បត់បែននិងលាក់មុខ និងសង្គមកិច្ចខ្មែរដែលមានការប្រែប្រួល ហើយដែលខ្ញុំ

ជឿជាក់ថា មានប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយពិចារណា និងស្គាល់ឲ្យកាន់តែច្បាស់ នូវជីវិតនយោបាយ និងសង្គមកិច្ចរបស់ខ្មែរយើងក្នុងសម័យកាលនីមួយៗ។

ជីវិតមនុស្សយើងគ្រប់រូបត្រូវឆ្លងកាត់ដំណាក់កាលយុវវ័យ មជ្ឈិមវ័យ ទៅបសិ្ចមវ័យដូចៗគ្នា។ ដូចនេះ ជីវិតត្រូវតែទទួលនូវបម្រែបម្រួល ធម្មជាតិរបស់ខ្លួន ដែលតម្រូវឲ្យខ្លួនប្រឹងគេចវេះអំពីបញ្ហាលំបាក សព្វបែបយ៉ាងតាមរយៈទង្វើដែលខ្លួនអាចធ្វើទៅបាន។ គឺនៅពេលនោះ ហើយដែលមនុស្សត្រូវការពត៌មាន ឬ គំរូពីមនុស្សចាស់ជំនាន់មុនៗ ឬ បទពិសោធន៍ផ្សេងៗ។ល។ ដើម្បីគេចវេះពីឧបសគ្គទាំងនោះ។ អ្វីដែលខ្ញុំមានបំណងចង់បន្សល់ទុកក្នុងសៀវភៅនេះ គឺជាបញ្ហានេះឯង។ ទាំងដំណើរជីវិត ទាំងការប្រព្រឹត្តិរបស់ខ្លួនខ្ញុំផ្ទាល់ក្តី របស់ប្តីខ្ញុំក្តី វាអាចចាត់ទុកជាតម្រុយជីវិត ឬជាបទពិសោធន៍ ឬជាគំរូសម្រាប់អ្នកទាំងអស់គ្នា ពីព្រោះខ្ញុំយល់ថា ខ្លឹមសារនៃកម្រងជីវិតនេះ ស្ថិតនៅត្រង់ស្មារតីតស៊ូឥតនឿយណាយរបស់យើងដែលខំព្យាយាមរស់តាមសម្មាជីវៈ ក្នុងជំហរខ្លួនទីពឹងខ្លួន ប្រកបដោយស្មារតីរឹងប៉ឹង ក្នុងឆន្ទៈស្រឡាញ់យុត្តិធម៌សង្គម ។

ខ្ញុំសូមឧទ្ទិសភាគផលកុសលដែលបានមកពីស្នាដៃដ៏តូចនេះ ជូនបុព្វការីដែលបានបន្សល់ទុកនូវទង្វើល្អៗ ទុកឲ្យកូនចៅ ញាតិផៅសន្តាន បងប្អូនជនរួមជាតិ និងអ្នកអានទាំងអស់គ្នា ។

សូមស្មារតីរឹងប៉ឹង និងឧត្តមគតិ មានដល់លោកអ្នកកុំបីអាក់ខាន។

ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១០

អ្នកស្រី **ពីង សយ ‿ ឆេងគី**

# មាតិកា

ទំព័រ


វគ្គទី ១ : ជីវិតក្រោយអាពាហ៍ពិពាហ៍..................................៥
វគ្គទី ២ : ការកសាងគ្រួសារថ្មី ...........................................១៨
វគ្គទី ៣ : ជីវិតក្នុងព្យុះនយោបាយ ...................................៥៥
វគ្គទី ៤ : ជីវិតគ្មានពំនឹង ..................................................៧៩
វគ្គទី ៥ : មេឃដ៏ស្រអាប់ ................................................១១១
វគ្គទី ៦ : ក្រោមនយោបាយមុខពីរ ...................................១៥៧
វគ្គទី ៧ : ជីវិតចុងក្រោយ ..............................................១៩៥

# វគ្គទី ១

## ជីវិតក្រោយអាពាហ៍ពិពាហ៍

## ឆ្នាំ ១៩៥៧ ...

ព្រឹកមួយនោះ (បីថ្ងៃក្រោយពិធីមង្គលការយើង) ប្អូនថ្លៃរបស់ខ្ញុំ **គីម ស្វរ** បានមកដល់ផ្ទះរបស់ខ្ញុំតាំងពីព្រលឹម ដើម្បីជួបនឹងប្តីខ្ញុំ **ពីង សយ** បែបប្រញាប់ប្រញាល់។ ប្រហែលកន្លះម៉ោងក្រោយមក គាត់ក៏លាចេញទៅវិញ ធ្វើឲ្យខ្ញុំឆ្ងល់សែនឆ្ងល់ ពីព្រោះគេទើបត្រឡប់ទៅភ្នំពេញវិញ បីថ្ងៃមុននេះសោះ ក្រោយពីចូលរួមក្នុងពិធីរៀបការរបស់ខ្ញុំ និង ម្យ៉ាងទៀតការធ្វើដំណើរពីភ្នំពេញមកដល់ស្រុកខ្ញុំ ត្រូវប្រើពេលយូរ ហើយមធ្យោបាយធ្វើដំណើរក៏ពិបាក គឺត្រូវជិះកាណូតអស់មួយយប់ទើបមកដល់។ តើប្អូនថ្លៃខ្ញុំនេះ ពេលមកមានការណ៍អ្វីទៅហ្ន៎ ? បានជាមកជួបជាមួយនឹងប្តីខ្ញុំ ទាំងតក់ក្រហល់យ៉ាងដូចនេះ?។

ខ្ញុំក៏ជជីកសួរគាត់ៗប្រាប់ថាប្អូនគាត់ ត្រូវធ្វើដំណើរទៅស្រុកក្រចឆ្មាជាមួយមិត្តភក្តិ ហើយក៏ឆ្លៀតពេលដែលកាណូតឈប់កន្លះម៉ោងក៏ឡើងមកលេងមួយភ្លែតទៅ។ ខ្ញុំមិនទាន់អស់ចម្ងល់នៅឡើយ... ប្តីខ្ញុំយល់ពីទឹកមុខរបស់ខ្ញុំក៏បញ្ជាក់បន្ថែមទៀតថា កុំឲ្យខ្ញុំបារម្ភអី គ្មានការណ៍អ្វីធំដុំនោះទេ ថ្ងៃក្រោយគង់តែដឹង។ ខ្ញុំនៅតែមិនអស់ចិត្ត ក៏ប៉ុន្តែគិតថាបើគាត់មិនចង់ឲ្យខ្ញុំដឹង ពេញ្ញើយកុំចង់ដឹងអី ។ ខ្ញុំក៏ទៅរៀបចំធ្វើបាយសម្លសម្រាប់អាហារថ្ងៃត្រង់។ យើងហូប បាយជុំគ្រួសារដូចសព្វដង។

យ៉ាងពិតខ្សៀលស្រាប់តែប្អូនប្រុសពៅរបស់ខ្ញុំ (ហៅអាអូន) ដែល

នៅលេងក្រោមផ្ទះ បានស្រែកហៅខ្ញុំថា "បងតូចៗ មានគេមករក "។ ប្អូនៗរបស់ខ្ញុំតែងហៅខ្ញុំដូច្នេះ ពីព្រោះបងស្រីរបស់គេមានពីរនាក់ដែលគេនាំគ្នាហៅថា "បងធំ " និង "បងតូច "។ ភ្ញៀវ (ម្នាក់នេះនៅរស់ដល់បច្ចុប្បន្នតែខ្ញុំសុំរក្សាសិទ្ធមិនបញ្ចេញឈ្មោះ) ដែលមករកនោះ បានប្រាប់ថាគេ ជាមិត្តរបស់ប្ដីខ្ញុំ ហើយចង់ជួបគាត់ ។ ក្រោយពីសម្ដែងការគួរសមចំពោះឪពុក និងម្ដាយខ្ញុំហើយ ភ្ញៀវនោះក៏អង្គុយជាមួយប្ដីខ្ញុំ និយាយគ្នាដោយរបៀបខ្សឹបខ្សៀវៗ។ ខ្ញុំឥតបានចូលរួមក្នុងការសន្ទនានោះទេ ហើយក៏ឥតបានដឹង ថាគេនិយាយពីអ្វីដែរ។ ប្រហែលជិតមួយម៉ោងក្រោយមក ខ្ញុំលឺឪពុកខ្ញុំនិយាយ នៅក្រោមផ្ទះជាមួយពូម្នាក់ ដែលខ្ញុំស្គាល់សំឡេងច្បាស់ថាគាត់ជាប៉ូលីស សាលាស្រុក។ ពូ " សៀន " សួរទៅកាន់ឪពុកខ្ញុំថា : "តើកូនប្រសារលោកពូដែលទើបនឹងរៀបការនោះនៅឯណា ? "។ ឪពុកខ្ញុំនាំពូសៀនឡើងលើផ្ទះ ដើម្បីមកជួបនឹងខ្ញុំ ហើយនិងប្ដីខ្ញុំ។ ក្នុងពេលដែលប៉ូលីសសៀនឡើង មកលើផ្ទះ ភ្លាមនោះមិត្តរបស់គាត់ក៏គេចខ្លួនចូលទៅក្នុងបន្ទប់ក្បែរនោះបាត់ទៅ ដោយមិនមាននរណាម្នាក់ចាប់អារម្មណ៍សោះ។ ពូសៀនផ្ដើមនិយាយៈ "លោកចៅហ្វាយស្រុកចង់ជួបលោក "។ គាត់និយាយដោយសម្លឹងមើលមុខប្ដីខ្ញុំ ។ ប្ដីខ្ញុំឥតមានប្រតិកម្មអ្វីទេ គាត់ក៏ទៅប្ដូរសំលៀកបំពាក់ រួចហើយគាត់ក៏ដើរទៅសាលាស្រុកដែលមានចម្ងាយប្រហែលជា ២០០ម៉ែត្រពីផ្ទះខ្ញុំ ជាមួយពូប៉ូលីសនោះបាត់ទៅ ។ ក្រោយពេលដែលអ្នកទាំងអស់គ្នាចេញទៅបាត់ មិត្តនោះក៏ចេញមកកន្លែងទទួលភ្ញៀវិញ ហើយនិយាយបែបលើកទឹកចិត្ត និងកម្សាន្តចិត្តខ្ញុំ ដើម្បីកុំឲ្យខ្ញុំព្រួយបារម្ភ ។

ហេតុការណ៍ដែលបានកន្លងទៅក្នុងមួយពព្រឹកភ្លែកនេះ វាធ្វើឲ្យអារម្មណ៍របស់ខ្ញុំប្រែប្រួលអស់មួយរំពេច ។ អ្វីដែលខ្ញុំក៏ដូចជាស្ត្រីគ្រប់រូបរំពឹងគិតថារាពាហ៍ពិពាហ៍នឹងនាំមកនូវសុភមង្គលពេញបរិបូរណ៍ ក៏ប៉ុន្តែឥឡូវវាប្រែក្លាយទៅជាសេចក្ដីព្រួយបារម្ភដែលគ្មានទិសដៅ ។

ប្រហែលជាមួយម៉ោងក្រោយមក ឡានហ្ស៊ីបមួយបរមកឈប់នៅមុខផ្ទះខ្ញុំ ។ ប្ដីខ្ញុំចុះពីឡាននោះ ហើយឡើងមកលើផ្ទះដោយរក្សាទឹកមុខធម្មតា ។ គាត់មកជិតខ្ញុំ ហើយយកដៃមកដាក់លើស្មាខ្ញុំ ទះស្មាខ្ញុំតិចៗ រួចនិយាយថា : " គេមកចាប់បងហើយ តែកុំបារម្ភអី ... មិនមានរឿងអ្វីធំដុំទេ! "។ អារម្មណ៍របស់ខ្ញុំក្នុងពេលនោះ ហាក់ដូចជាមានភាពច្របូកច្របល់ជាខ្លាំង មិនដឹងថាតើគួរយំ ឬស្រែក ឬបញ្ចេញកំហឹង ឬស្ដីបន្ទោសខ្លួនឯងយ៉ាងដូចម្ដេចទេ ក៏ប៉ុន្តែឥរិយាបថខាងក្រៅរបស់ខ្ញុំ ខ្ញុំឥតបានបញ្ចេញប្រតិកម្មអ្វីឡើយ ពីព្រោះខ្ញុំស្ថិតនៅចំពោះមុខមនុស្សច្រើនគ្នា ដែលមានឪពុកខ្ញុំ ម្ដាយខ្ញុំ ប្អូនខ្ញុំ និងជាពិសេសមិត្តម្នាក់របស់ប្ដីខ្ញុំ។ ខ្ញុំខំទប់ស្មារតីដែរ... ក៏ប៉ុន្តែដោយ និស្ស័យភ្នែកទន់របស់ខ្ញុំ រំពេចនោះ ទឹកភ្នែកប្រូនដប់ដំណក់ក៏រមៀលធ្លាក់ចុះ មកឯងៗ ដោយមិនដឹងខ្លួន ។

ខ្ញុំដើរតាមក្រោយប្ដីខ្ញុំ ដែលត្រូវទៅឡើងឡានជាមួយគេ ។ គេឲ្យគាត់ឡើងអង្គុយខាងមុខក្បែរអ្នកបើកបរ និងមានអ្នកជិះខាងក្រោយពីរនាក់ទៀតដែរ។ ឡានបានបើកចេញពីផ្ទះខ្ញុំទៅបាត់ហើយ។ ខ្ញុំតាមមើលរហូតដល់ឡានបត់ទៅផ្លូវមាត់ទន្លេ បាំងបាត់លែងមើលឃើញ។ ខ្ញុំនៅតែឈរកន្លែងដដែល តែកែវភ្នែកខ្ញុំបែរសម្លឹងទៅមើលទឹកទន្លេមេគង្គដែលកំពុងហូរតាមបណ្ដោយស្រុកមុខផ្ទះខ្ញុំ។ ខ្ញុំឥតបានបញ្ចេញការសោកសង្រេងឬភាពក្តុកក្តួល ក្នុងចិត្តច្រើនប៉ុន្មានទេ ពីព្រោះខ្ញុំធ្លាប់ដឹងលឺហេតុការណ៍នេះតាំងពីពេលមុន ខ្លះមកហើយ តាមរយៈមិត្តភក្តិ គូប្រដែង និងអ្នកជំទាស់ពីពេលពាហ៍ពិពាហ៍ របស់ខ្ញុំ។ គេប្រយោលពាក្យថា "ចាំមើលចុះ! យកប្ដីជាអ្នកនយោបាយ, ជាអ្នកសរសេរកាសែត មុខជាត្រូវយួរចានស្រាក់ហើយ" ។ ពាក្យនេះចង់ថា ប្ដីនោះនឹងត្រូវគេចាប់ដាក់គុក រីឯប្រពន្ធត្រូវតែយួរចានស្រាក់យកបាយទៅឲ្យប្ដី ។ គេថាអញ្ចឹង ឥឡូវអញ្ចឹងមែនហ្ន៎ ! ។

បួនថ្ងៃក្រោយមក បងស្រីរបស់ខ្ញុំ **លន់ អេង** ដែលបានដំណឹងពីរឿងការចាប់ខ្លួនប្ដីរបស់ខ្ញុំ ក៏បានមកសួរសុខទុក្ខប្អូនស្រីរបស់គាត់។ បងអេងរស់

នៅជាមួយប្ដីគាត់ដែលជាទាហានបារាំងនៅបន្ទាយទន្លេអំ ក្នុងក្រុងកំពង់ចាម។ បងស្រីបាននិយាយប្រាប់ខ្ញុំថា " មីអូនអើយ! ឯងដឹងទេ ប៉ាវាបានប្រាប់បងថា លោកតិញដែលមកចាប់ប្ដីឯងនោះ បាននិយាយប្រាប់គាត់ថា សំណាងហើយ ថ្នាក់លើគេវាយតេឡេក្រាមឲ្យមកចាប់លោក **តិន សយ** តាំងពីថ្ងៃចូលរោងការមកម្ល៉េះ ក៏ប៉ុន្តែគេវាយខុស គេដាក់ថា លោក**សយ**នៅស្ទឹងត្រង់តែគេបែរជាបញ្ជូនតេឡេក្រាមទៅស្ទឹងត្រែងទៅវិញ ។ ហេតុនឹងហើយបានជាយឺតអស់បីថ្ងៃ "។ លោកតិញនេះ ជាអធិការប៉ូលីស ធ្វើការនៅខេត្តកំពង់ចាម មានការិយាល័យប្រចាំនៅចំការកៅស៊ូបឹងកេត ជាពួកម៉ាកជិតដិតរបស់បង **យសុទ្រា** (ប្ដីបងស្រីខ្ញុំ) ។ បងស្រីបានបន្តទៀតថា "លោកតិញបានប្រាប់ប៉ាវាថា នៅពេលដែលគេឲ្យលោក**សយ**ឡើងឡាន លោកសយនេះឥតមានប្រែទឹកមុខអីសោះ ហើយនៅតាមផ្លូវពេលឡានកំពុងបរទៅមុខ លោកសយបាននិយាយទៅកាន់គាត់ថា " ម៉េចក៏លោកឲ្យខ្ញុំជិះឡាននៅខាងមុខ លោកមិនខ្លាចខ្ញុំហក់លោតចេញពីឡានរត់ចូលព្រៃគេចខ្លួនបាត់ទេអី ? យីហ្វសចិត្តតែម្ដង...! ហើយគាត់និយាយរហូតនៅតាមឡាន ហាក់ដូចជាមិនគិតថា ខ្លួនគាត់ជាអ្នកមានទោសដែលគេកំពុង ចាប់ហើយនាំខ្លួនចូលគុកទេ "។ លោកតិញបញ្ជាក់ថា "នរណាក៏ដោយ ឲ្យតែត្រូវប៉ូលីស ឬតិញចាប់ខ្លួនអ្នកនោះ ប្រាកដជាមុខឡើងស្លាន់ហើយ តែដោយឡែកប្អូនថ្លៃរបស់យសុទ្រាឯងឥតបញ្ចេញភាពតក់ស្លុតអ្វីទាំងអស់។ លោកចាងហ្វាងកាសែតរូបនេះពិតជាក្លាហាន និងរឹងប៉ឹងមែន! "។ បងស្រីរបស់ខ្ញុំបញ្ជាក់ថែមទៀតថា សំដីទាំងអស់នេះបានផុសចេញពីមាត់លោកតិញប្រាប់ប្ដីគាត់ នៅពេលដែលគាត់បានចាប់ប្ដីរបស់ខ្ញុំបញ្ជូនចូលទៅកន្លែងប៉ូលីសព្រហ្មទណ្ឌនៅក្រុងភ្នំពេញ។

ហេតុការណ៍ដ៏ក្រៀមក្រំនេះធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំមានទឹកមុខស្រពោនស្រងាត់។ ឪពុករបស់ខ្ញុំដែលកាល ក្នុងពិធីមង្គលការញញឹមរហូតព្រោះសប្បាយចិត្តនឹងបានកូនប្រសារល្អ មានចំណេះដឹងខ្ពស់ មកពីប្រទេស

បារាំង ហើយជាអ្នកប្រឡូកក្នុងឆាកនយោបាយមានទំនោរតាមលទ្ធិបែប " ប្រជាធិបតេយ្យ " ថែមទៀត ។ គាត់ដឹងយ៉ាងដូច្នេះ គឺដោយសារគាត់ឃើញឈ្មោះ **ពឹង សុយ** កាលពីមុនជាអ្នកសរសេរអត្ថបទ និពន្ធកាសែត "ប្រជាធិបតេយ្យ "។ គឺជាកាសែតបម្រើលទ្ធិប្រជាធិបតេយ្យ ដែលឲ្យតម្លៃខ្ពស់ទៅលើប្រជារាស្ត្រ ជាម្ចាស់លើប្រទេសរបស់ខ្លួន។ ឪពុកខ្ញុំតែងអានកាសែតនេះដោយពេញចិត្តយ៉ាងខ្លាំង។ ក្រោយមកទៀត ឪពុកខ្ញុំបានឃើញកាសែតថ្មីមួយទៀតទើបចេញផ្សាយគឺកាសែត " ឯកភាព " ដែលមានឈ្មោះ **ពឹង សុយ** ជាចាងហ្វាងកាសែតនេះតែម្ដង ។

កាសែតឯកភាពក៏មិនខុសពីកាសែតប្រជាធិបតេយ្យដែរ។ កាសែតនេះមានទំនោរគាំទ្រប្រជារាស្ត្រឲ្យប្រជារាស្ត្រយល់ពីសិទ្ធិរបស់ខ្លួនក្នុងការសម្រេច ជោគវាសនារបស់ប្រទេស ហើយហ៊ានសរសេរតិះទៀនដល់អ្នកកាន់អំណាចរូបណាដែលធ្វើខុស ឬ មិនគិតគូរដល់សុខទុក្ខរបស់ប្រជារាស្ត្រ។ ហេតុដូចនេះហើយបានជាឪពុករបស់ខ្ញុំ ពេញចិត្តនឹង កាសែតថ្មីនេះកាន់តែខ្លាំងហើយ ជាពិសេសឈ្មោះប្ដីរបស់ខ្ញុំនេះក៏កាន់តែធ្វើឲ្យគាត់សសើរនិងចងចាំក្នុងចិត្តរហូតដល់ដើរអួតប្រាប់គេឯងក្នុងស្រុកភូមិថាអ្នកចូលមកស្ដីដណ្ដឹងកូនស្រីរបស់គាត់ គឺលោក **ពឹង សុយ** ជាចាងហ្វាងកាសែត " ឯកភាព " ដែលជាអ្នកស្នេហាជាតិមួយរូប។ លើសពីនេះទៅទៀតអារម្មណ៍រំភើបសប្បាយរីករាយរបស់គាត់កាលពីបីថ្ងៃមុននេះនៅពុំទាន់អស់ចំហាយនៅឡើយ ដោយក្នុងពិធីការរបស់កូនស្រីគាត់មានភ្ញៀវច្រើនសន្ធឹកសន្ធាប់ជាអ្នកធំ មកពី ភ្នំពេញដូចជា លោក ហ៊ូ យន់, [illegible] ពេក, [illegible] ម៉ាន់... ជាអ្នកមានត្រកូលខ្ពស់ ជាអ្នកមាននៅខេត្តសៀមរាប ([illegible]បងឡុប ដែលជាប្អូនស្រីរបស់ លោកអាំង គឹមឃន់ ) ជាដើម ។ ជាពិសេសទៅទៀត គឺញាតិសណ្ដានរបស់សាមីខ្លួនខាងប្រុសក៏មកផ្ដល់[illegible]ច្រើនដែរ ។ តែអនិច្ចាអើយ ! ឥឡូវនេះ ឪពុកខ្ញុំបែរជា[illegible] ដើរចុះដើរឡើង ម្ដងចុះទៅក្រោមផ្ទះ ម្ដងឡើងលើផ្ទះ កាន់នេះ

បន្តិច កាន់នោះបន្តិច ឥតឆ្ពោះត្រង់ណាឡើយ មិនដឹងថាតើគាត់មានអារម្មណ៍យ៉ាងដូចម្តេចដែរទេ?។ រីឯម្តាយខ្ញុំវិញ គាត់មានចិត្តចង្អៀតចង្អល់បន្តិច គាត់សម្រាន្តលើអង្រឹងយោលតេកតោកៗពេលតែម្នាក់ឯងថា "ឱសហើយៗ ស្តាយណាស់ៗ!"។ ខ្ញុំមិនអន់ចិត្ត ឬ ខឹងនឹងម្តាយខ្ញុំទេពីព្រោះថាម្តាយខ្ញុំធ្លាប់ទទួលការលំបាកក្នុងពេលដែលឪពុករបស់ខ្ញុំបានចូលរួមជួយឃោសនាឲ្យគណបក្ស " ប្រជាធិបតេយ្យ " ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតនៅមណ្ឌលស្រុកស្ទឹងត្រង់នាឆ្នាំ ១៩៥៣ ហើយត្រូវគេចាប់យកទៅដាក់គុកអស់ជាច្រើនខែ ។ ដោយឡែកជីដូនរបស់ខ្ញុំដែលកាលណោះមានព្រះជន្មប្រហែលជាង ៧០ ឆ្នាំហើយនោះ តែងនិយាយបន្ទុចបង្អាក់សំដីរបស់ម្តាយខ្ញុំ នៅពេលដែលលឺម្តាយខ្ញុំរអ៊ូ ដោយពោលពាក្យថា "**មីឃីន**អើយ (ឈ្មោះម្តាយខ្ញុំ) កុំរអ៊ូអញ្ចឹងអញមិនជឿថាវាហ្នឹងជាមនុស្សអាក្រក់ធ្វើអ្វីខុសនោះទេ!ប្រហែលជាគេចាប់វាច្រឡំទេដឹង..."។ ជីដូនរបស់ខ្ញុំមានអារម្មណ៍បែបនេះ ដោយណាមួយគាត់ពេញចិត្តនឹងចៅប្រសារ ដែលមានសម្បុរស្បែកសជ្រះបែបកូនចៅចិន រីឯអ្នកមកស្តីដណ្តឹងចៅគាត់ពេលមុនៗច្រើនតែមានសម្បុរខ្មៅ បានន័យថាគាត់ចង់បានចៅប្រសារបែបនេះណាស់។ ដូច្នេះគាត់ត្រូវតែនិយាយការពារ ។

ចំពោះរូបខ្ញុំវិញ ខ្ញុំហាក់ដូចជាហេងហាងបន្តិចដែរ ពីព្រោះការរស់នៅក្នុងឋានៈជាប្តីប្រពន្ធជាមួយគ្នាបានបីថ្ងៃនោះ គឺជារយៈពេលមួយដ៏ខ្លីបំផុតគួបផ្សំនឹងទំនាក់ទំនងរបស់ខ្ញុំនិងគាត់មានតិចតួចនៅមុនពេលរៀបការ ធ្វើឲ្យខ្ញុំមិនសូវមានអនុស្សាវរីយ៍ផ្អែមល្ហែមច្រើនឡើយ។ យើងមិនដែលបានដើរលេងបែបគូសង្សារម្តងណាឡើយ សូម្បីតែនៅពេលមួយនោះប្អូនថ្លៃរបស់គាត់ដែលធ្វើគ្រូបង្រៀននៅសាលា"ព្រះជ័យជេស្ឋា "នៅក្រោយវាំង (អ្នកគ្រូ**គាន់ សារឿន** ដែលជាប្រពន្ធលោក ពេទ្យ **ពីន គឹមសៀ** ប្អូនប្រុសបងសយហើយដែលធ្លាប់បានស្គាល់ខ្ញុំកាលនៅរៀនលីសេស្សេនារី) បានសុំឲ្យខ្ញុំទៅជួបបង សយនៅហាងលក់គុយទាវ "ថៃសាន " ក៏ខ្ញុំឥតហ៊ានទៅជួបគាត់

តែម្នាក់ឯងដែរ។ ខ្ញុំនាំទាំងមិត្តស្រីម្នាក់ (បង **គាន់ ម៉ារ៉ា**) ដែលរៀននៅលីសេ្សនារីទៅជាមួយផង។ ហេតុការណ៍ទាំងអស់នេះហើយដែលធ្វើឲ្យមនោសញ្ចេតនារបស់ខ្ញុំ និងប្តីខ្ញុំពុំទាន់ចាក់ស្រេះជាធ្លុងមួយនៅឡើយ រហូតដល់ពេលខ្លះ ខ្ញុំស្មានថាការជួបគ្នាបីថ្ងៃនោះ គឺជាការយល់សប្តិទៅវិញ... ។ ក៏ប៉ុន្តែអ្វីដែលមិនប្រក្រតីនោះ គឺក្រសែភ្នែករបស់អ្នកភូមិ អ្នកស្រុក និងការនិយាយបួញមាត់បួញករបស់ពួកគេនោះ នៅពេលដែលឃើញខ្ញុំដើរកាត់ ។ ក្រៅពីនោះទៅទៀត ខ្ញុំតែងធុញថប់យ៉ាងខ្លាំង នៅពេលដែលញាតិមិត្តជិតខាងមកដដឹកសួរខ្ញុំអំពីរឿងរ៉ាវនិងមូលហេតុដែលបង្កើតឲ្យមានបញ្ហាដ៏អពមង្គលនោះ។ ក៏ប៉ុន្តែទោះបីជាខ្លួនខ្ញុំកំពុងស្ថិតនៅក្រោមបរិយាកាសដ៏ស្មុគស្មាញ និងវិបត្តិខាងផ្លូវចិត្តក៏ដោយ ក៏ខ្ញុំខំតាំងចិត្តជាប់ជានិច្ចថា ខ្ញុំមិនត្រូវចុះចាញ់ ការបំពារបំពានឡើយ ហើយក៏ខ្ញុំមិនត្រូវស្តីបន្ទោសខ្លួនឯងដែរ ពីព្រោះការសម្រេចចិត្តរបស់ខ្ញុំគឺរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលមានចរិតត្រឹមត្រូវ មានសេចក្តីក្លាហាន ប្រកបដោយឧត្តមគតិស្រឡាញ់យុត្តិធម៌សង្គម។ ម្យ៉ាងទៀតខ្ញុំមានគំនិតស្អប់បុរសដែលធ្វើបាបប្រពន្ធកូន តួយ៉ាងដូចជាបងថ្លៃរបស់ខ្ញុំ ដែលជាកូនលោកធំ ហើយមានរូបសម្បត្តិសង្ហា តែងដើរលេង ស៊ីផឹក ស្រីញី ចោលផ្ទះសម្បែងធ្វើឲ្យបងស្រីខ្ញុំពិបាកចិត្ត។ ខ្ញុំក៏ក្តៅក្រហាយណាស់ដែរ រហូតដល់ពេលខ្លះ ខ្ញុំនិយាយបញ្ចេះបងស្រីខ្ញុំ ឲ្យលែងប្តីនោះចោលទៅ ចាំខ្ញុំជួយចិញ្ចឹមនៅពេលដែលខ្ញុំចេញធ្វើការមានប្រាក់ខែ ។ អញ្ចឹងហើយបានជា ខ្ញុំតែងគិតថា ត្រូវពិចារណាឲ្យល្អិតល្អន់អំពីលក្ខណៈសម្បត្តិរបស់អ្នកដែលចូលមកស្តីដណ្តឹងខ្ញុំ។ ចំពោះបងសយ ថ្វីត្បិតតែខ្ញុំឥតបានស្គាល់ដោយផ្ទាល់ ហើយដែលយើងស្ថិតនៅក្នុងវ័យខុសគ្នាច្រើន (គាត់មានអាយុបងខ្ញុំដប់ឆ្នាំ) ហើយម្នាក់មានស្រុកកំណើតនៅខេត្តសៀមរាប ម្នាក់នៅខេត្តកំពង់ចាម ក៏ពិតមែន ក៏ប៉ុន្តែតាមរយៈមិត្តម្នាក់ដែលរៀននៅវិទ្យាល័យនារីក្នុងអន្តេវាសិកដ្ឋានជាមួយគ្នា ( **នាងម៉ាន** ដែលមានផ្ទះនៅជិតផ្ទះបង **សយ** នៅស្រុកពួក ខេត្តសៀមរាប ) គេតែងអួតអំពីគុណសម្បត្តិរបស់គាត់ថា៉ ៉ ខ្ញុំ តែងយកគំរូតាម

គុ **សាយ** (ឈ្មោះនៅផ្ទះរបស់បងសយ ) ជាកូនលោក **យាយហ្វត** បានទៅរៀនដល់ស្រុកបារាំង ហើយត្រឡប់មកវិញក៏ឥតធ្វើឫក ធ្វើរាង ឬ ក្រអឺតក្រទមអ្វីដែរ ។ ពេលទៅលេងស្រុកម្តងៗ គាត់តែងជួយធ្វើការងារ ម្តាយម៉េម៉ាយរបស់គាត់ គាត់ចេះគួរសមជាមួយអ្នកស្រុក អ្នកភូមិ ធ្វើឲ្យអ្នកស្រុកស្រឡាញ់ ហើយសរសើរ រហូតដល់យកគាត់ធ្វើជាឧទាហរណ៍ក្នុងការប្រដៅប្រដៅកូនចៅរបស់គេថែមទៀត "។ ម្តាយអារ៉ាន ព្រមទាំងអ្នកភូមិផ្សេងទៀត ឲ្យដំបូន្មានកូនចៅខ្លួនថា " "ត្រូវធ្វើដូចកូនប្រុស **យាយហ្វត** អញ្ចឹងទើបល្អ ខំរៀនសូត្រ មានចំណេះវិជ្ជាខ្ពង់ខ្ពស់ ហើយចេះជួយការងារផ្ទះសម្បែង..."។ បន្ថែមពីនេះ មានមិត្តនារីម្នាក់ទៀត នាង "**មូចាន់**" ដែលនៅស្រុកពួកជាមួយបងសយដែរនោះ ក៏តែងសរសើរពីគុណសម្បត្តិរបស់គាត់ថា គាត់ជាមនុស្សចេះដឹងខ្ពស់ជាងគេនៅស្រុកពួក ហើយជាមនុស្សទី១ក្នុងខេត្តសៀមរាប ដែលបានប្រលងជាប់សញ្ញាប័ត្រ **ឆាក់ឌុប** (ក្នុងជំនាន់នោះកម្រមាននរណារៀនបានដល់ឌីប្លូមផង កុំថាឡើយដល់ទៅបាក់ឌុប)។អញ្ចឹងហើយតាមរយៈការឲ្យតម្លៃខ្ពស់របស់មិត្តនារីទាំងពីរនាក់របស់ខ្ញុំ ចំពោះបង**សយ** ធ្វើឲ្យខ្ញុំគោរព និងលួចពេញចិត្តគាត់ដោយមិនដឹងខ្លួន សូម្បីតែមិនទាន់ស្គាល់គាត់ក៏ដោយ...។ ដូចនេះការសម្រេចចិត្តនេះ វាក្លាយទៅជាផ្នត់គំនិតកប់ជ្រៅក្នុងសតិអារម្មណ៍របស់ខ្ញុំ ជារៀងរហូតមក ទោះបីជាឋិតនៅក្នុងស្ថានភាពបែបណាក៏ដោយ ។

មួយខែក្រោយមក ពេលវាកងធំខែកក្កដាបានមកដល់។ ប្អូនប្រុសរបស់គាត់បានសរសេរសំបុត្រផ្ញើមកខ្ញុំ សុំឲ្យខ្ញុំមកភ្នំពេញ។ ពេលមកដល់ទីក្រុងគាត់បាននាំខ្ញុំទៅជួបនឹងបងសយ ដែលជាប់នៅក្នុងមន្ទីរឃុំឃាំង "គុកធំ "។ ឆ្មាំយាមគុកនាំយើងចូលទៅក្នុងកំផែងគុក រួចឲ្យទៅអង្គុយរង់ចាំនៅក្នុងបន្ទប់មួយ ។ ប្តីខ្ញុំចូលមកដល់ដោយមានទឹកមុខស្រស់ស្រាយ។ រូបរាងកាយរបស់គាត់ឥតមានអ្វីប្លែកបន្តិចសោះ មិនស្គមស្គាំង ឬស្លេកស្លាំងដូចដែល ខ្ញុំបាននឹកគិតស្មាននោះឡើយ ។ គឺមិនដូចឪពុកខ្ញុំ ដែលពីដំបូងគេ

ចាប់គាត់ដាក់គុកនៅខេត្តកំពង់ចាម រួចក៏បញ្ជូនមកដាក់ "គុកធំ" នៅភ្នំពេញនេះដែរ។ មិនទាន់បានមួយខែផង ឪពុកខ្ញុំចុះស្គម ហើយថែមទាំងត្រូវគេកោរត្រងោលទៀត មើលស្ទើរតែលែងស្គាល់តែម្ដង ។ នៅពេលដែលខ្ញុំទៅសួរសុខទុក្ខ ឪពុកខ្ញុំនៅគុកធំនោះហើយ <u>គឺជាលើកដំបូងដែលបងសយបានឃើញខ្ញុំ</u> ក្នុងខណៈដែលគាត់ក៏ទៅសួរសុខទុក្ខអ្នកទោសនយោបាយមួយចំនួនដែរ ដែលក្នុងនោះមានលោក **កេង វ៉ាន់សាក់** ជាដើម (លោក **កេង វ៉ាន់សាក់** គឺជាបញ្ញវន្តជឿនលឿន ហើយដែលជាសាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រនៅសកលវិទ្យាល័យភ្នំពេញ ) ។

ក្នុងពេលជួបគ្នានោះ បងសយឥតបាននិយាយអំពីអ្វីដែលទាក់ទងនឹងមនោសញ្ចេតនាប្ដីប្រពន្ធសោះ មានតែការនិយាយលើកទឹកចិត្ត និងបង្ហាញពីមូលហេតុនៃការចាប់ឃុំខ្លួនគាត់ប៉ុណ្ណោះ។ សូមជំរាបថា កាលពីសម័យនោះឲ្យតែមនុស្សណាហ៊ានប្រឆាំងនឹងរាជរដ្ឋាភិបាល អ្នកនោះឯងនឹងត្រូវបានគេចោទប្រកាន់ ហើយចាប់ខ្លួនដោយឥតចាំបាច់មានដីកាចេញពីតុលាការឡើយ។ បងសយប្រាប់ខ្ញុំថា "អូនឯងកុំបារម្ភ ប្រហែលជាបងជិតបានចេញវិញហើយ ពីព្រោះគេចោទថា បងសរសេរកាសែតរិះគន់ លោកចៅហ្វាយស្រុកដែលធ្វើការងារធ្វេសប្រហែស និងឃឹតឃ៉ារ។ បងប្រើពាក្យថា " [ដូចអូសឫស្សី បញ្ច្រាសចុង...] ។ ចៅហ្វាយស្រុកនោះខឹងហើយក៏ប្ដឹងចោទប្រកាន់ទៅ! "។ ១៥ នាទីនៃការសួរសុខទុក្ខបានកន្លងផុតទៅយ៉ាងឆាប់រហ័ស ខ្ញុំដើរចេញពីកំផែងគុកធំទាំងល្ហិតល្ហៃ។ ខ្ញុំបន្តសម្រាកលេងនៅភ្នំពេញបួន–ប្រាំថ្ងៃ ទៀត តែឥតស្នាក់នៅផ្ទះប្អូនថ្លៃខ្ញុំទេ គឺទៅនៅផ្ទះបងជីទូតមួយនៅក្រោយវាំងដែលជាផ្ទះខ្ញុំធ្លាប់នៅផ្ញើខ្លួនកាលខ្ញុំរៀននៅសាលាបណ្ដុះបណ្ដាលគ្រូបង្រៀន នៅក្រោយលីស្សេស៊ីសុវត្ថិពីឆ្នាំ ១៩៥៥ ដល់ ឆ្នាំ ១៩៥៦ ។ នៅពេលនោះខ្ញុំបានទៅលេងនឹងមិត្តភក្តិចាស់ៗជាច្រើនដែលរៀន នៅវិទ្យាល័យនារី ជាមួយគ្នាតាំងពីឆ្នាំ ១៩៥០ ក្នុងចំណោមមិត្តចាស់នោះ មានមិត្តនារីម្នាក់ ឈ្មោះ **ស៊ីមុំន** ដែលប្ដីរបស់

គាត់ឈ្មោះ **គីមអាន** ជាមិត្តសំឡាញ់របស់ប្ដីខ្ញុំដែរ។ អាប៊ុនបាននាំខ្ញុំទៅលេងផ្ទះមិត្តរបស់ខ្ញុំខ្លះៗ ហើយក៏បាននាំខ្ញុំទៅលេងផ្ទះមិត្តភក្តិរបស់ប្ដីខ្ញុំមួយចំនួនដែរ។ លោកទាំងអស់នោះសុទ្ធតែជាបញ្ញាវន្តមកពីបរទេស ។ យើងជជែកគ្នាលេងពីនេះពីនោះ តែភាគច្រើននិយាយនៅក្នុងប្រធានបទនយោបាយសង្គម ហើយមានលោកខ្លះច្រើន និយាយអួតពីគុណសម្បត្តិរបស់ប្ដីខ្ញុំប្រាប់ខ្ញុំថែមទៀត។ ប្រហែលជាពួកគាត់នឹកគិតថា និយាយសរសើរអញ្ចឹងទៅនឹងធ្វើឲ្យខ្ញុំកាន់តែមានទំនុកចិត្ត ចំពោះអ្វីដែលប្ដីខ្ញុំបានធ្វើកន្លងមក ។ សរុបសេចក្ដីទៅ ជំនួបជាមួយលោកទាំងអស់នោះ ពិតជាធ្វើឲ្យខ្ញុំធូរស្រាលក្នុងចិត្តច្រើន ហើយក៏មានការកក់ក្ដៅថែមទៀតដែរ ។

---

បវេសនកាលឆ្នាំសិក្សា ១៩៥៧–១៩៥៨ បានចាប់ផ្ដើម ។ ខ្ញុំត្រូវគេចាត់តាំងឲ្យនៅកាន់ថ្នាក់ឧត្តមដ្ឋាន ឬថ្នាក់ទី ៦ (ជំនាន់នោះថ្នាក់បឋមសិក្សាចែកចេញជាពីរកំរិត គឺបឋមសិក្សាបឋមភូមិ ៣ថ្នាក់ និងបឋមសិក្សាបំពេញវិជ្ជា ៣ថ្នាក់ ដែលមានឈ្មោះ ថ្នាក់ទី ១ កុមារដ្ឋាន, ថ្នាក់ទី ២ បរិវចនដ្ឋាន, ថ្នាក់ទី ៣ អាទិកដ្ឋាន, ថ្នាក់ទី ៤ មជ្ឈិមដ្ឋានទី ១, ថ្នាក់ទី ៥ មជ្ឈិមដ្ឋានទី ២, និង ថ្នាក់ទី ៦ ឧត្តមដ្ឋាន ) ។ ខ្ញុំបង្រៀននៅសាលាបឋមសិក្សាបំពេញវិជ្ជាព្រែកកក់ ក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលជាស្រុកកំណើតរបស់ខ្ញុំ ។

ស្រុកស្ទឹងត្រង់ស្ថិតនៅតាមបណ្ដោយទន្លេមេគង្គ ជាស្រុកមួយខុសពីស្រុកនានាក្នុងតំបន់ ។ គឺជាកំពង់ផែសំខាន់ ដឹកផលិតផលពីទីរួមខេត្តក្រចេះឆ្លងកាត់ទៅខេត្តកំពង់ចាម បន្តទៅក្រុងភ្នំពេញ ។ កប៉ាល់ កាណូតធំៗ ដែលដឹកអ្នកដំណើរ និងទំនិញសព្វសារពើ ពីខេត្តក្រចេះទៅភ្នំពេញតែងមកឈប់ចតនៅកំពង់ផែស្រុកស្ទឹងត្រង់ជានិច្ច ពីព្រោះផលិតផលនៅក្នុងតំបន់នោះមាន ពោត ល្ង សណ្ដែកបាយ សណ្ដែកសៀង សណ្ដែកដីកប្បាស និងផល្លានុផល ផ្សេងៗទៀត ដូចជា ក្រូច សាវម៉ាវ ខ្នុរ ។ល។

ត្រូវដឹកពីឃុំស្រែវាល , ស្វាស, មាឃ... មកចុះផែនៅទីនោះ ។ បើនិយាយពីទីផ្សារវិញ ស្រុកនេះមានផ្ទះលក់ទំនិញហូរហែតាមបណ្ដោយមាត់ទន្លេ ។ ទំនិញជាច្រើនសុទ្ធតែនាំចូលពីបរទេស មានគ្រឿងកំប៉ុង គ្រឿងទេស ប័រ ហ្វ្រូម៉ាស ទឹកស៊ីអ៊ីវ ម៉ាហ្ស៊ី ស្រាថ្លៃៗ ។ល។ ដែលសុទ្ធតែធ្វើនៅប្រទេសបារាំង និងប្រទេសនៅក្រោមអាណាព្យាបាលរបស់បារាំង ដូចជាមកពីម៉ារ៉ុក(Maroc) ជាដើម។ រឿងដែលចម្លែកមួយទៀត គឺរៀងរាល់ថ្ងៃអាទិត្យ ទីផ្សារនៅស្រុកខ្ញុំនេះ មានទិដ្ឋភាពប្លែកអស្ចារ្យ ។ ឡានធំៗដប់ប្លែគ្រឿង ដឹកពួកគូលីចំការកៅស៊ូ ឈរបញ្ជ្រុះណែនណាន់តាន់តាប់ក្នុងឡាន ចុះមកទិញស្បៀង និងវត្ថុចាំបាច់ ប្រើប្រាស់ប្រចាំសប្ដាហ៍។ ផ្ទះលក់ទំនិញម្ដែ សាមសិប មានមនុស្សចូលណែនៗ។ ក្នុងទីផ្សារដែលបិតនៅលើទីវាលដីទួល ក៏មានមនុស្សដើរប្រជ្រៀតគ្នាដែរ ។ រានលក់សាច់ជ្រូកដែលតាមធម្មតាមានត្រឹមមួយរាន ពីររាន តែដល់ថ្ងៃអាទិត្យ កើនដល់ទៅប្រាំ–ប្រាំមួយ រានឯណោះ...។ ទិដ្ឋភាពនេះ គួរឲ្យចាប់អារម្មណ៍ណាស់ ។ បើគេមើលពីចម្ងាយ គេឃើញហ្វូងមនុស្សទាំងអស់ នោះដើរប្រសេចប្រសាច ញាប់ដៃ ញាប់ជើង ប្រៀបបាននឹងស្រមោចខ្មៅ ដែលកំពុងពាំនាំស្បៀងទៅទុកក្នុងរូងអញ្ចឹង ។ យើងប្រៀបធៀបយ៉ាងនេះ ពីព្រោះពួកគូលីទាំងអស់នោះស្លៀកពាក់ខោអាវពណ៌ដីក្រហមចាស់ដូចៗគ្នា (ពណ៌ស្វាយឡាចាស់) ក្បាលផ្ចិតផ្ចូត ឡើងទ្រមើងៗ ធ្មេញរបស់គេពណ៌ខ្មៅ ។ គូលីចំការកៅស៊ូបឹងកេតទាំងនោះសុទ្ធតែពួក " យួនរើ " ។

បើនិយាយពីវិស័យអប់រំវិញ ស្រុកស្នឹងត្រង់មានដល់ថ្នាក់បឋមសិក្សាបំពេញវិជ្ជា តាំងពីខ្ញុំទើបចូលរៀនថ្នាក់កុមារដ្ឋានមកម្ល៉េះ។ ចំណែកឯនៅស្រុកជិតខាង ( ស្ពឺ ចំការលើ ក្រូចឆ្មា ) មានត្រឹមបឋមសិក្សា បឋមភូមិប៉ុណ្ណោះ។ ដូចនេះហើយ សិស្សដែលរៀនចប់បឋមភូមិ (ថ្នាក់ទី ៣) ត្រូវមកបន្តការសិក្សានៅស្នឹងត្រង់ឬបើកូនអ្នកធូរធារ គេទៅរៀននៅទីរួមខេត្តកំពង់ចាមតែម្ដង។ ដោយនៅស្រុកស្នឹងត្រង់ មានដល់ថ្នាក់ទី៦ ដូច្នេះ សិស្ស

ដែលមករៀនបន្តចាប់ពីថ្នាក់ទី៨ ឡើងទៅត្រូវបានទទួល រាល់ព័ត៌មានមក សម្ភារៈ ស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន ( Internat ) ដោយមានការឧបត្ថម្ភទាំងការហូប ចុកថែមទៀត ។

ព្រឹកមួយនោះ ពេលខ្ញុំកំពុងបង្រៀន ខ្ញុំឃើញ "មខ មុ" ដែលជាភ្នាក់ងារ ធ្វើការនៅប៉ុស្តិ៍ខ្សែលួស ដើរចូលមកដល់មាត់ទ្វារថ្នាក់ដែលខ្ញុំកំពុងបង្រៀន រួចហុចក្រដាស់មួយសន្លឹកឲ្យខ្ញុំ ។ គាត់ពោលពាក្យទាំងញញឹមថា សប្បាយចិត្តទេអាហ៊ុច? (ឈ្មោះក្រៅរបស់ខ្ញុំ) នេះជាតេឡេក្រាមពីប្ដី របស់អ្ហែង ។ ខ្ញុំចង់សួរគាត់បញ្ជាក់ តែគាត់ដើរមកជិតខ្ញុំ ហើយនិយាយ បែបខ្សឹបៗថា " ប្ដីអ្ហែងបានរួចពីគុកហើយ " ។ ខ្ញុំទទួលក្រដាស់នោះ ហើយ បង្វិលចុះឡើងរកមើល តែបងបូនិយាយកាត់ " ណែ!ចាំទៅមើល នៅផ្ទះទៅ ទើបមានពេល ព្រោះបងយល់ថា ឯងមុខជាមើលច្រើនសារមិន ខាន " ។ គាត់ សើចតិចៗរួចបន្តទៀតថា "ក្នុងតេឡេក្រាមនេះគាត់(ប្ដីខ្ញុំ)ថា មិនទាន់បានមកស្ទឹងត្រង់ទេ ប្រហែលជាមួយអាទិត្យទៀតទើបបានមក " ។ បងបូ និយាយចប់ក៏លាទៅវិញ ដោយលោតឆ្លោះរបងឈើដែលខ័ណ្ឌ សាលា និងមន្ទីរប៉ុស្តិ៍ ។

ប៉ុស្តិ៍ខ្សែលួសនៅស្រុកស្ទឹងត្រង់ ជាប៉ុស្តិ៍តែមួយរបស់ខេត្ត ដែលនៅតាម មាត់ទន្លេមេគង្គ។ ស្រុកធំៗនៅម្ដុំនោះ ដូចជាស្រុកស្ទឹ ចំការលើស្រុក ក្រូចឆ្មា ជាដើមតែងធ្វើទំនាក់ទំនងនៅប៉ុស្តិ៍ស្ទឹងត្រង់ទាំងអស់ ។ ឪពុកខ្ញុំធ្លាប់ និយាយថា តេដាក់ប៉ុស្តិ៍នៅស្រុកយើងនេះ តាំងពីយូរយារណាស់មកហើយ គាត់ក៏ឥតដឹងថាតាំងពីឆ្នាំណាមកដែរ។ ពេលគាត់ឡើងធ្វើ " មេស្រុក ឃើញមានប៉ុស្តិ៍ខ្សែលួសនេះស្រេចទៅហើយ ។ លឺគេថាមានប៉ុស្តិ៍ខ្សែលួស នេះ តាំងពីពួកបារាំងមកចាប់ដីក្រហមយកដាំដំណាំកៅស៊ូនៅភ្នំបឹងកេត មកម្ល៉េះ ។ ដូចបងបូនិយាយអញ្ចឹងមែន! ខ្ញុំអានតេឡេក្រាមនោះ ម្ដងហើយ ម្ដងទៀត មិនចេះឆ្អែតឆ្អន់ ។ អារម្មណ៍ទុក្ខព្រួយរបស់ខ្ញុំ ដែលកប់ជ្រៅក្នុង ដួងចិត្តអស់រយៈពេល ៨ ខែ និង ៥ ថ្ងៃមកហើយ ឥឡូវនេះវាសោត់បាត់

អស់រលីងនៅពេលដែលបានទទួលដំណឹងដ៏ល្អនេះ។ ចំណែកឯបរិយាកាសអាប់អួរក្នុងគ្រួសារ ក៏បានប្រែក្លាយទៅជាភាពសប្បាយរីករាយឡើងវិញផងដែរ ។

មួយសប្តាហ៍កន្លងមក បងសយក៏បានមកដល់មែន តែគាត់ពុំអាចនៅបានយូរទេ។ ពេលគាត់មកជួបខ្ញុំម្តងៗ គាត់នៅបានតែបួនដប់ថ្ងៃ គាត់ត្រូវត្រឡប់ទៅភ្នំពេញវិញហើយ ។ ចំណែកឯខ្ញុំវិញ ខ្ញុំក៏ពុំអាចទៅតាមគាត់បានដែរ ព្រោះនៅជាប់បង្រៀនសិស្សថ្នាក់ប្រលងសញ្ញាប័ត្រ ស្តែទីកា (Certificat)។ ក្នុងពេលទន្ទឹមនឹងនោះ យើងក៏បានពិគ្រោះគ្នារៀបចំបែបបទដាក់ពាក្យសុំផ្លាស់ទៅធ្វើការតាមប្តីនៅឯក្រុងភ្នំពេញហើយដែរ។

| | |
|---|---|
| - សង្ឃឹមថាបានសុខសេរី | មង្គលសូស្តីក្រែកន្លង |
| ព្រោះក្តីប្រាថ្នាបានដូចប៉ង | តែការណ៍សៅហ្មងគ្មានប្រណី ។ |
| - ជួបបានបីថ្ងៃ ខ្ញុំគិតស្មាន | យល់សប្តិកំសាន្ត ឬកើតក្តី |
| ស្រមៃអាក្រក់រៀងអប្រិយ៍ | ការពិតគូថ្មីត្រូវពង្រាត់ ។ |
| - រង់ចាំរាល់ថ្ងៃ មិនឃើញប្រាណ | ច្រើនខែក៏បានកន្លងផុត |
| តែក្តីសង្ឃឹមមិនរលត់ | ចាំពពកផាត់រសាត់ឆ្ងាយ |
| - ជាងប្រាំបីខែ ស្នេហ៍មកដល់ | ក្តីទុក្ខកង្វល់បានរសាយ |
| ញាតិមិត្តមូលមីរ រួមសប្បាយ | ជ្រោមជ្រែងដោះស្រាយជីវិតថ្មី ។ |

# វគ្គទី ២

## *ការកសាងគ្រួសារថ្មី*

ប្ដីរបស់ខ្ញុំបានមកទទួលខ្ញុំ ដើម្បីនាំទៅរស់នៅជុំគ្នាឯក្រុងភ្នំពេញ។ តែមុននឹងចាកចេញទៅ ខ្ញុំត្រូវទៅចូលរួមក្នុងពិធីបុណ្យខួបមួយរយថ្ងៃរបស់ជីដូនខ្ញុំនៅស្រុកស្អាង ចំការលើ ដែលគាត់បានទទួលមរណភាពក្នុងពេលដែលប្ដីខ្ញុំនៅក្នុងគុកនៅឡើយ ។ ម្ដាយធំរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា " តាំងពីពេលគេចាប់ប្ដីឯងទៅ ម៉ែតែងអង្គុយដកដង្ហើមធំ មិនដឹងថាគាត់គិតពីអ្វីទេ " ។ ខ្ញុំយល់ហើយ ជីដូនខ្ញុំប្រាកដជាពិបាកចិត្ត ពីព្រោះខ្ញុំជាចៅដែលគាត់ស្រឡាញ់ជាងគេ ហើយត្រូវទទួលការព្រាត់ប្រាសបែកប្ដីស៊ីបែបនេះ ។ សេចក្ដីសង្ឃឹម ថានឹងបានចៅប្រសារល្អជាទីពេញចិត្ត ត្រូវរលាយអស់ ។ ដោយសារពិបាកចិត្ត រួមផ្សំនឹងជំងឺជរាពាធផងនោះ គាត់ក៏លាចាកលោកបែកពីយើងទាំងអស់គ្នាជារៀងរហូតទៅ ។ ពិធីបុណ្យ បានបញ្ចប់ ខ្ញុំនិងប្ដីខ្ញុំបាននាំគ្នាទៅដុតធូបនៅផ្នូររបស់គាត់ ដែលបញ្ចុះនៅព្រៃខាងកើត ឆ្ងាយពីផ្ទះម្ដាយធំរបស់ខ្ញុំប្រហែលជាកន្លះគីឡូម៉ែត្រ ដោយមានប្អូនជីដូនមួយធ្វើគ្រូបង្រៀននៅស្អាង និងមានបងប្អូនបី-បួននាក់ទៀតជូនដំណើរយើង។ ខ្ញុំដោតធូបនៅមុខផ្នូរគាត់ដោយចិត្តសង្វេគក្រៃលែង។

និយាយអំពីជីវិតរបស់ជីដូនរបស់ខ្ញុំវិញ គាត់ជាស្ត្រីដែលមានរូបសម្ផស្សស្អាតជាទីបំផុត។ ខ្ញុំពុំសូវដឹងរឿងរ៉ាវរបស់គាត់ច្រើនទេ ដឹងខ្លះៗតាមរយៈម្ដាយធំរបស់ខ្ញុំ។ គាត់និយាយថា ជីដូនរបស់ខ្ញុំជាកូនចិន ឪពុកគាត់ជាចិនឆៅដែលគេហៅថា " កុងស៊ិនៗ " ព្រោះជាស៊ិនសែ... ចេះព្យាបាលជំងឺ។ ម្ដាយជាកូនចៅចិន។ ជីដូនខ្ញុំ មានបងប្អូនបួននាក់ ស្រីពីរ ប្រុសពីរ ។ គាត់ជាកូនទីបី។ គាត់ជាស្ត្រីមេម៉ាយ ប្ដីស្លាប់តាំងពីគាត់អាយុ ៣៣ ឆ្នាំ មាន កូន ៧ នាក់ក្នុងបន្ទុក។ ប្ដីគាត់ ឬជីតារបស់ខ្ញុំ ជាជាងឈើនៅស្រុកស្អាង

ជាអ្នកមានមួយរូបក្នុងចំណោមអ្នកមានផ្សេងទៀតដូចជា ដង្វៅ ទិន ដង្វៅប៊ិន ដង្វៅនូ ដែរ ។ តែដោយអកុសល ជីតារបស់ខ្ញុំត្រូវស្លាប់ដោយត្រូវគេបំពុល ប្លន់យកប្រាក់ នៅពេលដែលគាត់ទៅទារលុយពីអ្នកស្រុក នៅស្រុកលើ ។ ជីដូនខ្ញុំរស់នៅជាស្ត្រីមេម៉ាយតស៊ូចិញ្ចឹមកូន ៧ នាក់ (ម្ដាយខ្ញុំជាកូនទី ៧ របស់ គាត់) រហូតដល់បានចៅរាប់មិនអស់...។ អញ្ចឹងហើយក្រោយពេលដែល ជីតាខ្ញុំ "ដង្វៅ តេង " ស្លាប់ទៅ ជីដូនខ្ញុំបានមករស់នៅក្បែរបងប្រុសគាត់ (លោកតា "អាជ្ញា សេង ") ជាមន្ត្រីថ្នាក់ធំ នៅស្រុកស្ទឹងត្រង់វិញ ។

រីឯម្ដាយខ្ញុំ ដែលកាលឪពុកគាត់ត្រូវបានគេបំពុលស្លាប់ គាត់ពុំទាន់ កើតនៅឡើយ ។ ដូច្នេះហើយ ពេលគាត់កើតមក ជីដូនខ្ញុំចាត់ទុកថាម្ដាយខ្ញុំនេះជាកូនចង្រៃ...។ ម្ល៉ោះហើយពេលម្ដាយខ្ញុំកើតភ្លាម ជីដូនខ្ញុំមិនយកចិត្តទុកដាក់មើលថែទាំសោះ ហើយបញ្ជូនឲ្យទៅនៅជាមួយប្អូនប្រុសគាត់ដែលជាមន្ត្រីសាលាស្រុកនៅស្រុកសំបូរ ( ខេត្តក្រចេះ ) ដែលត្រូវជាឪពុកមា ( លោកតា ទុយ ) ដែលឥតមានកូន យកគាត់ទៅចិញ្ចឹមរហូតដល់ពេញក្រមុំ ។ អញ្ចឹងហើយបានជាម្ដាយខ្ញុំរៀនសូត្របានច្រើន ចេះអក្សរ ហើយធ្លាប់បានរៀន ភាសាបារាំង ចេះបានខ្លះៗដែរ ដែលកាលសម័យនោះកម្រមានកូនស្រី ឯណាបានទៅរៀននៅសាលាណាស់ ។ ហើយពេលទៅមកសាលារៀន លោក តា " ទុយ" មិនឲ្យក្មួយស្រីដែលគាត់ចាត់ទុកជាកូនស្រីបង្កើតរបស់គាត់ដើរ ដោយផ្ទាល់ដីទេ គាត់ទិញពួកទាសករ (ពួង) បកបញ្ជិះកូនគាត់លើស្នា ជូនទៅមកពីផ្ទះទៅសាលារៀនជារៀងរាល់ថ្ងៃ...។ នៅពេលត្រឡប់ មកនៅជាមួយម្ដាយបង្កើតរបស់គាត់វិញ ម្ដាយខ្ញុំត្រូវបានបង្ខំឲ្យរៀបការជាមួយកូនអ្នកធូរធារម្នាក់នៅក្នុងឃុំស្អិ ស្រុកចំការលើ ឈ្មោះ "លី ហាក់ " ។ តែជាអកុសល ការបានកូនស្រីពីរនាក់ ( គឺបងស្រី ហង់ អេង និងរូបខ្ញុំនេះតែម្តង ) ម្ដាយខ្ញុំត្រូវបានចែកផ្លូវគ្នាពីឪពុកខ្ញុំ ដោយកាលនោះខ្ញុំមានអាយុត្រឹមតែ ជាងមួយខួបប៉ុណ្ណោះ ។ តាមរយៈម្ដាយធំខ្ញុំប្រាប់ថា មូលហេតុនៃការបាក់បែក គ្រួសារនេះ គឺមកពីគ្រួសារទាំងសង

ខាងមិនចុះសម្រុងគ្នា (ខាងជីដូនខ្ញុំគឺជា គ្រួសារបែបមន្ត្រីរាជការ ខាងឪពុកខ្ញុំជាគ្រួសារអ្នករកស៊ីនៅតាមស្រុកស្រែចំការ ប្រកាន់បែបបទទំនៀមទម្លាប់ចិនស្រុកស្រែ...)។ អញ្ចឹងហើយបានជាម្ដាយខ្ញុំ និង "ប៉ាហាក់" បានបែកផ្លូវគ្នាទៅ ។ ម្ដាយខ្ញុំពុំដែលបាន រំលឹកអ្វីបន្តិចបន្តួចឲ្យខ្ញុំដឹងរំពីរឿងនោះឡើយ ។ ម្ដាយខ្ញុំរស់នៅជាស្ត្រីមេម៉ាយ មានកូនស្រីពីរនាក់ជាមួយជីដូនរបស់ខ្ញុំដែលក៏ជាស្ត្រីមេម៉ាយដែរ អស់រយៈពេល៥ឆ្នាំ ទើបឪពុកក្រោយរបស់ខ្ញុំដែលជា "មេស្រុក" កំលោះចាស់មកស្ដីដណ្ដឹងម្ដាយខ្ញុំរៀបការ។ កាលនោះ ខ្ញុំមានអាយុទើបបាន ៦ ឆ្នាំ ពុំទាន់យល់អ្វីទាំងអស់ ហើយចាស់ៗប្រាប់ថា ឪពុកក្រោយខ្ញុំនេះជាឪពុកបង្កើតទើបមកពីស្រុកបារាំង ... ។ ខ្ញុំឥតដឹងការពិតអ្វីទាំងអស់ ក្រៅពីទទួលស្គាល់ថាខ្ញុំជាកូន "តាមេស្រុកឈុំ" ។ គាត់ស្រឡាញ់ម្ដាយខ្ញុំ ស្រឡាញ់កូនស្រីទាំងពីររបស់ម្ដាយខ្ញុំ ដូចជាកូនបង្កើតរបស់គាត់ ។ អញ្ចឹងហើយបានជាគាត់បណ្ដុះបណ្ដាលខ្ញុំឲ្យបានរៀនសូត្រច្រើន ។ ការដែលខ្ញុំបានមករៀនដល់ ភ្នំពេញក៏ដោយសារតែគាត់ដែរ ។ ធម្មតាការបញ្ជូនកូនឲ្យមករៀននៅភ្នំពេញនេះត្រូវចំណាយប្រាក់យ៉ាងច្រើន ពីព្រោះដើម្បីចូលរៀន និងស្នាក់នៅអន្តេវាសិកដ្ឋានក្នុងវិទ្យាល័យនារីបាន ត្រូវមានប្រដាប់ប្រដារគ្រប់មុខសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនតាមដែលសាលាតម្រូវ។ លឺម្ដាយខ្ញុំនិយាយថា គាត់ចំណាយ លុយអស់ជាងមួយពាន់រៀលឯណោះ (ប្រហែលជា ៦ ឬ ៧ ដំឡឹងមាស) ដើម្បីឲ្យខ្ញុំអាចចូលរៀននៅវិទ្យាល័យនារីបាន។ តើកូនអ្នកស្រុកធម្មតាឯណាអាចទៅរៀនបាន បើត្រូវចំណាយយ៉ាងច្រើនបែបនេះ ? ម្យ៉ាងទៀត ចំពោះកូនស្រី តើម្ដាយឪពុកត្រូវព្រួយបារម្ភយ៉ាងណាទៅដែលត្រូវទៅឆ្ងាយពីផ្ទះសម្បែងនោះ? គេច្រើនយល់ថា "ប្រយ័ត្នផើមព្រៃ" នេះហើយជាទស្សនៈរបស់អ្នកស្រុកយើងកាលសម័យនោះដែលធ្វើឲ្យកូនស្រីឥតបានរៀនសូត្រអ្វី ច្រើនទេ។ រៀនបានត្រឹមថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ ម៉ែឪឈប់ឲ្យរៀនឲ្យនៅផ្ទះ ឬ ឲ្យមានគូស្រករហើយ...។ ដូច្នេះហើយបើតាបព្រាយ និងជីដូនរបស់ខ្ញុំៗប្រាកដជាពុំអាចចេញឆ្ងាយពីផ្ទះមករៀនបាន

ឡើយ។ នៅស្រុកស្ទឹងត្រង់ - កូនស្រីតាមេស្រុកឈើ - គឺរូបខ្ញុំនេះឯង ជាក្មេងស្រីទីមួយដែលបានចេញពីស្រុកទៅរៀននៅភ្នំពេញ។ នេះគឺជា សំណាងដ៏ធំរបស់ខ្ញុំយ៉ាងពិតប្រាកដ។ ខ្ញុំពុំអាចបំភ្លេចនូវទង្វើដ៏ល្អរបស់ ឪពុកក្រោយខ្ញុំ នេះបានឡើយ ។

ខ្ញុំដោតធូបបណ្តើរគិតដល់ប្រវត្តិខ្លួនបណ្តើរ ។ គិតទៅ! ជីដូនរបស់ ខ្ញុំត្រូវ ប្រឈមមុខនឹងការលំបាកមិនតិចឡើយ...។ ខ្ញុំអាណិតជីដូនខ្ញុំខ្លាំងណាស់ ហើយក៏កោតសរសើរគាត់ដែលប្រឹងចិញ្ចឹមកូនទាំង៧ នាក់ ដោយលំបាក ។ ទោះបីកូនទាំងអស់នោះមិនសូវធូរធារ ឬឧត្តុង្គឧត្តមក៏ពិតមែនតែជាមនុស្ស ត្រឹមត្រូវរស់នៅប្រកបរបរចិញ្ចឹមជីវិតតាមសម្មាជីវៈរៀងៗខ្លួន។

---

យើងបានមកដល់ភ្នំពេញហើយ ។ ស៊ីក្លូបាននាំយើងមកសង្កាត់វាលវង់ ដែលជាទីវាលសម្រាប់ប្រណាំងសេះ ( សព្វថ្ងៃជាទីតាំងនៃស្តាដអូឡាំពិក)។ យើងឈប់នៅលើផ្លូវមួយ ដែលគេកំពុងចាក់ដី ឈូសឆាយធ្វើថ្នល់ថ្មីទៅកាន់ ផ្សារដេប៉ូ ។ ស៊ីក្លូឈប់នៅមាត់ច្រកផ្លូវតូចមួយដែលចុះពីផ្លូវធំ ។ ច្រកតូច នោះជាផ្លូវជើង អបដោយស្មៅ ដើមត្រែង និងដើមស្នោដុះមួយៗ តាមមាត់ ចង្អូរទឹក។ បងសយបានចង្អុលទៅតាមច្រកនោះ ហើយប្រាប់ខ្ញុំថា " "នោះ គឺជាផ្ទះរបស់យើងហើយ មិត្តភក្តិរបស់បងបានលក់តម្លៃ៥ម៉ឺនរៀលឲ្យបង តែបងបានឲ្យប្រាក់តែដំបូងតែ ២ ម៉ឺនរៀលប៉ុណ្ណោះ ។ គេព្រមឲ្យបងនៅ ជំពាក់ និងសងតែរំលោះ រហូតដល់គ្រប់ចំនួនទឹកប្រាក់ "។ ខ្ញុំគិតថា ៥ ម៉ឺនរៀលមិនតិចទេ ពីព្រោះបើគិតជាមាស គឺស្មើនឹង ២០ សម្លឹងដែរ ។ ខ្ញុំ សម្លឹងរកមើលផ្ទះដែលគាត់បានចង្អុលប្រាប់ក្នុងចំណោមផ្ទះស្លឹករកេតរកូដ ដែលនៅពីមុខខ្ញុំ។ បងសយបានពន្យល់ប្រាប់ខ្ញុំអំពីហេតុផលដែលនាំឲ្យ គាត់ សម្រេចចិត្តមករស់នៅក្នុងតំបន់ដ៏កំសត់នេះថា ទីមួយម្ចាស់ផ្ទះមុនជា មិត្តភក្តិដែល គាត់ធ្លាប់ស្គាល់ ទីពីរតំបន់នេះនៅម្តុំបន្ទាយឃ្លាំង រីសេរដែល មានផ្ទះរបស់នាយទាហាន (សព្វថ្ងៃជាទីតាំងនៃមជ្ឈមណ្ឌលពាណិជ្ជកម្ម

ម៉ុងឌីយ៉ាល់)ដែលនៅក្នុងនោះមានផ្ទះបង **ស្រី សុខុម** ប្អូនបង **ស្រី យសន្ធា** (ប្ដីរបស់បងស្រីខ្ញុំ) ហើយជាពិសេសទៅទៀត នៅម្ដុំឃ្លាំងរំសេវនេះ មានផ្ទះរបស់លោកអ៊ុំ "**មហា ឆាន់**" ផងដែរ ។

អ៊ុំមហាឆាន់ ជាអតីតគ្រូសង្ក្រាជនៅ " វត្តតាទក " នៅស្រុកពួកដែលជាវត្តកសាងឡើងដោយលោកគ្រូ មហាឆាន់នេះឯង ។ លោក អ៊ុំមហាបានសង់សាលារៀននៅក្នុងបរិវេណ វត្តនេះបាន ៣ថ្នាក់ ។ បងសយ កាលនៅពីកុមារបានរៀននៅសាលាវត្តនេះឯង ហើយគាត់ជាកូនសិស្សជាទីសំណប់ចិត្តរបស់លោកគ្រូចៅអធិការមហាឆាន់នេះរហូតដល់ចប់បឋមសិក្សា ។ លោកអ៊ុំមហា ជាចៅអធិការដែលអ្នកស្រុកស្រឡាញ់ ពីព្រោះលោកតែងជួយយកអាសាប្រជាជនដែលត្រូវពួកខ្មែរឥស្សរៈក្លែងក្លាយចូលមកជំរិតទារលុយកាក់។ មិនតែប៉ុណ្ណោះ លោកតែងយកបច្ច័យដែលប្រជាជនបានប្រគេនលោកក្នុងពិធីបុណ្យផ្សេងៗមកឧបត្ថម្ភអ្នកទីទល់ក្រ។ ម្យ៉ាងទៀតលោកតែងផ្ដល់ដំបូន្មានឲ្យអ្នកស្រុកនាំកូនទៅរៀននៅក្នុងសាលាថែមទៀត។ លោកយាយហ្វូត ម្ដាយ បងសយ តែងនិយាយបដិសេធមិនព្រមឲ្យកូនទៅរៀន ដោយប្រើពាក្យថា "អានាងឯងទៅរៀនធ្វើអីគ្រួសារយើងមិនមែនជាពូជកុង្សីយ៍ឯណា!..."។ អ្នកភូមិនៅម្ដុំនោះ ក៏មានទស្សនៈដូចលោកយាយហ្វូតដែរ។ ក៏ប៉ុន្តែលោកអ៊ុំមហា បានព្យាយាមពន្យល់បញ្ចុះបញ្ចូល រហូតដល់បង្ខិតបង្ខំឲ្យអ្នកទាំងអស់គ្នានោះ ព្រមអនុញ្ញាតឲ្យកូនទៅរៀន។ កុមារមួយចំនួនដែលមានអាយុស្របាលគ្នានឹងបងសយ បានទៅចូលសាលាដោយសារលោក អ៊ុំមហា នេះឯង។ ដូចនេះលោកអ៊ុំមហាគឺពិតជាព្រះសង្ឃដែលមានគំនិតអ្នកជាតិនិយម និងជាអ្នកដែលនាំមកនូវគំនិតបណ្ដុះបណ្ដាលកុលបុត្រកុលធីតាខ្មែរ ដែលក្នុងសម័យកាលនោះសូម្បីរដ្ឋអំណាចក៏ពុំទាន់បានចាប់អារម្មណ៍ និងឲ្យតម្លៃខ្ពស់ទៅលើវិស័យសិក្សាអប់រំនេះនៅឡើយដែរ។ លោកអ៊ុំមហាឆាន់ ក្រោយមកបាននិមន្តមកគង់នៅ "វត្តដំណាក់"ក្នុងទីរួមខេត្តសៀមរាប ។ នៅពេលនោះទៀត បងសយ និងប្អូនគាត់ "ពឹង គឹមស៊ា " ដែលបានរៀនចប់ថ្នាក់ទី ៣ នៃបឋមសិក្សា

ក៏ត្រូវទៅបន្តការសិក្សានៅសៀមរាប ដោយស្នាក់នៅក្នុងវត្ត " ដំណាក់ ក្រោមការឧបត្ថម្ភរបស់លោកគ្រូមហានេះទៀត។ លោកអ៊ុំមហាស្រឡាញ់សិស្សរបស់គាត់យ៉ាងខ្លាំង។ បងសយបានឲ្យខ្ញុំដឹងថែមទៀតថា លោកគ្រូមហាធ្លាប់បានទៅរៀនសូត្រចេះដឹងខ្ពង់ខ្ពស់ចេញពីប្រទេសសៀម រៀនអស់ជាច្រើនឆ្នាំ ចេះភាសាសៀមយ៉ាងស្ទាត់។ ក្នុងសម័យខ្មែរឥស្សរៈ អ៊ុំមហាបានចាកផ្នួស ហើយក៏ចូលធ្វើការនៅក្រសួងឃោសនាការ ។ ប្រពន្ធរបស់គាត់ អ្នកមីង "**កែវ តាត** " ជាអ្នកភូមិ "ភ្នំស្រុក " ខេត្តបន្ទាយមានជ័យ ក៏បានមករស់នៅត្រង់ម្តុំឃ្លាំងរំសេវនេះដែរ ដែលធ្វើឲ្យបងសយមានការកក់ក្តៅច្រើន ព្រោះបានមករស់នៅក្បែរគ្រួសារលោកគ្រូដ៏ឧត្តមរបស់គាត់។ ក្រោយថ្ងៃ ៧ មករា ១៩៧៩ គ្រួសារលោកអ៊ុំមហាទាំងប្រពន្ធ និង កូនទាំងបីនាក់របស់គាត់ នៅរស់រានមានជីវិតក្នុងខេត្តបាត់ដំបង។ ក្រោយមកគាត់ក៏បានចូលកាន់ផ្នួសឡើងវិញនៅវត្តអំពិល ក្នុងស្រុកពួក ហើយក៏សុគតក្នុងទសវត្សទី ៨០ នៅទីនោះទៅ ។

ខ្ញុំឈរភ្លឹកអស់មួយសន្ទុះ ព្រោះអារម្មណ៍របស់ខ្ញុំហាក់ដូចជាអណ្តែតត្រសែតទៅឆ្ងាយ ព្រោះខ្ញុំឥតដែលបានគិតស្មានថាខ្ញុំនឹងត្រូវផ្តើមមកសាងជីវិតគ្រួសារដំបូង ក្នុងស្ថានភាពដូចដែលខ្ញុំបានឃើញនាថ្ងៃនោះសោះ ។ ខ្ញុំភ្ញាក់ខ្លួនមកវិញ នៅពេលដែលខ្ញុំលឺគាត់ហៅខ្ញុំឲ្យជួយជញ្ជូនឥវ៉ាន់ ។ អារម្មណ៍រវើរវាយមុននេះ គឺជាការស្រមើស្រមៃភ្លើតភ្លើនរបស់ខ្ញុំដែលធ្លាប់មានគេតាមស្រឡាញ់ និងតាមស្តីដណ្តឹងច្រើនគ្នា ហើយដែលសុទ្ធតែជាអ្នកមានទ្រព្យសម្បត្តិធូរធារ...។ អញ្ចឹងហើយខ្ញុំតែងស្រមៃថា នៅពេលខ្ញុំរៀបការរួច ខ្ញុំនឹងចាប់ផ្តើមជីវិតថ្មី ក្នុងស្ថានភាពស្តុកស្តម្ភជាមិនខាន... ។

---

យើងទាំងពីរនាក់ឥតមានឥវ៉ាន់ច្រើនទេ គឺមានកន្ត្រកខោអាវមួយបង្វិចវិទ្យុមួយគ្រឿង និងរបស់របរបន្តិចបន្តួចប៉ុណ្ណោះ ។ ម្តាយខ្ញុំក៏ចង់ជូនខ្ញុំមកភ្នំពេញ ដើម្បីរៀបចំផ្ទះសម្បែងថ្មីឲ្យកូន ដែលបានចេញពីគ្រួសារមករស់នៅ

ជាមួយប្តី កសាងគ្រួសារថ្មីដែរ ។ ក៏ប៉ុន្តែប្តីរបស់ខ្ញុំបានប្រាប់គាត់វិញថា គាត់បានរៀបចំរបស់របរប្រើប្រាស់រួចរាល់អស់ហើយ សូមអ្នក ( ខ្ញុំហៅម្តាយខ្ញុំថាអ្នក ) ប៉ាកុំបារម្ភ ។ យើងយួរឥវ៉ាន់ទាំងអស់នោះ ចុះពីផ្ទះធំចូលទៅកាន់ច្រកតូចឆ្ពោះទៅលំនៅដ្ឋានថ្មីនោះ ។

គឺកូនផ្ទះស្លឹកមួយ សង់ខ្ពស់ពីដីកំពស់ត្រឹមចង្កេះ ដំបូលប្រក់ហ្វីប្រូជញ្ជាំងបាំងស្លឹក តែក្តារក្រាលធ្វើអំពីឈើបន្ទះរលោងស្អាត បញ្ជាក់ថាមានការថែទាំដុសខាត់ជូតសម្អាតល្អគ្រាន់បើដែរ ។ ចង្ក្រានបាយខណ្ឌដាច់ពីផ្ទះមុខដោយមានទុកចន្លោះប្រវែងជាងពីរម៉ែត្រ ។ បន្ទប់ទឹក និងបង្គន់អនាម័យនៅដាច់ដោយឡែក សង់នៅផ្ទាល់ដីចំហៀងខាងលិចផ្ទះឯណោះ ។ ចំណែកឯជណ្តើរសម្រាប់ឡើងទៅលើផ្ទះ គេសង់សណ្ឋានជាស្ពាន ដាក់ទេរពីដីទៅលើផ្ទះសម្រាប់ងាយស្រួលរុញកង់ ឬម៉ូតូយកមកទុកលើផ្ទះក្នុងពេលយប់ព្រលប់ ។ ខ្ញុំយល់ហេតុការណ៍នេះហើយ ព្រោះកាលពេលមុននោះ បងសយមានម៉ូតូចាស់មួយគ្រឿងម៉ាក "សាស្ស" ដែលខ្ញុំតែងឃើញគាត់ជិះពេលជួបគាត់នៅតាមផ្លូវទៅសាលាគរុកោសល្យខាងជើង។ ខ្ញុំតែងដើរជាមួយមិត្តខ្ញុំម្នាក់ឈ្មោះ វ៉ា ស៊ឹង មកពីស្រុកឃ្លាំង (កម្ពុជាក្រោម)។ **វ៉ាស៊ឹង** ជាអតីតសិស្សរបស់គាត់ រៀននៅអនុវិទ្យាល័យឯកជន កម្ពុជបុត្រ ។ គេប្រាប់ខ្ញុំថា គាត់ជាសាស្ត្រាចារ្យផ្នែកវរ៉ៃវិទ្យារបស់គេ ។ គាត់ប្រើម៉ូតូសាស្សនេះ រហូតមកដល់ក្នុងពេលនេះ ។

យើងរស់នៅក្នុងជម្រកដ៏តូចក៏ពិតមែន តែមានសេចក្តីសុខបរិបូរណ៍។ យើងតែងដើរទៅរកទិញឧបករណ៍ខ្លះៗដែលខ្វះខាតទុកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារថ្មីរបស់យើង ។ នៅម្តុំផ្ទះថ្មីរបស់ខ្ញុំនេះ ពុំមានផ្ទះណាមានភ្លើងអគ្គីសនីប្រើប្រាស់ទេ មានតែផ្ទះខ្ញុំមួយតែប៉ុណ្ណោះឯង ពីព្រោះម្ចាស់ផ្ទះមុនគេមានបងប្អូនធ្វើការនៅនាយកដ្ឋានអគ្គីសនី ។ ដោយឡែកបញ្ហាទឹកម៉ាស៊ីនពុំទាន់ មានបណ្តាញចរន្តទឹកមកដល់តំបន់នេះនៅឡើយ។ អ្នកនៅម្តុំនោះតែងប្រើទឹកម៉ាស៊ីនដែលគេអូសតាមរទេះលក់តាមផ្លូវ។ ដោយមានការ

លំបាកក្នុងបញ្ហាខ្វះទឹក បងសយបានស៊ើបសួររកជួលគេមកជីកអណ្តូងទឹក។ យើងចំណាយប្រាក់អស់ប្រហែលបីបួនរយរៀលប៉ុណ្ណោះ សម្រាប់ការជីកអណ្តូងនោះ ហើយយើងបានរក្សាភទុកយកទឹកប្រើប្រាស់ជារៀងរហូតមក ។

នៅខែចែត្រចូលឆ្នាំថ្មី (១៩៥៨) បងសយបាននាំខ្ញុំទៅលេងនឹងបងប្អូនគាត់នៅស្រុកកំណើតឯស្រុកពួក ខេត្តសៀមរាប តាមរថយន្តឈ្នួល ។ គាត់បាននាំខ្ញុំទៅជំរាបសួរចាស់ទុំដែលជាញាតិសណ្តានក្នុងស្រុក តែឥតហ៊ានទៅឆ្ងាយពីទីប្រជុំជនទេ ពីព្រោះនៅទីនោះពុំសូវមានសុវត្ថិភាពឡើយ។ ខេត្តសៀមរាបទាំងមូល រួមទាំងខេត្តកំពង់ធំ និងបាត់ដំបង ត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់ឧត្តមសេនីយ "**ដាប ឈួន**" ដែលតាំងខ្លួនជាស្តេចត្រាញ់ ត្រួតត្រាផ្តាច់ការនៅក្នុងតំបន់ទាំងបីនោះ ( ដាប ឈួន ដែលខ្មែរយើងភាគច្រើនដឹងរឿងថាគាត់ក្រោយមកប៉ងធ្វើរដ្ឋប្រហារទំលាក់សម្តេចសីហនុ តែពុំបានសម្រេច ហើយត្រូវរាជរដ្ឋាភិបាលធ្វើឃាតគាត់នៅរវាងឆ្នាំ ១៩៥៩ ) ។ ដោយសារបងសយមានការបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំ អញ្ចឹងហើយគាត់ចង់នាំខ្ញុំទៅសម្រាកពេលយប់នៅផ្ទះបងស្រីទីបីរបស់គាត់ (បងហួរ ) នៅទីរួមខេត្ត ។ ក៏ប៉ុន្តែសំណាងដែរ ដែលបងសយមានមិត្តភក្តិរួមថ្នាក់ម្នាក់ ឈ្មោះ ស៊ី ជាទាហានពាក់សក្តិបីរបស់ដាប ឈួន គេបានធានាអះអាងសុវត្ថិភាពឲ្យ ទើបខ្ញុំអាចសម្រាកនៅផ្ទះម្តាយក្មេកខ្ញុំ (លោកយាយយ៉េប ហួត ) នៅចុងស្ពានឆ្លងស្ទឹងពួកទៅវត្តអំពិល ។

ស្ទឹង "ពួក " ក្នុងសម័យកាលយូរលង់ គឺជាផ្លូវគមនាគមន៍ដែលអ្នកស្រុកប្រើប្រាស់ក្នុងការធ្វើដំណើរ ឬដឹកទំនិញចេញចូលទៅតំបន់នានានៅជុំវិញបឹងទន្លេសាប និងឆ្ពោះទៅទីក្រុងភ្នំពេញថែមទៀត ។ តាមសំដីបងថ្លៃខ្ញុំ (បង សេ ជាកូនប្រុសទីមួយក្នុងគ្រួសារ) គាត់និយាយរឿងការរកស៊ីរបស់ឪពុកគាត់ ( លោកតា ពីង ជី ) ថា " ទៀវ (ឪពុកគាត់) តែងដឹកពីរចុង វល្លិ ដឹកជ្រូកទៅលក់នៅភ្នំពេញដោយចុះទូកនៅមាត់ស្ទឹងពួកមុខផ្ទះ

គាត់ដែលមានផែសម្រាប់ពួកឈ្មួញដឹកទំនិញចេញចូលក្នុងស្រុក ហើយក៏ជាទីតាំងនៃផ្សាររបស់ស្រុកពួកផងដែរ ។ ស្ទឹងនេះមានស្ពានសម្រាប់ឆ្លងកាត់ដែលប្រជាជន នៅតាមឃុំ តាមភូមិនានានៃស្រុក តែងដើរទៅកាន់មន្ទីរស្រុកចម្ងាយប្រហែលពីររយម៉ែត្រ ដោយដើរកាត់មុខផ្ទះម៉ែក្មេកខ្ញុំ ។ ស្ពាននេះ សព្វថ្ងៃត្រូវបានសង់ថ្មីជាស្ពានថ្ម តែមានប្រវែងខ្លីជាងមុនច្រើន ព្រោះស្ទឹងពួកកាន់តែរាក់ទៅៗ ទទឹងកាន់តែរួម រហូតដល់លែងមានទឹកគ្រប់គ្រាន់ សម្រាប់ទូកតូច ធំ ធ្វើដំណើរទៅមកបានដូចគ្រាមុន ។ អ្នកស្រុកតែងហៅ ឈ្មោះស្ពាន នេះ ថា "ស្ពានយាយ ហូត" ។

នៅសៀមរាប ខ្ញុំបានទៅដើរលេងមើលប្រាសាទអង្គរវត្ត និងប្រាសាទនានាច្រើនដែរ ដែលនោះជាលើកទីមួយហើយ ដែលខ្ញុំបានស្គាល់ខេត្តសៀមរាប ហើយបានទស្សនាប្រាសាទបូរាណខ្មែរដ៏អស្ចារ្យរបស់យើងនេះ។ លើសពីនេះទៅទៀត ខ្ញុំក៏មានសំណាងមួយទៀតដែរ ពីព្រោះខ្ញុំបានទៅលេងដល់ភ្នំគូលែន និងភ្នំក្រោម ។ កាលនោះ គេឡើងទៅភ្នំគូលេនដោយដើរតាមផ្លូវជើង មានតោងវល្លិ តោងមែកឈើ លំបាកក្រៃលែង ។ រីឯផ្លូវឡាន ក៏ពុំអាចឲ្យឡានធម្មតាបរឡើងបានឡើយ ពីព្រោះផ្លូវតូចមានបត់បែនច្រើន តាមសណ្ឋានភ្នំចោត ដែលមានផ្ទាំងថ្មរកិបរកុប ។ ក៏ប៉ុន្តែពួកយើងមានបង យស្សា ជាអ្នកបើកឡាន GMC ធ្វើដំណើរជូនឡើងភ្នំដោយនាំទាំងញាតិសណ្ដានរបស់បងសយទាំងក្មេងទាំងចាស់ប្រហែលជិតម្ភៃនាក់ពេញមួយឡានទៅជាមួយផងដែរ។ ដោយពុំទាន់មានផ្លូវត្រឹមត្រូវនៅឡើយ ដូច្នេះហើយសូម្បីតែអ្នកស្រុកសៀមរាបផ្ទាល់ក៏កម្រមានវាសនាបានឡើងដល់កំពូលភ្នំនោះដែរ ។ អ្នកស្រុកនៅខេត្តសៀមរាប និងនៅតាមខេត្តនានាក្នុងតំបន់នោះ តែងមានបំណងចង់ទៅស្គាល់ភ្នំគូលេនខ្លាំងណាស់ ពីព្រោះគេល្បីថានៅទីនោះ មានវត្ថុសក្ដិសិទ្ធ មានកន្លែងអច្ឆរិយៈច្រើន និងមានទឹកជ្រោះហូរធ្លាក់ពីកំពូលភ្នំ កាត់ជ្រលងថ្មចម្លាក់ "លិង្គព្រះឥសូរ រាប់ពាន់ ។ អ្នកទេសចរដែលបានទៅដល់កំពូលភ្នំ តែងទៅថ្វាយបង្គំព្រះអង្គធំ " ដែលជាពុទ្ធបដិមាករ ឆ្លាក់លើផ្ទាំងសិលាដ៏ធំស្កឹមស្កៃ ដើម្បី

បន់ស្រន់ប្រាថ្នាសុំនេះ សុំនោះអំពី "ព្រះអង្គធំ" ដែលគេតែងលឺតៗគ្នាថា "ស័ក្តិសិទ្ធណាស់ !។ ពេលឡានកំពុងបរឡើងភ្នំ ម្នាក់ៗភ័យភ្នែកនៅកញ្ចឹងក ...ចំពោះខ្ញុំ ខ្ញុំឥតមានការភ័យខ្លាចទេ ព្រោះខ្ញុំត្រូវបានគេឲ្យអង្គុយក្នុងកាប៊ីនខាងមុខ ដោយសារខ្ញុំមានផ្ទៃពោះពីរខែហើយ ។ សូមបញ្ជាក់ថា បងយស្សា ក្រោយពីចេញពីទាហានបារាំងមក គាត់សុំចូលបម្រើក្នុងជួរកងទ័ពពលរដ្ឋាភិបាលពាក់សក្តិ ២ ហើយផ្លាស់មកធ្វើការនៅខេត្តសៀមរាប ។ នៅសៀមរាបក្នុងស្រុកខាងបងសយ ខ្ញុំមានការសប្បាយរីករាយច្រើន ដោយបងប្អូនខាងគាត់ស្រឡាញ់ខ្ញុំ រាប់អានខ្ញុំ និងទទួលខ្ញុំ យ៉ាងរាក់ទាក់ជាទីបំផុត ជាពិសេសពីសំណាក់បងស្រីទីមួយ (**ពិន សេន**) បងស្រីទីពីរ (**ពិន សាន**) និងបងប្រុស (បង **គី** និងបង **ទន** ប្រពន្ធគាត់) ព្រមទាំងក្មួយៗដែលជាកូនរបស់បងៗទាំងនោះផង ហើយជាពិសេសពីម្តាយក្មេកខ្ញុំ។ គេទាំងអស់គ្នានោះរស់នៅក្នុងស្រុកពួកនេះ ប្រកបរបរលក់ដូរ មានជីវភាពធូរធារ ដែលអ្នកស្រុកទូទៅស្រឡាញ់រាប់អាន គេចាត់ទុកថាជា "គ្រួសារល្អ" នៅក្នុងស្រុកពួក ពីព្រោះជាគ្រួសារដែលចេះជួយយកអាសាគ្នា មិនថាឡើយតែនៅក្នុងរង្វង់គ្រួសារផ្ទាល់ទេ សូម្បីជាមួយញាតិភូមិផងរបងជាមួយ ក៏គ្រួសារនេះតែងរក្សាភាពល្អកល្អឺន រាក់ទាក់ រាប់អាន ឥតរើសអើងសោះឡើយ ។

ឆ្នាំសិក្សា ១៩៥៨ – ១៩៥៩ បានបើកបវេសនកាលហើយ ។ ខ្ញុំបានទទួលលិខិតជាផ្លូវការ ផ្លាស់ខ្ញុំពីស្រុកមកកាន់ប៉ុស្តិ៍ថ្មីនៅសាលាបឋមសិក្សាពាក់ទូក ដែលកាលនោះសាលានោះស្ថិតនៅលើផ្លូវក្នុង តូចចង្អៀត មានផ្ទះតូចៗ បែបសំណង់អនាធិបតេយ្យ រញ៉េរញ៉ៃ ពិបាកធ្វើដំណើរចេញចូលណាស់ ។ គេបានបង្កើតសាខារបស់សាលាមួយកន្លែងទៀតនៅ "ទួលព្រះស្រី" ដែលពីមុនមកជាកន្លែងកប់ខ្មោច មានម៉ុងចិនជាច្រើន ។ សាខានោះមានថ្នាក់រៀនប្រហែលជាង២០ ថ្នាក់ ដែលសុទ្ធជាថ្នាក់បំពេញវិជ្ជា ( ចាប់ពីថ្នាក់ទី ៤ ដល់ទី ៦ ) ។ ខ្ញុំក៏បានទៅបង្រៀននៅសាលាទួលព្រះស្រីនោះ កាន់ថ្នាក់ទី ៦ (ថ្នាក់ឧត្តមដ្ឋាន ) ។

ពេលយប់មួយនោះវេលាម៉ោង ៨ យប់ សន្ធឹកជើងមនុស្សដើរ និងរត់តាមច្រកផ្លូវ ព្រមទាំងសម្លេងស្រែកស្លន់ស្លោមិនច្បាស់លាស់ ធ្វើខ្ញុំនិងប្ដីខ្ញុំបើកទ្វារចេញមកក្រៅផ្ទះប្រុងស្មារនាំ តែភ្ញាក់ព្រើតនឹងផ្ទៃមេឃពេលនោះឡើងពណ៌ក្រហមដាស ទើបដឹងថាមានភ្លើងឆេះផ្ទះនៅជិតៗនោះហើយ ។ ប្ដី ខ្ញុំស្ទុះចូលទៅក្នុងផ្ទះ លើកកូនប្រុសទីមួយរបស់យើង "**ពិន សុខាច័ន្ទ**"ដែលទើបនឹងកើតមិនទាន់បានមួយខែផង ឲ្យខ្ញុំបីទៅចាំនៅមុខផ្ទះដោយនិយាយថា " អង្គុយនៅទីនេះហើយ! មិនអីទេ! ព្រោះផ្ទះយើងមានដំបូលប្រក់ហ្វីប្រូស៊ីម៉ង់ ទោះផ្កាភ្លើងធ្លាក់មកលើ ក៏មិនអាចឆេះបានដែរ "។ ខ្ញុំបីកូនប្រុសរបស់ខ្ញុំនេះ យ៉ាងថ្នាក់ថ្នមបំផុត ពីព្រោះគេជាទារកកើតមិនទាន់គ្រប់ខែ (កូនកើត ៧ ខែ ) មានសុខភាពខ្សោយមែនទែន ។ កាលនៅមន្ទីរពេទ្យគេដាក់កូននេះនៅក្នុងកែវរហូត។ ខ្ញុំសម្រាកនៅមន្ទីរពេទ្យអស់រយៈពេលពីរអាទិត្យ ទើបពេទ្យឲ្យចេញមកផ្ទះ។ ចាស់ៗបន្ទោសខ្ញុំថា កូននេះកើតមិនគ្រប់ខែគឺដោយសារខ្ញុំមិនចេះ ថែទាំខ្លួន ក្នុងពេលមានផ្ទៃពោះដូចជា ជិះឡានឡើងភ្នំគូលែន ធ្វើដំណើរច្រើន ហើយជាពិសេសដើរហើរហាក់លោត ឥតគិត។ ប្រហែលជាអញ្ចឹងមែនហើយ ! ពីព្រោះខ្ញុំធ្លាប់មាននិស្ស័យជាអ្នកកីឡា ។ កាលនៅរៀនអនុវិទ្យាល័យនារី ខ្ញុំលេងកីឡាបាល់បោះបាល់ទះ និងអត្តពលកម្ម... ហើយធ្លាប់ចេញ ទៅប្រកួតតំណាងសាលាជាញឹកញាប់។ កាយវិការជាកីឡាករ ធ្វើឲ្យខ្ញុំភ្លេចខ្លួនរហូត សូម្បីឡើងជណ្ដើរក៏ខ្ញុំចង់ រត់ឡើង ឬលោតឆ្លោះកាំជណ្ដើរដែរ។ បងសយស្ទុះចូលទៅក្នុងផ្ទះវិញ ដើរប្រមែប្រមូលទ្រព្យសម្បត្តិដ៏តិចតួចរបស់គ្រួសារថ្មីថ្មោងយើង ។ សម្បត្តិទ្រព្យទីមួយដែលគាត់យួរចេញពីក្នុងផ្ទះមកដាក់ក្បែរខ្លួនខ្ញុំ គឺវិទ្យុម៉ាក្ស "ស្សេនីក Zenith " ដែលគាត់តែងប្រើប្រាស់រាល់ពេលរាល់ម៉ោង ដើម្បីស្ដាប់ពត៌មាន ។ សូម្បីក្នុងពេលទៅការខ្ញុំនៅស្រុកស្ទឹងត្រង់ក៏គាត់យួរវាទៅតាមខ្លួនដែរ ទោះបីជាវាមានទំហំធំ និងធ្ងន់យ៉ាងណាក៏ដោយ។ ពេលនោះ មានកូនសិស្ស សាលាទួលព្រះស្រីម្នាក់ បានមកដល់ផ្ទះខ្ញុំ។ គេមានបំណងមកជួយជញ្ជូនឥវ៉ាន់។ គេបានប្រាប់ខ្ញុំថា គេនៅម្តុំ

ឃ្លាំងអំរសេវ គេបានរត់ទៅមើល កន្លែងកើតអគ្គីភ័យ ឃើញសាលារបស់គេកំពុងឆេះសន្ធោរសន្ធៅ ហើយផ្ទះ ខ្ទមតូចៗនៅម្តុំនោះ ក៏កំពុងត្រូវភ្លើងឆាបឆេះរាលដាលអស់ដែរ ។ ភ្លើងបានខិតជិតមកដល់វត្តព្រះពុទ្ធហើយ ហើយគេក៏នឹកឃើញថាផ្ទះរបស់ខ្ញុំនៅម្តុំ នោះដែរ ។ ផ្ទះរបស់ខ្ញុំស្ថិតនៅលើច្រកផ្លូវក្រោយវត្តព្រះពុទ្ធមែន តែនៅចុងម្ខាងទៀត គឺខាងផ្លូវផ្សារដេប៉ូឯណោះ តែក៏មានផ្កាភ្លើងខ្លះៗធ្លាក់ចុះនៅម្តុំផ្ទះ របស់ខ្ញុំដែរ ។ ព្រឹកឡើងមានឃើញសំណាកស្លឹកប្រក់ផ្ទះដែលឆេះភ្លើងខ្មៅជ្រុះរាយនៅមុខផ្ទះ ។ លឺគេនិយាយតៗគ្នាថា អគ្គីភ័យនេះកើតឡើងដោយ មានគេលួចដុតពីព្រោះតំបន់នោះមានតែខ្ទមអនាធិបតេយ្យ ហើយដែលសាលាក្រុងត្រូវការដីសម្រាប់សង់ប៉ុរីកីឡា។ មែនហើយមើលទៅ ! ក្រោយពេល នោះបន្តិចមកឃើញមានឡាន និងគ្រឿងចក្រធំៗ បរចូលទៅកាន់ទួលព្រះស្រី ឈូសឆាយកាយចូកដី ដឹកជញ្ជូនចេញចូលគគ្រឹកគគ្រេង ។ ចំណែកឯសាលាខ្ញុំបង្រៀននៅទីនោះដែលបាត់របរាងអស់ទៅហើយនោះ ក៏ត្រូវគេរៀបចំសង់ជាបន្ទាន់ និងជាបណ្តោះអាសន្នដែរ នៅទីកន្លែងថ្មី ដើម្បីឲ្យសិស្សឆាប់បានរៀន ព្រោះទើបចូលកងរៀនបានប្រហែលជាពីរខែប៉ុណ្ណោះ ។ ដូចនេះសាខាថ្មីនៅទួលព្រះស្រី ត្រូវដូរទៅនៅខាងត្បូង ជាប់នឹងរបងវត្តព្រះពុទ្ធវិញ ។ ថ្នាក់រៀនមានតែដំបូល និងជញ្ជាំងស្លឹកជុំវិញ ឥតមានជញ្ជាំងខ័ណ្ឌពីថ្នាក់មួយទៅថ្នាក់មួយទៀតនោះទេ។ ខ្ញុំដឹងថា ខ្ញុំមុខជាត្រូវទៅបង្រៀននៅសាលាវត្តព្រះពុទ្ធនេះហើយ។ សម្រាប់ខ្ញុំ វាជារឿងល្អដែរ ព្រោះវានៅកាន់តែជិតផ្ទះខ្ញុំ។ ខ្ញុំដើរតែប្រាំនាទីដល់សាលានោះហើយ ។ តែខ្ញុំឥតទាន់ចូលទៅបង្រៀននៅឡើយទេ ព្រោះខ្ញុំមិនទាន់ដល់ថ្ងៃចូលធ្វើការ ក្រោយច្បាប់សម្រាកពេលសម្រាលកូន។ ថ្នាក់បង្រៀននៅទួលព្រះស្រីរបស់ខ្ញុំ (ហើយឥឡូវទៅនៅឯ វត្តព្រះពុទ្ធនោះ) ត្រូវបានគ្រូថ្មីមកជំនួស។ គឺប្អូនថ្លៃរបស់ប្តីខ្ញុំដែលទើបផ្លាស់ចូលមកធ្វើការ គឺនាង **ហុក ស៊ុនលី** ។ នាងទើបរៀបការជាមួយប្អូន ពៅរបស់ប្តីខ្ញុំ (**គឹមស្នូរ** )។ ផ្ទះរបស់ពួកគេនៅក្នុងរបងវាលវង់បរសេះ គឺជិតសាលាវត្តព្រះពុទ្ធនេះតែម្តង ។

ដល់ពេលដែលខ្ញុំត្រូវចូលធ្វើការវិញហើយ ។ ខ្ញុំទៅបង្រៀននៅសាលាដែលសង់ជាបណ្តោះអាសន្ន នៅក្បែរបងវត្តព្រះពុទ្ធនោះមែន ។ បង្រៀនមិនទាន់បានមួយឆ្នាំផង សាលាវត្តព្រះពុទ្ធនេះបានលើកទៅនៅក្នុងសាលាបាក់ទូកថ្មីដែលមានទីតាំងលើផ្លូវធំទល់មុខនឹងកន្លែងសាលាទួលព្រះស្រីដែលបាត់បង់ដោយអគ្គីភ័យកាលពីឆ្នាំមុន ហើយដូរឈ្មោះទៅជា "សាលាអង្គចន្ទទី ១ " វិញ ។ ចំណែកឯនៅលើផ្ទៃដីទំនេរនោះ សាលាក្រុងបានយកទៅសង់ជាប៉ុរីកីឡាវិញ សម្រាប់កីឡាករស្នាក់នៅក្នុងឱកាសបើកកីឡាអូឡាំពិក " គ្គាណេហ្វូ " ឆ្នាំ ១៩៦២ ខាងមុខនេះ ។

---

ខ្ញុំបានបំពេញការងារសិក្សាអប់រំអស់រយៈពេលប្រាំឆ្នាំហើយ។ ក្រសួងអប់រំបើកសិទ្ធិឲ្យគ្រូថ្នាក់ឧីបូមេ មានសិទ្ធិប្រឡងចូលរៀននៅមហាវិទ្យាល័យគរុកោសល្យ ដើម្បីចូលក្នុងក្របខ័ណ្ឌសាស្ត្រាចារ្យ ។ នៅឆ្នាំដំបូង ខ្ញុំប្រឡងប្រជែងនឹងគេដែរ ក៏ប៉ុន្តែឥតបានទទួលលទ្ធផលល្អទេ ។ ឆ្នាំបន្ទាប់ (១៩៦២) ទើបខ្ញុំប្រឡងជាប់ខាងមុខវិជ្ជា រូប-គីមី ។ និយាយដល់ត្រង់នេះ ខ្ញុំនឹកឃើញ ហើយចង់អស់សំណើចនឹងការរៀនត្រៀមប្រឡងរបស់ខ្ញុំ ។ គ្រូខ្ញុំបានរៀបចំ មេរៀនឲ្យខ្ញុំស្រេចៗ ។ ខ្ញុំចាំតែយកមេរៀននោះទៅមើល និងទន្ទេញតែប៉ុណ្ណោះ ព្រោះខ្ញុំមិនដែលធ្លាប់បានរៀនរូប-គីមី ក្នុងកម្មវិធីថ្នាក់ទី១ទំនើប សោះ (ខ្ញុំមានតែសញ្ញាប័ត្រឌីប្លូម) ។ ហេតុនេះហើយបានជាលោកគ្រូបញ្ជាឲ្យ ខ្ញុំទន្ទេញឲ្យចាំ ។ រាល់យប់ មុនពេលចូលដំណេក ឬជួនកាលពេលចូលមុង គាត់បានធ្វើ "កុងត្រូល " លើមេរៀនដែលគាត់ដាក់ឲ្យខ្ញុំរៀន ។ ខ្ញុំឥត បានដឹងថាមេរៀនណាសំខាន់ ណាមិនសំខាន់ឡើយ ។ ខ្ញុំរៀនចាំមាត់ទាំងដប់មេរៀន ដែលគាត់បានរៀបចំឲ្យតែម្តង ។ ពេលប្រឡងចេញមេរៀននៅចុង កម្មវិធីសិក្សា ដែលសិស្សថ្នាក់ទីមួយទំនើបមិនសូវចាប់អារម្មណ៍ និងឲ្យតម្លៃ ។ ដោយឡែកចំពោះខ្ញុំ វាចំប្លង់តែម្តងខ្ញុំពួយសរសេរពីរម៉ោងកន្លះ ឥតមានឈប់ដៃ ។ លទ្ធផលល្អ បានមកដល់ខ្ញុំហើយ ។

ខ្ញុំបានចូលរៀននៅមហាវិទ្យាល័យគរុកោសល្យ រៀនតាមមុខវិជ្ជារូប-គីមីនោះ ។ បានតែជាងពីរសប្តាហ៍ទេ ខ្ញុំដឹងខ្លួនថាយ៉ាប់ហើយ ព្រោះខ្វះមូលដ្ឋានច្រើនក្នុងមុខវិជ្ជានោះ ។ ចៃដន្យល្អ ពេលនោះសាលាត្រូវការនិស្សិត ផ្នែកអក្សរសាស្ត្រខ្មែរ ផ្នែកប្រវត្តិ-ភូមិវិទ្យាបន្ថែម ហើយអនុញ្ញាតឲ្យនិស្សិត ផ្នែកមុខវិជ្ជាផ្សេងៗទៀត ដូរមកមុខវិជ្ជាទាំងពីរនេះបាន ។ ជាឱកាសល្អសម្រាប់ខ្ញុំៗក៏ដូរយកមុខវិជ្ជាប្រវត្តិ-ភូមិវិទ្យាភ្លែត ។ មានមិត្តភក្តិខ្ញុំម្នាក់ដែល ចូលចិត្តបណ្តុះបង្អាប់ខ្ញុំ ហើយចង់ឲ្យខ្ញុំដូរទៅផ្នែកអក្សរសាស្ត្រដូចគេដែរនោះ បាននិយាយរិះគន់ខ្ញុំថា " ខ្លួនឯងនេះសាវ៉ាណាស់ ឆ្នាំមុនប្រឡងយកមុខវិជ្ជា អក្សរសាស្ត្រខ្មែរ ឆ្នាំនេះប្រឡងយករូប-គីមី ប្រឡងជាប់ហើយ បែរជាដូរ ទៅរៀនភូមិវិទ្យាធ្វើព្រងើយ គួរតែដូរចូលរៀន ខាងអក្សរសាស្ត្រវិញទៅ!"។ ប្រហែលជាខ្ញុំសាវ៉ាមែនទេដឹង ព្រោះខ្ញុំរៀនចប់ពីរឆ្នាំផ្នែកប្រវត្តិ-ភូមិវិទ្យាតែបែរជាចេញទៅធ្វើសាស្ត្រាចារ្យបង្រៀនផ្នែកអក្សរសាស្ត្រទៅវិញដដែល ។ ក៏ប៉ុន្តែលើបញ្ហានេះ មិនមែនជាចេតនារបស់ខ្ញុំទេ គឺសាលាខ្វះសាស្ត្រាចារ្យ ផ្នែកអក្សរសាស្ត្រ នាយកសាលាក៏តម្រូវឲ្យសាស្ត្រាចារ្យផ្លាស់ចូលថ្មី ទៅបង្រៀនមុខវិជ្ជានេះទៅ ។ ខ្ញុំព្រមទទួលក៏ដោយសារខ្ញុំធ្លាប់រៀនអក្សរសិល្ប៍ខ្មែរ កាលខ្ញុំរៀនត្រៀមប្រឡងចូលសាស្ត្រាចារ្យផងដែរ ។ ខ្ញុំចាប់បង្រៀន ខាងអក្សរសិល្ប៍ខ្មែរនៅថ្នាក់ទី៣ទំនើប(ថ្នាក់ប្រលងឌីប្លូម) នៅអនុវិទ្យាល័យ សង្គមរាស្ត្រនិយមដែលមានទីតាំងក្នុងរបងជាមួយគ្នានឹងសាលាបឋមសិក្សា "ពៅអ៊ុំ" ។ ខ្ញុំបង្រៀននៅទីនោះបានតែពីរឆ្នាំទេ (១៩៦៥-១៩៦៦) ព្រោះ នៅសាលា នរ៉ោត្តម ខាងជើង ដែលជាមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន (Centre de Formation des Instituteurs) គេត្រូវការរកសាស្ត្រាចារ្យដែលធ្លាប់មានបទពិសោធន៍ក្នុងការបង្រៀននៅបឋមសិក្សា ។ ក៏ត្រូវគេជ្រើសរើសឲ្យចូលទៅបង្រៀននៅក្នុងមជ្ឈមណ្ឌលនោះ នៅឆ្នាំ ១៩៦៧ រហូតមក ។

ប្តីរបស់ខ្ញុំ ក្រោយពីកសាងគ្រួសារជាមួយខ្ញុំមក គាត់បានឈប់សរសេរកាសែត ហើយបានដាក់ពាក្យសុំចូលធ្វើការក្នុងក្រសួងសិក្សាអប់រំដែរ ។

គាត់ ក៏ត្រូវបានគេទទួលឲ្យធ្វើការភ្លាម ដោយឲ្យឋានៈជា "សាស្ត្រាចារ្យជាប់កិច្ចសន្យា (Professor Contratuel)"។ បងសយធ្លាប់បង្រៀនមុខវិជ្ជារូបគីមីនៅសាលាឯកជនតាំងពីយូរមកហើយៗគាត់ត្រូវបានគេចាត់តាំងឲ្យទៅបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិតាំងពីឆ្នាំ ១៩៥៨ កំណើតកូនប្រុសទីមួយរបស់ខ្ញុំ ។ គាត់ឥតមានជំនាន់ដូចសាស្ត្រាចារ្យក្រោយៗមកទៀតទេ ពីព្រោះកាលណោះ ពុំទាន់មានសាលាសម្រាប់បណ្តុះបណ្តាលគ្រូក្របខ័ណ្ឌសាស្ត្រាចារ្យនៅឡើយ ។

នៅឆ្នាំ១៩៦០ ខ្ញុំក៏បានកើតកូនស្រីដំបូង គឺនាង "**ពីន សិរិអារ្យ**" ; ខ្ញុំនិងប្ដីខ្ញុំធ្វើការទាំងពីរនាក់បានប្រាក់ច្រើន ហើយសន្សំលុយក៏បានច្រើនដែរ ។ ប្រាក់ខែពីរនាក់ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ មានប្រាក់ខែកូន,ប្រាក់លំនៅដ្ឋាន ប្រាក់គរុកោសល្យ បានប្រហែលមួយម៉ឺនប្រាំពីរពាន់ប្លាយ (គិតជាមាសមួយតំឡឹង ពីរពាន់ប្រាំរយរៀល គឺបានក្នុងមួយខែៗ ស្មើនឹងប្រាំមួយប្រាំពីរតំឡឹង ឯណោះ)។ ខ្ញុំចាំហាងឆេងមាសច្បាស់ណាស់ ពីព្រោះកាលណោះ បងសយ បានយកមាសដែលម្ដាយក្មេកខ្ញុំចងដៃមួយតំឡឹងទៅលក់បានតែប៉ុណ្ណោះឯង ។ យើងចាប់សង់ផ្ទះថ្មី នៅលើដីដែលសាលាក្រុងទើបឈូសឆាយផ្លូវ ហើយវាយជាឡូត៍ចែកឲ្យប្រជាជនដែលមានលំនៅដ្ឋានស្របច្បាប់ ទំហំ ២០ ម៉ែត្រគុណ ៣០ ម៉ែត្រ ។ ដោយថវិកាយើងស្ដួចស្ដើង យើងសង់ដំបូងតែផ្ទះផ្នែកខាងក្រោយសិន ដែលមានផ្ទះបាយមួយ បន្ទប់តូចៗពីរ និងការ៉ាសឡាន ។ យើងចូលទៅនៅក្នុងបន្ទប់ដែលទើបសង់ហើយនោះនៅឆ្នាំ ១៩៦១ កំណើតនាងដា "**ពីន សិដ្ឋា**"ជាកូនទីបី ជាបណ្ដោះអាសន្ន ។ យើងបន្តសង់ផ្ទះធំខាងមុខអស់ ពេលយ៉ាងយូរទើបហើយ គឺមានតែទ្រង់ទ្រាយសំណង់តែប៉ុណ្ណោះ ។ យើងចូលនៅលើផ្ទះធំ នៅកំណើតនាងទ្បុំ "**ពីន យោសិតា**"កូនទីបួន ឆ្នាំ ១៩៦៣ ។ ផ្ទះសង់រួចរាល់មែនហើយ តែពុំមានឧបករណ៍ ឬ សំភារៈប្រើប្រាស់នៅឡើយ ។ ប៉ុនតែប៉ុណ្ណោះ នៅមានជាប់បំណុលគេ ២០ ម៉ឺនរៀលទៀត ដែលត្រូវចេញ

ការប្រាក់ ១ ភាគរយក្នុងមួយខែ ។ និយាយដល់ត្រង់នេះ ខ្ញុំសូមសរសើរគំនិតរបស់ម្ដាយក្មេកខ្ញុំ។ គាត់ពូកែរកស៊ីណាស់ ហើយក៏ពូកែសន្សំប្រាក់ដែរ ។ គាត់ចាយវាយយ៉ាងតិចតួចបំផុត រហូតដល់មានពាក្យអ្នកស្រុកនិយាយថា គាត់ជាមនុស្សកំណាញ់ ហើយមានគេយកឈ្មោះគាត់ទៅប្រើជាមួយអ្នកដែលមាន ចរិតដូចនោះ ។ គេថា "កុំកំណាញ់ ដូចយាយហួត " ។ កំណាញ់អញ្ចឹងទៅគាត់មានសល់ប្រាក់ច្រើន ហើយមានគំនិតចង់ជួយកូនៗណាដែលក្រ ។ គាត់ ផ្ដល់ប្រាក់ឲ្យខ្ចី ហើយយកការប្រាក់ទាបបំផុត ។ កូនទាំងអស់បានពិភាក្សាគ្នា សម្រេចថា ខ្ចីប្រាក់គាត់ម្នាក់ដប់ម៉ឺនរៀលៗ ហើយត្រូវជូនការប្រាក់គាត់មួយម៉ឺនរៀលក្នុងមួយឆ្នាំ ទោះបីគេមិនខ្វះខាតក៏ដោយ ព្រោះគេយល់ថា ការប្រាក់មួយម៉ឺនរៀលក្នុងមួយឆ្នាំ មិនច្រើនទេ ហើយចាត់ទុកថា ជូនម៉ែទៅចុះ ព្រោះម៉ែមានបំណងចង់ធ្វើអ្វីមួយជាប្រយោជន៍ ដល់ស្រុកភូមិរបស់គាត់ ។ គាត់កំពុងទាក់ទងនឹងសាលាស្រុក ដើម្បីសុំដីមួយកន្លែងសង់មន្ទីរពេទ្យសម្រាប់ ស្រុកពួក ខេត្តសៀមរាប ។ អាគារបានសង់ហើយរួចរាល់ជាស្ថាពរ (អាគារ ដែលគាត់បានសង់ក្នុងមន្ទីរពេទ្យនោះ សង់អស់ទឹកប្រាក់ជាងម្ភៃម៉ឺនរៀល តែពុំទាន់ មានបំពាក់គ្រឿងឧបករណ៍ ហើយក៏ពុំទាន់បានប្រើប្រាស់នៅឡើយដែរ ព្រោះចូលដល់



សម័យសង្គ្រាម។ ក្រោយមកអាគារ យាយហួត ត្រូវខ្មែចខ្ទាំ ដោយការប្រយុទ្ធគ្នារវាងទាហានការពារសាលាស្រុក និងពួកខ្មែរក្រហម ជាមួយពួកទ័ពយៀកកុង ) នៅសល់តែគ្រឹះដែលនៅគង់វង្សរហូតដល់សព្វថ្ងៃ ហើយដែលក្រោយឆ្នាំ ១៩៧៩ ត្រូវបានអង្គការ MSF សង់អាគារពីលើគ្រឹះនេះសម្រាប់ជាកន្លែងពិគ្រោះជំងឺរបស់មណ្ឌលសុខភាពពួក។

ដោយដឹងថាយើងកំពុងខ្វះខាតលុយកាក់ ប្អូនប្រុសពៅរបស់ប្ដីខ្ញុំបានបង្វែរលុយកំចីនោះឲ្យមកយើងវិញ ។ អញ្ចឹងហើយបានជាខ្ញុំអាចធ្វើផ្ទះវីឡាមួយយ៉ាងសមរម្យ (ល្អ និងធំជាងគេនៅម្តុំនោះក្នុងសម័យនោះ) ។ ប្រាក់ដែលខ្ញុំជំពាក់គេ ២០ម៉ឺនរៀលនោះ គឺសុទ្ធតែជាប្រាក់ម៉ែក្មេកខ្ញុំនោះឯង ។ ខ្ញុំនិងប្ដីខ្ញុំ ត្រូវតែត្បិតត្បៀតរកប្រាក់សងម៉ែ ទាំងចំណែកខ្ញុំខ្ចី ទាំងចំណែកប្អូនថ្លៃខ្ញុំ ដែលបានឲ្យលុយមកខ្ញុំខ្ចីបន្ត ។ ចំណែកឯប្រាក់ដែលម៉ែឲ្យកូនគ្រប់ៗគ្នាខ្ចីដប់ម៉ឺនរៀលនោះ គាត់បាននិយាយថា ពេលឥតពីគាត់ទៅប្រាក់នោះចាត់ទុកជាប្រាក់ដែលម៉ែចែកឲ្យកូនៗទៅចុះ ។ " ខ្ញុំតែងចងចាំទង្វើនេះដោយគិតថា ខ្ញុំនឹងធ្វើយ៉ាងនេះដែរ ដល់ពេលខ្ញុំចាស់ទៅប្រសិនបើខ្ញុំមានប្រាក់សល់ច្រើន " ។

យើងរស់នៅក្នុងស្ថានភាពតឹងតែង មិនសូវជាយូរឆ្នាំប៉ុន្មានទេ យើងបានសងបំណុលអស់ ។ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយក៏យើងនៅតែរក្សាគំនិតសន្សំសំចៃបន្តទៅទៀតដែរ ដើម្បីមានប្រាក់សម្រាប់រៀបចំផ្ទះសម្បែងឲ្យបានសមរម្យ ឲ្យមានឧបករណ៍គ្រប់គ្រាន់សម្រាប់ប្រើប្រាស់ ។ ការសន្សំសំចៃនេះ គឺជាគំនិតរបស់ប្ដីខ្ញុំច្រើនជាងខ្ញុំ ព្រោះខ្ញុំជាមនុស្សចូលចិត្តសប្បាយ និងហ៊ុំហាបន្តិចដែរ បើប្រៀបធៀបជាមួយនឹងគាត់ ។ ឯប្ដីខ្ញុំវិញប្រហែលជាគាត់កាត់ទៅតាម " **ម៉ែហួត** " របស់គាត់ហើយ! ចាយវាយត្បិតត្បៀត មិនខ្ជះខ្ជាយ ដើម្បីសន្សំប្រាក់ទុកសម្រាប់សេដ្ឋកិច្ចគ្រួសារ ពីព្រោះអាជីពគ្រូបង្រៀននេះ ឥតមានចំណូលអ្វីក្រៅអំពីប្រាក់ខែនោះឡើយ ។ ទោះបីជាដឹងថាប្រាក់ខែប៉ុណ្ណឹង ពុំអាចធានាជីវភាពគ្រួសារឲ្យបានធូរធារ

សំបូរសប្បាយក៏ដោយ ក៏គាត់ឥតមានមហិច្ឆតាខ្ពស់ ចង់បានភាពស្ដុកស្ដម្ភអ្វីដែរ ។ ផ្ទុយទៅវិញ គាត់តែងយកពេលទំនេរពីការងារទៅតាមដានព្រឹត្តិការណ៍នៅលើពិភពលោក គាត់អានសៀវភៅដែលមានគំនិតជឿនលឿន កត់ត្រាគំនិតល្អៗ ដែលអប់រំប្រជាពលរដ្ឋឲ្យក្លាយជាមនុស្សថ្មី មានសីលធម៌ មានសមត្ថភាព និងឧត្ដមគតិ...។ ដោយមានជំហរបែបនេះហើយបានជាក្នុងមួយជីវិតរបស់គាត់ៗពុំដែលស្វែងរកលាភសក្ការៈសម្រាប់ខ្លួនគាត់ឡើយ ។ គាត់តែងធ្វើគំរូ ល្អ ដល់អ្នកដទៃ តែងជួយណែនាំអ្នករួមការងារ ក្នុងស្មារតីចង់ពួកគេចូល រួមកសាងអភិវឌ្ឍន៍ប្រទេសជាតិជាប់ជានិច្ច។

ការកសាងជីវិតគ្រួសាររបស់យើង ថ្វីត្បិតតែមិនស្ទូវធូរធារ សម្បូរសប្បាយក៏ពិតមែន តែជាជីវិតដែលប្រកបទៅដោយភាពល្អកល្អើន និងសេចក្ដីថ្លៃថ្នូរ ។ យើងមានញាតិសន្ដានមកពឹងពាក់ស្នាក់អាស្រ័យនៅជាមួយ។ ក្រោយមកខ្ញុំបានបង្កើតកូនស្រីមួយទៀតឈ្មោះ " **ពិន ជុតិមា** " ហៅ **ពិន** ។ ឥឡូវយើងមានកូន ៥ នាក់ ដែលជាកូនល្អ ស្រឡាញ់ឪពុកម្ដាយ ស្រឡាញ់បងប្អូន មានស្មារតីរឹងប៉ឹង និងជំហរខ្លួនទីពឹងខ្លួន ដូចចរិតឪពុករបស់គេដែរ ។ អញ្ចឹងហើយការរស់នៅរបស់យើង ឋិតនៅក្នុងភាពសុខដមរមនាឥតមានសៅហ្មង ។

- មាតាបិតា បណ្ដុះបុត្រភ្វា កាយបញ្ញាចិត្ត
  មូនមាំឈ្លាសវៃ ចរិតបរិសុទ្ធ កបលក្ខណ៍សម្បត្តិ
  ពលរដ្ឋរឹងប៉ឹង ។
- មាតាបិតា ផ្ដល់បុត្រធីតា គំរូតឹងរ៉ឹង
  ខ្លួនទីពឹងខ្លួន កសាងទ្រព្យធន គតិថ្លៃថ្នូរផង
  ជាពលរដ្ឋល្អ ។

# វគ្គទី ៣

## *ជីវិតក្នុងព្យុះនយោបាយ*

ព្រឹត្តិការណ៍នយោបាយក្នុងប្រទេស ដែលធ្លាប់មានតាំងពីមុន និង ក្រោយសម័យបារាំង ដូចជាសម័យខ្មែរឥស្សរៈសម័យដាបឈួន (ឆ្នាំ ១៩៥៨–៥៩) សម័យខ្មែរយៀកមិញ ដែលបានកន្លងផុតទៅហើយនោះ ឥឡូវផ្ទុះរឿង ការរត់ចូលព្រៃរបស់ក្រុមនិស្សិត បញ្ញវន្តថែមទៀត ។ ពួកគេបានសន្មតថា ជាក្រុមអ្នកជឿនលឿន ហើយបង្កើតចលនាតស៊ូមួយ ដើម្បីលទ្ធិប្រជាធិបតេយ្យ ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម រិះរកគ្រប់វិធានការ ទប់ស្កាត់ ។ គេចាប់ជនដែលគេសង្ស័យថាបានចូលរួមចំណែកប្រឆាំងនឹងរាជរដ្ឋាភិបាលជាបន្តបន្ទាប់ ។ កាលនោះប្តីរបស់ខ្ញុំជាសាស្ត្រាចារ្យបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ គាត់ធ្លាប់មានទំនាក់ទំនងជាមួយសាស្ត្រាចារ្យ និង ជាមួយសិស្សជាច្រើននាក់ដែរ ដែលក្នុងចំណោមអ្នកទាំងនោះ មានមនុស្សមួយចំនួនបានរត់ចូលព្រៃបាត់អស់ទៅហើយ ។ ដូច្នោះហើយ បានជាគេស្រង់ ឈ្មោះអ្នកដែលគេមិនទុកចិត្ត ដើម្បីទប់ស្កាត់ការរត់ចូលព្រៃរបស់និស្សិត សាស្ត្រាចារ្យ និង បញ្ញវន្ត ។ រាជរដ្ឋាភិបាលបានចាប់ជនដែលគេមិនទុកចិត្ត យកទៅឃុំឃាំងនៅកន្លែងប៉ូលីសព្រហ្មទណ្ឌ។ គេចាប់សាស្ត្រាចារ្យ គ្រូបង្រៀន វរៈជនខ្លះៗក្នុងនោះមានប្តីខ្ញុំផងដែរ ( ទាំងអស់ប្រហែលជា ៣០ នាក់ ) ។ ខ្ញុំស្គាល់មនុស្សប្អូនដប់នាក់ដែរ តែចាំឈ្មោះបានខ្លះតែប៉ុណ្ណោះ ដូចជា លោក សាស្ត្រាចារ្យ ឃុន **ស្រ៊ុន** ( អ្នកនិពន្ធសៀវភៅ លំនៅចុងក្រោយ ) កញ្ញា សាស្ត្រាចារ្យ ស.ច.យ (អ្នកនិពន្ធសូមរក្សាសិទ្ធមិនបញ្ចេញឈ្មោះតាមសំណូមពររបស់សាម៉ីជន) **ង៉ូ ទណ្ឌធន** លោកសាស្ត្រាចារ្យ **ឡាំ សខ្ខារ** ទាំងប្តី ទាំង ប្រពន្ធ

( **ម៉ែន ម៉ៀ** ) លោក **ចៅ សៅ** ...។ គេចាប់ អ្នកទាំងនោះបង្ខាំងទុកនៅក្នុងប៉ូលីសព្រហ្មទណ្ឌ PJ ភ្នំពេញ ហើយឲ្យនៅជុំគ្នាអត់មានដាក់ខ្នោះឃ្នាងអ្វីទេ ។ គេអនុញ្ញាតឲ្យគ្រួសារយកបាយ ទឹកទៅឲ្យរាល់ពេល ។ មកដល់ចំណុចនេះ ខ្ញុំក៏នឹកឃើញឡើងវិញម្តងទៀត នូវសំដីទិតៀនរបស់មនុស្សមួយចំនួនដែលធ្លាប់បានរិះគន់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍ ម្តងចង់យំ ម្តងចង់អស់សំណើច ។ ចង់យំ ពីព្រោះតូចចិត្ត និងខឹងចំពោះការបំពារបំពានយ៉ាងអយុត្តិធម៌ ពីសំណាក់អ្នកកាន់អំណាចខ្មែរ ។ ចង់សើច ពីព្រោះយល់ថាការទិតៀនរបស់គេត្រូវមែន គឺឃ្យូរចានស្រាក់មែន ។ ក៏ប៉ុន្តែ ខ្ញុំឥតបានឃ្យូរចានស្រាក់ដាក់បាយ ទៅឲ្យប្តីខ្ញុំរាល់ថ្ងៃនោះទេ គឺក្នុងមួយសប្តាហ៍ ខ្ញុំយកម្ហូបអាហារទៅឲ្យគាត់តែមួយដងប៉ុណ្ណោះ ដោយសារពួកគេទាំងនោះ ហូបបាយជុំគ្នា ហើយចែកវេនគ្នា ឲ្យសាច់ញាតិយកម្ហូបទៅឲ្យ ។ ការបែកគ្នារវាងប្តីខ្ញុំនិងខ្ញុំនៅលើកនេះ មានរយៈពេលតែជាងបីខែ មិនយូរដូចពេលគាត់ជាប់នៅគុកធំនោះទេ គឺដល់ទៅប្រាំបីខែ និងប្រាំថ្ងៃឯណោះ ។

ព្រឹត្តិការណ៍ប្លែកៗកើតមានជាបន្តបន្ទាប់ ធ្វើឲ្យគ្រួសាររបស់ខ្ញុំរស់នៅក្នុងភាពខ្វះល់នឹង ។ សូមគិតមើលចុះ ! សូម្បីការមកធ្វើទស្សនកិច្ចរបស់លោកប្រធានាធិបតីប្រទេសបារាំង " **ស្ហាលដឺហ្គោល** " ឆ្នាំ ១៩៦៦ ដែលពេលនោះរាជរដ្ឋាភិបាលបានកែនកូនសិស្ស និងប្រជាជនឲ្យទៅធ្វើជារបងកិត្តិយសចាំទទួលស្វាគមន៍លោកប្រធានាធិបតី តែដោយឡែកប្តីរបស់ខ្ញុំ និងសាស្ត្រាចារ្យមួយចំនួនទៀតវិញ ត្រូវបានថ្នាក់លើរបស់ក្រសួងអប់រំ បញ្ជាឲ្យមកជួបនៅសាលាពីរបីថ្ងៃមុន ដើម្បីឲ្យគេដឹកពួកគាត់ជន្លៀសចេញពីភ្នំពេញ ទៅឲ្យឆ្ងាយពីទីដែលគណៈប្រតិភូឆ្លងកាត់ ។ សូមជំរាបថា ក្នុងអំឡុងពេលដែលគេដឹកពួកគាត់ជន្លៀសទៅទុកនៅកន្លែងណាមួយនោះ គឺតែងតែមានមនុស្សនៅតាមគ្រប់គ្រង និងតាមឃ្លាំមើលជានិច្ច មិនឲ្យឃ្លាតចេញពីក្រសែភ្នែករបស់គេឡើយ ។ ដរាបណាដែលគណៈប្រតិភូជាន់ខ្ពស់ បញ្ចប់ទស្សនកិច្ចទើបគេអនុញ្ញាតឲ្យពួកគាត់ត្រឡប់មកផ្ទះសម្បែងវិញ ។

ក៏ដូចគ្នានេះដែរ នៅពេលដែលលោកប្រធានាធិបតីប្រទេសឥណ្ឌូណេស៊ី "**ស៊ីការណូ**" មកទស្សនកិច្ច ក៏គេធ្វើរបៀបនេះចំពោះប្ដីរបស់ខ្ញុំ និងក្រុមគាត់ដែរ ។ និយាយដល់រឿងទស្សនកិច្ចនេះ ខ្ញុំនឹកដល់រឿងមួយដែលគួរឲ្យអស់សំណើច ។ ដោយសារតែចង់តម្រូវចិត្តលោកប្រធានាធិបតី ឥណ្ឌូណេស៊ី កាលនោះ គេឲ្យរកនារីៗ មានរូបសម្ផស្សស្អាត មានចំណេះដឹងខ្ពស់ ចេញពីមជ្ឈដ្ឋាននិស្សិតបញ្ញាវន្តឲ្យទៅដើរហែហមគណៈប្រតិភូ ។ ក្នុងនោះ គេជ្រើសចេញពីពួកអ្នកគ្រូៗ ដែលនៅលីវនិងនិស្សិត នៅមហាវិទ្យាល័យ ដែលឲ្យតែឃើញ ឈ្មោះមានដាក់ថា " កញ្ញា..." នៅពីមុខ គេចុះក្នុងបញ្ជីអញ្ជើញអ្នកនោះ ទៅចូលរួមដើម្បីជ្រើសរើស ។ គេហៅឈ្មោះម្នាក់ម្ដងៗ គេពិនិត្យរូបសម្ផស្ស ហើយបើត្រឹមត្រូវតាមលក្ខខ័ណ្ឌ ទើបគេទទួលយកឈ្មោះនោះ ។ កាលនោះ គេមិនបានគិតពីអាយុទេ ឲ្យតែនៅលីវត្រូវបានគេហៅទាំងអស់ ។ អញ្ចឹង ហើយសូម្បីតែក្រមុំចាស់ ក៏ត្រូវមានឈ្មោះហៅចេញដើរឲ្យគេមើលដែរ ។ ថៃជន្យអី គេហៅឈ្មោះ អ្នកគ្រូម្នាក់ដែលចាស់ជាងគេ មានសក់ស្កូវទៅហើយ (គាត់ធ្វើការនៅអនុវិទ្យាល័យ នារីកាលសម័យនោះ) ឲ្យចេញមកបង្ហាញខ្លួនជាមួយគេដែរ ។ គ្រាន់តែចេញអើតផុតពីមាត់ទ្វារ ស្នូរសំណើចហួសចិត្ត របស់គណៈមេប្រយោគ ហោរិតិលលីលាន់រំពងពេញបន្ទប់តែម្ដង ធ្វើឲ្យអ្នកគ្រូមានការអាម៉ាស និងខឹងសម្បាយ៉ាងក្រៃលែង ។

វិធានការដែលរាជរដ្ឋាភិបាលបានប្រើចំពោះសាស្ត្រាចារ្យ បញ្ញាវន្ត និងនិស្សិត គឺជាគំនិតទប់ស្កាត់ចលនាតស៊ូ កុំឲ្យលូតលាស់បាន ។ ក្នុងស្មារតីប្រយ័ត្នប្រយែងនេះដែរ រាជរដ្ឋាភិបាលបានតម្រូវឲ្យក្រសួងអប់រំដកប្ដីខ្ញុំឈប់ឲ្យបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិតទៅទៀត ដោយបំផ្លាស់គាត់ទៅធ្វើការនៅ " សកលវិទ្យាល័យ ប្រជារាស្ត្រ " ដែលជាសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ (ទីតាំងសកលវិទ្យាល័យ នៅឈៀងពីមុខ សាលាពេទ្យជិតក្រសួងឃោសនា–ការ)វិញ ដើម្បីទៅឲ្យឆ្ងាយពីទំនាក់ទំនងជាមួយសិស្ស

និងគ្រូៗ ដ៏ទៃទៀត។ ប្ដីខ្ញុំទៅធ្វើការនៅទីនោះ ក្នុងតួនាទីជាអ្នកគ្រប់គ្រង សាលាឯកជនផ្នែកបច្ចេកទេស ( កាលនោះមាន ច្រើនតែជា សាលារៀន កាត់ដេរ វាយអង្គុលីលេខ និង ខាងភ្លើងអគ្គីសនី តិចតួចប៉ុណ្ណោះ ) ។ ភាព រង្គោះរង្គើបានរីកដុះដាល ។ ចលនាតស៊ូដែលពួកគេបានប្រកាសថា ជាកង ទ័ពរំដោះជាតិបាន វាយរំដោះភូមិ ឃុំនានាដែលនៅដាច់ស្រយាល ឬ ក៏នៅ ឆ្ងាយពីទីប្រជុំជនធំៗ បានជាបន្តបន្ទាប់ ។

ព្រឹត្តិការណ៍ថ្ងៃ ១៨ មិនា ឆ្នាំ ១៩៧០ បានកើតមានឡើង នៅពេល ដែលសម្ដេចព្រះប្រមុខរដ្ឋ ( សម្ដេចសីហនុ )ទ្រង់យាងទៅធ្វើទស្សនកិច្ចនៅ ប្រទេសបារាំង ។ វីរជនបីរូប គឺព្រះអង្គម្ចាស់ **សិរីមតៈ** ឯកឧត្តម **អ៊ិន តាំ** និង ឯកឧត្តម **ចេង ហេង** បានធ្វើរដ្ឋប្រហារ ទំលាក់សម្ដេចសីហនុ ហើយ ប្រកាសដូររាជាណាចក្រកម្ពុជាទៅជាសាធារណរដ្ឋវិញ ។ រដ្ឋាភិបាលថ្មីក៏ ត្រូវបានគេបង្កើតឡើងដោយលោកឧត្តមសេនីយ **លន់ ណុល** ជាប្រមុខរដ្ឋ រីឯសមាជិកនៃរដ្ឋាភិបាលនោះ មានភាគច្រើនជាមនុស្សថ្មី ជាមន្ត្រីយោធា ជាបញ្ញវន្តខ្លះដែរ ។ រដ្ឋាភិបាលថ្មីនេះ ត្រូវប្រឈមមុខនឹង ចលនាតស៊ូ រំដោះជាតិ ហើយចលនាតស៊ូនេះ ដឹកនាំដោយពួកនិន្នាការសង្គមនិយម បានទទួលសហការណ៍អំពីសម្ដេចដែលបានធ្លាក់ពីព្រះតំណែង និងក្រុម អ្នករាជានិយម ព្រមទាំងកំលាំងប្រយុទ្ធរបស់កងទ័ពព្រៃវៀតណាម "ពួក វៀតកុង " ថែមទៀត ។ ចលនានេះធ្វើការរំដោះជាតិ មានកំលាំងខ្លាំងក្លា តែ មួយប៉ព្រិចភ្នែកប៉ុណ្ណោះ កងទ័ពព្រៃនេះ រំដោះបានខេត្តក្រចេះ ស្ទឹងត្រែង និងមួយផ្នែកនៃ ខេត្តកំពង់ចាម ។ អញ្ចឹងហើយ មានស្រុកភូមិមួយចំនួនធំ បានក្លាយជាតំបន់រំដោះ គ្រប់គ្រងដោយកងទ័ពរំដោះជាតិ ។ អសន្តិសុខ និងវិនាសកម្ម បង្កអោយមានវិបត្តិសង្គមធ្ងន់ធ្ងរ។ ចលាចល ចារកម្ម ចោរកម្ម អំពើពុករលួយ ទំនិញឡើងថ្លៃ ។ល។ និង ។ល។ ធ្វើឲ្យពពួកឱកាសនិយម បំពេញនូវមហិច្ឆិតាដ៏ស្មោកគ្រោករបស់ខ្លួននាឱកាសនោះ ។ ពួកជនទុច្ចរិត ដើរតំរាម កំហែងជនស្លូតត្រង់ ។ ពួកជនអាក់សែឆ្លៀតឱកាសដើរឆក់ប្លន់

វាយឃ្លាំងរដ្ឋ ឃ្លាំងឯកជន ដណ្តើមគ្នាយ៉ាងប្រញាប់ ដឹកជញ្ជូនអង្ករ គ្រឿងឧបភោគ បរិភោគ ចេញពីឃ្លាំង ។

ចំណែកឯអ្នករដ្ឋការតូចតាច មានប៉ូលីស ទាហាន បុគ្គលិកនៃក្រសួងនានា ជាពិសេសបុគ្គលិកសិក្សា បានធ្វើការតវ៉ាសុំឲ្យបញ្ចុះតំលៃទំនិញ ដែលពួកឈ្មួញតំឡើងថ្លៃតាមអំពើចិត្ត ។ ភាពរពើតរពើងពុំមែនមានតែនៅក្នុងជួរអ្នករដ្ឋការប៉ុណ្ណោះទេ អ្នកដែលទទួលផលវិបាកខ្លាំងជាងគេនោះគឺប្រជាជនស្រទាប់កណ្តាល និងថ្នាក់ក្រោម( ចំនួន ៩០% នៃប្រជាជននៅក្នុងផ្ទៃប្រទេសដែលជា ជនក្រីក្រតោកយាក) ។ សកម្មភាពនៃការតវ៉ានេះ មានលក្ខណៈផុលផុសជាង គេនៅក្នុងជួរបុគ្គលិកសិក្សា ពីព្រោះមានសមាគមគ្រូ(AMCEK)ជួយគាំទ្រ ។ គ្រូបង្រៀននៅតាមខេត្ត ខ័ណ្ឌនានា ក៏បានចូលរួមយ៉ាងសកម្មដែរ ។ ស្រប នឹងដំណើរការណ៍នេះ មានចលនាបះបោរមួយរបស់ពួកនិស្សិតសាលាច្បាប់ ដឹកនាំដោយនិស្សិតឈ្មោះ **កុយ ម៉ិច, សន ថាត, អ៊ុំ ឃុំមា** ជំរុញឲ្យនិស្សិត និងសិស្សនៅវិទ្យាល័យអនុវិទ្យាល័យជាច្រើន ចូលរួមក្នុងចលនាតវ៉ានោះ យ៉ាងគគ្រឹកគគ្រេងផងដែរ ។ នៅវិទ្យាល័យ ១៨ មិនា ( នៅកាច់ ជ្រុងភ្លើងស្តុបពេទ្យចិន ) ពួកសិស្សវិទ្យាល័យក៏បានធ្វើកូដកម្ម នៅក្នុងសាលាអស់រយៈពេល បី–បួនថ្ងៃ ដែលធ្វើឲ្យលោករដ្ឋមន្ត្រីក្រសួងអប់រំ "**ថាច់ ខា**" រួមជាមួយលោកវេជ្ជបណ្ឌិត " **កែវ សាំងគិម** "ចូលទៅធ្វើការសម្រុះសម្រួល ។ តែផ្ទុយទៅវិញ បែរជាមានជនបង្កប់ មកបន្លំខ្លួនក្នុងជួរសិស្ស ដើម្បីធ្វើឃាត លោកទាំងពីរយ៉ាងព្រៃផ្សៃ ដោយបាញ់នឹងគ្រាប់កាំភ្លើង ។ ព្រឹត្តិការណ៍ជំ រន្ធត់ជាច្រើនបានកើតឡើង មានការដើរដង្ហែក្បួន ការដង្ហែក្តារមឈូស នៅវិមានឯករាជ្យជាដើម ។ ដោយហេតុថាការតវ៉ារបស់យើងទាំងអស់គ្នាឥតមានដំណោះស្រាយ គេក៏ប្រមូលមតិគ្នា បង្កើតគណៈកម្មាការនៅក្នុងសមាគមគ្រូ ដើម្បីរៀបចំធ្វើមិទីញមួយតវ៉ាសុំឲ្យរដ្ឋាភិបាលសាធារណរដ្ឋ បញ្ចុះតំលៃទំនិញ ។ ក្នុងគណៈកម្មាការនោះ មានតំណាងគ្រូៗមកពីខេត្តនានាផង និងសមាជិកនៃសមាគម

គ្រូនៅក្រុងភ្នំពេញផង ដែលមានឈ្មោះប្ដីរបស់ខ្ញុំផងដែរ។

ថ្ងៃ ១៧ មិនា ឆ្នាំ ១៩៧៣ បានមកដល់ មិទីញធំមួយបានប្រារព្ធធ្វើឡើង ដើម្បីធ្វើការតវ៉ាសុំបញ្ចុះតំលៃទំនិញ។ មិទីញនេះធ្វើឡើងនៅក្នុងទីតាំងបរិវេណមហាវិទ្យាល័យគរុកោសល្យ ( សាលានរម៉ាល់ខាងត្បូង–ខាងជើងរង្វង់មូលវិមានឯករាជ្យ ) ។ អ្នកចូលរួមក្នុងមិទីញនោះមានសមាជិកសមាជិកានៃសមាគមគ្រូ និងមានមកពីគ្រប់មជ្ឈដ្ឋានសិស្ស និស្សិត បញ្ញវន្តអ្នករដ្ឋការ ប្រជាជន និងមានព្រះសង្ឃទៀតផង ។ ខ្ញុំក៏នៅក្នុងក្រុមអ្នកធ្វើមិទីញនោះដែរ ហើយបានទទួលការងារជាអ្នកផ្គត់ផ្គង់ស្បៀង (លក់នំប៉័ងដាក់សាច់ និងតែទឹកកកសំរាប់អ្នកចូលរួមមិទីញ ) ដោយលក់តំលៃថោកបំផុត ឥតគិតអំពីប្រាក់ ចំណេញឡើយ ពីព្រោះក្រុមខ្ញុំនេះជាក្រុមគ្រូ និងនិស្សិតស្ម័គ្រចិត្ត មិនមានបំណងយកចំណេញពីការលក់ដូរនោះឡើយ ។ ក្រុមអ្នកលក់របស់យើងមានគ្នា ចំនួនប្រហែលម្ភៃនាក់ ។ គណៈកម្មាការចាត់ឲ្យយើងលក់ នៅក្នុងបន្ទប់មួយនៃអាគារជិតច្លោងទ្វារចូលខាងជើង ។ នៅពេលដែលមិទីញចាប់ផ្ដើម យើងលក់ដាច់មែនទែន រហូតដល់អស់ទឹកតែលក់ឲ្យភ្ញៀវ ។ អ្នកចូលរួម ប្រជ្រៀតគ្នាចូលតាមទ្វារខាងកើតផង ទ្វារខាងជើងផង ចូលក្នុងបរិវេណ សាលា ។ យើងឥតបានរៀបចំឲ្យអ្នកចូលរួមបំពេញបែបបទអ្វីនោះទេ ព្រោះយល់ថា បញ្ហាទំនិញឡើងថ្លៃ មិនប៉ះពាល់តែចំពោះគ្រូប៉ុណ្ណោះទេ គឺវាផ្ដល់ការលំបាកគ្រប់បែបយ៉ាងគ្របសង្កត់លើប្រជាជនទូទៅនៅក្នុងប្រទេស ។ ម្លោះហើយ មនុស្សណាក៏អាចចូលបាន ។ យើងឥតបានដឹងថា មនុស្សច្រើនពាន់នាក់ ក្នុងពេលនោះមកពីសមាសភាពអ្វីខ្លះនោះទេ ។

នៅលើវេទិកាដែលសង់ក្បែរដើមពោធិ ខាងកើតសហសាល វាគ្មិនយើងឡើងនិយាយជាបន្តបន្ទាប់ ។ ប្រដាប់បំពងសំឡេង បញ្ចេញសូរស័ព្ទនិយាយលឺខ្ទរក្នុងបរិវេណសាលា ហើយនិងលឺដល់ទៅខាងក្រៅថែមទៀតព្រោះមានមនុស្សឈរស្ដាប់ជាហូរហែនៅក្រៅរបង ។ កំណាព្យមួយដែល

ស្មូតដោយនារី " ១៨ " ( ក្រុមអ្នកនិពន្ធអត្ថបទចំរៀង ផ្កាត្របែកព្រៃ ) បានកន្ត្រាក់អារម្មណ៍របស់អ្នកស្តាប់ឲ្យមានកំហឹងឈឺចាប់ ចំពោះការជិះជាន់មកលើប្រជាជនតូចតាច ។ កំណាព្យនោះ បានត្រូវកូនស្រីខ្ញុំម្នាក់នៅចាំអត្ថន័យ និងពាក្យពេចន៍ខ្លះៗ ដោយសារនាងចូលចិត្តច្រៀង និងស្មូត្រកំណាព្យកាលពីនៅតូចៗ ហើយតែងត្រូវបានចាស់ៗហៅឲ្យច្រៀងឲ្យញាតិមិត្តស្តាប់ ។ អត្ថន័យនៃបទកំណាព្យដែលនារីនោះស្មូត្រក្នុងពេលធ្វើមិទីញនោះមានដូចតទៅ "

"រាស្ត្ររស់មិនកើតថាសេរី រដ្ឋគ្មានបានអ្វីថាខ្មែរដើរ
រាស្ត្រដាច់ពោះស្លាប់នៅធ្វើពើ ខ្មែរណាខំរើថាខ្មែរក្បត់។
ខ្មែរក្រោកវាយខ្មែរឲ្យខ្មែរក្រាប ជិះជាន់ធ្វើបាបបង្ហូរឈាម
សម្លាប់ចាប់ចងចោទគំរាម ហារភ្លាមបារភ្លែតស្រវាវេច។ "

ស្នូរទះដៃស្វាគមន៍អត្ថន័យនៃកំណាព្យ លាន់ឥតឈប់ឈរ ធ្វើឲ្យបរិយាកាសរំភើប និងពុះកញ្ជ្រោល ចូលជ្រៅទៅក្នុងអារម្មណ៍របស់អ្នកដែលបានស្តាប់លឺ ទាំងអ្នកចូលរួម ទាំងអ្នកនៅក្រៅរបង និងទាំងអ្នកដំណើរនៅតាមផ្លូវ ។ ក៏ ប៉ុន្តែមិនយូរប៉ុន្មាន ស្រាប់តែមានសំឡេងស្លន់ស្លោ រួមនឹងសន្ធឹកជើងមនុស្សរត់ ប្រសេចប្រសាច ។ សំឡេងនោះបានទាក់ទាញឲ្យខ្ញុំស្ទុះទៅមើលនៅមាត់ បង្អួច ដើម្បីចង់ដឹងពីសភាពការណ៍ដែលកើតឡើង ។ សំឡេងស្លន់ស្លោ នោះស្រែកឡើងថា " មានអ្នកគប់គ្រាប់បែកៗ "។ រំពេចនោះដែរ ស្នូរគ្រាប់ បែកផ្ទុះលាន់ " ភ្លាំង " ជ្រែកអាគារដែលនៅទីនោះ ។ សំឡេងរញ៉េរញ៉ៃ ពោរពេញទៅដោយភាពភ័យតក់ស្លុតលាន់លឺពេញបន្ទប់លក់នំប៉័ងដាក់សាច់។ ខ្ញុំស្រែកដោយឥតដឹងខ្លួន "ពួកយើងនាំគ្នាក្រាបៗ"។ ស្រែកមិនទាន់ចប់ផង មានអ្នកខ្លះរត់ទៅក្រាបស្រេចទៅហើយ ។ ខ្លះក្រាបនៅលើឥដ្ឋ អ្នកខ្លះក្រាប ផ្តុំគ្នានៅជ្រុងជញ្ជាំង ហើយអ្នកខ្លះទៀត រត់ទៅជ្រកនៅក្រោមតុដាក់សំភារៈ និងតុដាក់ទំនិញ ។ សំលេងញ័រៗស្រែកថា " ពុទ្ធោ!

ពុទ្ធោអើយ! " លាយឡំ ជាមួយសំលេងយំស្រែកអង្វរករសុំឲ្យគេជួយ ធ្វើឲ្យខ្ញុំដែលកំពុងក្រាបដែរនោះងើបក្បាលឡើងហើយបន្លឺពាក្យដោយឥតព្រាងទុកថា " មិនអីទេ ពួកយើង កុំភ័យៗ ! ពួកយើងត្រូវនៅលាក់ខ្លួនក្នុងបន្ទប់នេះសិន ចាំស្ងាត់ សឹមយើងរត់ចេញ ហើយកុំភ័យយើងនៅសល់នំប៉័ងច្រើនដែរ!" ។ ខ្ញុំនិយាយ ឃ្លាចុងក្រោយនេះ ប្រហែលមកពីខ្ញុំមានគំនិតគិតថា ត្រូវនៅពួនរហូតដល់ ថ្ងៃត្រង់ ឬ ថ្ងៃរសៀលក៏មិនដឹង ។ ភ្លាមនោះស្រាប់តែមានអារម្មណ៍ មួយមកជំរុញឲ្យខ្ញុំក្លាយទៅជាមនុស្សតក់ស្លុតដូចគេឯងដែរ ព្រោះខ្ញុំគិតទៅដល់ប្ដីខ្ញុំដែលកំពុងនៅជាមួយក្រុមគណៈកម្មការរៀបចំក្នុងសហសាល។ តើពេលនេះគាត់មានបានជួបប្រទះគ្រោះថ្នាក់អ្វីដែរទេ ? កាន់តែនឹកគិត ខ្ញុំកាន់តែព្រួយបារម្ភ និង តក់ស្លុត...។

នៅក្នុងបរិវេណសាលា សំឡេងមនុស្សរត់ផ្អើលរញ៉េរញ៉ៃ សំលេងថ្ងូរ "អូយៗ " លាយឡំនឹងស្នូរ " ធឹងៗៗៗៗ " ឥតដាច់សូរ នៃមីក្រូដែលវាគ្មិនពោះបង់ចោល ធ្វើឲ្យខ្ញុំញ័រខ្លួនចំប្រប់ ហើយព្រឺឆ្អឹងខ្នងខ្លាកៗ ។ ម៉ោងជិត១២ ហើយស្នូរទាំងឡាយនោះបានចុះថយកាន់តែតិចទៅៗ ធ្វើឲ្យយើងលឺច្បាស់សំដីជជែកគ្នា របស់ពួកអ្នកសង្គ្រោះជនរងគ្រោះ ដោយបំណែកគ្រាប់បែកនៅខាងក្រៅអគារលក់នំប៉័ង ។ ខ្ញុំលបមើលតាមប្រហោងតូចៗ តាមទ្វារ និង បង្អួច ( យើងឥតហ៊ានបើកវាទេ ព្រោះខ្លាចក្រែងនៅមានគេមកគប់គ្រាប់បែកតាមបន្ទប់ទៀត ) ឃើញមាននារីម្នាក់ ដែលមានប្រឡាក់ឈាមជោគជាំ ត្រូវគេសែង និងបី–បួន នាក់ទៀត មានឈាមតិចតួច នៅលើផ្ទៃមុខ និងដៃជើង ដើរទ្រេតទ្រោតជាមួយអ្នកជួយគ្រាហ៍ ។ ខ្ញុំឥត ដឹងថាតើមានអ្នករងរបួសប៉ុន្មាននាក់ទៀតដែរទេ ពីព្រោះលឺថាមានអ្នកត្រូវបំណែកគ្រាប់បែកច្រើននាក់ តែគេបានលោតផ្លោះរបងសាលា (របងណាទាបៗ) រត់គេចខ្លួនរស់ទៅហើយ ។ ស្នូរមនុស្សរត់ និង ដើរក្នុងបរិវេណ សាលា បានស្ងប់បាត់ទៅហើយ តែស្នូរមីក្រូ "ធឹងៗ " នៅបន្តក្នុងលំហ អាកាសដ៏ស្ងាត់ជ្រងំគួរឲ្យភ័យខ្លាច ។ នៅមានមនុស្សដើរទៅមកខ្លះៗដែរ តែក្នុងសភាពធម្មតា ។

ពេលនោះខ្ញុំកំពុងចាប់គិតថា តើត្រូវនៅចាំសិន ឬ រត់ចេញ ។ មិនទាន់បានពិចារណានៅឡើយផង ស្រាប់តែមានដៃមួយមក គៀសខ្ញុំខ្ទាតចេញពីមាត់ទ្វារ ទាញទំពក់ដៃទ្វារបើក ហើយស្ទុះរត់ចេញក្រៅព្រាវអស់ សល់តែប្អូនប្រាំនាក់ប៉ុណ្ណោះ ។ មិត្តម្នាក់របស់ខ្ញុំនិយាយកាត់ មុនខ្ញុំថា " បង! យើងគួរប្រមូលយកឥវ៉ាន់ខ្លះៗសិនទៅ សឹមចេញ " ។ ស្របយោបល់គ្នា ហើយយើងរកមើលឥវ៉ាន់ឃើញកន្ត្រកដាក់ប្រាក់ដែលលក់ បានធ្លាក់នៅក្បែរជើងតុជ្រុះលុយអារាត់អារាយ ។ យើងប្រមូលសំភារៈ ដែលយកមកពីផ្ទះរៀងៗខ្លួន ព្រមទាំងនំប៉័ង និងសាច់ប៉ាតេ ដែលនៅសល់ ញាត់ចូលក្នុងកន្ត្រកយួរយ៉ាងតក់ក្រហល់ចេញពីបន្ទប់។ ក្រឡេកមើលទៅក្រៅរបងឃើញស្ថានភាពនៅជ្រួលច្របល់នៅឡើយ... ។ សំឡេងមិត្ត ដដែលនោះស្រែកឡើងថា មិនស្រួលទេបង ! ចោលកន្ត្រកដាក់ឥវ៉ាន់ទៅ យើងត្រូវរត់ចេញឲ្យលឿនលឿនឡើងៗ !" ពេលនោះយើងមិនត្រឹម រត់ចោលកន្ត្រកឥវ៉ាន់ទេ សូម្បីតែស្បែកជើង ក៏រលាស់ចោលដែរ ពីព្រោះពាក់ស្បែកជើងមានកែងខ្ពស់និងខ្លះកែងចោត រត់មិនបានលឿនទាន់គេឡើយ ។ មិនមែនមានតែក្រុមខ្ញុំទេ ដែលរត់ចោល ស្បែកជើងនោះ ឃើញមានស្បែកជើង ដែលគេចោលពាសវាយនៅតាមផ្លូវ ទៅកាន់ច្រកចេញនៃទ្វារខាងជើង ច្រើនគួរសមដែរ ។ ចេញផុតរបងសាលា ខ្ញុំដើរដោយខ្លួនទទេ ឥតមានស្បែកជើង ឥតមានកាបូបយួរ រហិតរហៃ ហាក់ដូចជាគ្មានវិញ្ញាណ ។ ខ្ញុំដើរជិតដល់កាច់ជ្រុងពេទ្យចិន ទើបភ្ញាក់ខ្លួន ដឹងថាខ្លួនពុំអាចដើរបែបនេះទៅដល់ផ្ទះបានទេ ។ ខ្ញុំសម្រេចចិត្តរកស៊ីក្លូជិះ តែខ្ញុំឥតមានលុយជាប់នឹងខ្លួនទេ, អូ ! មិនអីទេចាំដល់ផ្ទះសឹមឲ្យគេក៏បានដែរ ។ ស៊ីក្លូដឹកខ្ញុំមកដល់ជិតអាងទឹក ក្បែរស្ពានអូឡាំពិកហើយ ស្រាប់តែស្នូរ " ក្តាំង " ម្តងទៀត លឺលាន់ខ្ទរអាកាស ។ ខ្ញុំចង់បាត់ព្រលឹងទៀតហើយ តែខ្ញុំងាកមើលមនុស្សម្នានៅតាមផ្លូវ ឥតឃើញមាននរណាភ័យតក់ស្លុត ឬរត់ប្រសេចប្រសាចនោះឡើយ ។ ពូស៊ីក្លូដែលដឹកខ្ញុំ បាននិយាយខ្លាំងៗ ឲ្យគេឯងលឺថា " អូ! ប្រហែលជាអាកបាល់ហោះ ដែលហោះទៅទិសខាងកើតអំបាញ់មិញនោះហើយ វាទៅ

ទំលាក់គ្រាប់បែក នៅកន្លែងណា ហើយមើលទៅ !" ។ ពូស៊ុក្លួ ឥតរីវរល់ ឬ ខ្វាយខ្វល់នឹងហេតុការណ៍នេះទេ គាត់នាំខ្ញុំមកដល់ផ្ទះ ។ ពេលដើរតាម មាត់ផ្លូវ ចូលផ្ទះ ខ្ញុំលឺអ្នកជិតខាង ដែលឈរជជែកគ្នានៅមុខផ្ទះថា កប៉ាល់ហោះទៅទំលាក់គ្រាប់បែកនៅលើចំការមន (ចំការមនគឺជាវាំងរបស់ សម្តេចឪ មុនពេល រដ្ឋប្រហារ តែក្រោយមកគឺជាទីស្នាក់នៅ ឬជាវាំងរបស់ ប្រមុខរដ្ឋ ឬប្រធានាធិបតី នៃសាធារណរដ្ឋខ្មែរ គឺលោកឧត្តមសេនីយ លន់ ណុល នេះឯង )។ ខ្ញុំកាន់តែញ័រជង្គង់ហើយ ក្រោយពីដឹងហេតុការណ៍ រន្ធត់ជំផ្ទួនៗគ្នា បែបនេះ ។ ពេលខ្ញុំដើរចូលទៅក្នុងផ្ទះ ខ្ញុំឃើញកូនៗរបស់ ខ្ញុំកំពុងឈរផ្តុំគ្នា រួចរត់ស្រមករកខ្ញុំ ។" ម៉ាក់!លឺសូរអីហ្នឹង? " ពេលនោះខ្ញុំឥត ទាន់បានឆ្លើយនឹងសំណួររបស់គេទេ តែខ្ញុំបែរជាសួរពួកគេវិញថា "ឃើញប៉ា ទេ? ប៉ាមកដល់ផ្ទះវិញហើយ ឬ នៅ? " ។ កូនស្រីពៅរបស់ខ្ញុំ ឆ្លើយកាត់ បងៗថា" " ឥតទាន់បានឃើញប៉ាមក ផ្ទះទេម៉ាក់ "។ អារម្មណ៍ខ្ញុំកាន់តែវិល វល់ហើយ ខ្ញុំតាំងចិត្តបន្លប់ព្រោះ ឃើញកូនខ្ញុំទាំងអស់គ្នា សម្លឹងមើលមុខខ្ញុំ ដោយចម្ងល់ និងការភ័យខ្លាច ។ ខ្ញុំ នាំពួកគេទាំងនោះឡើងទៅលើផ្ទះ ជាន់ទីមួយ ហើយសួរនាំអំពីបញ្ហាផ្សេងៗ នៅក្នុងពេលដែលខ្ញុំមិននៅផ្ទះ តាំងពីព្រលឹមមកម្ល៉េះ ។ នៅផ្ទះខ្ញុំក៏មានបងប្អូន កូនក្មួយមួយចំនួនស្នាក់នៅ ផងដែរ គឺមានក្មួយស្រីពីរនាក់ ក្មួយប្រុសមួយនាក់ (បីនាក់ខាងប្តីរបស់ខ្ញុំ) និងប្អូនស្រីបង្កើតរបស់ខ្ញុំពីរនាក់ដែរ ។ គេទាំងអស់នោះ សុទ្ធតែមករៀននៅ ភ្នំពេញ ដើម្បីបន្តការសិក្សានៅមហាវិទ្យាល័យ និងរៀននៅសាលាបណ្តុះ បណ្តាលគ្រូ ។ មួយម៉ោង ពីរម៉ោង បីម៉ោង... កន្លងទៅយ៉ាងឆាប់រហ័ស នៅតែមិនឃើញប្តីខ្ញុំមកដល់ផ្ទះទៀត ។ យប់ថ្ងៃនោះ ខ្ញុំគេងមិនលក់សោះ អារម្មណ៍វើវាយទាល់ភ្លឺ ។

| | | | |
|---|---|---|---|
| ខំសម្ងំដេក | ដេកមិនលក់ | អារម្មណ៍វិលវក់ | វក់ស្មារតី |
| គិតយូរវែងឆ្ងាយ | ឆ្ងាយមេឃដី | ភ័យព្រួយខ្លាចថ្ងៃ | ថ្ងៃព្រាត់ទៀត ។ |

ម៉ោងជិតប្រាំទៀបភ្លឺ ខ្ញុំលឺស្គរតែសំឡេងឆ្កែព្រូស ។ ខ្ញុំវែកវាំងននមើលតាមបង្អួច ឃើញមានមនុស្សដើរទៅមកកាត់មុខផ្ទះខ្ញុំ ។ ខ្ញុំចាប់ សង្ស័យព្រោះជាធម្មតាមិនដែលមានទិដ្ឋភាពបែបដូច្នោះទេ ។ ខ្ញុំក៏ស្ទុះចេញពីបន្ទប់សម្រាក ដើរទៅបន្ទប់ធ្វើការ រកមើលឯកសារខ្លះៗ ដែលប្តីខ្ញុំធ្លាប់អាន និងសរសេរកន្លងមក ។ ខ្ញុំប្រមូលទស្សនាវដ្តី " តង់នូវ៉ូ Temps Nouveau" ដែលកាលនោះគេតែងចោទប្រកាន់ថាជាទស្សនាវដ្តីមាននិន្នាការសង្គមនិយម ។ ខ្ញុំប្រមូលបានច្រើនក្បាលគួរសមដែរ ហើយយកទៅលាក់យ៉ាងសំងាត់នៅច្រើនកន្លែង ។ អត្ថបទខ្លះៗដែលខ្ញុំតែងឃើញប្តីខ្ញុំសរសេរ ដាក់រាយចោលលើតុក៏បានប្រមូលវាទៅដុតចោល ( ដុតក្នុងបន្ទប់ ទឹក ) ។ ក្រដាសខ្លះៗទៀត ត្រូវខ្ញុំនិងក្មួយខ្ញុំ ហែកជាបំណែកតូចៗចោលក្នុងជាលដាក់សំរាមត្រង់នេះ មួយក្តាប់ ត្រង់នោះមួយក្តាប់ ។

មែន! ម៉ោងប្រហែលប្រាំមួយភ្លឺ មានមនុស្សបីនាក់ឈរនៅមាត់ទ្វាររបងខាងក្រៅផ្ទះខ្ញុំ ហើយស្រែកហៅថា "សុំជួបលោកម្ចាស់ផ្ទះៗ"។ គេទាំងនោះថ្វីត្បិតតែស្លៀកពាក់ស៊ីវិលមែន តែខ្ញុំដឹងច្បាស់ថា ពួកគេគឺជាគិញហើយ ព្រោះទាំងទឹកមុខក្តី ទាំងកាយវិការក្តី ទាំងសំដីសំដៅក្តី ហើយជាពិសេសពួកគេមករកប្តីខ្ញុំក្នុងស្ថានភាពបែបនឹងនោះ ។ ខ្ញុំត្រូវចេញមក៏សួរនាំភ្ញៀវ ។ គ្រាន់តែអើតក្បាលចេញពីមាត់ទ្វារជាន់ទីមួយភ្លាម គេក៏ស្រែកសួរខ្ញុំខ្លាំងៗថា " លោកគ្រូនៅផ្ទះដែរឺទេៗ ខ្ញុំចង់ជួបគាត់ " ។ ខ្ញុំឆ្លើយតវថា " គាត់មិននៅទេ " រួចប្រុងដកខ្លួនចូលក្នុងផ្ទះវិញ ។ ក៏ប៉ុន្តែសំឡេងដដែលនោះបានបន្តធ្វើឲ្យខ្លួនខ្ញុំ ទុចង៉ក់ ចាំស្តាប់សំណួររបស់គេតទៅទៀត ។ គេថា គេសុំចូលក្នុងផ្ទះបានដែរឺទេ ។ ខ្ញុំឆ្លើយតិចៗ ហើយលឺខ្សាវៗថា " ចាំបាន ! " ។ ខ្ញុំក៏ចុះមកក្រោម ដើរតម្រង់ទៅមាត់ទ្វាររបង ។ ភ្លាមនោះគេ ចាប់ផ្តើមឧទ្ទេសនាមខ្លួនគេថា ពួកគេជាអធិការប៉ូលីសសុំចូលឆែកឆេក្នុងផ្ទះ ។ នេះជាលើកទីមួយហើយ ដែលប៉ូលីសមកឆែកឆេផ្ទះអញ្ចឹង ខ្ញុំដើរចូលក្នុងផ្ទះ នាំមុខពួកគេមែន តែខ្ញុំឥតដឹងថា តើត្រូវទៅកន្លែងណាមុនទេ ។

ខ្ញុំខំប្រឹងទប់ ជើងកុំឲ្យញ័រ ខំបន្លប់ដោយនិយាយក្នុងនាមជាម្ចាស់ផ្ទះថា "លោកអញ្ជើញចូល អញ្ជើញអង្គុយសិនទៅ !" ។ គេបដិសេធ ហើយសុំឲ្យខ្ញុំនាំពួក គេទៅឆែកឆេរក្នុងបន្ទប់មួយម្តងៗ សព្វទិសទី ។ ចំណែកឯក្មេងៗ ឯង និងមនុស្សម្នាទាំងអស់នៅក្នុងផ្ទះ ត្រូវពួកគេបញ្ជាឲ្យនៅមួយកន្លែងមិនឲ្យរត់ចេញទៅណាឡើយ ។ ខ្ញុំចាំបានថា ពេលនោះពុំមានភាពរញ៉េរញ៉ៃ រឺមានការយំយែកអ្វីទេ ពីព្រោះកាលនោះកូនតូចជាងគេរបស់ខ្ញុំគេដឹងក្តីហើយដែរ ហើយការឆែកឆេនោះទៀតសោត ក៏ហាក់ដូចជាមិនសូវជាតឹងតែងប៉ុន្មានផងដែរ ។ តាមខ្ញុំស្មានមើលទៅ ប្រហែលជាគេឆែកចង់រកប្តីខ្ញុំ ក្រែងគាត់នៅផ្ទះ ហើយលាក់ខ្លួននៅទីណាប៉ុណ្ណោះ។ រីឯការឆែកឆេរកឯកសារ ក៏ហាក់ដូចជាពុំមានសារៈសំខាន់ដែរ គឺគេគ្រាន់តែទាញសៀវភៅប៉ុន្មានទំព័រមើលបន្តិចបន្តួចប៉ុណ្ណោះ ។ រឿងមួយដែលខ្ញុំចាំឥតភ្លេច គឺកាលណោះគេទាញបានក្រដាស មេរៀនមួយសំណុំសរសេរជាភាសាចិន ដែលខ្ញុំកំពុងយកថ្នាក់រៀនភាសានៅមហាវិទ្យាល័យអក្សរសាស្ត្រ (សូមបញ្ជាក់ថា ខ្ញុំចង់បន្តរៀនយកបរិញ្ញាប័ត្រ ផ្នែកអក្សរសាស្ត្របន្ថែមទៀត ) ។ គេសួរខ្ញុំថា ហេតុអ្វីបានជាខ្ញុំរៀនភាសាចិន ហើយរៀនដើម្បីអ្វី ។ ខ្ញុំឆ្ងល់នឹងសំណួរគេនេះណាស់ ថាតើគេចង់ដឹងអ្វីទៅហ្ន៎ តែខ្ញុំត្រូវតែឆ្លើយ "ចាំខ្ញុំរៀនភាសាចិន ព្រោះនៅសកលវិទ្យាល័យអក្សរ-សាស្ត្រ គេតម្រូវឲ្យរៀនភាសាបរទេសណាមួយមានអង់គ្លេស អេស្បាញ៉ុល រុស្ស៊ី និងចិននេះឯង ។ ហើយខ្ញុំយកភាសាចិន ព្រោះខ្ញុំយល់ថា វាអាចប្រើប្រាស់បាននៅក្នុងស្រុកខ្មែរយើង "។ មេគិញបានបន្តសួរ បែបចោទប្រកាន់ថា " អញ្ចឹងអ្នកស្រីចូលចិត្ត ហើយស្រឡាញ់ចិនណាស់មែនទេ ? " ខ្ញុំចង់ខឹង នឹងការចោទប្រកាន់នេះ ហើយឆ្លើយយ៉ាងកំបុតថា " មិនមែនជារឿងស្រឡាញ់ ឬចូលចិត្តនោះទេ តែវាគឺជាតម្រូវការ " ។ គេឈប់និយាយរួច បន្តការរើកកាយសៀវភៅតទៅទៀត ។ គេឥតបានរកឃើញអ្វីដែលគេត្រូវការនោះឡើយ ។ ការឆែកឆេរក៏ត្រូវបញ្ចប់ ក្នុងរយៈពេលពីរម៉ោងក្រោយមក ។ ហ៊ឺស ! ខ្ញុំធូរទ្រូងហើយៗលែងដកដង្ហើមញាប់ទៀតហើយ ។ ក៏ប៉ុន្តែទោះបី

ជាពួកតិញទៅបាត់មែន ខ្លួនខ្ញុំនៅតែញ័រ និងស្រាលខ្លួនដដែលដោយមនុស្ស ដែលខ្ញុំបារម្ភ នៅតែបាត់ដំណឹងនៅឡើយ ។

មួយថ្ងៃ ពីរថ្ងៃ រហូតដល់មួយអាទិត្យ ខ្ញុំនៅតែមិនទាន់ឃើញប្ដីខ្ញុំទៀត តើគាត់មានបញ្ហាអ្វីទៅហ្ន៎? ។ មួយអាទិត្យក្រោយមក ទើបមានយុវជនម្នាក់មកដល់ផ្ទះខ្ញុំ យកកូនសំបុត្រតូចមួយមកឲ្យខ្ញុំ រួចនិយាយថា ស្អែកនៅពេលថ្ងៃត្រង់ គេនឹងមកជួបខ្ញុំម្ដងទៀត ។ រកតែខ្ញុំសួរនាំអ្វីមិនទាន់ បានផង គេក៏លាខ្ញុំទៅវិញភ្លាម ដោយបន្លឺពាក្យថា " អ្នកមីងអានសំបុត្រនេះទៅនឹងដឹងរឿងរ៉ាវហើយ "។ ខ្ញុំលាកូនក្រដាសប៉ុនបាតដៃ ដែលមានអក្សរបួនប្រាំបន្ទាត់ ហើយដែលខ្ញុំស្គាល់ច្បាស់ថាជាអក្សរប្ដីខ្ញុំ មានសេចក្ដីថា គាត់សុខសប្បាយជាទេ កុំឲ្យខ្ញុំព្រួយបារម្ភ ហើយផ្ដាំឲ្យខ្ញុំផ្ញើអីវ៉ាន់ខ្លះៗឲ្យគាត់ ។ វត្ថុទាំងអស់ដែលគាត់ប្រាប់ឲ្យផ្ញើនោះ សុទ្ធតែបានបញ្ជាក់រួចជាស្រេចថាខោអាវ សារុងណាមួយៗ ហើយនៅកន្លែងណាៗ ។ ថ្ងៃស្អែកឡើង នៅពេលដែលប្អូនប្រុសនោះមកយកអីវ៉ាន់ មានកូនសំបុត្រមួយទៀតដែលគាត់សរសេរប្រាប់ឲ្យខ្ញុំទៅសួរប្អូនប្រុសរបស់គាត់ (**ពឹង គឹមស្វ**) ថាតើគាត់អាចមកផ្ទះវិញបានហើយឬនៅ ? តើគេនៅតែរកចាប់ខ្លួនគាត់ទៀតរឺទេ ? ។ គ្រាន់តែអានន្ទវសំណួរនោះរួច ខ្ញុំបានឆ្លើយភ្លាមដោយផ្ទាល់មាត់តែម្ដងថា ខ្ញុំបាននាំដំណឹងទៅប្រាប់ប្អូនគាត់ហើយៗប្អូនប្រុសគាត់បានប្រាប់ខ្ញុំវិញថា គេនៅតែតាមរកចាប់បងសយនៅឡើយ កុំអាលឲ្យគាត់មកផ្ទះអី ។ ចាប់តាំងពីពេលនោះមក ខ្ញុំតែងទៅសួរព័ត៌មានអំពីការរកចាប់ចងប្ដីរបស់ខ្ញុំតាមរយៈគឹមស្វ ដែលគេមានមិត្តភក្តិច្រើន ធ្វើជាអធិការប៉ូលីសខាងស៊ើបអង្កេតនេះឯង ។ មួយខែកន្លងផុតទៅហើយ ដំណឹងពីប្ដីរបស់ខ្ញុំស្ងាត់ស្ងន្យឈឹងមិនមានដឹងអ្វីសោះ ។ មានព្រឹកមួយនោះ មាននាងស្រីម្នាក់ដែលខ្ញុំស្គាល់ជាសិស្សរបស់ខ្ញុំ នៅសាលាបណ្តុះបណ្តាលគ្រូបង្រៀន បានយកសំបុត្រមួយច្បាប់ព្រមទាំង ស្បោងអីវ៉ាន់មួយមកឲ្យខ្ញុំ ដោយណែនាំខ្លួននាងជាជាក្មួយរបស់បងមេធាវី " **អ៊ុំ** " ។ ខ្ញុំទទួលយកស្បោងអីវ៉ាន់ និងសំបុត្រ

ដោយញ័រដៃ ខ្ញុំអានយ៉ាងញ័ររន្ធត់នូវខ្លឹមសារនៃលិខិតនោះដែលនិយាយផ្ទឹញតែបញ្ហាដែលយើងត្រូវតែបែកគ្នា និងពាក្យផ្ដាំផ្ញើខ្លះៗថា " អូន ! មើលថែទាំខ្លួន និងមើលកូនផង បងសុំបែកមួយរយៈសិនហើយ " ។ ភាពក្ដុកក្ដួលដែលខ្ញុំប្រឹងទប់អស់រយៈ ពេលជាយូរមកហើយ ក៏វាផ្ទុះចេញមកម្ដងទៀត លាយឡំជាមួយនឹងទឹកភ្នែក ហូរសស្រាក់ឥតឈប់ឈរ ហើយជានិច្ចកាលនៅរាល់ពេលដែលខ្ញុំនឹកឃើញ ដល់សំដីដ៏ខ្លីក្នុងលិខិតនេះ ខ្ញុំតែងចុះចាញ់មនោសញ្ចេតនាដ៏ទន់ជ្រាយរបស់ខ្ញុំ ព្រោះខ្ញុំពុំអាចទប់ទឹកភ្នែកមិនឲ្យហៀរចេញមកបានឡើយ ។ ជាធម្មតា ប្ដីខ្ញុំជាមនុស្សមិនដែលបញ្ចេញមនោសញ្ចេតនា ឬពាក្យសំដីផ្អែមល្ហែមឲ្យគេឯងលឺជាពិសេសឲ្យខ្ញុំលឺម្ដងណាឡើយ ។ ខ្ញុំតែងនឹកឆ្ងល់នឹងខ្លួនឯងថា ហេតុអ្វីក៏ខ្ញុំមានអារម្មណ៍ក្ដុកក្ដួលខ្លាំងម្ល៉េះនៅពេលនោះ ដែលវាខុសប្លែកពីធម្មតារញ៉ៀង ។ បើតាមការពិចារណាមើលទៅ គឺប្រហែលជាកាលខ្ញុំធ្លាប់បែកគាត់ពីពេលមុនប៉ុន្មានដងនោះ វាខុសគ្នានឹងពេលនេះ ដែលវាជាការបែកគ្នាដោយមិនមានទិសដៅ គឺប្លែកពីពេលមុនៗ ដែលយ៉ាងហោចណាស់ក៏ខ្ញុំដឹងថា គាត់នៅទីណាៗដែរ ។ លើសពីនេះទៅទៀត ការបែកគ្នាលើកនេះ វាស្ថិតនៅក្នុងបរិយាកាសគ្រោះថ្នាក់ ដែលសង្គមយើងកំពុងកើតហេនកលិយុគ ។ ដូច្នេះ អ្វីដែលធ្វើឲ្យខ្ញុំស្រងេះស្រងោចខ្លាំងនោះគឺពាក្យសំដីផ្ដាំផ្ញើ ដែលគាត់បានសរសេរនៅក្នុងសំបុត្រដ៏ខ្លីនោះ មានអត្ថរសយ៉ាងស្រទន់ដែលខ្ញុំពុំធ្លាប់បានលឺ ក្នុងពេលមុនៗកន្លងមក ម្ដងណាឡើយ ។

ខ្ញុំផែកមើលអីវ៉ាន់ក្នុងស្បោង ដែលគាត់បានផ្ញើត្រឡប់មកវិញ ។

អ្វីៗមានគ្រប់ដូចដើម ឃើញបាត់តែភួយស្ដើងមួយប៉ុណ្ណោះ ធ្វើឲ្យខ្ញុំនឹកពិតវែងឆ្ងាយថា គាត់ប្រាកដជាទៅឆ្ងាយហើយ ទៅតំបន់ខ្យត់ខ្យោយ... ដែលធាតុអាកាសពិបាកទ្រាំទ្រ ។ គួរឲ្យបារម្ភមែន !...។

ខ្ញុំអង្គុយសញ្ជប់សញ្ជឹងតែម្នាក់ឯង ។ អារម្មណ៍ឯកោរបស់ខ្ញុំ កាន់តែ

ពុះកញ្ជ្រោលធ្វើឲ្យខ្ញុំនឹកគិតសព្វគ្រប់ជំពូក ។ មានគំនិតមួយជំរុញខ្ញុំឲ្យធ្វើការត្រិះរិះពិចារណាទៀតហើយ ថាហេតុអ្វីក៏ប្ដីរបស់ខ្ញុំ សុំបែកពីខ្ញុំនិងកូនៗបែបនឹង ! តើបែកពីព្រោះអ្វី ? ហើយបែកដើម្បីអ្វី ? ។ តាមការណ៍ដែលខ្ញុំបានស្គាល់គាត់ ១៦ឆ្នាំមកហើយ ខ្ញុំយល់ថាគាត់ជាមនុស្សដែលស្រឡាញ់ប្រពន្ធ កូន មិនដែលទៅណាទៅណីចោលប្រពន្ធកូនម្ដងណាទេ ។ ដូចនេះការចុះចោលគ្រួសារក្នុងគ្រានេះ គឺមិនមែនជាចេតនារបស់គាត់ឡើយ មុខជាមានកត្តាជំរុញអ្វី មួយជាមិនខាន ពីព្រោះអ្វីដែលគាត់បានធ្វើកន្លងមកក្រៅអំពីបញ្ហាគ្រួសារគឺជាសកម្មភាពបំរើផលប្រយោជន៍ដល់មនុស្សនៅក្នុងសង្គមខ្មែរយើងតែប៉ុណ្ណោះ ។ តួយ៉ាងដូចជាក្នុងការធ្វើកាសែត គាត់ជាអ្នកនិពន្ធអត្ថបទផ្សាយក្នុងទំព័រកាសែត " ប្រជាធិបតេយ្យ " ។ គាត់ធ្វើជាចាហ្វាងកាសែត " ឯកភាព " គឺក្នុងគោលបំណងចង់យកគំនិតប្រជាធិបតេយ្យមកបណ្ដុះនៅក្នុងសង្គមខ្មែរយើង ។ រីឯការចូលរួមធ្វើមិទ្ទីញថ្មីៗនេះទៀតសោត ក៏គឺដើម្បីជួយដល់អ្នករដ្ឋការតូចតាច និងជាពិសេសដល់ប្រជាជនក្រីក្រដែលបានទទួលការលំបាក ធ្ងន់ធ្ងរជាងគេ ក្នុងបញ្ហាដំណោះស្រាយជីវភាព ដោយសារទំនិញចេះតែឡើងថ្លៃឥតឈប់ឈរ ។ ខ្ញុំបន្តចោទសួរខ្លួនឯងតទៅទៀតថា ហេតុអ្វីបានជាមនុស្សម្នាក់ដែលមានទឹកចិត្តស្រឡាញ់យុត្តិធម៌ ក្លាហាន ធ្វើការតវ៉ា ដើម្បីប្រជាពលរដ្ឋទូទៅតែទីបំផុតគាត់គ្មានជំរើសនឹងអាចរស់នៅក្នុងគ្រួសាររបស់ខ្លួនរួមរស់ ជាមួយប្រពន្ធកូន កសាងសុភមង្គលដូចគ្រួសារគេឯងដទៃទៀតអញ្ចឹង ? ។ តើទង្វើទាំងអស់របស់ប្ដីខ្ញុំនេះ វាមិនត្រឹមត្រូវ វាក្បត់នឹងឧត្តមគតិជាតិនិងផលប្រយោជន៍របស់ប្រជាជន ដែលត្រូវតែទទួលរងនូវការព្រាត់ប្រាសបែបនេះរឺ ? ហេតុដូច្នេះហើយ ផ្លូវដើររបស់ប្ដីខ្ញុំគឺសែនតូចចង្អៀត ហើយក៏មានតែមួយដែរ នោះគឺគេចខ្លួនរត់ចូលព្រៃ ដើម្បីជៀសផុតពីការចាប់ចងនិងជាប់គុកច្រវាក់។ បន្ទាប់ពីនេះ ខ្ញុំក៏បានសាកល្បងធ្វើការពិចារណាបញ្ច្រាសទៅវិញ ដោយគិតថា ប្រសិនបើប្ដីខ្ញុំបោះបង់ឧត្តមគតិស្រលាញ់យុត្តិធម៌ ស្រលាញ់ប្រជាជន ហើយធ្វើគធ្វើថ្លង់ឬចូលរួមក្នុងសង្គមពាលា

ពុករលួយ ដូចមនុស្សមួយចំនួនក្នុងសម័យនោះ ប្រហែលជាគ្រួសារខ្ញុំពុំមានជួបរឿងព្រាត់ប្រាស រឿងឈឺចាប់ ឬសោកសង្រេងអ្វីឡើយ អាចថ្កុំថ្កើង ឧត្តុងឧត្តមផងក៏មិនដឹង...។ ក៏ប៉ុន្តែខ្ញុំជឿជាក់ថា ការគិតបញ្ច្រាសនេះពុំអាចកើតមានបានឡើយនៅក្នុងសង្គមគ្រួសារខ្ញុំ ជាពិសេសចំពោះបងសយ ។ ដូចនេះខ្ញុំយល់ថា ការបែកបាក់របស់យើង គឺជាការបង្ខិតបង្ខំយ៉ាងអគតិ និងសាហាវអំពីជនល្មោភអំណាច ដែលបង្កឲ្យមានព្យុះនយោបាយបោកបក់ក្នុងសង្គមខ្មែរយើងនៅពេលនោះ និងពេលក្រោយ ៗជាបន្តបន្ទាប់មកទៀត ។ ក្នុងស្ថានភាពដ៏តឹងតែងនាពេលនោះ ជីវិតរបស់ខ្ញុំនិងក្រុមគ្រួសារ ពុំមានអ្វីធានាសុវត្ថិភាពឡើយ ។

**ពាក្យចាស់លោកពោលថា :**

| | |
|---|---|
| - កុំឆ្អែតពេកតែឯង | ត្រូវគិតក្រែងគ្រប់គ្នីគ្នា |
| គេឃ្លាន ឃ្លានផ្ទៃផ្សា | ឲ្យស៊ីវាបានឆ្អែតផង ។ |
| - គេរស់ចង់បានសុខ | មានហូបចុក លំនៅគ្រង |
| មានសិទ្ធិជារបង | កុំកន្លងច្បាប់មនុស្សជាតិ ។ |
| - អ្នកមានជួយអ្នកក្រ | អ្នកធំល្អ មិនបៀនបៀត |
| ស្មោះត្រង់រក្សាញាតិ | ជាសារជាតិ រួមលោហិត ។ |

# វគ្គទី ៤

## ជីវិតគ្មានពំនឹង

ក្រោយពេលដែលប្តីខ្ញុំទៅចោលខ្ញុំបាត់ ស្ថានភាពនៃការរស់នៅរបស់ខ្ញុំត្រូវប្រែប្រួលហើយ ។ កូនទាំងប្រាំនាក់របស់ខ្ញុំ ដែលត្រូវទៅសាលារៀន និងរូបខ្ញុំដែលតែងទៅធ្វើការ ដោយមានប្តីខ្ញុំជាអ្នកបើកឡានជូនទៅមក ឥឡូវយើងទាំងអស់គ្នាត្រូវធ្វើដំណើរតាមមធ្យោបាយផ្សេងវិញ ។ គឺត្រូវជិះស៊ីក្លូមួយ ដែលមានអ្នកជិះ៥នាក់ រួមទាំងរូបខ្ញុំផង ឯកូនប្រុសធំរបស់ខ្ញុំបានត្រូវប្អូនខ្ញុំ ឧបកង់ ជូនទៅសាលារៀន ។ រាល់លើក ខ្ញុំមានការពឹងពាក់លើប្តីទាំងអស់ ធ្វើឲ្យខ្ញុំមិនចេះបើកឡានទេ ។ អញ្ចឹងហើយបានជាបងស្រីរបស់ខ្ញុំ ( បង លន់ អេង ) តែងនិយាយបង្អាប់ខ្ញុំថា " អន់ថយណាស់ " ។ បងស្រីរបស់ខ្ញុំ ដែលកាលពីមុន ប្តីរបស់គាត់ជាទាហានបារាំង ក្រោយមកជាទាហានពាក់ស័ក្តិ ២ រួចឡើងឋានន្តរស័ក្តិពាក់ស័ក្តិ ៤ ផ្នែកភស្តុភារ កាន់កាប់រោងចក្រត្រាប់រំសេវ នៅស្ទឹងច្រាលក្បែរពេជ្រនិល ហើយត្រូវពួកទ័ពព្រៃខ្មែរក្រហម វាយបំបែកបន្ទាយក្នុងឆ្នាំ ១៩៧០ ត្រូវចាប់ខ្លួន និងបាត់ខ្លួនរហូតមក។ បងស្រីបាន ក្លាយជាស្ត្រីមេម៉ាយមានកូនប្រាំនាក់ក្នុងបន្ទុក។ គាត់មករស់នៅភ្នំពេញ ប្រកបរបរកាត់ដេរ មានហាងនៅលើផ្លូវមុនីរេត មិនឆ្ងាយពីផ្ទះខ្ញុំប៉ុន្មានទេ ។ គាត់តែងមកលេងនិងមកកំដរខ្ញុំរាល់ថ្ងៃ ។ គាត់តែងបន្ទោសខ្ញុំពីរឿងដែលខ្ញុំ មិនព្រមរៀនបើកឡាន ។ គាត់និយាយបន្ទោសថា " មីអូនឯង គិតតែ បញ្ឆេះឡានចោលរាល់ព្រឹករហូតអញ្ចឹងរឺ ? ធ្វើអញ្ចឹងមិនកើតទេ ត្រូវតែរៀនបើកឡាន ចាំបងជួយបង្រៀនឯង " ។ មែន! មិនទាន់ដល់ម៉ោងប្រាំមួយ ព្រឹកផង គាត់បានមកដល់ផ្ទះខ្ញុំ បង្ខំឲ្យខ្ញុំឡើងឡាន "ស៊ីត្រូអេន" ពីរសេះរបស់ខ្ញុំ ដែលទិញតាំងពីកំណើតកូនទី ៣ (១៩៦៣) ។

បងស្រីអង្គុយក្បែរខ្ញុំ បង្រៀនខ្ញុំឲ្យកាន់ចង្កូត កាច់ទៅឆ្វេង កាច់ទៅស្តាំ ឲ្យជាន់ហ្វ្រាំង ជាន់ ហ្វ្រាំង ឲ្យដូរលេខ... និងប្រាប់អំពីការបត់ឆ្វេង បត់ស្តាំ ។ ខ្ញុំរៀនបើក ដំបូង នៅតាមផ្លូវក្នុងៗ ក្រោយវត្តព្រះពុទ្ធ រួចចេញមករោងកុនវិមានសួស្តី (សព្វថ្ងៃក្លាយទៅជាការ៉ាស់សាំងរបស់ក្រុមហ៊ុនសូគីមិច)។ បងខ្ញុំមកបង្រៀន បានតែពីរព្រឹកប៉ុណ្ណោះ ហើយនៅព្រឹកថ្ងៃទីបី ពេលបងខ្ញុំមិនទាន់មកដល់ ខ្ញុំសម្រេចចិត្តឡើងឡាន បើកតែម្នាក់ឯង ទៅផ្ទះគាត់តែម្តង ។ គិតសព្វៗទៅ ការប្តេជ្ញាចិត្ត និងការសម្រេចចិត្តសំខាន់ណាស់ ពីព្រោះកាលណោះ មុនពេលឡើងបើកបរម្នាក់ឯង គ្មានអ្នកនៅអែប ខ្ញុំតាំងចិត្តថា ខ្ញុំជាអ្នកបញ្ជាឡាន ដូច្នេះឡានឯងត្រូវស្តាប់បញ្ជាខ្ញុំ ។ តាំងពីពេលនោះមក ខ្ញុំហ៊ានបើកឡានហើយ ។ ខ្ញុំប្រឡងយកប័ណ្ណបើកបរ ខ្ញុំបើកឡានទៅធ្វើការ ដាក់កូនទៅរៀន ( កូនទាំងប្រាំរបស់ខ្ញុំរៀននៅសាលាអនុវត្តន៍ ដែលស្ថិតនៅក្នុងបរិវេណមហាវិទ្យាល័យគរុកោសល្យ ជាមួយគ្នានឹងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និង សាស្ត្រាចារ្យ ) ។

ផ្ទះរបស់ខ្ញុំដែលកាលពីពេលមុនមានអ្នកស្នាក់នៅច្រើនគ្នា តែក្នុងពេលនោះបានកាត់បន្ថយចំនួនសមាជិកអស់ច្រើនហើយ ។ ក្មួយស្រីប្តីរបស់ខ្ញុំ (នាង **ឈៀង** ) ត្រូវដូរផ្ទះទៅនៅជាមួយបងប្អូនខាងម្តាយនាង នៅផ្សារកណ្តាល ។ ក្មួយប្រុស **ស៊ុនលី** ដែលរៀននៅសកលវិទ្យាល័យវិទ្យាសាស្ត្រ ផ្លាស់ទៅនៅផ្ទះ ម្តាយធំនៅទួលគោក។ ក្មួយប្រុសម្នាក់ទៀត **គីលុន** ត្រូវចេញទៅរៀនបន្តការសិក្សានៅស្រុកបារាំង ។ ដូចនេះផ្ទះរបស់ខ្ញុំមានតែរូបខ្ញុំ កូនប្រាំនាក់ ប្អូនស្រីពីរនាក់របស់ខ្ញុំ ដែលកំពុងរៀននៅសាលាបណ្តុះបណ្តាលគ្រូបង្រៀន និងអ្នកដាំបាយមួយនាក់តែប៉ុណ្ណោះ ។

ដោយផ្ទះរបស់ខ្ញុំជាវីឡាមួយសមរម្យគ្រាន់បើដែរនោះ បងប្អូនទាំងខាងខ្ញុំ និងខាងប្តីខ្ញុំ តែងយកផ្ទះខ្ញុំធ្វើជាកន្លែងជួបជុំញាតិសន្តាន មិត្តភក្តិ និងជាកន្លែងធ្វើពិធីផ្សេងៗ ដូចជាធ្វើជាផ្ទះការរបស់ក្មួយគន្ធ កូនស្រីទីពីររបស់

បងថ្លៃខ្ញុំ ផ្ទះការរបស់ប្អូនស្រី**សុខត្ថិ** និងផ្ទះការរបស់នាង**ស៊ីជន**(កូនច្បងរបស់បងស្រីខ្ញុំ ) ។ ក្រៅពីនេះ នៅថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកពេលបុណ្យទានក្មួយៗ តែងនាំមិត្តភក្តិរបស់គេមកលេង ធ្វើពិធីជប់លៀងនៅផ្ទះខ្ញុំ ដែលធ្វើឲ្យមានបរិយាកាសអ៊ូអរ ប្លែកជាងកាលពីពេលដែលប្តីខ្ញុំនៅ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏បញ្ហាក្នុងគ្រួសារធ្វើឲ្យខ្ញុំខ្វាយខ្វល់ គួបផ្សំនឹងទុក្ខព្រួយនៅតែមកញាំញីចិត្តរបស់ខ្ញុំ ឲ្យវិលវល់ក្នុង អារម្មណ៍ស្មុគស្មាញដដែល ។

ក៏ប៉ុន្តែខ្ញុំនៅតែតាំងស្មារតីបានល្អ ពីព្រោះខ្ញុំសង្ឃឹមក្នុងចិត្តថាប្តីរបស់ខ្ញុំនៅតែនឹកគិតដល់ប្រពន្ធកូន ហើយនឹងអាចវិលមកជួបជុំគ្នាវិញ នៅពេលណាមួយជាក់ជាមិនខាន ឬក៏អាចគាត់ឲ្យគេមកនាំខ្ញុំនិងកូនទៅនៅជុំគ្នានៅទីណា មួយក្នុងពេលណាមួយក៏សឹងមាន ។ ខ្ញុំគិតយ៉ាងនេះតែម្នាក់ឯងបែបរវើរវាយ ឬក៏ឡប់សតិ ឬត្រឹមត្រូវក៏មិនដឹង ។ យ៉ាងណាក៏ដោយក៏ខ្ញុំត្រូវតែត្រៀមខ្លួន ទទួលការរស់នៅជួបជុំគ្រួសាររបស់ខ្ញុំឡើងវិញដែរ ។ ការគិតបែបនេះក៏ដោយសារមានហេតុផល ពីព្រោះខ្ញុំតែងទទួលព័ត៌មាននៃការបាត់ខ្លួនរបស់បញ្ញវន្តខ្លះៗ ដែលខ្លះបាត់ទាំងគ្រួសារៗ ដូចជាលោកសាស្ត្រាចារ្យ **នួន ខឿន** ដែលបាត់ ទាំងប្តីបាត់ទាំងប្រពន្ធ លោក**ជី គីមអាន** ទៅបាត់មួយរយៈ ហើយក្រោយមក ទាំងកូននិងប្រពន្ធរបស់គាត់ ក៏ចេញទៅបាត់ ។ល។ ឃើញសភាពការណ៍បែបនេះ ខ្ញុំគិតថានឹងអាចមានថ្ងៃណាមួយដែលបងសយនឹងផ្តល់ដំណឹង ឬឲ្យគេមកនាំខ្ញុំ និងកូនៗទៅជួបគាត់។ ដូចនេះខ្ញុំត្រូវទន្ទឹងរង់ចាំថ្ងៃខែ ដែលយើង អាចមានឱកាសបានរស់នៅជួបជុំគ្នា ។ គំនិតទាំងអស់នេះហើយ ដែលបាន ជំរុញឲ្យខ្ញុំត្រៀមខ្លួន ។

ខ្ញុំដេរថង់យាមដាក់ខោអាវឲ្យកូនខ្ញុំម្នាក់មួយៗ ដែលក្នុងនោះមានដាក់ប្រដាប់ដេរ (ម្ជុលដេរដៃ អំបោះហុង កូនកន្ត្រៃ ) កូនកាំបិត កន្ត្រៃកាត់ក្រចក..ចំណែកឯខោអាវ ក្រមា កន្សែងពោះគោ ខ្ញុំពុំទាន់ញាត់បញ្ចូលថង់នៅឡើយទេ គឺថាចាំដល់ពេលនោះទើបចាប់ញាត់វាតែម្តង ។ ចំពោះថ្នាំសង្កូវ ក៏ដូចគ្នាដែរ ។ ក្រៅពីការរៀបចំប្រដាប់ប្រដា សម្រាប់ធ្វើដំណើរ

ប្តូរទីលំនៅ ខ្ញុំយល់ថាត្រូវឲ្យកូនខ្ញុំមានចំណេះដឹងច្រើនអាចរស់នៅក្នុងព្រៃ ឬក្នុងតំបន់ផ្សេងៗទៀត ដែលមានការលំបាកក៏បាន ។ ខ្ញុំបានឲ្យកូនទៅរៀនហែលទឹក (នៅពីស៊ីនក្នុងស្តាតអូឡាំពិក) ឲ្យរៀនឡើងដើមឈើ (នៅផ្ទះខ្ញុំមានដើមជម្ពូ ដើមត្របែក ដើមដូងតឿ) ដែលក្នុងពេលមុនៗ ខ្ញុំតែងហាមឃាត់ពួកកូនៗ ទាំងនោះ មិនឲ្យឡើងដើមឈើទេ ព្រោះខ្លាចធ្លាក់បាក់ដៃបាក់ជើង ។ តែពេលនេះ ខ្ញុំបែរជាជំរុញឲ្យគេរៀនឡើងដើមឈើទៅវិញ ដោយ មានអ្នកតាម ឃ្លាំមើលជានិច្ច ជួនកាលខ្លួនខ្ញុំផ្ទាល់ ជួនកាលប្អូនស្រីខ្ញុំ ។ បងស្រីរបស់ខ្ញុំដឹង រឿងនេះ និងដឹងអំពីបំណងរបស់ខ្ញុំ ។ គាត់បាននិយាយថា " មីអូនឯង គិតវែងឆ្ងាយពេកហើយ! ឯង និងកូន ពុំអាចទៅណាកើតទេ តាមបងយល់ ពីព្រោះការរស់នៅក្នុងព្រៃបែបនោះ វាពិបាកទ្រាំទ្រខ្លាំងណាស់ គឺត្រូវទប់ទល់នឹងបញ្ហាច្រើនជំពូក ដូចជាជំងឺដង្កាត់ បញ្ហាថ្នាំសង្កូវសម្រាប់ព្យាបាល ការការពារនឹងសត្វសាហាវ ហើយជាពិសេសការហូបចុកនេះតែម្តង " ។ ខ្ញុំក៏យល់ដូចបងខ្ញុំផងដែរ តែខ្ញុំត្រូវតែត្រៀមឲ្យរួចជាស្រេច ព្រោះវាឥតមានខាតបង់អ្វីឡើយ មានតែចំណេញខាងសមត្ថភាព លទ្ធភាព និងស្មារតីតស៊ូរឹងមាំប៉ុណ្ណោះ ។ ខ្ញុំយល់ថាធ្វើដូច្នោះ គឺកូនរបស់ខ្ញុំ នឹងក្លាយទៅជាមនុស្សរឹងប៉ឹង ហ៊ានប្រយុទ្ធនឹងការលំបាកៗ ដែលនៅចំពោះមុខ ទាំងនៅក្នុងព្រៃ ទាំងនៅក្នុងទឹក និងទាំងនៅលើគោក ។ សូមបញ្ជាក់ថា មកដល់សព្វថ្ងៃនេះ ខ្ញុំយល់ថា អ្វីដែលខ្ញុំបានធ្វើនៅពេលកន្លងមកនោះពិតជាត្រឹមត្រូវ ពីព្រោះកូនៗ របស់ខ្ញុំទាំងអស់ដែលមានជីវិតរស់នៅដល់សព្វថ្ងៃនេះ សុទ្ធតែជាមនុស្ស រឹងប៉ឹង មានសមត្ថភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្ត (ចេះតស៊ូ ចេះអំណត់ ចេះដោះស្រាយ) និងជាពិសេសមានជំហរម្ចាស់ការលើខ្លួនឯង បានសេចក្តីថា កូនស្រីទាំងប្រាំរបស់ខ្ញុំគឺពិតជាកូនដ៏ល្អនៃគ្រួសារមែន ធ្វើឲ្យខ្ញុំធូរស្រាលក្នុងចិត្ត និងមានក្តីសង្ឃឹមថា អនាគតដ៏រុងរឿងនឹងរង់ចាំពួកនាងជាមិនខាន ។

ពេលនោះបញ្ហាលំបាកក្នុងការធ្វើដំណើរ ជូនកូនទៅរៀន និងខ្ញុំទៅ

ធ្វើការលែងចោទទៀតហើយ ។ ក៏ប៉ុន្តែនៅមានបញ្ហាធំមួយទៀត ដែលខ្ញុំត្រូវប្រឈមមុខ គឺការចាយវាយសម្រាប់គ្រួសារទាំងមូល ។ ពេលមុនយើងមានចំណូលពីរ ហើយឥឡូវមានប្រាក់ខែរបស់ខ្ញុំតែម្នាក់ឯង ( ជិតមួយម៉ឺនរៀលដែរ) តែចាយមិនគ្រប់ទេ ព្រោះកូនៗកាន់តែធំ ត្រូវចំណាយច្រើន ហើយទំនិញចេះតែឡើងថ្លៃទៀត ។ ក្នុងករណីនេះ ខ្ញុំសម្រេចចិត្ត ដូរផ្ទះពីម្តុំអាងទឹកស្តាដអូឡាំពិក ទៅរកជួលផ្ទះនៅជិតកន្លែងធ្វើការ ដើម្បីកាត់បន្ថយថ្លៃធ្វើដំណើរផង ចំណេញពេលវេលាផង និងជាពិសេសបានចំណូលពីប្រាក់ដែលខ្ញុំជួលផ្ទះធំរបស់ខ្ញុំ បានក្នុងមួយខែមួយម៉ឺនរៀលផង ។ ខ្ញុំមកជួលផ្ទះល្វែង តម្លៃត្រឹមតែពីរពាន់រៀលប៉ុណ្ណោះ ។ ផ្ទះជួលនោះស្ថិតនៅលើផ្លូវនរោត្តមខាងត្បូងវិមានឯករាជ្យ ។ ជីវភាពគ្រួសារដ៏កំសត់របស់ខ្ញុំមានដំណោះស្រាយ បានស្រួលបួលបន្តិចហើយ ។ លើសពីនេះដើម្បីមានប្រាក់ចំណូលឲ្យបានច្រើនថែមទៀត ខ្ញុំទទួលបង្រៀន ម៉ោងបន្ថែមក្នុងមួយសប្តាហ៍បានបួនម៉ោង(ម៉ោងបន្ថែមចំពោះសាស្ត្រាចារ្យ ទុតិយភូមិបាន ២៧០ រៀលក្នុងមួយម៉ោង បើគិតជាមាស ខ្ញុំបង្រៀនថែមមួយម៉ោងអាចទិញមាសបានជិតមួយជីងណោះ ) ។ ដូចនេះប្រាក់ចំណូលសរុបរបស់ខ្ញុំ លែងបង្កើតការលំបាកក្នុងជីវភាពទៀតហើយ ទោះបីជាខ្ញុំ ត្រូវរ៉ាប់រងចិញ្ចឹមកូនប្រាំនាក់ តែម្នាក់ឯងក៏ដោយ ។ ក៏ប៉ុន្តែគ្មាន ចំណោទបញ្ហាក្នុងជីវភាពក៏ពិតមែនតែបញ្ហាផ្សេងៗ កើតមានជាបន្តបន្ទាប់ រំខានជីវិតគ្មានពំនឹងរបស់ខ្ញុំនៅឡើយ ។ ម្ចាស់ផ្ទះដែលខ្ញុំជួលស្នាក់នៅ (លោក ស្រីប្ញព្រិក្យ-ប្រពន្ធមន្ត្រីថ្នាក់ខ្ពស់ក្នុងរដ្ឋការ) ជាមនុស្សតឹងរ៉ឹង ត្រួតពិនិត្យតាំង ពីរបស់របរកំប៉ិកកំប៉ុកដែលខ្ញុំដាក់ក្នុងរបងផ្ទះល្វែង ដែលខ្ញុំជួលឡើងទៅ ។ នេះដោយសារតែលោកស្រី និងក្រុមគ្រួសារគាត់រស់នៅល្វែងទាំងបួនខាងលើចំណែកឯល្វែងផ្ទាល់ដី គឺជាផ្ទះសម្រាប់ជួល ។ ខ្ញុំចាំបានថាពេលមួយនោះ ម្ចាស់ផ្ទះបានស្រែកព្រមានដល់ខ្ញុំ ដែលបានដឹកជញ្ជូនទូងមាន់ចូលទៅក្នុងល្វែងផ្ទះជួលនោះ ។ ទ្រុងមាន់នេះមានតាំងពីខ្ញុំ នៅផ្ទះចាស់របស់ខ្ញុំម្ល៉េះ ។ កាលណោះ នៅពេលដែលប្តីខ្ញុំមិននៅ រោងចិញ្ចឹមព្រាបរបស់គាត់បានត្រូវ

បោះបង់ចោល ម្ល៉ោះហើយខ្ញុំក៏ទិញទ្រុងមាន់ពីរ ទ្រុងដែលមានបីថត ក្នុងមួយទ្រុងៗសម្រាប់ដាក់មាន់ឲ្យកូនចិញ្ចឹមម្នាក់មាន់មួយៗ ។ នេះគឺជាការទម្លាប់ឲ្យកូនខ្ញុំរៀនចេះទទួលខុសត្រូវលើការងារតែប៉ុណ្ណោះ ។ ពួកគេសប្បាយចិត្តណាស់ ព្រោះមាន់ ដែលគេចិញ្ចឹមនោះ ជាមាន់ចិញ្ចឹមយកពងមួយថ្ងៃពងមួយៗ ។ ហេតុនេះហើយមាន់ទាំងប្រាំមួយក៏ត្រូវបានជន្លៀសចេញពីផ្ទះចាស់ទៅនៅកន្លែងថ្មីជាមួយនឹងពួកយើងដែរ ។ ទោះបីជាម្ចាស់ផ្ទះស្រែករអ៊ូរទាំ ដោយឃើញមានទ្រុងមាន់រញ៉េរញ៉ៃ ហើយពេលខ្លះដោយធុំក្លិនអាចម៍មាន់ផង ដែរក៏មិនដឹង ក៏ខ្ញុំពុំអាចបោះបង់ការចិញ្ចឹមមាន់នេះចោលបានដែរ ខ្ញុំត្រូវតែធ្វើមិនលឺ ហើយទ្រាំធ្វើមុខក្រាស់ ក្នុងពេលដែលគេស្រែកពីលើផ្ទះមក ត្មះតិះដៀលឲ្យថា " "អញស្មានថាគ្រាន់បើតែបែរជាមនុស្សរស់នៅជាមួយ សត្វធាតុសោះ..." ។ ហ៊ឺ ! គួរអនិច្ចាម្ចាស់សំដីអគតិនេះណាស់ !

ស្ថានភាពសង្គ្រាមក្នុងស្រុក កាន់តែរីកនិងក្ដៅគគុក ពីមួយថ្ងៃទៅមួយថ្ងៃ។ កងទ័ពពួកខ្មែរក្រហមវាយលុកបន្ទាយរបស់រដ្ឋាភិបាលសាធារណរដ្ឋនៅតាមភូមិស្រុក ដណ្ដើមធ្វើជាតំបន់រំដោះ កាន់កាប់ដោយពួកគេ ។ ការប្រទាញប្រទង់គ្នារវាងទ័ពរដ្ឋាភិបាល និងទ័ពព្រៃ បង្កើតចលាចល ការរីករវនិងវិបត្តិសង្គមធ្ងន់ធ្ងរ ។ ផ្លូវគមនាគមន៍ឆ្លងពីរដ្ឋធានីទៅកាន់ខេត្តមួយចំនួនត្រូវកាត់ផ្ដាច់ជាអន្លើៗ ។ ចលនារត់ចេញពីភូមិដ្ឋានសម្រុកចូលទីក្រុងមានកាន់តែច្រើនឡើងៗ ។ រដ្ឋាភិបាលនេះត្រូវប្រឈមមុខនឹង " ចលនាតស៊ូរំដោះជាតិ " ហើយ ។ សង្គ្រាមក្នុងស្រុកផ្ទុះឡើងនៅគ្រប់ទិសទីក្នុងផ្ទៃប្រទេស ។ កងទ័ពរបស់រដ្ឋាភិបាលបានរៀបចំផែនការ " ចេនឡាទីមួយ " ដើម្បីបើកផ្លូវជាតិលេខប្រាំមួយ (ពីភ្នំពេញទៅកំពង់ធំ) និងផែនការ "ចេនឡាទីពីរ " ដើម្បីបើកផ្លូវជាតិលេខបួន (ពីភ្នំពេញទៅក្រុងកំពង់សោម) បានវាយបណ្ដេញពួកខ្មែរក្រហម នៅតាំងគោក នៅរលាង និងផ្លូវទៅខេត្តកំពង់ធំ ។ ម្ដងឈ្នះរុលទៅមុខ ម្ដងចាញ់ដកថយមកក្រោយ... ។

ប្រជាជននៅតាមជនបទរត់ចូលមកនៅក្នុងទីរួមខេត្ត ។ អ្នកនៅទីប្រជុំជនខេត្តរត់ចូលក្រុង ។ បងប្អូនខាងប្ដីខ្ញុំដែលនៅខេត្តសៀមរាប និងខ្លះនៅបាត់ដំបង ក៏រត់មកនៅភ្នំពេញដែរ ក្នុងនោះមានគ្រួសារក្មួយរបស់ខ្ញុំដែលជាសាស្ត្រាចារ្យ និងមួយគ្រួសារទៀតជាគ្រូបង្រៀន នៅអនុវិទ្យាល័យដំដែក ក៏បានសុំផ្លាស់មកក្រុងភ្នំពេញ។ ដំបូងគេរកផ្ទះជួល ពុំទាន់បាន ដូច្នោះគេក៏មកសុំនៅបណ្ដោះអាសន្នជាមួយខ្ញុំអស់មួយរយៈ ។ សន្តិសុខនៅភ្នំពេញក៏មិនសូវធានាដែរ ។ គ្រាប់រ៉ុកែតបាញ់ធ្លោងចូលស្ទើររាល់ថ្ងៃ ជួនកាលធ្លោងចូលទីផ្សារ ជួនកាលលើចាត្រូវចំផ្ទះរបស់ប្រជាជននៅម្តុំនេះ នៅម្តុំនោះ បណ្ដាលឲ្យមានមនុស្សរបួស បញ្ជូនចូលពេទ្យជាបន្តបន្ទាប់ ។ មនុស្សម្នាដែលរស់នៅក្នុងទីក្រុង ក៏ពុំសូវហ៊ានចេញទៅក្រៅផ្ទះដែរ ។ គេខ្លាចគ្រាប់បែកធ្លោង ហេតុនេះហើយបានជាម្នាក់ៗ នៅពេលចេញទៅក្រៅផ្ទះម្ដងៗ ក្អែកនៅកញ្ចឹងក តែចាំបាច់ត្រូវតែទៅរកទិញស្បៀង យកមកស្តុកទុកនៅផ្ទះ បង្ការពេលមានអាសន្ន ចេញក្រៅមិនបាន ។ ដោយមានអារម្មណ៍ភ័យខ្លាចយ៉ាងនេះ បានជាឲ្យតែលឺសូរអ្វីប្លែក គេនាំគ្នាក្រាបភ្លាម សូម្បីជាសំឡេងម៉ូតូ ហុងដា ឆាលី ដែលបញ្ចេញសំឡេង " រ៉ុកៗៗ " ក៏នាំគ្នារត់ប្រសាចរកកន្លែងក្រាបដែរ ព្រោះគ្រាប់រ៉ុកែត ដែលមុនធ្លាក់លឺសូរបែបដូចសំឡេងឆាលីអញ្ចឹងដែរ ។ អ្នកដែលមានស្មារតីតិច ប្រាកដជាកើតជំងឺបេះដូងជាមិនខាន ។ ពួកអ្នកមានទ្រព្យ និងអ្នកធំនៅភ្នំពេញ ក៏ដូចអ្នកនៅតាមខេត្តនានាដែរ តែងបញ្ជូនកូនចៅ ចេញទៅរៀននៅក្រៅប្រទេស ហើយដល់ ពេលស្រុកមានអសន្តិសុខបែបនេះទៀត គេក៏បញ្ជូនប្រពន្ធកូនជន្លៀសទៅបរទេសទាំងគ្រួ ។ សំបុត្រយន្តហោះចេញទៅប្រទេសក្រៅត្រូវបានគេកក់ អស់តាំងពីបី–បួនខែមុនមកម្ល៉េះ ។ បងជីទូតមួយរបស់ខ្ញុំ(បង **ឌុំ ឃិន** ) ដែលជាប្រធានភស្តុភារនៃក្រសួងការពារជាតិ មានទ្រព្យសម្បត្តិច្រើន ហើយចង់បញ្ជូនប្រពន្ធ និងកូនទៅស្រុកបារាំងដែរ ក៏ប៉ុន្តែយឺតពេលហើយ អាចកក់សំបុត្របានដល់ទៅពាក់កណ្ដាលខែ៥ ឯណោះ ។ ដូចនេះ

គាត់គិតបញ្ជូនប្រពន្ធ និងកូនទៅប្រទេសថៃជាបណ្តោះអាសន្នសិន។ ដោយឡែកប្រពន្ធគាត់មិនព្រមទៅ ព្រោះគាត់បានរកគ្រូទាយថា នៅចុងឆ្នាំខាលនេះ ជើងលេខល្អមធ្យម ហើយដល់ចូលឆ្នាំថោះ រាសីគាត់នឹងឡើងខ្ពស់ត្រដែត...។ ហ៊ឺស! គួរឲ្យស្រណោះគាត់ណាស់ បងឃិនក៏ស្លាប់ ប្រពន្ធ និងកូនពីរនាក់ក៏ស្លាប់ ស្លាប់ក្នុងសម័យខ្មែរក្រហមនេះឯង បន្សល់កូនបីនាក់នៅរស់កំព្រាវេទនា រហូតដល់សព្វថ្ងៃនេះ ( ក្មួយ**ឪណាត** ក្មួយ**ដា** និងក្មួយ**ម៉ុំ** )។ ខ្ញុំរំលឹករឿងបងជីទួតមួយនេះ ដោយសារគាត់នេះឯងជាអ្នកជួយមើលខុសត្រូវ និងជួយផ្គត់ផ្គង់ខ្ញុំ នៅពេលដែលខ្ញុំបានមករៀននៅអនុវិទ្យាល័យនារីនាឆ្នាំ ១៩៥០ ។ កាលនោះ គាត់ទើបចេញពីសាលានាយទាហាន ហើយនៅពេលចុងក្រោយនេះគាត់ឡើងពាក់ស័ក្តិប្រាំ ។

នៅចំពោះមុខស្ថានភាពដ៏ជ្រួលច្របល់នេះ ខ្ញុំកាន់តែហេងហាងក្នុងចិត្តក្រៃលែង ។ ម្តងលឺថាអ្នកនេះចេញទៅប្រទេសបារាំងហើយ ម្តងលឺថា អ្នកនោះ ក៏ចេញក្រៅដែរ ។ ខ្លះទៅប្រទេសថៃ ខ្លះទៅប្រទេសជប៉ុន... ។ចុះខ្លួនខ្ញុំនិងកូនៗ ត្រូវគិតយ៉ាងណា? ខ្ញុំឥតមានអ្នកជួយពិគ្រោះ ឬជួយលើកទឹកចិត្តទេ មានតែបងស្រីមេម៉ាយម្នាក់ ទន់ខ្សោយដូចគ្នានឹងខ្ញុំដែរ...។

រដូវចូលឆ្នាំខ្មែរខិតមកដល់ ។ យើងតែងប្រមូលគ្នាទៅជួបជុំ ម្តងនៅផ្ទះបងស័ក្តិប្រាំ ម្តងនៅផ្ទះប្អូនថ្លៃគាត់ដែលនៅម្តុំកេងកង ហើយជួនកាលទៅនៅផ្ទះបងស្រីខ្ញុំ ដែលប្តូរទៅនៅម្តុំបឹងត្របែកវិញ ដែលនោះជាផ្ទះឈើធំទូលាយ ជាកេរ្តិ៍មរតបានមកពីលោកយាយ " **យឿម** " ម្តាយក្មេករបស់គាត់ ។ នៅថ្ងៃចូលឆ្នាំខ្មែរ ពួកខ្ញុំបានទៅលេងនៅផ្ទះបងស្រីនៅបឹងត្របែកទុកផ្ទះដែលខ្ញុំជួល នៅមុខវត្តប្រយូវង្សបិទទ្វារចោល ដោយសារអ្នកដាំបាយនៅផ្ទះខ្ញុំ បានសុំទៅលេងស្រុកកំណើតក្នុងរដូវចូលឆ្នាំ ។ ខ្ញុំនាំកូនទៅលេងជាមួយបងស្រីខ្ញុំ ថ្ងៃទី ១៤,១៥ អស់ពីរយប់ ហើយក៏ត្រឡប់មកផ្ទះវិញ នៅព្រឹកថ្ងៃទី ១៦ ( ខែ មេសា ឆ្នាំ ១៩៧៥ )។ នៅតាមផ្លូវ ខ្ញុំឃើញស្ថានភាព

មិនធម្មតា ដូចជាមានហេតុការណ៍អ្វីចំឡែក ។ អ្នកដំណើរតាមផ្លូវដើរញាប់ជើង មានបង្វិចនៅតាមខ្លួន ខ្លះមានទូល ស្ពាយអីវ៉ាន់ ខ្លះមានរទេះរុញ ។ អ្នកទាំងអស់នោះច្រើនធ្វើដំណើរពីទិសខាងកើតមកទិសខាងលិចឬពីត្បូងមកជើង ។ សូរកាំភ្លើងដែលកាលពីយប់លឺយូរៗម្តង តែឥឡូវកាន់តែរន្ថើន ហើយកាន់តែលឺខ្លាំងថែមទៀត ។ មកដល់មុខផ្ទះ ខ្ញុំចតឡាននៅលើផ្លូវ ហើយចុះទៅសួរអ្នកដើរតាមផ្លូវ ។ គេថាមានវាយគ្នានៅតាមផ្លូវជាតិលេខ១ ត្រង់ម្តុំណាៗនោះ គេក៏ឥតបានដឹងច្បាស់ដែរ គ្រាន់តែថាគាត់ឃើញគេរត់ និង លឺគេថា គេវាយគ្នាឆ្លងពីអ្នកលឿងមកហើយ ហើយក៏រត់ដែរទៅ ។ ក្នុងពេលនោះ ខ្ញុំឥតមានការតក់ស្លុតអ្វីច្រើនទេ គ្រាន់តែខ្លាចគ្រាប់កាំភ្លើងរបស់គូបដិបក្ខ ដែលប្រយុទ្ធគ្នាក្នុងពេលប៉ះទង្គិចគ្នាប៉ុណ្ណោះ ។ ខ្ញុំបើកឡានបង្វាសទៅផ្ទះបង ស័ក្តិប្រាំ ដើម្បីសួរព័ត៌មាន ។ ទៅដល់មុខផ្ទះឃើញអ្នកបើកឡានឲ្យគាត់ កំពុងជញ្ជូនអីវ៉ាន់ដាក់ឡាន " ឡានរ៉ុលវ៉ាគ្វើនស្កាស្ប៉ុង " យ៉ាងញាប់ដៃ ។ អ្នកបង **ឈេ** (ប្រពន្ធបងស័ក្តិប្រាំ) និយាយប្រាប់ខ្ញុំភ្លាមថា " ប៉ាវាឲ្យបង រៀបចំគ្រឿងហូបចុក និងរបស់របរខ្លះៗដាក់ឡានធំ ពីព្រោះសភាពការណ៍ មិនល្អទេ " ។ ខ្ញុំលាគាត់យ៉ាងប្រញាប់ប្រញាល់ត្រឡប់មកផ្ទះវិញដើម្បីរៀបចំអីវ៉ាន់ដែរ ។ មួយសន្ទុះក្រោយមកបងស្រីខ្ញុំក៏មកដល់ ដឹកកូននិងអីវ៉ែអីវ៉ាន់ ពេញតូទឡាន ហើយក៏បបួលគ្នាទៅផ្ទះ " អាណា " ប្អូនបងណេ ។ យើង ជជែកគ្នាអំពីបញ្ហាការគេចវៀសខ្លួន ក្នុងគ្រាមានអាសន្ននេះ ថាតើយើងទៅណា? ទៅយូរឆាប់? តើត្រូវយកអ្វីទៅតាមខ្លួនខ្លះ? ចុះមាសប្រាក់កែវកងត្រូវទុកដាក់លាក់ដូម្តេច? អាណាដូចជាតក់ស្លុត ភ័យព្រួយជាងបងស្រីខ្ញុំ និងខ្ញុំទៅទៀត។ ខ្ញុំយល់ថានេះមកពីគេមានទ្រព្យសម្បត្តិច្រើន ( ប្តី របស់អាណាជាប្រធានពន្ធដានៅខេត្តស្ទឹងត្រែង)។ យើងទាំងអស់គ្នានៅជួបជុំគ្នា ញ៉ាំបាយថ្ងៃត្រង់ បាយល្ងាចហើយ ក៏សម្រាកមួយយប់នៅទីនោះ ព្រោះអាណាយាត់ថា " ផ្ទះម៉ែឯងនៅបឹងត្របែកជិតស្ពានមុនីវង្ស បើពួកវាវាយចូលភ្នំពេញ វានឹងមកដល់

ផ្ទះម៉ីង៉ឹងឯងមុនគេ ។ ចំណែកឯបងហ៊ុច ផ្ទះនៅលើផ្លូវធំ គឺផ្លូវដែលគេប្រយុទ្ធគ្នា អញ្ចឹងហើយអ្នកទាំងអស់គ្នាស្នាក់នៅផ្ទះខ្ញុំ សិនទៅ " ។

ព្រឹកថ្ងៃទី ១៧ មេសា ខ្ញុំត្រូវត្រឡប់មកផ្ទះខ្ញុំវិញដើម្បីយកអីវ៉ាន់ ។ ឯបងស្រីខ្ញុំក៏មកតាមខ្ញុំដែរ ។ មកដល់មុខផ្ទះ ខ្ញុំឃើញប្អូនស្រីខ្ញុំទាំងពីរនាក់ដែលធ្វើគ្រូបង្រៀន និងប្តីរបស់នាង មកឈរចាំខ្ញុំនៅទីនោះរួចជាស្រេចទៅហើយ ។ ខ្ញុំបើកទ្វារចូលមើលក្នុងផ្ទះ មើលរបស់របរដែលប្រុងជញ្ជូនដាក់ឡាន ។ ពេលនោះស្នូរគ្រាប់កាំភ្លើងបាញ់ផ្ទងផាង ពីរ–បីរាវ លាយឡំជាមួយនឹងសំឡេងមនុស្សស្រែកទ្រហឹង ធ្វើឲ្យខ្ញុំរត់ចេញពីក្នុងផ្ទះមកមើលហេតុការណ៍ ។ មានមនុស្សយ៉ាងច្រើន ឈរនៅតាមដងផ្លូវ ដោយបែរមុខទៅទិសខាងត្បូង សម្លឹងមើលរទេះតង់មួយ ដែលកំពុងបញ្ចេញសំឡេងគ្រូកគ្រាក់ៗ ខ្ទររំពងអាកាស បើកយ៉ាងលឿនពីទិសខាងត្បូងមកទិសខាងជើង។ មនុស្ស បួន–ប្រាំនាក់ ស្លៀកពាក់ខោអាវប៉ារ៉ា អង្គុយលើខ្នងរទេះតង់កាន់ក្រណាត់ស គ្រវីញាប់ដៃ ។ អ្នកដែលឈរនៅលើចិញ្ចើមផ្លូវទាំងអស់ហាក់ដូចជាយល់ សភាពការណ៍ ក៏លើកដៃគ្រវីស្វាគមន៍ទាហានបាក់ទ័ពទាំងនោះ ។ ក្នុងពេល នោះស្រាប់តែមានសំឡេងមួយស្រែកឡើងថា "ត្រូវលើកទង់ជ័យសទៅៗ"។ ពួកបងប្អូន កូនក្មួយខ្ញុំ ដែលកំពុងឈរញៀវញៀនៅមុខផ្ទះ មិនបាននឹកនាអំពីទង់សនោះទេ ព្រោះពេលជាមួយគ្នានោះខ្ញុំងាកទៅមើលខាងត្បូងឃើញមាន ផ្សែងដាស ដឹងថាប្រាកដជាមានការប្រទូសប្រទ្រាសគ្នា ។ ខ្ញុំមើលមិនច្បាស់ ព្រោះភ្នែកខ្ញុំអន់ ។ ក្មួយស្រីខ្ញុំដែលឈរនៅក្បែរនោះនិយាយថា " ប្រាកដជា មានការប៉ះទង្គិចគ្នានៅផ្សារត្តថាន់ហើយ " ។ ខ្ញុំគិតថាបើអញ្ចឹងមែននោះ មិនយូរទេប្រហែលជាកន្លះម៉ោងទៀត វានឹងមកដល់ផ្ទះយើងហើយ ។ ខ្ញុំប្រុងដើរ ចូលទៅក្នុងរបងផ្ទះស្រាប់តែក្មួយប្រុសខ្ញុំម្នាក់ " ឈាន " (ប្តីនាង ស៊ីដន) ដែលឈរនៅក្រោមដើមក្បោក មើលហេតុការណ៍ដែរនោះ បានស្រែកថា "យីស! គ្រាប់កាំភ្លើងនេះធ្លាក់ពីទីណាមក?"។ ខ្ញុំក្រឡេកមើលតាមសំឡេងនោះ ឃើញក្មួយ

ឈានយកដៃខ្ទប់ត្រង់ស្មាខាងឆ្វេង ហើយនៅគៀនបាតដៃមាន ជិតឈាមផង...។ ទាំងអស់គ្នាផ្អើលឆោឡោ ស្ទុះស្រទៅមើលដោយក្តីបារម្ភ។ តែក្មួយនោះ បែរជានិយាយទាំងញញឹមថា " ខ្ញុំអត់កើតអីទេ ទាំងអស់គ្នាកុំបារម្ភអី "។ រួចគេឈ្ងោកទៅមើលខាងក្រោម ហើយអោនឈោងចាប់យកដុំអ្វីមួយ ដែលនៅក្បែរជើងរបស់គេមកបង្ហាញ ។ គឺជាគ្រាប់កាំភ្លើងទំហំប៉ុនចុងចង្កឹះ ដែលធ្លាក់មកប៉ះត្រង់ឆ្អឹងដងកាំបិត ធ្វើឲ្យរបួស ដាច់សាច់ស៊ើស្បែក ។ សំណាងដែរ ដែលគ្រាប់នោះអស់ល្បឿនទៅហើយ ប្រហែលជាហើរមកប៉ះនឹងមែកក្រោក ទើបបន្តធ្លាក់មកក្រោមទៀត។ យើងនាំគ្នាចូលទៅក្នុងផ្ទះរកថ្នាំក្រហម និងបង់ស្អិតមកបិទមុខរបួស ។ ជាមួយគ្នានេះដែរ សំឡេងប៉ប្រូសប៉ប្រះ លាយឡំនឹងសំដីគំរាមកំហែង បានលេចលឺលាន់ រំពងនៅខាងមុខផ្ទះខ្ញុំ " ចេញៗៗៗ ប្រយ័ត្នត្រូវគ្រាប់បែកយន្តហោះពួក អាមេរិក!។។។ "។ យើងទាំងអស់គ្នាពុំហ៊ានតវ៉ា ឬរកមធ្យោបាយទប់ទល់ នឹងពាក្យសំឡុតទាំងនោះទេ ។ ឬមួយបិទទ្វាររត់ទៅពួនក្រោយផ្ទះ ឬមួយ ចេញពីផ្ទះតាមការបញ្ជាដាច់ខាតរបស់ពួកទាហានអាវខ្មៅ ដែលភ្ជង់កាំភ្លើងមករកយើងឥតឈប់ ។ ខ្ញុំជ្រើសរើសយកមធ្យោបាយទីមួយ គឺបិទទ្វារ ហើយរត់ទៅពួន ដើម្បីមានពេលរៀបចំទុកដាក់អីវ៉ាន់ខ្លះៗ ដែលខ្ញុំចាត់ទុកថា ជារបស់មានតម្លៃ។ គឺពុំមែនជាគ្រឿងអលង្ការ មាសពេជ្រ កែវកងអ្វីនោះទេ តែជាឯកសារ ជាសៀវភៅរបថត ជាសំបុត្រកំណើត ជាប្លង់ផ្ទះ...។ បង ស្រីខ្ញុំ និងកូនគាត់ព្រមទាំងគ្រួសារ រង់ចាំខ្ញុំនៅកាច់ជ្រុងផ្លូវខាងត្បូង ។ ប្អូនៗរបស់ខ្ញុំមកជួយរៀបអីវ៉ាន់ដាក់ឡាន ។ ខ្ញុំចេញផុតពីមាត់ទ្វារប្រុងទាញ ទ្វារដែកបិទ ស្រាប់តែកូនប្រុសរបស់ខ្ញុំ (សុខាវន្ត័) ស្រែកថា " ម៉ាក់ភ្លេច យកមាន់ៗ "។ ខ្ញុំឈរម៉ឹងមាំងមួយសន្ទុះ ទាល់តែប្អូនប្រុសខ្ញុំ (សុផល) ស្រែកថា " ក្រវែកយកវាទៅៗ "។ គេទាំងអស់គ្នាចូលទៅក្នុងផ្ទះ បើកទ្វារក្រោយ ចាប់មាន់ទាំងប្រាំមួយក្បាល យួរដេករង៉ាកមកដាក់ក្នុងកាប៉ូឡានខាងមុខ( ឡាននេះកាប៉ូនៅពីមុខ ហើយម៉ាស៊ីនឡាននៅខាងក្រោយ ) ។ ពេលនោះ

ពីផ្ទះហើយ ចេញទាំងការសង្វេគចិត្ត ។ ឡានបងស្រីខ្ញុំ ឡានប្អូនម៉េង (ប្ដីប្អូនសុវត្ថិ) និងឡានខ្ញុំ បើកជាប់ៗគ្នា ចេញតាម ផ្លូវព្រះនរោត្តម សំដៅទៅទិសខាងត្បូង ។ មកដល់មុខសាលាចៅពញ៉ាហុក ឡានបរទៅមុខលែងរួច ពីព្រោះមនុស្សដែលជាជនភៀសខ្លួនដូចជាពួកខ្ញុំដែរ ដើរសម្រុកទៅមុខ ខ្លះរុញឡាន ខ្លះរុញរទេះ រុញស៊ីក្លូ ផ្ទុកអីវ៉ាន់ សំពីងសំពោង ណែនពេញផ្លូវ។ យើងចុះពីឡានហើយ ក៏រុញឡានទៅមុខ ដូចគេឯងដែរ ។ រុញបានប្រហែលជាងកន្លះម៉ោង យើងបានទៅដល់រង្វង់មូលស្ពានច្បារអំពៅ ព្រលប់ល្មម ។ យើងត្រូវឈប់នៅទីនោះ ដើម្បីរកបាយទឹក ដែលយើងបានខ្ចប់យកមកពីផ្ទះរួចស្រេចមកហើយ ។ ក៏ប៉ុន្តែពេលបើកកាប៉ូឡានភ្លាម ឃើញមាន់របស់ខ្ញុំងាប់អស់បួនក្បាលទៅហើយ ហើយពីរក្បាលទៀតក៏ទន់ករង៉ៀកដែរ ។ យើងទាំងអស់គ្នាស្លុតចិត្ត ដោយឃើញមាន់ដែលពួកយើងចិញ្ចឹមដោយផ្ទាល់ដៃ បែរជាមកត្រូវស្លាប់ដោយដៃខ្លួនឯងអញ្ចឹង ។ ចំណែកឯកូនៗរបស់ខ្ញុំវិញគេរឹតតែតក់ស្លុតថែមទៀត។ ម្នាក់ៗស្ទុះមក មើលមាន់ហើយទាញមាន់មួយណាដែលគេចិញ្ចឹមដែលគេស្គាល់ច្បាស់ ដោយទឹកមុខក្រៀមក្រំយ៉ាងខ្លាំង ។ ប្អូនៗខ្ញុំក៏សម្រេចចាត់ការ យកមាន់ទាំងនោះ មកធ្វើជាស្បៀងសម្រាប់ដោះស្រាយក្នុងពេលធ្វើដំណើររបស់យើងតទៅមុខទៀត ។ សូមបញ្ជាក់ថា ពីដំបូងកូនៗរបស់ខ្ញុំ មានការអាណិតអាសូរជាខ្លាំង ដល់ជីវិតមាន់របស់គេ ដោយបដិសេធមិនព្រមញុំាមាន់នោះទេ តែនៅពេលដែលអត់មានអីញុំា មានឯណាត្រូវតែញុំា ។

ដោយមានការបង្ខិតបង្ខំពីហ្វូងមនុស្ស យើងត្រូវបន្តដំណើរចេញទាំងយប់ពីទីនោះ ឆ្លងស្ពានក្បាលថ្នល់ ទៅច្បារអំពៅដែលនៅត្រើយម្ខាងទៀត។ ពិតហើយឆ្លងស្ពាននេះត្រូវប្រើពេលពេញមួយយប់ ព្រោះអីស្ពានណែនណាន់តាន់តាប់ ដោយម្ខាងឆ្លងទៅច្បារអំពៅ (មនុស្សភៀសខ្លួន) និងម្ខាងទៀតដែលមកពីក្រុងគឺសុទ្ធតែជាឡានទ័ព។ យើងសម្រាកនៅតាមផ្លូវក្បែរៗនោះ ដើម្បីរុករកឱកាសឲ្យពួកកូនចៅក្មេងៗត្រឡប់ទៅក្បាលថ្នល់វិញ ដើម្បីទៅ

រកស្បៀងបន្ថែម ។ យើងឃើញគេគ្រប់គ្នាធ្វើបែបនេះ។ គេបានវាយទម្លាយឃ្លាំងទំនិញ មានឃ្លាំងអង្ករ ឃ្លាំងស្ករ ឃ្លាំងពោតសណ្តែក ។ ល ។ ដែលស្ថិតនៅតាម ផ្លូវមាត់ទន្លេ ។ ប្អូនប្រុសខ្ញុំ ប្អូនថ្លៃ និងក្មួយប្រសារ ក៏ទៅនឹងគេដែរ ដោយរកពោងហែលទឹក ឆ្លងទៅត្រើយក្បាលថ្នល់ ។ លើកទីមួយពួកគេត្រឡប់មកវិញបានអង្ករ គ្រឿងទេស និងស្ករ ។ ថ្ងៃបន្ទាប់ គេទៅម្តងទៀតដើម្បីយកសណ្តែកបាយ សណ្តែកសៀង និង ចានឆ្នាំងខ្លះៗ ។ ពេលត្រឡប់មកវិញ នៅលើកនេះស្រាប់តែបាត់ប្អូនថ្លៃខ្ញុំម្នាក់ (**ម៉េង**) ដែលធ្វើជាទាហានប៉េអឹម ។ គេពុំទាន់មកទេ ។ គេផ្តាំឲ្យប្រាប់ខ្ញុំ និងប្រពន្ធគេថាគេនៅស៊ើបសួររកប្តីរបស់ខ្ញុំ (បង**សយ**) សិន ។ ពីរបីថ្ងៃក្រោយមកយើងនៅរង់ចាំប្អូន**ម៉េង** តែនៅតែមិនទាន់ឃើញមកដល់ដដែល ។ យើងត្រូវតែបន្តដំណើរ ដោយសារគេមិនអនុញ្ញាតឲ្យជនភៀសខ្លួន ស្នាក់នៅត្រង់ម្តុំនោះទេ ហើយដំណឹងរបស់ប្អូនម៉េង ក៏ស្ងាត់ឈឹងទៀត គឺស្ងាត់រហូតមកដល់សព្វថ្ងៃនេះ ។ ដូច្នេះបងប្អូនយើង ដែលរួមដំណើរកាលពីមុនមានចំនួន ២១ នាក់ ពេលនេះនៅសល់តែ ២០ នាក់ប៉ុណ្ណោះ ។

ពីរថ្ងៃក្រោយមក យើងមកដល់ព្រែកឯង ។ យើងបានជួបបងស័ក្តិព្រាំ (បង **ឃិន**) ដែលកំពុងឈរជិតឡានយោធាម៉ាក "កាត់កាត់" កំពុងនិយាយជាមួយពួកទាហានអាវខ្មៅ ។ គាត់ងាកមកញញឹមដាក់ខ្ញុំ ហើយប្រាប់ ថា " " បងសម្រេចចិត្តចូលសារភាពហើយ!" រួចក៏ឡើងទៅអង្គុយលើឡាន ដែលមានមនុស្សបី–បួននាក់ នៅទីនោះដែរ ។ បងឃិនបែរទៅមើលប្រពន្ធ និងកូនគាត់ ដោយទឹកមុខញញឹមស្ងួត រួចក៏លើកដៃជាសញ្ញាលាហើយៗ "។ ខ្ញុំដើរទៅឈរក្បែរអ្នកបងណោ រួចសួរគាត់ថា " ម៉េចក៏បងប្រុសឆាប់ចូល សារភាពម៉្លេះ ? គួរតែចាំមើលសភាពការណ៍សិន " ។ ខ្ញុំនិយាយយ៉ាងនេះ ក៏ដោយសារខ្ញុំគិតថា ក្រែងបានជួបបង**សយ** ឲ្យគាត់ជួយធ្វើអន្តរាគមន៍ ។ តែអ្នកបងណោបានតបមកខ្ញុំវិញថា ប្តីរបស់គាត់មិនចង់ទៅសារភាពភ្លាមទេ តែត្រូវបង្ខំចិត្ត ។ គេបានប្រកាសថា " ចំពោះពួក

អ្នករដ្ឋការ ឬពួកនាយទាហាន ដែលចូលសារភាព គេនឹងអនុញ្ញាតឲ្យប្រពន្ធកូនស្នាក់នៅទីនោះបន្តទៅទៀត ដោយមិនរករឿងអ្វីឡើយ បើមិនដូច្នោះទេ គេនឹងជន្លៀសចេញឲ្យទៅមុខទៀតហើយ ៕ កន្លែងដែលពួកគាត់ស្នាក់នៅក្នុងព្រៃកឯងនោះ គឺជាភូមិដ្ឋានរបស់លោកសក្តិ ៥ ម្នាក់ ដែលជាមិត្តភក្តិរបស់បងឃិន ។ ភូមិ ដ្ឋាននោះធំទូលាយ មានដើមឈើហូបផ្លែជាច្រើនមុខដែលចោលម្លប់ត្រជាក់ល្ហឹម គួរចង់ឲ្យរស់នៅ ។ អ្នកបងណោបានឃាត់ពួកខ្ញុំឲ្យទៅស្នាក់នៅជាមួយគាត់ដែរ តែពួកយើងមានបញ្ហាខុសពីគាត់ដែលត្រូវតែទៅមុខទៀត ។ ឡាន " កាត់កាត់ " បរចេញទៅបាត់ហើយ រីឯព័ត៌មានអ្វីៗអំពីបងឃិនក៏បាត់ឈឹងផងដែរ បាត់រហូតមកដល់សព្វថ្ងៃនេះ។

ខ្ញុំបន្តដំណើរទៅមុខ រកកន្លែងឈប់សម្រាក ដើម្បីរង់ចាំដំណឹងរបស់ប្តីខ្ញុំ។ ខ្ញុំបានជួបនឹងក្មួយស្រីបងអ៊ុមទៀតហើយ ។ នាងនោះបានហៅខ្ញុំឲ្យទៅនៅក្នុងដីភូមិរបស់នាង នៅមុខវត្តចំប៉ា ដែលមានដើមល្មុត ដាំជាជួរៗចោលម្លប់ដ៏ត្រឈៃ ។ យើងស្នាក់នៅក្រោមដើមល្មុត ដែលមានចងក្រណាត់ កៅស៊ូធ្វើជាដំបូល ជាមួយអ្នកភៀសខ្លួនច្រើនគ្រួសារទៀត ( ដែលគាត់ច្រើនជាគ្រួសារអភិជន និងមានពួករាជវង្សផងដែរ) ។ អស់រយៈពេលជាងមួយខែហើយ នៅតែមិនទាន់បានទទួលព័ត៌មានអ្វីសោះអំពីគាត់។ ខ្ញុំតែងមកឈរ នៅលើចិញ្ចើមផ្លូវជាតិលេខ១ ដើម្បីមើលស្ថានភាពនៃប្រជាជនភៀសខ្លួនចេញពីភ្នំពេញផង និងអ្នកដំណើរទៅមកតាមដងផ្លូវនោះផង ។ ព្រឹកមួយនោះ ខ្ញុំ បានជួបនឹងលោកគ្រូម្នាក់ ដែលបង្រៀននៅវិទ្យាល័យទេវមិនា ហើយដែលធ្លាប់ចូលរួមធ្វើមិទីញនៅសាលាគរុកោសល្យដែរ ព្រមជាមួយនឹងនិស្សិតមហាវិទ្យាល័យខ្លះៗ ដែលខ្ញុំធ្លាប់ស្គាល់មុខ ។ គេស្លៀកពាក់ខោអាវខ្មៅ ជិះឡានហ្ស៊ីប បរតាមផ្លូវឆ្ពោះទៅអ្នកលឿង ។ ខ្ញុំស្រែកហៅគេ [illegible] ក៏បក់ដៃឲ្យឡានឈប់ ដើម្បីសាកសួរព័ត៌មានអំពីស្ថានភាពនៅក្នុងទីក្រុងភ្នំពេញផង និងជាពិសេសវត្តមានរបស់បង**ពីន សយ** ផង ។ គេបដិសេធថាអត់ដែលបានឃើញ ប្តីខ្ញុំទេ តែគេសន្យាថា ចាំស៊ើប

ស្វរកេឲ្យ ។ មួយខែកន្លងផុតទៅទៀតហើយៗ ដំណឹងអំពីគាត់ក៏នៅតែបាត់ស្ងន្យ ។ ការរំពឹងគិត និងក្តីសង្ឃឹម របស់ខ្ញុំត្រូវបានចុះខ្សោយអស់ហើយពីមួយថ្ងៃទៅមួយថ្ងៃ ។ ភាពគ្មានពំនឹង បានធ្វើឲ្យខ្ញុំ ត្រូវតែផ្លាស់ប្តូរឥរិយាបថ...។

| | | |
|---|---|---|
| ទុកខ្ញុំរសាត់ | តាមវាយោផាត់ | ក្រោមព្យុះព្យោមា |
| ឆ្លងការលំបាក | អនេកប្បការ | ចិត្តកាយវាចា |
| | រក្សាកេរ្តិ៍ឈ្មោះ ។ | |

ពួកយើងទាំងអស់គ្នា ក៏សម្រេចចេញពីវត្តចំប៉ា ត្រឡប់ទៅស្រុកកំណើតវិញ ដើម្បីទៅជួបឪពុកម្តាយខ្ញុំពីព្រោះស្បៀងក៏ជិតអស់ ប្រាក់កាសក៏ឥតចាយវាយបាន ។ បើទ្រាំរង់ចាំតទៅទៀត ក៏មិនដឹងថាបានជួប ឬមិនបានជួបបងសយដែរ ហើយការរង់ចាំរបស់យើង អស់ពេលជិតបីខែមកហើយ បើគិតតាំងពីថ្ងៃជន្លៀសចេញពីភ្នំពេញ ។ យើងក៏សម្រេចចិត្តចេញដំណើរ ។

យើងត្រូវជិះកាណូតឆ្លងពីព្រែកឯងទៅត្រើយម្ខាងទៀត នៅក្នុងស្រុកអរិយក្សត្រ ជាមួយអ្នកភៀសខ្លួនច្រើនគ្រួសារទៀត ហើយដើរតាមមាត់ទន្លេរហូតទៅ ។ ក្រុមយើងដែលមានមនុស្ស ២០ នាក់ មានចំណាស់ពីរនាក់ គឺបងស្រីខ្ញុំ និងខ្ញុំ អ្នកឯទៀតជាយុវវ័យ និងកូនក្មេងតូចៗពីរនាក់ ដែលដើរមិនទាន់ត្រង់ផ្លូវនៅឡើយ។ អ្វីដែលធ្វើឲ្យយើងមានការលំបាកក្នុងការធ្វើដំណើរនោះ គឺការដឹកជញ្ជូនបង្វិចខោអាវ ស្បោងដាក់អង្ករ អំបិល និងគ្រឿងទេសមួយចំនួន ព្រមទាំងស្ករស សណ្តែកបាយ ដែលពួកយើងយកបានពីឃ្លាំងនៅក្បាលថ្នល់ ។ ការពិតទៅ គឺដោយសារស្ករស និងសណ្តែកបាយនេះហើយ ដែលយើងអាចដោះដូរអាហារបាន ដូចជាត្រី សាច់ ហូបនៅពេលនោះ ។ យើងមានកូនរទេះឈើមួយ ដែលគេបោះបង់ចោលនៅតាមផ្លូវ

សម្រាប់ផ្ទុក ឥវ៉ាន់ខ្លះៗ ។ ក្មួយប្រសារខ្ញុំ បានយកកង់របស់គេ ដែលទើប ទិញ សម្រាប់ជិះហាត់ប្រាណទៅតាមដែរ ហើយពេលនោះ វាក៏ក្លាយទៅ ជាកង់ដឹកអង្ករ និងការុងសណ្តែកទៅវិញ ដោយមានក្មួយប្រុស វីរៈ ( កូនទី ៣ របស់បងស្រី ) ជាអ្នកជួយទប់ឥវ៉ាន់ និងជួយរុញ ពេលឡើងទួល ឬផុង ឬធ្លាក់គន្លុកម្តងៗ ។ យើងធ្វើដំណើររហូតមកដល់ទន្លេបិទ ។ ពួកទាហាន ខ្មែរក្រហមឃាំងផ្លូវ ដោយបង្ហាញមុខសញ្ញាដែលគេត្រូវឲ្យទៅនោះ គឺទៅ តាមផ្លូវឆ្ពោះទៅស្រុកអូរាំងឪ...។ ក៏ប៉ុន្តែ ពួកយើងចង់ធ្វើដំណើរទៅ ស្រុកស្ទឹងត្រង់ ដែលនៅតាមដងទន្លេមេកុង ចម្ងាយពីទន្លេបិទប្រហែលជិត ៣០ គីឡូទៀត ។ ដូច្នេះហើយ ពួកយើងត្រូវរិះរកមធ្យោបាយគេចវេះពីមុខ សញ្ញាដែលគេតម្រូវឲ្យទៅនោះ។ យើងបណ្តាក់គ្នា គេចពីទីនោះម្តងម្នាក់ៗ។ ខ្លះចុះទៅមាត់ទន្លេ ដើរបន្តិចៗតាមមាត់ទឹក ខ្លះទៀតចុះដើរកាត់ទៅតាមចំការ អំពៅធ្វើហាក់ដូចជា រកកន្លែងបន្ទោរបង់...។ យើងទៅរង់ចាំជួបជុំគ្នាទាំងអស់ ដើម្បីបន្តដំណើរ។ យើងបន្តដើរតាមមាត់ទន្លេរហូត មកដល់ភូមិទ្រា ទើបរកទូកឆ្លងទៅត្រើយម្ខាងទៀត ។ ការពិតទៅ វាពិបាករកទូកចម្លងណាស់ ពីព្រោះភូមិទ្រាកាលពីមុន ជាភូមិរបស់ពួកខ្មែរឥស្លាម ហើយដែលខ្ញុំធ្លាប់ស្គាល់ម៉ែង ម្នាក់ឈ្មោះ " **ម៉ីខ ស្មូម** " ជាក្លើរបស់ម្តាយខ្ញុំ ។ តែឥឡូវបាត់ពួកខ្មែរឥស្លាមទាំងនោះអស់ ។ ខ្ញុំដើរសួរគេឯង រកជួលទូកចម្លង ។ ជាសំណាងល្អ មានពូម្នាក់ជាសាច់ញាតិ**ម៉ីខស្មូម** ហើយស្គាល់ឪពុករបស់ ខ្ញុំដែរ គាត់ក៏ជួយទាក់ទងបានទូកឆ្លងទៅត្រើយម្ខាង ដែលជាស្រុកកំណើតរបស់ខ្ញុំនោះឯង ។ យើងទាំង ២០ នាក់បានមកដល់ មាត់ច្រាំងនៃស្រុកស្ទឹងត្រង់ហើយ... ។ ខ្ញុំហាក់ដូចជាវង្វេងវង្វាន់ ពីព្រោះកន្លែងដែលទូកចុះចត ពុំមែនជាកំពង់ផែ ដែលខ្ញុំធ្លាប់ឡើងចុះឡើយ ។ អ្វីៗដែលខ្ញុំធ្លាប់ស្គាល់ពីមុន ដូចជាប៉ុស្តិ៍ប៉ូលីស សាលាឆទាន ហាងគុយទាវ ផ្ទះលក់ទំនិញដែលនៅតាមជួរមាត់ទន្លេ... ឥឡូវបាត់អស់រលីង ។ ខ្ញុំខានមកស្រុកខ្ញុំនេះ តាំងពីឆ្នាំ ១៩៧០ ដែលកាលណោះ ស្រុកស្ទឹងត្រង់ត្រូវបានកាន់កាប់ជាតំបន់រំដោះ

ដោយពួកខ្មែរក្រហមរហូតមក ។ ទិដ្ឋភាពនៅទីនោះស្ងាត់ឈឹងពុំសូវមានអ្នកដំណើរទៅមក ដូចកាលពីមុននោះទេ ហើយមនុស្សម្នាក់ៗ ដែលខ្ញុំជួបពីជាមនុស្សដែលខ្ញុំមិនធ្លាប់ស្គាល់សោះ ។

ឪពុកម្ដាយខ្ញុំឥតបានដឹងអំពីការមកដល់របស់ពួកយើងទេ តែគាត់ចេះតែរង់ចាំ និងសង្ឃឹមថាកូនចៅរបស់គាត់ នឹងមករកគាត់ជាមិនខាន ។ យើងទាំងអស់គ្នាបានមកដល់ផ្ទះហើយ ។ យើងស្ទុះទៅរកគាត់ ក្រាបក្បែរជើងគាត់ ឱនសំពះគាត់ដោយការគោរព និងក្ដីនឹករលឹកយ៉ាងខ្លាំង ។ ឪពុកម្ដាយ កូន និងចៅទាំងអស់ ដែលខានជួបគ្នាអស់រយៈពេលរាប់ឆ្នាំមកហើយៗឥតដែលបានទាក់ទងគ្នាសោះនោះ តើពេលនេះយើងមានអារម្មណ៍បែបណាទៅហ្ន ? ។ យើងសន្ទនាគ្នា អស់ពីរឿងមួយចូលរឿងមួយទៀត ភ្លេចបាយ ភ្លេចទឹក ហើយជាពិសេសភ្លេចទាំងគិតថា តើថ្ងៃស្អែកវានឹងមានហេតុការណ៍ អ្វីកើតឡើងឡើយ។ មែន! ស្អែកឡើងមានបុរសម្នាក់ស្លៀកពាក់ខ្មៅ មកលេងផ្ទះឪពុកខ្ញុំៗ ហៅបុរសនោះ " មិត្តកួយៗ " ។ ដំបូងគេនិយាយសួរសុខទុក្ខរបស់យើង ក្នុងការធ្វើដំណើរពីភ្នំពេញមក សួរពីស្ថានភាពនៅភ្នំពេញផងដែរ និងនៅទីបំផុត គេក៏និយាយរៀបណែនាំ ថានៅភូមិយើងគេកំពុងអនុវត្តផែនការ ដាំពោត សណ្ដែក នៅម្ដុំ " ព្រែកបារាំង" (តំបន់លិចទឹកនៅរដូវទឹកឡើង ចូលព្រែក ហើយនារដូវទឹកស្រកតំបន់នោះក្លាយទៅជាចំការដាំដំណាំសព្វបែបយ៉ាង ) ដែលកាលពីមុនអ្នកភូមិតែងដាំដំណាំសម្រាប់គ្រួសារ មានពោត សណ្ដែក ដំឡូង ត្រាវ ប៉ិះគួក... និងដំណាំឧស្សាហកម្ម ដូចជាដាំដើមថ្នាំជក់ជាដើម ។ ពេលនោះពួកយើងត្រូវបង្ខំចិត្ត ចូលរួមចុះទៅធ្វើចំការ ជាមួយអ្នកភូមិទាំងនោះដែរ ទៅតែមនុស្សធំៗទេ ឯកូនៗនៅផ្ទះ ។ ខ្លះធ្វើស្មៅលើករងសម្រាប់ដាំដំឡូង ខ្លះរៀបចំធ្វើទ្រុងមាន់ (មាន់ដែលយើងដូរ បានពីអ្នកស្រុក នៅតាមផ្លូវធ្វើដំណើរ ) ។ ដំបូងយើងរស់នៅក្នុងស្ថានភាពបែបនេះ ដោយមិនមានសតិអារម្មណ៍នឿយណាយប៉ុន្មានទេ ពីព្រោះយ៉ាងហោចណាស់ក៏វាគ្រាន់

ប៉េជាងកាលយើងរស់នៅក្រោមដើមល្មុតនោះដែរ ពីព្រោះយើងបាននៅជួបជុំ ឪពុកម្ដាយយើង ហើយយើងក៏មានផ្ទះនៅស្រួលបួលដែរ ។ គឺផ្ទះឈើបីខ្នងធំទូលាយជញ្ជាំង និងក្ដារក្រាលធ្វើ អំពីឈើស្រឡៅវាយជាប់គ្នាជិតស្អុង។ នៅចន្លោះពីផ្ទះធំទៅចង្ក្រានបាយ មានស្ពែងមួយទទឹងប្រហែល ៤ម៉ែត្រ ក្រាលដោយឈើកកោះជ្រៀកជាបន្ទះតូចៗ ប៉ុនពីរផ្ទាប់ដៃធ្វើជារនាបក្រាលរលោងស្រិល ត្រជាក់ស្រួលណាស់នៅពេលសម្រាកថ្ងៃត្រង់ ។

ស្ថានភាពមិននៅនឹងនដូចស្មានឡើយ ចេះតែតឹងតែងមួយថ្ងៃបន្តិចៗ ពីព្រោះគេផ្លូវនយោបាយដោយឲ្យនារីៗ និងយុវជន ទៅធ្វើការនៅឆ្ងាយពីផ្ទះ ដោយតម្រូវឲ្យដេកនៅទីនោះបួនប្រាំថ្ងៃទើបមកផ្ទះម្ដង ។ ខ្ញុំនិងកូន និងក្មួយ តូចៗ នៅផ្ទះជាមួយយាយតាដដែល ។

ព្រឹកមួយនោះ មានមនុស្សម្នាក់មកផ្ទះឪពុកខ្ញុំ ហើយសួរថា - តើកូនស្រីមិត្តតាឯង ដែលធ្វើគ្រូបង្រៀននៅភ្នំពេញ បានមកដល់ហើយឬនៅ ?-។ ខ្ញុំដែលនៅក្បែរនោះ លឺសំណួរនេះភ្លាម ក៏ដើរទៅជួបបុរសនោះដែរ ហើយសួរដំណឹងរបស់ប្ដីខ្ញុំ ។ គេនិយាយប្រាប់ខ្ញុំខ្លះៗដែរ តែគេគ្រាន់តែថាគាត់នៅរស់ ហើយចង់ជួបខ្ញុំ ។ ឯបញ្ហាដែលថាគាត់នៅទីណា ទីណានោះ គេមិនបាននិយាយឲ្យច្បាស់លាស់អ្វីទាំងអស់ ។ ខ្ញុំបានស្នើសុំផ្ញើសំបុត្រមួយច្បាប់ តាមគេនោះទៅឲ្យប្ដីខ្ញុំ ។ គេក៏អនុញ្ញាត ។ ភ្លាមនោះ ខ្ញុំក៏រត់ឡើងទៅលើផ្ទះហើយចាប់សរសេរសំបុត្រ ដែលក្នុងសេចក្ដីសំបុត្រនោះ ខ្ញុំរៀបរាប់តែពីរឿងការលំបាក និងការខ្វះខាតក្នុងជីវភាពប្រចាំថ្ងៃ របស់ក្រុមគ្រួសារយើងតែប៉ុណ្ណោះ ។ ទទួលសំបុត្រហើយ គេក៏លាចេញទៅ ។ ចាប់ពីពេលនោះមក សេចក្ដីសង្ឃឹមរបស់ខ្ញុំ ដែលកន្លងមកមិនមានភាពនឹងន ម្ដងស្រពាប់ស្រពោន ម្ដងខ្មៅងងឹត ឥឡូវមានជីវិតឡើងវិញ និងភ្លឺថ្លាថែមទៀត...។ ប្រហែលជាមួយអាទិត្យក្រោយមកមានឡានដឹកទឹក GMC បើកមកឈប់នៅមុខផ្ទះឪពុកខ្ញុំ ។ គេប្រាប់ថា គេមកទទួលខ្ញុំ និងកូនរបស់ខ្ញុំទាំងអស់គ្នា ឲ្យទៅជួបជាមួយប្ដីខ្ញុំ ។ ខ្ញុំអរក្រៃលែង ខ្ញុំក៏បានជម្រាបលា

ឪពុក និងម្ដាយខ្ញុំ ។ ចំពោះ បងស្រី ប្អូន និងក្មួយ ដែលចុះទៅតាមភូមិអស់ ខ្ញុំឥតបានលាពួកគេដោយផ្ទាល់ទេ ។ គេឲ្យយើងឡើងជិះឡានខាងលើ ទាំងរសេះគ្នា ។ នៅមុនពេលដែលឡានរៀបផ្ដើមចេញដំណើរអ្វីដែល កន្ត្រាក់អារម្មណ៍របស់ខ្ញុំ ដែលកំពុងលង់លក់ក្នុងមនោសញ្ចេតនារំភើប រីករាយសប្បាយនោះ គឺសូរកាំភ្លើងដែល បាញ់រះទៅលើអស់ពីរ - បី បង់ លឺសូរប្រាវៗ ដោយអ្នកដែលមកទទួលខ្ញុំនោះ ។ កូនទាំងប្រាំរបស់ខ្ញុំភ័យ ស្ទុះមករកខ្ញុំ ។ ខ្លះអោបក ខ្លះក្រាបលើជង្គង់ លើភ្លៅ គរលើគ្នា...។ នេះគឺជាទម្លាប់របស់គេ ដែលត្រូវតែបាញ់រះឡើងលើ នៅរាល់ពេលមុន ចេញដំណើរដើម្បីយកជ័យ ។ បន្ទាប់មកខ្ញុំបាន សួរអ្នកបរឡានថា "មិត្ត! តើមិត្តនាំខ្ញុំទៅជួបប្ដីខ្ញុំនៅភ្នំពេញមែនទេ ?" ។ គេឆ្លើយហ៊ោងខ្លីថា " បាទ! នៅជិតៗហ្នឹង " ។ ខ្ញុំជជីកសួរគេបញ្ជាក់ "នៅជិតភ្នំពេញមែនទេ ? " ។ គេឆ្លើយដោយពាក្យដដែលមកខ្ញុំ ធ្វើឲ្យខ្ញុំវង្វេងវង្វាន់ លែងដឹងទិសតំបន់ ព្រោះខ្ញុំតែងនឹកគិតថា នៅពេលបដិវត្តន៍ចប់ហើយ អ្នកតស៊ូក្នុងព្រៃប្រាកដ ជាចូលទៅធ្វើការនៅភ្នំពេញជាមិនខាន ។

ឡានចេញដំណើរទៅហើយ ។ ខ្ញុំមើលទៅមុខ ខ្ញុំងាកមើលឆ្វេងងាក មើលស្ដាំ មើលទីកន្លែងដែលខ្ញុំធ្លាប់ស្គាល់ ។ ខ្ញុំពុំមានការភ្ញាក់ផ្អើលនឹង ភាពប្រែប្រួលនៅទីនោះទេ ឧទាហរណ៍ដូចជា បាត់ផ្ទះខ្ទមតូចៗ ដូរទៅជា រោងវែងៗ បាត់ថ្លុកត្រពាំង ទៅជាភ្លឺស្រែ... ពីព្រោះជារឿងធម្មតាដែលអ្វីៗ ត្រូវតែវិវត្តអញ្ចឹងហើយ គឺជិតដប់ឆ្នាំទៅហើយដែលខ្ញុំឥតបានមកទីនោះ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់តាមសង្កេតមើល គឺអ្នកដើរតាមផ្លូវ ក្រែងមានអ្នកដែលខ្ញុំ ធ្លាប់ស្គាល់ ឬក៏ជួបនឹងបងប្អូនខ្ញុំ ។ ឡានបើកហួសភូមិត្នោតទន្សាយចូល ដល់តំបន់ដីក្រហម គឺជិតដល់ភូមិ " មាឃ " ដែលមានផ្ទះតាយាយរបស់ខ្ញុំ នៅទីនោះ ។ ខ្ញុំសង្ឃឹមថានឹងបានជួបជីតាខ្ញុំ និងបងប្អូនខ្លះៗជាមិនខាន ។ ក៏ប៉ុន្តែ មុនទៅដល់ភូមិអ្នកស្រុក ឡានបានបត់ក្បាលចូលតាមផ្លូវដីក្រហម ចូលក្នុងចំការកៅស៊ូទៅវិញ ។ កូនស្រីធំរបស់ខ្ញុំ ដែលធ្លាប់ស្គាល់ផ្ទះតាទួត

គេសួរខ្ញុំថា “ម៉េចក៏ឡានមិនទៅតាមផ្លូវត្រង់ បែរជាបត់ចូលចំការកៅស៊ូទៅវិញ ?” ។ ខ្ញុំក៏អត់ដឹងដែរ តែចេះតែនិយាយស្មានៗទៅថា ប្រហែលជា... គេចូលទៅដាក់មនុស្សថែមទៀត ឬក៏ទៅយកអីវ៉ាន់អ្វីផ្សេងៗទៀតក៏មិនដឹង។ ឡានបរចូលទៅក្នុងចំការកៅស៊ូ កាន់តែឆ្ងាយទៅៗ ។ ដើមកៅស៊ូដាំជាជួរៗត្រង់ភ្លឹង មើលដាច់កន្ទុយភ្នែក ចោលម្លប់ត្រជាក់ល្ហឹម បាំងបាត់នូវពន្លឺព្រះអាទិត្យរកមើលផ្លូវដែលកាត់ខ្វាត់ខ្វែង ក្នុងចំការស្ទើរតែមើលមិនឃើញ។ ទិដ្ឋភាពបែបនេះ គួបផ្សំជាមួយនឹងភាពស្ងាត់ជ្រងំ គ្មានមនុស្សដើរ គ្មានកង់ ឬ ឡានបរទៅមក ហើយយូរៗម្តងទើប ឃើញពន្លឺថ្ងៃចាំងតាមចន្លោះមែកកៅស៊ូ ធ្វើឲ្យកូនៗរបស់ខ្ញុំរងា ព្រឺឆ្អឹងខ្នង លែងចង់ទស្សនាទេសភាពចម្លែកទាំងនោះទៀត ។ ម្នាក់ៗបែរជាស្ទុះមកអង្គុយប្រជ្រៀតគ្នា កៀកនឹងខ្លួនខ្ញុំទៅវិញ ។ ឡានបរកាត់ចំការកៅស៊ូ អស់រយៈពេលជាងមួយម៉ោងហើយ ឥឡូវវាបានបត់ក្បាលចេញពីជួរដើមកៅស៊ូ តម្រង់ទៅទីវាលមួយ ដែលមានថ្ងៃចាំងចែង មើលទៅឃើញមានដំណាំដើមឈើហូបផ្លែ ដូចជាដើមខ្នុរ មៀន... ចំការម្នាស់ ចំការបន្លែ ដាំក្បែរខ្ទមដែលមើលឃើញតែដំបូលឯនេះមួយ ឯណោះមួយប៉ុណ្ណោះ ។ បន្ទាប់មក ឡានក៏ឈប់ឈឹក ។ អ្នកបើកបរនិងម្នាក់ទៀតដែល អែបតែកុងអង្គុយនៅកាប៊ីនមុខ ស្ទុះចុះពីឡាន ។ ពួកខ្ញុំឥតហ៊ានកម្រើកខ្លួនទេ គ្រាន់តែងកកអើតក្បាល លួចមើលឆ្វេង មើលស្តាំ ឃើញថាឡាននោះឈប់ នៅក្បែរអណ្តូងទឹកដ៏ធំមួយខាងឆ្វេងដៃ ។ រីឯខាងស្តាំមានរោងមួយដែល មានតុដ៏វែងសម្រាប់មនុស្សច្រើនអង្គុយដង្ហែគ្នា... ។ នៅកៀនម្ខាងទៀត នៃរោង ឃើញមានចង្ក្រានធំៗពីរដែលមានខ្ទះត្នោតទំពីលើ ។ គឺប្រាកដជា រោងបាយហើយ...។ ពេលនោះស្រាប់តែមាន កុមារជំទង់ម្នាក់ស្លៀកពាក់ ខោអាវខ្មៅ លេចចេញពីក្នុងរោងនោះមក ដោយមានកាំភ្លើងមួយដើមស្ពាយ នៅស្មាវែងជិតដល់ដី ។ គេដើរតម្រង់មកឡាន ជួបនឹងអ្នកបើកបរដែលកំពុងបើករនាំងក្រោយឲ្យពួកខ្ញុំចុះពីលើឡាន។ គេប្រាប់កុមារនោះថា “មិត្តឯងនាំពួកគាត់ទៅជួបនឹងអ៊ំទៅ !” ។ កុមារយោធាសម្លឹងមើលពួក យើងរបៀបចម្លែក ហើយបោយដៃជាសញ្ញាឲ្យ

យើងដើរតាមគេ ។ យើង ដើរទៅមុខ យួរកូនថង់ដែលយើងបានត្រៀមតាំងពីពីរ–បីឆ្នាំមុននោះ ដោយមានខោអាវញាត់បន្ថែមបន្តិចបន្តួចប៉ុណ្ណោះ ។ ការពិត នៅពេលចេញពី ភ្នំពេញមក ខ្ញុំបានយកអីវ៉ាន់ក្រាស់ក្រែលដែរ មានសារុងថ្មីៗ មិនទាន់ស្លៀក បួន–ប្រាំ មានខោអាវល្អៗ ខ្លះ និងមានគ្រឿងអលង្ការ មាសប្រាក់ខ្លះដែរ តែខ្ញុំបានទុករបស់ទាំងអស់នោះ ជូនម្ដាយ និងផ្ញើទុកឲ្យបងប្អូនខ្ញុំទាំងអស់ ។ យើងដើរតាមក្រោយមិត្តកុមារនោះ តាមផ្លូវតូចមួយ ដែលមានដើមមៀន ដើមសាវម៉ាវដាំជាជួរ រហូតដល់ផុតចុងចូលដល់ចំការចេក ។ នៅចំពីមុខយើង មានកូនរោងមួយដែលមានមនុស្សម្នាក់អង្គុយនៅទីនោះ ។ កូនខ្ញុំស្រែកព្រមគ្នាឡើងថា "ម៉ាក់ៗនោះប៉ា" ។ មែនហើយ នោះគឺពិតជាបងសយមែន មិនមែនជាការយល់សប្តិទេ ! ។ ឪពុកស្ទុះមកជិតកូន អង្អែលក្បាល រួចមើលមុខទាំងញញឹមឥតឈប់ ហើយសួរខ្ញុំថា "ម៉េចទៅ ? មិនអីទេឬ? " ។ ខ្ញុំនៅឈរទ្រឹងមួយសន្ទុះ រកនិយាយអ្វីមិនចេញ រួចខ្ញុំខំ ឆ្លើយទាំងរអាក់រអួល ដោយឥតព្រៀងទុកថា "ចាំអត់អីទេ កូនៗគេសប្បាយរីករាយណាស់ក្នុងការធ្វើដំណើរមកទីនេះ..."។

| | | |
|---|---|---|
| – ដំណើរជីវិត | រាល់រូបត្រូវគិត | ឆ្លងភ្លើងលោកិយ |
| ឥទ្ធិពលខ្លាំងក្លា | រង់ចាំប្រល័យ | កំទេចនិស្ស័យ |
| | ជាតិជាមនុស្សជា ។ | |
| – ទោះបាត់ពំនឹង | អស់ក្ដីពឹង | នៅតែហានក្លា |
| រក្សាជំហរ | ពឹងកាយប្រាជ្ញា | ឧបសគ្គប៉ុនណា |
| | ត្រូវស្រាយឲ្យបាន ។ | |

# វគ្គទី ៥

## មេឃដីស្រអាប់

យើងបានមករស់នៅជួបជុំគ្នាវិញហើយៗ លើកនេះ គឺរស់នៅក្នុងតំបន់ដីក្រហមក្នុងចំការកៅស៊ូ " អូរប្រាំ " (បឹងកេត) ក្នុងស្រុកស្ទឹងត្រង់ចម្ងាយពីទីប្រជុំជនស្រុក ប្រហែលជា ២០ គីឡូម៉ែត្រ ។ តំបន់នេះចូលជ្រៅទៅក្នុងចម្ងាយជាង ១០ គីឡូមែត្រពីផ្លូវស្រុក កាត់តាមចំការកៅស៊ូរបស់ក្រុមហ៊ុនបារាំង ។ គឺជាចំការឯកជនរបស់អ្នកស្រុក ជាពិសេសជាចំការរបស់ពួកមន្ត្រីក្នុងសម័យមុនៗ ។ កន្លែងដែលគេឲ្យពួកយើងស្នាក់នៅនោះ គឺមន្ទីរ " ប-២០" ដែលជាអតីតមន្ទីររបស់អង្គការ ។ មិនមានអ្វីចម្លែក ឬអស្ចារ្យទេ គឺមានតែរោងបួន-ដប់នៅក្នុងចំការចេក ចំការសាវម៉ាវ សង់ឯនេះមួយ ឯណោះមួយឆ្ងាយពីគ្នាប្រហែលជា ១០០ ម៉ែត្រ ។ រោងដែលគេឲ្យខ្ញុំនៅ និង រោងរបស់កូនខ្ញុំ ស្ថិតនៅក្នុងចំការចេកជាមួយគ្នា ។ តែយើងនៅជុំគ្នាបានតែ ពីរថ្ងៃប៉ុណ្ណោះ ក្រោយមកគេចាត់តាំងកូនៗរបស់ខ្ញុំឲ្យទៅនៅតាមក្រុមៗវិញ ។ យុវ័យត្រូវចូលទៅក្នុងក្រុមយុវជន កូនស្រីចូលទៅនៅជាមួយមិត្តនារីៗ ឯកូនតូចៗ ចូលទៅក្នុងកងកុមារ ។ កងនីមួយៗមានមនុស្សតែបី-បួននាក់ប៉ុណ្ណោះ ។ លឺពួកគេនិយាយថា ក្រោយថ្ងៃរំដោះ ១៧ មេសា អ្នកខ្លះ សុំចេញទៅនៅតាមសហករណ៍ក្នុងស្រុកកំណើត អ្នកខ្លះទៀតទៅកាន់អង្គភាពផ្សេងៗ នៅតាមតំបន់ ឬភូមិភាគនានា ។ ក៏ប៉ុន្តែនៅមន្ទីរ "ប-២០" នេះមានមនុស្សចេញចូលញឹកញាប់ណាស់ ។ ប្រហែលជាកន្លែងឆ្លងកាត់ ឬកន្លែងស្នាក់នៅបណ្ដោះអាសន្នក៏មិនដឹង...។ គេឲ្យពួកយើងចូលរួម ចុះអនុវត្តការងារដាំដុះ និងខាងដឹកជញ្ជូន ។ ដំបូងយើងមានអារម្មណ៍សប្បាយខ្លះដែរ ថ្វីត្បិតតែមានការប្រែប្រួលក្នុងរបៀបរស់នៅ

ក៏ដោយព្រោះវាមានអ្វីៗថ្មី ប្លែកៗដែល យើងមិនធ្លាប់ស្គាល់ និងធ្លាប់លឺពីមុនមកជាពិសេសសម្រាប់កូនៗរបស់ខ្ញុំ ។ ចំពោះរូបខ្ញុំវិញ ក៏ដូចជាប្តីរបស់ខ្ញុំដែរ យើងពុំមានអ្វីគួរឲ្យត្រេកត្រអាលឡើយ ក្រៅអំពីការរីករាយដែលបានមករស់នៅជួបជុំគ្នាប៉ុណ្ណោះ ។ អារម្មណ៍ផ្តេសផ្តាស ដែលខ្ញុំមានកាលពីមុនមកបានបាត់បង់អស់ទៅហើយៗ វាបានប្រែក្លាយទៅជាការកក់ក្តៅសម្រាប់ជីវិតរបស់ខ្ញុំទៅវិញ ។ ចំពោះបង **សយ** ខ្ញុំសង្កេតឃើញថាគាត់ក៏មានអារម្មណ៍នឹងនខ្លះដែរ ។ ក៏ប៉ុន្តែនៅពេលខ្លះទៀត ខ្ញុំឃើញគាត់មានអាការៈចំឡែក ស្ងួតស្ងាញ ហាក់ដូចជាមានអាថ៌កំបាំងអ្វីមួយ ដែលគាត់មិនចង់ឲ្យខ្ញុំដឹង ហើយពិបាកចិត្ត ជាមួយនឹងគាត់ ។ ចំពោះរូបខ្ញុំវិញ ក្រៅពីរីករាយនឹងការមករស់នៅជួបជុំគ្រួសារ ខ្ញុំហាក់ដូចជាមានអារម្មណ៍ចម្លែកអ្វីមួយ ។ ខ្ញុំឆ្ងល់ក្នុងចិត្តជាខ្លាំង ពីព្រោះមិនយល់ថាហេតុអ្វីបានជាគ្រួសារខ្ញុំត្រូវមករស់នៅក្នុងតំបន់ដ៏ក្រហមបែបនេះ ខុសប្លែកពីអ្នកនៅក្នុងផ្លូវដ៏ទៃៗទៀត។ បងសយឥតបានបកស្រាយបំភ្លឺ ឬបង្ហាញហេតុផលអ្វីទាំងអស់។ គាត់គ្រាន់តែបាននិយាយរឿងខ្លះៗ ឲ្យខ្ញុំបានដឹងប៉ុណ្ណោះ។ គាត់និយាយថា ប្រហែលជាពីរអាទិត្យក្រោយថ្ងៃរំដោះ ១៧ មេសា ពួកគាត់ ៣ នាក់រួមមាន **ហ៊ូ យន់** មិត្ត **ហម** និងរូបគាត់ ត្រូវបានអង្គការដឹកចេញពីមន្ទីរក្នុងព្រៃមកចូលក្រុងភ្នំពេញតាមរថយន្តហ្ស៊ីប ដែលមានគ្នាប្រាំនាក់រួមទាំងអ្នកបើកបរ។ គាត់និយាយថែមទៀតថា នៅតាមផ្លូវចូលក្រុង ក្រុមគាត់បានឃើញប្រជាជនដែលត្រូវគេជន្លៀសចេញពីភ្នំពេញ ដើរទាំងហ្វូងហ្វាយមានក្មេង មានចាស់ជរា ដែលត្រូវកូនចៅអៀវ មានអ្នកជំងឺដែលគេៗជន្លៀសចេញពីមន្ទីរពេទ្យកាន់ដបសេរ៉ូម ។ល។ ឃើញសភាពការណ៍បែបនេះលោក **ហ៊ូ យន់** លាន់មាត់ថា "អង្គការជន្លៀស ប្រជាជនចេញពីភ្នំពេញបែបនេះគឺដូចជាសម្លាប់ទីក្រុងទាំងមូល ហើយ - C'est comme tuer la ville toute entiere" ។ នេះជាពាក្យដែលលោក **ហ៊ូ យន់** បាននិយាយ ។ បង**សយ**ក៏បានបន្ថែមទៀតថា " មែនហើយមិត្ត មើលចុះពួកអ្នកជន្លៀស ទាំងនោះ

ជាពិសេសអ្នកជំងឺ និងមនុស្សចាស់ជរា ពុំអាចទៅណាបានឆ្ងាយទេ មុខជាត្រូវស្លាប់តាមផ្លូវហើយ...  ។ បងសយបានប្រាប់ខ្ញុំទៀតថា ពួកគាត់ឥតបានចូលក្រុងភ្នំពេញភ្លាមទេ ។ ឡានដឹកក្រុមគាត់ទៅនៅមន្ទីរមួយក្នុងស្រុកឧត្តុង្គ ហើយស្នាក់នៅទីនោះអស់រយៈពេលជិតមួយខែឯណោះ។ ជាញឹកញាប់ ពួកគាត់តែងបានទទួលជួបនឹងថ្នាក់ដឹកនាំ ដែលតែងមកនិយាយលេងផង និងឆ្លៀតពន្យល់ដល់ពួកគាត់ផង អំពីមូលហេតុដែលអង្គការសម្រេចចិត្តជន្លៀសប្រជាជនចេញពីភ្នំពេញ និងមូលហេតុនៃការបិទផ្សារការមិនចាយលុយ ។ល។ នៅរសៀលថ្ងៃមួយ ឡានបានមកដឹកពួកគាត់ចូលក្រុងភ្នំពេញ ហើយឲ្យសម្រាកនៅផ្ទះមួយនៅក្បែរវត្តភ្នំ ដែលគាត់សន្និដ្ឋានថាជាផ្ទះពួកជនបរទេសរស់នៅពីមុន ព្រោះថានៅផ្ទះនោះមានទាំងស្រាល្អៗមានការរៀបចំបែបផែនពួកបរទេស ។ គេឲ្យពួកគាត់ហូបម្ហូបបារាំងនៅពេលល្ងាច មានបង្អែម ផ្លែឈើ ដូចជា ធូរេន ដែលពួកគាត់ឥតដែលបានហូបជាច្រើនឆ្នាំមកហើយ គឺចាប់តាំងពីថ្ងៃរត់ចូល ព្រៃមកម្ល៉េះ។ ស្រាប់តែស្អែកឡើង តាំងពីព្រលឹមស្រាងៗ ពួកគាត់ត្រូវបានគេឲ្យរៀបចំបន្តដំណើរទៅទៀត ដោយឥតបានប្រាប់ថាទៅទីណាទេ ។ ឡានបានដឹកពួកគាត់ទៅចុះកាណូតបញ្ជូនចូលក្នុងចំការកៅស៊ូនេះតែម្តងទៅ។ និយាយដល់ចំណុចនេះ ខ្ញុំហាក់ដូចជាភ្ញាក់ខ្លួន ព្រោះគិតថានេះប្រហែល ជាដោយសារតែរូប ខ្ញុំដែលមិនមែនជាអ្នកក្នុងជួរទេដឹង បានជាគេឲ្យគាត់ត្រឡប់ មកនៅដីក្រហមវិញ មិនឲ្យគាត់ទៅធ្វើការនៅភ្នំពេញជាមួយអ្នកបដិវត្តន៍ដទៃទៀតនោះ។ បង**សយ** បដិសេធគំនិតនេះចោល ដោយបង្ហាញហេតុផល និងធ្វើការសន្និដ្ឋានថា  នេះប្រហែលជាអង្គការយល់ថា ពួកបងមិនទាន់យល់អំពីគោលការណ៍របស់អង្គការហើយ ។

តាំងពីពេលនោះមក បងសយតែងតែនិយាយណែនាំខ្ញុំ និងកូនៗជូនកាល និយាយច្រំដែលៗដូចជាថា  កុំសូវនិយាយច្រើន... កុំធ្វើអ៊ំពាររំពើចិត្ត...ត្រូវខំប្រឹងធ្វើការៗ។ល។  រឿងមួយទៀតដែលគាត់ហាមដាច់ខាត

នោះគឺការប្រើពាក្យម៉ាក់-ប៉ា-លោក-អ្នក-ញ៉ាំ-គេង...ដែលជាពាក្យសម្រាប់អ្នកក្រុងប្រើ ឬពួកថ្នាក់លើ ដែលគេចាត់ទុកថាជាពួកអភិជន ឬពួកមូលធនដែលជាវណ្ណៈជិះជាន់។ ចាប់ពីពេលនោះមក កូនខ្ញុំដូរហៅម៉ាក់ប៉ាថា : "ម៉ែង-ពួ" រហូតមក ។

ជីវិតរស់នៅរបស់ប្រជាជននៅលើដីក្រហម តែងជួបប្រទះនឹងផលវិបាកច្រើន មានជាអាទិ បញ្ហាទឹក ( នៅរដូវភ្លៀង ដីជាប់ជើងស្អិត ដើរស្ទើរទៅមុខមិនរួច នៅរដូវប្រាំង ដីហួតហែង ខ្វះទឹក ត្រូវទៅរកទឹកនៅទីឆ្ងាយដល់អូរ ព្រោះអណ្តូងទឹកជ្រៅមែន តែមានទឹកតែនៅក្នុងរដូវវស្សា) ចំណែកបន្លែបង្ការ ឬដំណាំផ្សេងៗវិញ ឥតមានបញ្ហាចោទទេ ពីព្រោះឲ្យតែបានដាំ គឺដុះល្អបានផលល្អជាក់ជាមិនខាន។ ចំពោះសត្វព្រៃក៏សំបូរឲ្យតែចេញទៅប្រមាញ់មុខជាបានជ្រូកព្រៃឈ្លូស ប្រើស ឬយ៉ាងហោចណាស់ ក៏បានទន្សាយព្រៃ សំពោច ឬអណ្តើក កំប្រុក កង្ហែន ឬពស់ព្រៃដែរ ។ ក៏ប៉ុន្តែការលំបាកធំបំផុតនៅតំបន់នោះ គឺជំងឺដង្កាត់ដែលតែងគំរាមកំហែងដល់ជីវិតរបស់អ្នកចំការទាំងនោះ គឺជំងឺគ្រុនចាញ់គ្រុនសន្និ ។ ល ។ ខ្ញុំរស់នៅក្នុង តំបន់ដីក្រហមអស់រយៈពេល ១៤ ខែ ។ ខ្ញុំក៏ពុំអាចជៀសផុតពីការយាយីនៃ ជំងឺទាំងនោះបានដែរ ។ ខ្ញុំឈឺគ្រុនក្តៅខ្លួនរៀងរាល់ថ្ងៃ ។ រាងកាយរបស់ខ្ញុំ បានស្រុតចុះស្គមមួយថ្ងៃបន្តិចៗ រហូតដល់ដើរលែងរួច... រហូតដល់មានពេលខ្លះ ខ្ញុំអង្គុយក្នុងរោងចំការចេករើរវាយ សើចតែម្នាក់ឯង សប្បាយជាមួយនឹងដើមចេក ដែលបន្ទាបធាងវាមកក្បែរខ្លួនខ្ញុំ អោនងើបៗ ញញឹម មករកខ្ញុំ...។ មានយប់មួយនោះ មិនដឹងជាខ្ញុំយល់សប្តិ មមើ ឬ កើតអ្វី ក៏មិនដឹង ខ្ញុំក្រោកឈរនៅក្រៅមុង រួចប្រុងលោតចុះពីលើរាន ដែលគេធ្វើសម្រាប់ប្រើជាគ្រែដេក មានកម្ពស់ជាងមួយម៉ែត្រខ្ពស់ពីដី ។ ភ្លាមនោះប្តីខ្ញុំ ភ្ញាក់ក្រោកឡើងស្រែកសួរខ្ញុំ "ម៉ែងឯងធ្វើអ្វីហ្នឹង " (សម័យនោះអង្គការ មិនអនុញ្ញាតឲ្យប្រើពាក្យ ឪពុកម្តាយ បងប្អូនប្តីប្រពន្ធទេ ដូច្នេះចំពោះប្តី ប្រពន្ធរបស់ខ្ញុំក៏ដូចគ្នាដែរ គាត់ហៅខ្ញុំថា ម៉ែង

ហើយខ្ញុំហៅគាត់វិញថាពូ ) ។ បងសយចាប់ដៃខ្ញុំ ទាញចូលក្នុងមុងវិញ ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំចេះហោះហើយ ខ្ញុំចង់សាកមើល តើអាចហោះបានមែនទេ ?។ បើអាចបាននោះ ខ្ញុំនឹងរៀបចំ កន្លែងមួយសម្រាប់ហោះឲ្យគេមើលដោយលក់សំបុត្រចូលមើល... អញ្ចឹងខ្ញុំនឹងបានកម្រៃច្រើន សម្រាប់យកទៅកសាងស្រុកភូមិកំណើតរបស់ខ្ញុំ ។ ប្ដីខ្ញុំ ចាប់អោបខ្ញុំជាប់ដោយនិយាយថា គេងទៅកុំគិតអ្វីទៀត ។ នេះជា លើកទីមួយហើយ ដែលខ្ញុំមានជំងឺធ្ងន់រហូតដល់រវើរវាយ ចង់ឡប់សតិ...។ ក្រោយមកពេគសញ្ញាបានលេចចេញមក ខ្ញុំចាប់រងាញាក់ញ័រពេញអង្គប្រាណអស់បីបួនថ្ងៃជាបន្តបន្ទាប់ ទើបដឹងថាខ្ញុំមានជំងឺគ្រុនចាញ់ហើយ ។ **បងសយ** បានទៅទាក់ទងនឹងអ្នកទទួលខុសត្រូវនៅមន្ទីរនោះ ។ គេបានឲ្យមិត្ត នារីម្នាក់មកពិនិត្យ រួចក៏ហុចថ្នាំមួយកញ្ចប់តូចមកខ្ញុំ ដោយបញ្ជាក់ថា " ថ្នាំនេះពូកែណាស់ សម្រាប់ជំងឺគ្រុនចាញ់ ហូបតែបីគ្រាប់ទៅមុខជាជាហើយ " ។ មែន! ដូចមិត្តនារីនោះថាមែន ខ្ញុំលេបអស់បីគ្រាប់លែងរងាញាក់ទៀត ហើយកំដៅក្នុងខ្លួនក៏ចុះមកធម្មតាវិញ ។ ពិតមែនតែខ្ញុំបានធូរស្បើយបន្តិច តែខ្ញុំនៅស្គម ដើរញ័រជង្គង់នៅឡើយ ។ ខ្ញុំអាចចុះទៅជួយធ្វើការងារ ខ្លះៗបានដែរ ដូចជាថែទាំដំណាំ បោចស្មៅ ជ្រួយដី ពូនគល់ ។ ល ។ មួយខែក្រោយមកខ្ញុំបានស្រួលបួលច្រើនហើយៗទៅសុំគេចូលរួម ធ្វើការងារនៅរោងបាយជ្រូក ដែលមានជ្រូកធំទង់ៗជាង ១០ ក្បាលប៉ុណ្ណោះ ។ អាកូនជ្រូកនេះវាប៉ិលប៉ូចណាស់ វាតែងលោតចេញពីទ្រុង រត់លេងពាសវាលពាសកាលក្នុងចំការដំណាំធ្វើឲ្យខ្ញុំនិងកុមារីម្នាក់ទៀត ដែលរួម ការងារជាមួយខ្ញុំរត់ដេញចាប់ហត់យ៉ាងខ្លាំង ។ កុមារីនោះអាយុប្រហែល ១១ ឬ ១២ ឆ្នាំ បានប្រាប់ខ្ញុំថា នាងទើបមកពីក្រុងប៉េកាំង (ប្រទេសចិន) ជាមួយឪពុកម្ដាយនាង ។ នាងធំដឹងក្ដីឡើងនៅស្រុកចិន អញ្ចឹងហើយភ្លេច ស្រុកខ្មែរអស់ហើយមិនដែលស្គាល់តាំងពីដើមចេកឡើងទៅ ។ ចំណែកឯឪពុក ម្ដាយនាងក៏នាងឥតដឹងថាពេលនោះគាត់នៅទីណាដែរ ។ នាងនៅក្នុងមន្ទីរ ប-២០ នេះ

បានប្រហែលមិនដល់មួយខែផង ក៏ត្រូវគេបញ្ជូនចេញទៅបាត់ ។ ខ្ញុំនៅបន្តមើលអាកូនជ្រូកតូចៗនោះតទៅទៀតជាមួយកុមារីម្នាក់ថ្មីផ្សេងទៀត។ យើងដើររកកាប់ត្រួយដំឡូង រើសមើមដំឡូងមី ដែលសល់ពីសត្វឈ្លូសស៊ី ចូលទៅចំការចេក រកផ្លែចេកដែលរលំដើម បាក់កញ្ជុះធ្លាក់ដល់ដីរើស ផ្លែល្ហុងទុំដែលសល់ពីសត្វស៊ី... ដើម្បីមកផ្សំជាមួយទឹកសម្លួ និងទឹកអង្ករសេល់ពីផ្ទះបាយ មកដាំជាមួយបន្លែ ធ្វើបាយឲ្យជ្រូក ។ យើងធ្វើបែបនេះជារៀងរាល់ថ្ងៃ ។ ខ្ញុំមិនសូវនឿយណាយនឹងការងារនេះទេ ខ្ញុំអាចដើរសេរី លួចហូបសេរីបាន ដូចជារើសបានល្ហុងទុំជ្រុះ ចេកទុំ យកមើមដំឡូងមួយដុំ ពីរដុំមកដុតនៅចង្ក្រានបាយជ្រូកបាន ។ មានពេលមួយ កុមារីម្នាក់នោះរត់ត្រហេបត្រហាបមកដល់រោងបាយជ្រូក ហើយលូកយកពងមាន់ពីក្នុងហោប៉ៅមួយដំបរទំលាក់ក្នុងខ្ទះបាយជ្រូកធ្វើឲ្យខ្ញុំភ័យភ្នែកក្រឡេបក្រឡាប់ខ្លាចគេឃើញ ។ ប៉ុន្តែកុមារីនិយាយថា គេឥតបានលួចពងមាន់នៅមន្ទីរនេះទេ គេរើសបាននៅក្នុងខ្ទមដែលគ្មានមនុស្សនៅ ឯចំការក្បែរព្រៃឯណោះ ។ គេស្ងោរពងមាន់ឆ្អិនហើយ គេហូបអស់ពីរ និងទុកឲ្យខ្ញុំពីរផងដែរ ដោយប្រាប់ខ្ញុំទៀតថា នៅមានសល់៥-៦ ពងទៀតក្នុងសំបុក ។ ខ្ញុំហូបតែមួយ ទុកមួយអោយ"ពូ" ។ មិនជាប៉ុន្មានថ្ងៃក្រោយមកកុមារីរូបនោះក៏បាត់ខ្លួនទៀត ។ ខ្ញុំក៏មិនដឹង ពីមូលហេតុ អ្វីឡើយ...។

នៅក្នុងមន្ទីរនោះ គេតែងប្រជុំជីវភាពរាល់ចុងសប្តាហ៍ ដែលមានមនុស្សជាង ១០ នាក់ចូលរួម ។ ខ្ញុំអត់ត្រូវបានគេហៅឲ្យទៅប្រជុំទេ ព្រោះតែជាខ្ញុំឈឺ ឯបងសយឥតបានទៅប្រជុំដែរ ព្រោះគេអត់ឲ្យទៅ ។ គេឲ្យតែកុមារតូចៗនិងមិត្តនារី មិត្តយុវជនចូលរួមប៉ុណ្ណោះ។ បងសយចាប់អារម្មណ៍ច្រើនចំពោះបញ្ហានោះ ។ ថ្ងៃមួយពេលជួបនឹង "មិត្តកាន់" ប្រធានមន្ទីរគាត់សួរអំពីសៀវភៅ "យុវកក" ដែលជាសៀវភៅរបស់អង្គការចេញបោះពុម្ពផ្សាយ សរសេរពីសភាពការណ៍នយោបាយស្រុកទេស ។ សៀវភៅនោះអង្គការតែងចែកឲ្យពួកកម្មាភិបាលអាន តែក្រោយមកបងសយពុំដែល

បានទទួលទៀតទេ ។ មិត្តកាន់និយាយថា អង្គការលែងបោះពុម្ពសៀវភៅនេះ ទៀតហើយ ។ លែងប៉ុន្មានថ្ងៃក្រោយមក បងសយឃើញមិត្តម្នាក់កំពុងអាន សៀវភៅនោះ ។ គឺនៅពេលនោះហើយ ដែលគាត់ដឹងខ្លួនច្បាស់ថា " គាត់ មានបញ្ហាអ្វីហើយ! " ។ អញ្ចឹងហើយបានជាប៉ុន្មានខែចុងក្រោយនេះ ខ្ញុំតែងឃើញបងសយមានទឹកមុខស្ងួត លែងស្រស់ស្រាយដូចកាលពេលជួបគ្នាដំបូងឡើយ ។ តែគាត់នៅតែរក្សាភាពនឹងនរដដែលដោយខំទូន្មានខ្ញុំ និងកូនៗ អោយខំធ្វើការៗ ។

និយាយអំពីកូនៗរបស់ខ្ញុំវិញ ខ្ញុំអាណិតពួកគេណាស់ ។ គេគោរពការណែនាំរបស់ឪពុកគេ ។ គេខំប្រឹងធ្វើការ ។ កូនប្រុសខ្ញុំ " សុខាវន្ត " មានរាងខ្ពស់ (ខ្ពស់ជាងឪពុករបស់គេទៅទៀត) ហើយនៅពេលចុះដឹកជញ្ជូនម្តងៗ គេត្រូវប្រើអស់កម្លាំងកាយ ដូចជាមានពេលមួយនោះ ខ្ញុំឃើញគេលីសសរមួយដើមវែង ដែលមានគ្នាបីនាក់ ។ សុខាវន្តលីនៅកណ្តាលសសរឯអ្នកលីនៅខាងមុខនិងខាងក្រោយមានកម្ពស់ទាបៗ ដូច្នេះហើយទម្ងន់ទាំងអស់ត្រូវសង្កត់លើសុខាវន្តខ្លាំងជាងគេ ។ ឯពីរនាក់ទៀត គ្រាន់តែជួយទប់ៗប៉ុណ្ណោះ ។ **សុខាវន្ត** កូនប្រុសខ្ញុំ ដែលស្ទើរតែលីសរសរមួយដើមធំតែម្នាក់ឯង លីឡើងញ័រក្បាល មុខឡើងក្រហម ដោយប្រឹងខ្លាំង ។ ចំណែកឯកូនស្រីៗវិញ ពេលត្រូវទៅដឹកជញ្ជូនម្តងៗ កូននេះត្រូវលីចេកទាំងស្ទងៗ (ចេកនៅដីក្រហម នេះមានស្ទងវែងហើយធ្ងន់ លើកម្នាក់ឯងពុំអាចរួចឡើយ) ដើម្បីជញ្ជូនដាក់ឡាន និងលីចេញពីឡាន ចុះច្រាំងទន្លេទៅដាក់កាណូត ដឹកចេញទៅទីក្រុង ។ កូនៗខ្ញុំទាំងអស់នោះ នៅពេលខ្លះក៏រអ៊ូខ្លះៗដែរថា "ហត់ចង់ងាប់ហើយ" ។ តែទោះជាយ៉ាងណាក៏ដោយក៏ពួកគេសប្បាយចិត្តដែរ ព្រោះបានទៅដឹកជញ្ជូន គឺបានទៅជួបនឹងមនុស្សម្នាជាពិសេសអាចជួបយាយតា ឬជួបបងប្អូនមកពីភ្នំពេញជាមួយគ្នា ហើយដែលគេស្រឡាញ់ ។ ម្តាយខ្ញុំបានដឹងថាពួកកូនខ្ញុំតែង ទៅដឹកជញ្ជូនឥវ៉ាន់ចុះផែ ក៏ស្ពាត់មកចាំជួប ។ កូនខ្ញុំឃើញយាយ និងបងប្អូនជីដូនមួយពីរនាក់

ដែរ ដែលនៅឈរក្បែរឡានដឹកចេក ។ គេមិនហ៊ានធ្វើស្គាល់ ។ ការនេះធ្វើឲ្យម្ដាយខ្ញុំឈឺចិត្តជាខ្លាំង គាត់ដើរទៅជិតមិត្តនារីៗ ហើយសួរបៀបបញ្ឈឺចិត្តឲ្យកូនខ្ញុំលឺថា "មិត្តៗ នៅបដិវត្តន៍ គេមិនឲ្យកូនចៅស្គាល់ យាយតាបងប្អូនទេឬអី?" កូនខ្ញុំឥតឆ្លើយធ្វើដូចជាឥតលឺ ដើម្បីទុកតួនាទីនេះឲ្យមិត្តនារីម្នាក់ទៀតឆ្លើយជួស ព្រោះខ្លាចគេលែងឲ្យមកដឹកជញ្ជូនទៀត ។ ក៏ប៉ុន្តែពេលនៅឆ្ងាយពីភ្នែកពួកមិត្តនារីទាំងអស់នោះ កូនខ្ញុំធ្វើសញ្ញាឲ្យប្អូនជីដូនមួយទៅជួប ដើម្បីលួចហុចកញ្ចប់ឥវ៉ាន់ដែលនាងបានត្រៀមទុក ក្នុងនោះមានស្ករស កាហ្វេ មានសាប៊ូ និង ថ្នាំខ្លះៗ ហើយព្រមទាំងសាកសួរសុខទុក្ខគ្នាទៅវិញទៅមកផងដែរ ។ ជួបបានតែម្ដងនោះឯង លើកក្រោយៗមកកូនខ្ញុំខំរកដែរ តែឥតបានជួបទៀតទេ ។ លឺគេថា អ្នកនៅមុំសាលារៀនត្រូវគេប្រមូលឲ្យទៅនៅជុំគ្នាឯសហករណ៍ព្រែកបារាំង ( ឆ្ងាយពីផែកាណូត ) បាត់អស់ហើយ។

**មខសយ** យល់ច្បាស់អំពីស្ថានភាពមិនល្អរបស់គ្រួសារយើង ពីព្រោះអ្នកតស៊ូក្នុងព្រៃទាំងអស់គ្នាដែលនៅក្នុងជួរក្រោយថ្ងៃជ័យជំនះ គេបានទៅចូលរួមរៀបចំស្រុកទេស ។ ដោយឡែកពួកយើង ត្រូវជាប់នៅក្នុងព្រៃដដែលដូចពាក្យដែលគេតែងឲ្យឈ្មោះថាជាមន្ទីរឃុំឃាំង ឬគុកឥតជញ្ជាំងអញ្ចឹង! ។ តែយើងត្រូវតែទ្រាំតទៅទៀត ដើម្បីជីវិតរស់។

ថ្ងៃរសៀលមួយក្នុងខែ ៧ នាឆ្នាំ ១៩៧៦ មិត្តកាន់ បានមកជួបនិយាយគ្នាជាមួយប្ដីខ្ញុំមួយភ្លែត រួចក៏ដើរចេញទៅវិញភ្លាម ។ ប្ដីខ្ញុំដើរយ៉ាងលឿនមករកខ្ញុំ ហើយប្រាប់ខ្ញុំថា "យើងត្រូវចេញដំណើរទៅឥឡូវនេះហើយរៀបចំឥវ៉ាន់ភ្លាមទៅ " ។ ខ្ញុំបានសួរអំពីទីដៅដែលយើងត្រូវទៅ តែប្ដីខ្ញុំនិយាយថា ខ្លួនគាត់ក៏អត់បានដឹងដែរ ព្រោះនេះជាទម្លាប់របស់អង្គការគឺ " ឥតសួរ ឥតតវ៉ា " ។ ខ្ញុំក៏បន្តសួរទៀតថា " ចុះកូនៗយ៉ាងម៉េចដែរ? " ។ គាត់ឆ្លើយថា អង្គការឲ្យយើងទៅតែពីនាក់ទេ ។ ដូច្នេះយើងក៏បានសុំគេជួបនឹងកូនៗទាំងអស់ ដើម្បីផ្ដាំផ្ញើពាក្យសំដីខ្លះៗ ។ បងសយផ្ដើមនិយាយ

ថា " ពូ–មឹង បែកពីមិត្តៗទាំងអស់គ្នាមួយរយៈ សុំមិត្តខិតខំធ្វើការងារបំរើអង្គការណាមិត្ត! " ។ គេទាំងអស់គ្នាឈរឥតកំរើកដងខ្លួន គ្រាន់តែងាក់ក្បាល សម្លឹងមើលម៉ែឪដោយក្រសែភ្នែកទន់ ( បែបចង់រលីងរលោងទឹកភ្នែក តែគេឥតយំទេ ) ។ ប្រហែលជាគេធ្លាប់បានទទួលការអប់រំតាមរយៈមិត្តនារីខ្លះៗទៀត អស់រយៈពេលជាងមួយឆ្នាំមកហើយ ធ្វើឲ្យគេមានទឹកចិត្តម៉ឺងម៉ាត់ចិត្តដាច់ ហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីបដិវត្តន៍ហើយមើលទៅ! ។ ដោយឡែកខ្ញុំវិញ ខ្ញុំមិនដាច់ចិត្តទេ ទោះបីជាខ្ញុំខ្លាចគេឃើញយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនអាចឃាត់ដំណក់ទឹកភ្នែករបស់ខ្ញុំ មិនឲ្យហូរចុះបានដែរ ។ ខ្ញុំគិតសព្វគិតគ្រប់ គិតថាកូនៗរបស់ខ្ញុំនៅក្មេងយ៉ាងនេះ ហើយត្រូវបែកពីឪពុកម្តាយ តើមានការលំបាកយ៉ាងណាទៅ ។ ខ្ញុំពិតជាសង្វេតណាស់ ។ ឡាន "កំម៉ង់កា "ដឹកយើងពីរនាក់ ព្រមទាំងមិត្តម្នាក់ទៀត"មិត្តផា" ដែលត្រូវរួមដំណើរចេញពី ប–២០ ទៅស្រុកកំណើតរបស់គាត់នៅខេត្តព្រះវិហារ ។ ឡានបរចេញពីចំការកៅស៊ូ បត់ទៅទិសខាងកើតធ្វើឲ្យខ្ញុំអរព្រើត ព្រោះដឹងថាជាដំណើរទៅស្រុកស្ទឹងត្រង់ហើយ ។ មែនយើងទៅដល់កំពង់ផែ នៅភូមិលើ ( ភូមិលើសំដៅទៅភូមិដែលស្ថិតនៅខាងលើនៃចរន្តទឹកទន្លេមេគង្គ ឯភូមិក្រោមគឺភូមិនៅចរន្តទឹកខាងក្រោម ) ។ ក្រោយស្រស់ស្រូបបាយល្ងាច ហើយខ្ញុំ និងបងសយបានសុំគេទៅជួបពុកម៉ែខ្ញុំមួយភ្លែត។ គេបដិសេធព្រោះ គ្មានបញ្ជាអនុញ្ញាត ។ ខ្ញុំចង់ស្ទះ ខ្ញុំដកដង្ហើមធំ ព្រោះហួសចិត្ត ។ **បងសយ** ប្រហែលជាមានអារម្មណ៍ដូចខ្ញុំដែរ ។ គាត់ចុះតាមផណ្តើរទៅណាបាត់ភ្លាមតែម្តង ហើយប្រហែល១៥នាទីក្រោយមក ទើបឃើញគាត់ត្រឡប់មកវិញ រួចនិយាយថា "តស់ទៅ! គេព្រមឲ្យទៅហើយ គេឲ្យមិត្តផាទៅជាមួយ យើងផងដែរ " ។ ខ្ញុំស្ទុះទៅទាញបាឡូប្រុងយករបស់ខ្លះៗទៅជូនម៉ែឪខ្ញុំ (នេះជាទម្លាប់របស់កូនខ្មែរ)។ តែខ្ញុំភ្លេចគិតថាក្នុងបាឡូនោះឥតមានអ្វីក្រៅពីសំពត់អាវខ្មៅៗ និងរបស់កំប៉ិចកំប៉ុកដែលខ្ញុំតែងប្រើនៅដីក្រហមសោះ ។ ខ្ញុំឈប់គិតអ្វីតទៅទៀត ព្រោះខ្លាចក្រែង

មានសភាពការណ៍ប្រែប្រួល ។ ខ្ញុំស្ទុះរឹងទៅតាមប្ដីខ្ញុំ ដែលរង់ចាំនៅមុខផ្ទះសំណាក់ជាមួយមិត្តផា ។ យប់ម៉ោងជិត ១០ ទៅហើយ ផ្ទះរបស់ខ្ញុំបិទទ្វារឃើញតែពន្លឺចង្កៀនប្រេងកាតព្រឹមៗធ្លុះចេញពីស្លាបព្រិលបង្អួច ។ ខ្ញុំគោះទ្វារ ស្រែកហៅ "ប៉ាៗអ្នកៗ ! បើកទ្វារ " ។ ឪពុកម្ដាយខ្ញុំស្ទុះចេញមក ហើយទាញដៃខ្ញុំឲ្យចូលក្នុងផ្ទះ ហើយបងស្រីខ្ញុំក៏ស្ទុះចេញមកដែរ ។ ខ្ញុំឈរស្រឡាំងកាំងមើលគាត់ ឃើញខ្នង ដៃស្ដាំរបស់បងស្រីខ្ញុំហើមប៉ោង ម្រាមដៃលាក្រញ៉ាង ។ " យីស! បងធំ កើតអីនឹង ? " ខ្ញុំសួរ ។ ឪពុកខ្ញុំនិយាយកាត់ " មកអង្គុយ សិនទៅសយ និងអាហ៊ុច " ។ ម្ដាយខ្ញុំអធិប្បាយរៀបរាប់ថា បងស្រីខ្ញុំទៅជួយផាត់អង្ករ នៅពេលគេជាន់ត្លៀងផាត់មិនទាន់អង្រែត្លៀងបុកចំខ្នងដៃ អញ្ចឹងទៅ (ត្លៀងជាឧបករណ៍សម្រាប់បុកអង្ករសម្រួបដើម្បីឲ្យទៅជាអង្ករសម្រិត ហើយត្រូវមានមនុស្សនៅជាន់ដងត្លៀងដើម្បីឲ្យអង្រែធ្លាក់មកបុកលើអង្ករ ហើយក៏ត្រូវមានមនុស្សនៅចាំកៀសអង្ករដើម្បីបុកឲ្យបានសព្វ ) ។ ទន្ទឹមនឹងនេះ ម្ដាយ ខ្ញុំបានបង្ហាញអំពីការព្រួយបារម្ភរបស់គាត់មួយទៀត គឺប្អូនប្រុសធំរបស់ខ្ញុំ ឈ្មោះ **សុផល** ត្រូវបានគេយកទៅឲ្យរៀនសូត្រ អស់ប្រាំមួយថ្ងៃទៅហើយ ពុំទាន់ឃើញត្រឡប់មកវិញនៅឡើយ ។ ខ្ញុំនិយាយលួងលោមគាត់ ព្រោះ ខ្ញុំឥតដឹងថាពាក្យ " ទៅរៀនសូត្រ " នេះមានន័យផ្សេងទេ ។ យើងមិនទាន់ បាននិយាយដល់រឿងប្អូនៗនិងក្មួយៗ ដែលចុះទៅធ្វើការនៅភូមិដំទៃឆ្ងាយពីផ្ទះផង ស្រាប់តែមិត្តផាដែលអង្គុយរង់ចាំនៅមាត់ទ្វារខាងក្រៅអើតមកតឿនថា " យើងត្រូវប្រញាប់ត្រឡប់ទៅវិញ ព្រោះស្អែកត្រូវចេញដំណើរ តាំងពីព្រលឹម " ។ ខ្ញុំចង់ធ្វើសំណូមពរសុំពន្យារពេលបន្តិចទៀតដែរ តែនឹកឃើញពាក្យ " ឥតសួរឥតតវ៉ា " ក៏ព្រមត្រឡប់ទៅវិញ ទាំងមិនអស់ចិត្តនៅឡើយ និងក្ដុកក្ដួលយ៉ាងខ្លាំង ។ បងសយខំរករឿងផ្សេងៗមកនិយាយ ដើម្បីបន្លប់ខ្ញុំ តែខ្ញុំពុំអាចរំងាប់អារម្មណ៍ក្នុងគ្រាបែកចេញពីក្រុមគ្រួសារដែលកំពុងមានវិបត្តិធ្ងន់ធ្ងរនេះបានឡើយ ។ យប់នោះខ្ញុំគេងរសាប់រសល់ ហើយរឿងដែលខ្ញុំបានឃើញ និង

លើនៅថ្ងៃនោះ ធ្វើឲ្យខ្ញុំពុំអាចបំភ្លេចបានជារៀងរហូតមក ។

ស្អែកឡើង កាណូតផ្ទុកផលិតផលចេញពីដីក្រហម ដឹកយើងទាំងពីរនាក់ និងមិត្តផា មកដល់កំពង់ផែនៅមុខភាំង ប្រហែលជាម៉ោង៨កន្លះយប់។ គេឲ្យយើងហូបបាយ និងសម្រាកនៅក្នុងវិឡាមួយកាច់ជ្រុងខាងជើងភាំង ។ ភ្លឺឡើង... តាំងពីព្រហាម មិត្តម្នាក់មកជួបនឹងប្ដីខ្ញុំ ហើយប្រាប់ឲ្យខ្ញុំរៀបចំបន្តដំណើរទៅខេត្តព្រះវិហារជាមួយមិត្តផា ។ ខ្ញុំសួរបងសយថា "ពូឯងទៅទេ? " គាត់គ្រវីក្បាល ។ ខ្ញុំទ្រហោយំ ទឹកភ្នែកទឹកសម្បោរហូរតគ្រូកៗ ។ បងសយនិយាយមកកាន់ខ្ញុំលឺខ្សាវថា " មីឯឯងយកអ្វីខ្លះៗ ទៅជាមួយទៀតទៅ មានថ្នាំនៅក្នុងបាឡខ្ញុំ ។ យើងត្រូវបែកគ្នាហើយ ដូច្នេះយើងចែកឥវ៉ាន់កំប៉ិកកំប៉ុកនោះទុកប្រើរៀងៗខ្លួនទៅ " ។ បងសយដើរចេញពីបន្ទប់ដោយទឹកមុខស្រងូតស្រងាត់ខ្លាំង ដែលខ្ញុំពុំធ្លាប់បានឃើញកន្លងមក ។ បន្ទាប់ មកគាត់ទៅសុំគេនិយាយតអូជាមួយថ្នាក់លើ សុំទុកខ្ញុំឲ្យនៅជាមួយគ្នាតទៅទៀត ។ គាត់និយាយជាមួយគេមួយសន្ទុះធំ ក្រោយមកគាត់ត្រឡប់មកវិញ ប្រាប់ខ្ញុំថាឥឡូវអង្គការយល់ព្រមឲ្យខ្ញុំនៅវិញហើយ...។ ហ៊ឺស! ទំរាំបានដឹងថាគេលែងបញ្ជូនខ្ញុំទៅខេត្តព្រះវិហារ ខ្ញុំត្រូវបាត់ទឹកភ្នែកអស់រាប់រយតំណក់ និងជាពិសេសវាធ្វើឲ្យបេះដូងខ្ញុំដើរខុសសង្វាក់អស់ពេលជិតមួយម៉ោង ។ ពេលនោះខ្ញុំអាចយល់ហើយថាហេតុអ្វីក៏គេឲ្យមិត្ត ផា ធ្វើដំណើរមកជាមួយពួកយើង ? នេះពិតជាគម្រោងការរបស់គេដែលចង់បញ្ជូនខ្ញុំទៅលត់ដំនៅព្រះវិហារ ពីព្រោះខ្ញុំពុំមែនជាអ្នកបដិវត្ត ពុំដែលទទួលការអប់រំអំពីលទ្ធិសង្គមនិយមអ្វីទាំងអស់ ពោលគឺខ្ញុំជាមនុស្ស ១៧ មេសា ពុំអាចចូលក្នុងជួរអ្នកបដិវត្តបានឡើយ ។ គិតទៅនៅក្នុងរបបនេះ គេបែងចែកមនុស្សជាជាន់ជាថ្នាក់ ទៅតាមមនោគមវិជ្ជា ដោយឥតគិតអំពីបញ្ហាមនុស្សធម៌អ្វីឡើយ ។

គេបញ្ជូនយើងពីមន្ទីរមួយ ទៅមន្ទីរមួយ នៃអង្គភាពក្រសួងឃោសនាអប់រំ ។ ដំបូងគេឲ្យយើងធ្វើការនៅក្នុងរោងពុម្ព " ក-២៦ " (ខាងជើង ស្ពាន)

ជួយផ្ទៀងផ្ទាត់អក្សរ និងទំព័រកាសែត ។ បន្ទាប់មកផ្លាស់ទៅមន្ទីរ ក-៣០ ដើម្បីរៀបចំតែងសៀវភៅអក្សរនិងសៀវភៅលេខ សម្រាប់ថ្នាក់ដំបូង ពីព្រោះគេយល់ថា ខ្ញុំពុំអាចសរសេរអត្ថបទកាសែតកើតទេ ដោយសារភាសាសរសេររបស់ខ្ញុំ មិនមានលក្ខណៈបដិវត្តផ្ទិនផ្ទៅ ។ យើងនៅមន្ទីរ ក-៣០ ធ្វើការជាមួយ " **មិត្តតាល់** " ( **សេខ ម៉ុនថន** ដែលជាប្រធានសិក្សានៅមហាវិទ្យាល័យគរុកោសល្យក្នុងសម័យមុន ) ។ យើងធ្វើការជាមួយគ្នាបានមួយរយៈដែរ ហើយក្រោយមកបងតាល់ និងបង**សយ** ត្រូវបានគេដកចេញ ។ បងសយត្រូវគេបញ្ជូនទៅនៅមន្ទីរ ក-២៩ ដែលស្ថិតនៅក្នុងអង្គភាពឃោសនាអប់រំ ដែលមានទីតាំងនៅក្នុងសកលវិទ្យាល័យភ្នំពេញ។ ចំណែកឯបង **តាល់** វិញ ត្រូវបានអង្គការដកឲ្យទៅមន្ទីរ ក-២៥ ដែលជាមន្ទីរកណ្ដាល របស់ អង្គភាព ។ ក្រោយមកបងតាល់រួមទាំងមិត្តចៀវ ( **ឡុច សឿន** ) លោក សាស្ត្រាចារ្យ **ម៉ែន ម៉ានិល, ឡៅ មាន , ម៉េត ឡូ...** ត្រូវបានប្រធានមន្ទីរ ក-២៥ ហៅមកប្រជុំ ដោយនិយាយថា អង្គការឲ្យមិត្តទាំងអស់នោះ ទៅធ្វើការនៅស្ថានទូតនៃប្រទេសសង្គមនិយម ដើម្បីជួយបង្រៀនភាសាខ្មែរ ដល់អ្នកធ្វើការនៅទីនោះ និងដើម្បីត្រៀមខ្លួនទៅធ្វើជាទូតប្រចាំនៅប្រទេសទាំងនោះ ក្នុងពេលអនាគតផងដែរ ។ ដោយឡែកចំពោះខ្លួនខ្ញុំ អង្គការឲ្យនៅបន្តធ្វើសៀវភៅភូមិសាស្ត្រមួយតទៅទៀត ព្រោះគេយល់ថាខ្ញុំជាសាស្ត្រាចារ្យ ផ្នែកភូមិសាស្ត្រនេះស្រាប់ ។ ដំបូងខ្ញុំហាក់ដូចជាអន់ចិត្ត ព្រោះច្រណែននឹងមិត្ត ទាំងនោះដែរ ក៏ប៉ុន្តែខ្ញុំគិតថាបើអង្គការឲ្យខ្ញុំទៅ គឺខ្ញុំត្រូវបែកពីប្ដីខ្ញុំទៀតហើយ ។ ដូច្នេះការដែលមិនចាត់តាំងឲ្យខ្ញុំចេញទៅណានោះ ក៏វាជារឿងមួយល្អសម្រាប់រូបខ្ញុំដែរ ។

មួយអាទិត្យក្រោយមក គេធ្វើមិទិញមួយដើម្បីថ្កោលទោសអ្នកដែលគេដកប៉ុន្មាននាក់ខាងលើ ដោយចោទថា ខ្លះជាពួក " សេអ៊ីអា " ខ្លះជាពួក "កាហ្សេប៉េ " និងខ្លះទៀតជាពួក " ខ្មែរយួនខាងជើង " ដែលបង្កប់ខ្លួន...។ ក្រោយមិទិញ (មកពីពាក្យអង់គ្លេស meeting ប្រែថាប្រជុំ) នោះ ខ្ញុំនិង

បងសយ លបផដែកគ្នា ព្រោះគិតថា ការចោទប្រកាន់នេះពិតជាមិនត្រឹមត្រូវទេ ពីព្រោះអ្នកទាំងអស់នោះ តែងខំប្រឹងធ្វើការបម្រើបដិវត្តន៍ យ៉ាងខ្លាំងមិនសមចាពួកគេក្បត់បដិវត្តន៍ទេ ។ ពេលនោះបងសយបាននិយាយបន្ថែមថា "ថ្ងៃនេះគេចោទពួកនោះថាក្បត់ ប្រហែលជាថ្ងៃក្រោយនឹងដល់វេនពួកយើងផងដែរក៏មិនដឹង..." ។ ចាប់ពីពេលនោះមក ខ្ញុំសង្កេតឃើញបងសយមានអាកប្បកិរិយាប្លែកៗ ដែលបញ្ជាក់ពីភាពអស់សង្ឃឹមរបស់គាត់ ហើយជារឿយៗគាត់តែងពោលថា ""ណេ្ហីយ! ជីវិតនេះ ទុកដូចជាឆាចោលទៅចុះ !" ។

ខ្ញុំត្រូវបន្តការងារតែងនិពន្ធសៀវភៅតទៅទៀត ដោយមានមិត្តផ្សេងៗទៀតមកចូលរួម ដូចជា មិត្តតូច មិត្តសៅ ដែលខ្ញុំស្គាល់តែឈ្មោះបដិវត្តន៍របស់គេប៉ុណ្ណោះ ។ ពួកគេនេះបានឲ្យខ្ញុំដឹងថា គេជាអតីតគ្រូបង្រៀនដែរនៅក្នុងសង្គមចាស់ ។ សូមបញ្ជាក់ថា គេឲ្យមិត្តពីរនាក់នេះមកជួយធ្វើការជាបណ្ដោះអាសន្នប៉ុណ្ណោះ ព្រោះគេទាំងពីរមានតួនាទីជាប្រធានមន្ទីរនៅកន្លែងផ្សេងទៅហើយ ។

សៀវភៅអក្សរ និងសៀវភៅលេខ បានតែងនិពន្ធចប់ហើយ ។ យើងផ្ដើមតែងសៀវភៅភូមិសាស្ត្រមួយទៀត ។ ធ្វើបានតែមួយរយៈប៉ុណ្ណោះ គេឲ្យមិត្តទាំងពីរវិលទៅធ្វើការនៅមន្ទីរគេវិញ ។ ចំណែកខ្ញុំ គេប្ដូរឲ្យទៅនៅមន្ទីរ ក-២៩ ជាមួយបងសយវិញ ។ ក-២៩ ជាមន្ទីរផ្ដល់ភស្តុភារ និងស្រាវជ្រាវរបស់ក្រសួងឃោសនាការ និងអប់រំទាំងមូល ។ នៅទីនោះមានបញ្ញាវន្តមួយចំនួនធំដូចជាមិត្តមាន មិត្តនារីហ៊ីន មិត្តរ៉ា មិត្តម៉ុ... ដែលសុទ្ធតែជាអ្នកមានជំនាញបច្ចេកទេសផ្សេងៗ ។ ក្រុមនេះមានគំនិតខាងច្នៃផលិតផលសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ដែលអាចផលិតបាននៅក្នុងស្រុកដូចជា ធ្វើសាប៊ូ ថ្នាំដុសធ្មេញ ឆ្លាក់ពុម្ពអក្សរ និង រៀបចំលាយទឹកខ្មៅសម្រាប់រោងពុម្ពជាដើម។ ម្យ៉ាងទៀត ដោយទីតាំងនៃមន្ទីរនេះមានផ្ទៃដីធំ គេបង្កើត

ក្រុមដាំបន្លែបង្ការសម្រាប់ឧបត្ថម្ភអង្គភាព។ ចំពោះខ្ញុំដែលទើបចូលទៅនៅទីនោះ នៅតែបន្តការងារនិពន្ធដដែល ពីព្រោះតែងសៀវភៅភូមិសាស្ត្រមិនទាន់ចប់ ។ យើងមានមិត្តនារី ៩ មកជួយក្នុងការនិពន្ធ និងមានមិត្តម្នាក់ដែលនៅមន្ទីរផ្សេងធ្លាប់ធ្វើការនៅផ្នែកភូមិបាល ក៏បានមកជួយផ្តល់យោបល់ក្នុងការសរសេរសៀវភៅនេះផងដែរ។ មិនទាន់ចប់ផងអង្គការបានលើកគម្រោង បើកវគ្គបណ្តុះបណ្តាលគ្រូថែមទៀត ។ ខ្ញុំរៀបចំសៀវភៅភូមិសាស្ត្រចប់ហើយ។ ខ្ញុំបានឲ្យមិត្តជំនួយការពិនិត្យ។ គេទទួលយកហើយប្រាប់ខ្ញុំវិញថាមិនថ្វីទេគាត់នឹងប្រគល់ពង្រាងឯកសារនិពន្ធនោះទៅជូនអង្គការតែម្តង។ តាំងពីពេលនោះមក ក៏ដូចជាពេលមុនៗដែរ សៀវភៅទាំងពីរក្បាលរួមទាំងសៀវភៅ មួយក្បាលចុងក្រោយនេះដែលក្រុមខ្ញុំបានតាក់តែងនិពន្ធហើយៗផ្ញើទៅថ្នាក់លើ ឥតដែលឃើញត្រឡប់មកម្ចាស់ដើមវិញឬក៏ឲ្យដឹងថាសៀវភៅទាំងនោះបានមើល បានកែ បានបោះពុម្ពដែរឬក៏... ស្ងាត់ឈឹងតែម្តង(មកដល់សម័យកម្ពុជា ប្រជាមានិតទើបខ្ញុំបានដឹងខ្លះៗអំពីស្នាដៃទាំងនោះតាម រយៈជនជាតិបារាំងម្នាក់ ឈ្មោះ **មាន់ រី** ដែលបានមកជួបខ្ញុំដោយយកសៀវភៅ " យើងរៀនអក្សរ " និង " យើងរៀនលេខ "មកសួរនាំរកអ្នកនិពន្ធ)។ ក៏ប៉ុន្តែសៀវភៅទាំងពីរក្បាលនោះពុំមែនជាសៀវភៅដើមទេ គឺថតចម្លងហើយបាត់សន្លឹកខ្លះៗ ។ រីឯទម្រង់មេរៀនគឺនៅដដែលតែពាក្យពេចន៍មួយចំនួនបានកែ ឬ ថែម ដោយប្រើពាក្យបដិវត្តន៍ខ្លាំងៗដូចជាថា "ក្តៅគគុក ដាច់ខាត ប្តូរផ្តាច់... មហាអស្ចារ្យ "។ល។

ការតែងសៀវភៅសម្រាប់បឋមសិក្សាបានចប់ហើយ ប្រធានមន្ទីរ "ក-២៩" បានហៅក្រុមស្រាវជ្រាវនិងពួកខ្ញុំមកប្រាប់ អំពីទិសដៅរបស់អង្គការ :

១. ត្រូវបន្តរៀបចំកម្មវិធីសម្រាប់កំរិតថ្នាក់មធ្យមសិក្សា (ថ្នាក់អនុវិទ្យាល័យ ) ក្នុងនោះមានឈ្មោះបួននាក់ គឺប្តីខ្ញុំ មិត្តរ៉ា និងពីរនាក់ ទៀត ( ខ្ញុំមិនចាំឈ្មោះប្រាកដ )។

២. ត្រូវរៀបចំបណ្តុះបណ្តាលគ្រូបដិវត្តន៍ ដែលជ្រើសរើសចេញពីប្រជាជននៅតាមមូលដ្ឋាន ( ជាយុវជន និងយុវនារីបដិវត្តន៍ ) ។ ក្នុងមួយវគ្គៗ គេអាចទទួលសិស្សចំនួន ៥០០ នាក់មករៀនក្នុងរយៈពេលបីខែ ។

អង្គការបានឲ្យខ្ញុំជាអ្នករៀបចំកម្មវិធីបង្រៀន ជាមួយមិត្តនារីម្នាក់ទៀតគឺ " មិត្តផង " ប្រពន្ធរបស់សាស្ត្រាចារ្យ **ជែក សាគន្ធ** និងពីរនាក់ទៀតដែលជាមិត្តនារីក្នុងជួរបដិវត្តន៍ ឲ្យរៀបចំកន្លែងស្នាក់នៅ ដូចជាគ្រែ កន្ទេល មុង ខ្នើយជាដើម ។ ខ្ញុំសប្បាយចិត្តបន្តិចដែរ ព្រោះយល់ថា ជាទិសដៅល្អ ហើយកម្មវិធីនេះវាត្រូវនឹងជំនាញរបស់ខ្ញុំស្រាប់ ។ គេបានប្រាប់ទៀតថា គម្រោងការណ៍នេះ នឹងត្រូវចាប់ផ្តើមនៅដើមឆ្នាំ ១៩៧៨ ។ ក៏ប៉ុន្តែទិសដៅនេះឥតទាន់បានអនុវត្តនៅឡើយ គឺបានត្រឹមតែគ្រោងប៉ុណ្ណោះ ។ មិត្តនារីដែលនៅក្នុងក្រុមរបស់ខ្ញុំបាននិយាយប្រាប់ថា អង្គការរវល់ខ្លាំងណាស់ក្នុងការការពារព្រំដែន ។ គេថាកងទ័ពបច្ចាមិត្ត ( ទ័ពវៀតណាម ) បានចូលមកជ្រៅក្នុងដីខ្មែរទាំងកងពលៗ។ កងទ័ពមជ្ឈិមត្រូវកែនកម្លាំងបន្ថែម ដើម្បីបញ្ជូនទៅទប់ទល់ ដែលជាហេតុនាំឲ្យគម្រោងការនោះចេះតែពន្យារម្តងហើយម្តងទៀត ។

ក្រោយពីពេលនោះបន្តិចមក ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅនៅ មន្ទីរ ក-៣១វិញ ។ ខ្ញុំ និងបងសយត្រូវរស់នៅបែកគ្នាទៀតហើយ ប៉ុន្តែគេឲ្យយើងបានជួបគ្នាក្នុង ១០ ថ្ងៃម្តងដែរ ។ មន្ទីរ ក-៣១ គឺជាសាលារៀន " សាលាកុមារបដិវត្តន៍ " ( ទីតាំងមុខស្ថានទូតចិន ) សម្រាប់កុមារតូចៗ ដែលឪពុកម្តាយរបស់គេ ខ្លះជាកម្មាភិបាលក្នុងជួរ ខ្លះជាកម្មករនៅក្នុងសម័យសង្គមចាស់ ដែលអង្គការប្រមូលឲ្យមកភ្នំពេញ ដើម្បីជួយការងារតាមជំនាញនៅអង្គភាពអគ្គីសនី, អង្គភាពរោងចក្រទឹក, និងអង្គភាពផ្លូវដែក ។ បន្ទាប់មកគេបំបែកពួកកុមារៗទាំងនោះជាពីរក្រុម ។ ក្រុមទីមួយគឺកុមារតូចៗ ដែលទើបចាប់រៀនថ្នាក់ដំបូងឲ្យនៅក្នុងសាលាកុមារបដិវត្តន៍ និងមួយក្រុមទៀត

គឺកុមារធំៗ ដែលមានការចេះដឹងបង្គួរឲ្យចូលថ្នាក់ទីពីរនៅសាលាថ្មីមួយទៀត ដែលគេទើបបង្កើតនៅក្នុងបរិវេណសាលា "ចៅពញាហុក" ។ គឺនៅសាលាក្រោយនេះហើយដែលគេតែងនាំភ្ញៀវបរទេសមកធ្វើទស្សនៈកិច្ច ដើម្បីបង្ហាញអំពីដំណើរការនៃក្រសួងសិក្សាអប់រំ ។ ខ្ញុំនៅជួយបង្រៀនពួកគ្រូៗ ដែលបង្រៀនកុមារនៅសាលាទាំងពីរនោះ។ ខ្ញុំនៅមន្ទីរ ក-៣១ រហូតមក ។

នៅខែ ១០ ឆ្នាំ ១៩៧៨ ដែលកាលណោះខ្ញុំទៅលេងបងសយនៅមន្ទីរ ក-២៩ ស្រាប់តែឃើញមានឡាំព្រីតាមួយ មកចុះចតនៅមុខសាលាគរុកោសល្យជាន់ខ្ពស់ ផ្លូវសហព័ន្ធរុស្ស៊ី (បច្ចុប្បន្នជាសាលាភាសាបរទេស) ។ ពេលនោះស្រាប់តែខ្ញុំឃើញកូនទាំងអស់របស់ខ្ញុំ លោតចេញពីឡាំប្រ៊ីតា ។ បងសយស្រែកទាំងត្រេកអរថា "កូនយើងមកដល់ហើយ"។ យើងសប្បាយរីករាយរកអ្វីប្រៀបពុំបាន ព្រោះការខ្វល់ខ្វាយរបស់យើង ដែលតែងតែគិតដល់ពួកគេជារៀងរាល់ថ្ងៃ ព្រោះឥតដឹងសុខទុក្ខយ៉ាងណា នៅឯចំការកៅស៊ូនោះ បានរសាត់បាត់អស់ហើយក្នុងពេលនោះ។ យើងបាននៅជួបជុំគ្នាទាំងឪពុកម្តាយ និងកូនទាំងអស់របស់យើង ។ បានតែ ២-៣ ថ្ងៃប៉ុណ្ណោះ គេក៏បានបញ្ជូនកូនទាំងអស់នោះ ទៅកាន់មន្ទីរផ្សេងៗនៃអង្គភាព ដូចជា មិត្តវ័ន្ត (កូនប្រុសធំ) ទៅនៅមន្ទីរឃោសនាការ មិត្ត **សិទ្ធ** (កូនស្រីទី១) ទៅនៅមន្ទីរក-២៥ ដែល ជាមន្ទីរកណ្តាល មិត្ត **ដា** និង មិត្ត **ឡុំ** (កូនស្រីទី ២ និងទី៣) ទៅសាលាកុមារបដិវត្តន៍ ក-៣១ នៅជាមួយខ្ញុំ ដើម្បីរៀនធ្វើគ្រូ ព្រោះនាងបានរៀន ដល់អនុវិទ្យាល័យហើយ ក្នុងសម័យសាធារណរដ្ឋ ។ មិត្ត **ពិន** (កូនស្រីទី ៤) ឲ្យទៅនៅមន្ទីរក-២៧ ដែលជារោងពុម្ព និងកូនស្រីពៅ ទៅមន្ទីរកុមារដដែល ។ តាំងពីពេលដែលគេបញ្ជូនពួកកូនៗ ទៅមន្ទីរផ្សេងៗនោះមក ខ្ញុំមិនដែលបានជួបកូនណាមួយទាល់តែសោះ ក្រៅពីមិត្តដា មិត្តឡុំ និងកុមារលឿន ដែលគេអនុញ្ញាតឲ្យមកជួប ១-ម៉ោង នៅរាល់ ១០ ថ្ងៃម្តង ។

ខ្ញុំនៅមន្ទីរក-៣១ រហូតដល់ថ្ងៃដែលកងទ័ពវៀតណាម ចូលមកដល់ក្រុងភ្នំពេញតែម្តង។ ក៏ប៉ុន្តែប៉ុន្មានអាទិត្យមុននេះ (ប្រហែលពាក់កណ្តាលខែ១២) ខ្ញុំឃើញមានសភាពការណ៍មិនល្អ ។ មានឡានតូចធំបើកចេញចូលស្ថានទូតចិន ឥតសម្រាកទាំងថ្ងៃទាំងយប់ រហូតដល់ថ្ងៃចូលឆ្នាំសកល ១៩៧៩ ទើបស្ថានទូតចិនបានបិទទ្វារស្ងាត់ឈឹង ។ នៅពេលនោះដែរ ខ្ញុំបានតាមដានពិនិត្យស្ថានភាពនៅក្រៅសាលា ឃើញថានៅតាមផ្លូវម៉ៅសេទុង មានមនុស្សដើរកាត់ មុខសាលាជាហូរហែខុសប្លែកពីធម្មតា ។ ចលនាប្លែកៗនេះបានធ្វើឲ្យមានសកម្មភាពប្រែប្រួលនៅក្នុងមន្ទីរក-៣១ដែរ គឺរាល់យប់ មិត្តប៉ុន ដែលជាប្រធានមន្ទីរបានលើកអង្គប្រជុំ ។ ខ្លឹមសារសំខាន់គឺ " អង្គការរឹងមាំណាស់-ប្រយ័ត្នចាញ់កលខ្មាំង - ជនណានិយាយផ្តេសផ្តាសគឺ ខ្មាំង..." ។ មានអី ? ព្រឹកថ្ងៃ ៧ មករា ពួកខ្ញុំដែលបានធ្វើត្រីប្រហុក អស់ពេញមួយយប់ទៅហើយទើបចូលសម្រាកបានបន្តិច ក៏ត្រូវគេមកដាស់ឲ្យរៀបចំឥវ៉ាន់ដើម្បីធ្វើដំណើរ។ ខ្ញុំចង់ដឹងនិងចង់សួរគេដែរ ថាតើយើងត្រូវធ្វើដំណើរទៅណា? ហើយហេតុអ្វី?។ ក៏ប៉ុន្តែខ្ញុំឥតហ៊ានសួរគេទេ សុខចិត្តនៅស្ងៀម ធ្វើតាមអ្វីដែលគេប្រាប់ ។ មិត្តប៉ុននិយាយបន្តទៀតថា " " ឆាប់ៗ ប្រយ័ត្នយួនចូលមកបាញ់សម្លាប់ " ។ ឡាំព្រឹតាបញ្ឆេះចាំនៅក្រោមដើមស្រល់ មាត់ច្រកចូលសាលាកុមារបដិវត្តន៍ ។ គេឲ្យខ្ញុំកុមារតូចៗ និងមិត្តនារីដែលមានកូននៅមន្ទីរកុមារ ក-៣០ ទៅមុន ឆ្ពោះទៅស្ថានីយរថភ្លើង ។ នៅទីនោះមានទូរទេះភ្លើង ២-៣ មានមនុស្ស ជិះពេញ ។ ក្បាលរទេះភ្លើងក៏បញ្ឆេះ ចោលដែរ តែឥតចេញដំណើរទេ ។ មីងៗនៅមន្ទីរ ក-៣០ បាននាំកុមារៗ មកចាំនៅទីនោះ ដើម្បីប្រគល់ កុមារតូចៗឲ្យពួ-ម៉ែង (ឪពុកម្តាយ)គេវិញ។ កូនស្រីពៅរបស់ខ្ញុំ ក៏នៅទីនោះដែរ ដោយមានបាឡូតូចមួយជាប់នឹងខ្លួន ។ ខ្ញុំទាញដៃកូន ហើយរត់ទៅឡើងទូរទេះភ្លើង ។ នៅទីនោះខ្ញុំជួបកូនស្រីម្នាក់ទៀត គឺកូនស្រីទី៤ អង្គុយកន្ទឹមទឹមនៅក្នុងទូនោះដែរ ។ ទូរថភ្លើងនៅនឹងថ្កល់ ឯក្បាលរថភ្លើងនៅតែបញ្ឆេះតែឥតទៅមុខទេ ។ រំពេចនោះស្នូរទ្រហឹង កក្រើកអាកាសបានលាន់លឺឡើងដោយ

រថក្រោះនិងគ្រាប់កាំភ្លើងបាញ់រះ នៅតាមផ្លូវ សហភាពសូវៀត ។ សម្រែក ខ្សៀវខ្សារស្អួតរន្ធត់ លាយឡំនឹងពាក្យស្រែកថា ពួកយើងរត់រួចយួនចូលមកដល់ហើយ! ធ្វើឲ្យយើងទាំងអស់គ្នា លោតចេញ ប្រសាចពីទូរថភ្លើង ។ យើងរត់លាយឡំនឹងមនុស្សចាស់ ក្មេង ទារក ជនពិការ ជាពិសេសអ្នកជំងឺដឹកចេញពីមន្ទីរពេទ្យ រុំខ្លួននឹងក្រណាត់ស មានកាន់ដបសេរ៉ូមនៅដៃ ។ ខ្ញុំរត់បណ្តោយផ្លូវរទេះភ្លើងជាមួយកូនស្រីទីបួន និងទីប្រាំ រួមជាមួយហ្វូងអ្នកភៀសខ្លួនដទៃទៀត ។ សូរកាំភ្លើងតូច សូរកាំភ្លើងធំ នៅតែផ្ទុះឥតមានដាច់ ។ ពួកយើងបានរត់ទៅដល់ក្បែរវ៉ាពោធិចិនតុង ស្រាប់តែឃើញកូនស្រីធំរបស់ខ្ញុំ ដើរម្នាក់ឯងតយង៉យៗ ។ នាងខូចជើងម្ខាងត្រូវ គេរត់ចោលអស់។ ម៉ែនិងកូនស្រីបីនាក់ បានបន្តដំណើរទៅតាមហ្វូងមនុស្ស ។ យើងបានទៅដល់សហាករណ៍មួយ នៅក្នុងស្រុកឧត្តុង (សហាករណ៍ស្តុកស្រាត) ដើម្បីរកបាយហូប រួចបន្តដំណើរទៀត ។ យប់នោះ យើងសម្រាកនៅលើថ្នល់រទេះភ្លើង ក្បាលកល់លើរ៉ៃដែក ជើងសំយុងតាមជំរាលដី ធ្លាក់ចុះ ទៅក្រោម ។ ខ្ញុំដេកមិនលក់ទេ ព្រោះនៅកណ្តាលវាល នារដូវលំហើយ អាកាសធាតុត្រជាក់ខ្លាំង ។ ម្យ៉ាងទៀតកន្លែងសម្រាកក៏ពិបាកហើយ ក៏ខ្លាចគេដើរពារលើខ្លួន ពីព្រោះចលនារត់ភៀសខ្លួនចេញពីទិសខាងកើតទៅខាងលិច (ពីភ្នំពេញ ចេញទៅសហាករណ៍ផ្សេងៗនៅទិសពាយ័ព្យ ) មានសភាពខ្វូលខ្វាញ់ នៅតាមផ្លូវដែកនេះដែរ ។

មេឃមិនទាន់ភ្លឺស្រឡះនៅឡើយ ហ្វូងមនុស្សមានកាន់តែច្រើនឡើងៗ បង្ខំពួកក្រុមយើងឲ្យងើប និងរៀបចំបន្តដំណើរទៅមុខ ។ រំពេចនោះ សូរគ្រាប់បែកទម្លាក់ពីយន្តហោះ " ក្តាំង " លឺក្បែរៗត្រចៀកយើងញ័រដីធ្វើឲ្យកូនខ្ញុំ និងកុមារតូចៗ ជាង១០ នាក់ដែលរួមដំណើរពី ក-៣១ មកជាមួយខ្ញុំស្រែកយំទ្រហឹង ក្រាបគរលើគ្នា ។ សម្លេងយ៉ាងច្រើនស្រែកព្រមគ្នាៗថា " ពួកយើងត្រូវរត់ចេញឲ្យឆ្ងាយពីទីនេះ ប្រយ័ត្នត្រូវគ្រាប់បែក លឿនឡើងៗ!" ។ យើងទាំងអស់គ្នាស្ទុះងើប ហើយរត់យ៉ាងស្លន់ស្លោ ប្រាសអាយុភ្លេចរម្

ស៊ំពត់ អាវ និងរបស់របរខ្លះៗ ទុកចោលរាយប៉ាយ នៅលើផ្លូវដែក ។ អ្នកខ្លះរត់ទៅមុខឥតងាកក្រោយ ក៏ប៉ុន្តែខ្ញុំនឹកឃើញឥវ៉ាន់ និងគិតថាទៅមួយចង្កេះអញ្ចឹងមិនកើតដែរ ក៏ស្រែកហៅកូន និងកុមារៗ ( កុមារផន លក្ខណ៍ផល...)ឲ្យត្រឡប់ទៅយកបាឡ្យរៀងៗខ្លួនវិញ ។ យើងបានធ្វើដំណើរទៅមុខទាំងងឹតងងល់ ឥតស្គាល់ទិសតំបន់ គ្រាន់តែចាំពាក្យ របស់មិត្តប៉ុនដែលថា " យើងនឹងធ្វើដំណើរទៅពាយ័ព្យ " តែប៉ុណ្ណោះ ។ នៅតាមផ្លូវ ក្រុមយើងបានជួបនឹងក្រុមដ៏ទៃទៀតនៃអង្គភាពឃោសនាអប់រំ មានពួកមកពីមន្ទីរ "ក-២៧ "ដែលក្នុងនោះមានក្រុមគ្រួសារ មិត្តម្នាក់ ឈ្មោះ មិត្តចក់ ប្រពន្ធឈ្មោះមិត្តជួន ដែលធ្លាប់ធ្វើការជាមួយគ្នា នៅមហាវិទ្យាល័យគរុកោសល្យ គាត់ជាសាស្ត្រាចារ្យផ្នែកគំនូរ ។ ហ្វូងរបស់ខ្ញុំឥឡូវ មានមនុស្សច្រើនទៅៗ ក៏ប៉ុន្តែច្រើនជាកុមារ និង មីងៗ ដែលមានកូនតូចៗប៉ុណ្ណោះ ។ អញ្ចឹងហើយបានជានៅពេលដែលខ្ញុំជួបជាមួយពួកមិត្តចក់ ខ្ញុំសប្បាយចិត្ត ព្រោះបានអ្នកជិតជិតរួមដំណើរជាមួយ ដើម្បីជួយពិភាក្សាគ្នារកដំណោះស្រាយបញ្ហាហូបចុក និងរកផ្លូវដែលត្រូវធ្វើដំណើរ ។ ទៅដល់ សហករណ៍និមួយៗ មិត្តចក់ និងខ្ញុំតែងតែទៅទាក់ទងគេ ដើម្បីសុំឆ្នាំងបាយ ឆ្នាំងសម្ល និងអង្ករ អំបិល ប្រហុក ។ គេមិនចិត្តអាក្រក់ទេ ព្រោះ ពួកយើងប្រាប់គេថា ពួកយើងធ្វើការនៅអង្គភាពនេះ អង្គភាពនោះ ។ ជួនកាលពួកគេបានឲ្យបន្លែបង្ការ មានត្រឡាច ល្ពៅ និងជួនកាលទៀត ឧបត្ថម្ភថ្នាំសង្កូវ សម្រាប់បង្ការជំងឺថែមទៀត ។ យើងត្រូវដើរតាមផ្លូវតែមួយ គឺឆ្លងកាត់ព្រៃ កាត់ភ្នំ អស់ ៣-៤ថ្ងៃទើបទៅដល់ស្រុកអមលាំង ( ខេត្តកំពង់ស្ពឺ ) ។ យើងត្រូវឈប់នៅទីនោះ ព្រោះមានសហករណ៍មួយដែលគេប្រាប់ថា ពួកអង្គភាពឃោសនាអប់រំមួយចំនួនរង់ចាំនៅទីនោះ ។ ខ្ញុំត្រេកអរណាស់ព្រោះគិតថាប្តីរបស់ខ្ញុំ និងកូនខ្ញុំបីនាក់ទៀត ប្រហែលជានៅទីនោះដែរ ។ មិត្តធូក នៅមន្ទីរក-២៧ គ្រាន់តែឃើញខ្ញុំភ្លាមក៏សួរថា " ម៉េចក៏មិនឃើញអ៊ុំឆេងអញ្ចឹង? (ឈ្មោះបងសយនៅក្នុងជួរបដិវត្តន៍) " ។ ខ្ញុំឥតបានឆ្លើយនឹងសំណួរនេះទេ ហើយបែរជាសួរទៅវិញថា " អញ្ចឹង ឥតទាន់ឃើញគាត់មកដល់ទីនេះទេឬ ? ចុះពួក

អង្គភាពឃោសនាការក៏ពុំទាន់ ឃើញមកដល់ទីនេះដែរមែនទេ ? " ។ មិត្ត ធូកគ្រវីក្បាល ។ ពួកក្រុម យើងបានទៅជួបនឹងអ្នកទទួលខុសត្រូវនៃក្រសួង ឃោសនាអប់រំ ដើម្បីទាក់ទងរកកន្លែងស្នាក់នៅ ។ ស្រែកឡើងទើបឃើញ ពួកមន្ទីរ ក-២៩ មកដល់ ដែលមានប្ដីខ្ញុំផងដែរ ។ ពេលដែលយើងជួបគ្នា បងសយសួរខ្ញុំអំពីកូនបីនាក់ទៀត (គឺមិត្តវន្ត មិត្តដា និង មិត្តឡុំ ) ខ្ញុំប្រាប់ គាត់ថា ខ្ញុំក៏អត់ដឹងថាកូនខ្ញុំបីនាក់ទៀតនោះនៅឯណាឡើយ ពិតមែនតែ មិត្តដា និងមិត្តឡុំ នៅអង្គភាពជាមួយខ្ញុំមែន ព្រោះគេឲ្យខ្ញុំរត់មកមុន ។

យើងរស់នៅក្នុងសហករណ៍ "អមលាំង" បាន ៣-៤ ថ្ងៃប៉ុណ្ណោះ ។ ដោយសហករណ៍នេះនៅជាប់នឹងផ្លូវធំ ដែលមានឡានបើកចេញចូល ពួក យើង ត្រូវគេឲ្យជន្លៀសចេញទៅនៅកន្លែងផ្សេងៗទៀត ចូលជ្រៅទៅឆ្ងាយ ពីផ្លូវឡាន គឺនៅ " ពោងស្ករ " ដែលនៅក្បែរអូរមួយមានទឹកហូរ ខ្ចបព្រាំង ខ្ចបវស្សា ។ ការរស់នៅរបស់យើងនៅទីនោះ ពុំមានចោទបញ្ហាប៉ុន្មានទេ ពី ព្រោះមានស្ករហូប ហើយអាចរកក្ដាមខ្យង រួមទាំងបន្លែបង្ការផ្សេងៗ ហូប បានស្រួល ។ ក៏ប៉ុន្តែរឿងមួយដែលយើងនៅមានការបារម្ភ គឺប្រធានសហ-ករណ៍តែងកោះប្រជុំពួកអ្នកចំណូលថ្មីមកធ្វើជីវទស្សន៍ (ឲ្យយើងរាយការណ៍ ពីចំណាប់អារម្មណ៍ក្នុងការរស់នៅទីនោះ ) ហើយនៅពេលបូកសរុបមតិ ម្ដងៗ ប្រធានសហករណ៍ច្រើននិយាយច្រំដែលៗថា " អង្គការមានភ្នែក ម្នាស់ អង្គការត្រូវរែងរកមាសទឹកដប់ មាសទឹកប្រាំបី ទឹកប្រាំបួន មាស ជ្រលក់ ឬក្រឡែត្រូវតែដកចេញ..." ។ ពាក្យទាំងអស់នេះបានធ្វើឲ្យម្នាក់ៗ ព្រឺឆ្អឹងខ្នង ។ នៅទីនោះបានមួយរយៈខ្លី លេចលឺដំណឹងថា កងទ័ពយួន ចូលមកដល់ជិតៗនេះហើយ ដូច្នេះពួកយើងត្រូវជន្លៀសបន្តទៅទៀត ។

យើងដើរឆ្លងកាត់ជួរភ្នំអូរាល់ (ភ្នំដែលមានកម្ពស់ខ្ពស់ជាងគេនៅស្រុក ខ្មែរ គឺកំពស់ ១,០៨៣ ម៉ែត្រ ) ។ យើងដើរឡើងភ្នំ ចុះភ្នំ ( ភ្នំមួយរយ ស្រទាប់ ) អស់ច្រើនថ្ងៃ ទើបទៅដល់សហករណ៍មួយឈ្មោះ សហករណ៍ " ផ្លោច " ហើយបានជួបនឹងមិត្តនារីម្នាក់ដែលនៅក្នុងអង្គភាពឃោសនាអប់រំ

ដែរ ។ គេបានប្រាប់ពួកខ្ញុំថា មិត្តដា និងមិត្តឡំ ទើបត្រូវជន្លៀសចេញពីរោង ព្រឹកមិញនេះឯង ដើម្បីទៅកាន់សហករណ៍មួយទៀតនៅ "បឹងព្រះពន្លៃ" ( ខេត្តពោធិសាត់ )។ ចំណែករូបគាត់ៗបានសុំអង្គការទៅស្រុកកំណើតរបស់គាត់ដែលនៅជិតថ្លោចនេះដែរ ។ ព័ត៌មាននេះបានធ្វើឲ្យខ្ញុំ និងបងសយ រីករាយ ហើយក៏នាំគ្នាស្រូតដំណើរ ដើម្បីទៅឲ្យទាន់កូនទាំងពីរ ។ ប្រហែលជាម៉ោងមួយរសៀល យើងទៅដល់កន្លែងមួយ ទាន់មិត្តដា និងមិត្តឡំ ដែលពួក នាងកំពុងហូបបាយថ្ងៃត្រង់ នៅតាមផ្លូវទៅបឹងព្រះពន្លៃ ។ យើងបានជួបជុំកូនចៅទាំង៥នាក់ហើយ នៅសល់តែកូនប្រុសច្បងមួយតែប៉ុណ្ណោះ ។

ដំណើរឆ្លងតាមផ្លូវភ្នំអូរ៉ាល់ មានការលំបាកក្រៃលែង គឺលិចវាលចូលព្រៃ លិចព្រៃចូលវាល ឡើងភ្នំ ចុះភ្នំ កាត់ជ្រលងដងអូរ និងជាពិសេសដើរប្រជ្រៀតគ្នា តាមផ្លូវតូចៗ ដោយក្រុមមនុស្សអ្នកជន្លៀស ដូចពួកយើងដែរ ។ អញ្ចឹងហើយយើងដើរបណ្ដើរ ស្រែកប្រកួកហៅគ្នាបណ្ដើរ ដើម្បីកុំឲ្យដើរដាច់គ្នា ក្រែងវង្វេងបាត់គ្នាទៀត ។ យើងដើរអស់បីថ្ងៃ ទើបទៅដល់ស្ទឹងលាជ ។ យើងត្រូវដើរឆ្លងស្ទឹង ដែលមានទឹកហូរខ្លាំង ។ អ្នកដើរមុខយើង ស្គាល់ស្ថានភាពទឹក គេដឹងថាកន្លែងណាមានទឹកជ្រៅ កន្លែងណាមានទឹករាក់។ យើងដើរកាត់ទឹកក្រោយពួកគេនោះ ដោយឥតហ៊ានងាកខុសអំពីគន្លងទឹកដែលគេដើរឡើយ ។ ឆ្លងផុតស្ទឹង យើងបានទៅដល់សហករណ៍មួយទៀត ដែលយើងទាំងអស់គ្នាត្រូវតែចូលសម្រាកនៅទីនោះ ព្រោះហេវហត់ខ្លាំង ។

គឺនៅសហករណ៍នោះហើយ ដែលខ្ញុំបានឃើញកូនប្រុសរបស់ខ្ញុំជាលើកចុងក្រោយ ដោយសារកូនស្រីរបស់ខ្ញុំម្នាក់ ដែលនៅឈរមើលអ្នកជន្លៀសច្រើនរយពាន់នាក់ កំពុងដើរទៅមុខ ក្នុងនោះមានពួកក្រុមឃោសនាការ (ក្រុមមិត្តវន្ត)ផងដែរ ។ កូនស្រីរបស់ខ្ញុំរត់មកស្រែកប្រាប់ខ្ញុំ "ម៉ែង ! ឃើញក្រុមមិត្តវន្ត ដើរជិតមកដល់ហើយៗ" ។ ភ្លាមនោះ ខ្ញុំនិងកូន

ស្រីៗអរខ្លាំងណាស់ ស្ទុះចេញមកឈរចាំជួបនៅមាត់ផ្លូវ ។ មិត្តវ័ន្ត ក្បាលរុំនឹងក្រមា ឃើញតែចន្លោះមុខ មើលស្ទើរតែមិនស្គាល់ តែដោយរូបរាងកាយស្តើងខ្ពស់ចោងដោង ទើបខ្ញុំអាចសន្មតថា ពិតជាកូនប្រុសរបស់ខ្ញុំហើយ ។ ភ្លាមនោះកូនស្រីខ្ញុំស្រែកហៅ " មិត្តវ័ន្តៗៗ " ។ គេងាកក្បាល បែរមុខសម្លឹងរកប្រភពសំលេង ។ ពេលឃើញខ្ញុំ និងប្អូនស្រីគេ មុខគេឡើងក្រហមហើយញញឹមស្ងួត... ហាក់ដូចជាចង់រត់ចេញពីជួរមករកពួកយើងដែរ តែជើងរបស់គេត្រូវបង្ខំបោះជំហានទៅមុខ ជាមួយកងយុវជននៃអង្គភាពរបស់គេដដែល ។ ពេលនោះ បងសយឥតបាននៅទីនោះទេ គាត់កំពុងទៅរកជួបអ្នកទទួលខុសត្រូវនៅអង្គភាពរបស់កូនស្រីៗ ដើម្បីសុំអនុញ្ញាតឲ្យពួកនាងមកនៅជុំគ្នាជាមួយពូម៉ីងរបស់គេ ។ ពេលគាត់ត្រឡប់មកវិញ ខ្ញុំបានរាយរ៉ាប់រឿងជំនួបកូនវ័ន្តប្រាប់គាត់។ បងសយនិយាយថា គាត់ស្តាយណាស់ បើសិនជា គាត់ដឹងមុន គាត់នឹងសុំគេយកកូនទាំងអស់រួមទាំងមិត្តវ័ន្តមកនៅជុំគ្នាផងដែរ។ គាត់នៅស្ងៀមមួយសន្ទុះ រួចនិយាយបន្តថា " ណើ្ល យឲ្យវាទៅតាម គេសិនចុះ ចាំយើងទៅដល់បឹងព្រះពន្លៃ សឹមទាក់ទងគេនៅពេលក្រោយ ព្រោះថាបើយើងចេះតែសំណូមពរម្តងហើយម្តងទៀត គេនឹងចោទយើងថា កម្មសិទ្ធិក្រាស់ " ។ បងសយដកដង្ហើមធំ លែងនិយាយស្តីតទៅទៀត ។

យប់នោះយើងត្រូវសម្រាកនៅក្នុងសហករណ៍ដដែលចាំភ្លឺឡើងនឹងធ្វើដំណើរចេញទៅមុខទៀត ។ ស្រាប់តែព្រឹត្តិការណ៍ដ៏ខ្លោចផ្សាមួយបានកើតឡើង ។ អ្នកទទួលខុសត្រូវនៃអង្គភាពរបស់យើងបានប្រកាសប្រមូលរកពួកយុវ័យឲ្យចូលកាន់អាវុធ ដើម្បីធ្វើការវាយទប់ទល់ និងដេញកងទ័ពវៀតណាមឈ្លានពាន ។ ពួកយុវជន យុវនារីបដិវត្តទាំងអស់បានទៅជួបជុំគ្នាដើម្បីរង់ចាំការបំពាក់អាវុធ ។ ចំណែកឯកូនស្រីរបស់ខ្ញុំបីនាក់ ( កូនស្រីទីពីរ ទីបី និង ទីបួន ) ក៏បានប្តេជ្ញាចិត្តទៅចូលរួមក្នុងការបំពាក់អាវុធ នេះជាមួយគេដែរ ។ គេបានមកលាពូ–មីងរបស់គេ ។ គ្រាន់តែពួកគេមកជួបខ្ញុំ និង

បង **សយ** ហើយប្រាប់អំពីការសម្រេចចិត្តរបស់គេភ្លាម ខ្ញុំអួលដើមកនិយាយលែងចេញ ហាមាត់និយាយអ្វីលែងរួចតែម្ដង ព្រោះខ្ញុំមិននឹកស្មានថា កូនស្រីៗរបស់ខ្ញុំ ដាច់ចិត្តទៅចោលម៉ែឪផ្ទះសោះ ។ ដំបូងបងសយនៅស្ងៀមអស់មួយសន្ទុះទើបបន្លឺឡើងថា "រឿងនេះស្រេចលើសណ្ដានចិត្តរបស់មិត្តឯងរាល់ៗគ្នា ពូ-មីង មិនហ៊ានឃាត់ឃាំងពួកឯងទេ ។ ចំពោះពូវិញពូគ្រាន់តែចង់ប្រាប់ឲ្យឯងយល់ថា ... បើបដិវត្តន៍ឈ្នះមិត្តឯងស្លាប់ដោយបានកិត្តិយស តែបើបដិវត្តន៍ចាញ់ មិត្តឯងនឹងស្លាប់ ស្លាប់ដូចខ្មោចឆ្កែខ្មោចឆ្មាអញ្ចឹង !"។ ដំបូន្មានរបស់បងសយ បង្កប់ដោយអត្ថន័យយ៉ាងជ្រៅធ្វើឲ្យកូនស្រីទាំងបីរបស់ខ្ញុំយល់ភ្លាមថា វាមិនមានផ្លូវណាដែលគេនឹងរស់បានទេ ប្រសិនបើគេ ចេញទៅធ្វើទ័ពនោះ មិនថាផ្លូវមួយណាទេ ចាញ់ក៏ស្លាប់ខ្លួន ឈ្នះក៏ស្លាប់ខ្លួន ... ។ ទោះបីជាមានការបង្ហាញផលវិបាកអាក្រក់បែបនេះក៏ដោយ ក៏វាពុំមានឥទ្ធិពលធ្វើឲ្យពួកគេត្រឡប់ក្រោយបានឡើយ ពីព្រោះពួកគេយល់ថា មិត្តយុវវ័យគ្រប់ៗគ្នា គេប្ដេជ្ញាចិត្តធ្វើពលិកម្មអស់ហើយៗ បើយើងមិនធ្វើដូចគេ គឺយើងជាមនុស្សកំសាក អន់ថយមែនទែន...។ បន្ទាប់មក កូនស្រីទាំងបីរបស់ខ្ញុំបានយកបាឡូរបស់គេរៀងៗខ្លួន ស្ពាយលើស្មា ដើរចេញទៅ ។ ខ្ញុំអង្គុយនៅក្រោមតង់កៅស៊ូយំស្រងេះស្រងោចតែម្នាក់ឯង ។ រីឯបង**សយ** គាត់ដើរមួយៗ យ៉ាងល្វិតល្វៃក្រោយពួកកូនៗ ដើម្បីជូនដំណើរ ពួកគេ ដែលត្រូវបានគេកែនទៅធ្វើទ័ព ។ កូនស្រីទាំងបីត្រូវរង់ចាំឡើងឡាន ដើម្បីចេញដំណើរ។ ប្រហែលជាកន្លះម៉ោងក្រោយមក ឡាន GMC មួយគ្រឿងបានបើកមកដល់ ដែលមានកងយុវជនស្ម័គ្រចិត្តឈរជ្រោងនៅលើឡាន ។ មេកង ចុះពីលើឡាន ហើយស្រែកប្រកាសថា : " ឡានពេញហើយ ទទួល មនុស្សបានប្រហែលជា ៤–១០ នាក់ទេ អញ្ចឹងសុំឲ្យតែយុវជនៗ ឡើងទៅមុន ហើយអ្នកដែលនៅសល់ទាំងប៉ុន្មាន ចាំឡើងឡានជើងក្រោយទៅ " ។ ប្រុសៗ ដែលកំពុងឈរតម្រង់ជួររង់ចាំក៏ស្ទុះស្រឡើងឡាន ។ ឡានដឹកទ័ព ក៏ចេញដំណើរទៅបាត់ ។ កូន

ស្រី របស់ខ្ញុំទាំងបីនាក់ ត្រូវខកខានមិនទាន់បានចេញទៅជាមួយគេនៅឡើយ ត្រូវរង់ចាំឡានជើងក្រោយ ។ ភ្លឺឡើង ក្រុមស្ម័គ្រចិត្ត ( ឬក្រុមស៊ូស្លាប់ដើម្បីជាតិ) ទៅឈរត្រៀមខ្លួនរង់ចាំឡានមកទទួលយកទៅទៀត ។ ចាំបាត់ៗ រហូតដល់ម៉ោងប្រហែលជា ១០ ព្រឹក ទើបឃើញមាននារី ម្នាក់យកដំណឹងមកប្រាប់ថា គម្រោងនេះត្រូវផ្លាស់ប្តូរហើយ ព្រោះអីឡានដែលចេញកាលពីយប់មិញនោះ ជាឡានពួកក្រុមយួន បង្កប់ខ្លួន ហើយមនុស្សដែលជិះនៅលើឡានទាំងអស់គ្នាត្រូវពួកវាបាញ់សម្លាប់អស់ហើយ ។ ភ្លាមនោះគម្រោងការណ៍បំពាក់អាវុធ ត្រូវរំសាយជាបន្ទាន់ ។ កូនស្រីខ្ញុំក៏ដូចជាអ្នកស្ម័គ្រចិត្តផ្សេងទៀត មានការតក់ស្លុតនិងអាណិតស្ទើរ នៅពេលលឺដំណឹងនេះ រួចក៏បំបែកគ្នារៀងៗខ្លួនទៅ ។ ពេលនោះហើយ ពាក្យបណ្តាំរបស់បង **សយ** ហាក់ដូចជាធ្វើឲ្យកូនស្រីទាំងបីយល់អត្ថន័យ កាន់តែច្បាស់ឡើង ។ គេក៏ត្រឡប់មកតាមយើងវិញ ។ បន្ទាប់មកយើងទាំងអស់គ្នាក៏ចាប់ផ្តើមរត់ចេញពីទីកន្លែងនោះ យ៉ាងប្រញាប់ប្រញាល់តម្រង់ទៅសហករណ៍បឹងព្រះពន្លៃដូចជាអ្នកភៀសខ្លួនដទៃទៀតដែរ ។

សហករណ៍បឹងព្រះពន្លៃស្ថិតនៅក្នុងស្រុកបាកាន ខេត្តពោធិសាត់នៅចន្លោះជួរភ្នំអូរ៉ាល់ និងភ្នំក្រវ៉ាញ ។ មានការដ្ឋានដ៏ធំមួយ ដែលគេកែនប្រជាជន ទាំងពួក ១៧ មេសា ( ពួកថ្មី ) និងពួកមូលដ្ឋាន (ពួកចាស់) ដើម្បីលើកទំនប់ដ៏ខ្ពស់ និងវែងស្រឡូម ភ្ជាប់ពីភ្នំមួយទៅភ្នំមួយទៀត ទប់ទឹកដែលមាននៅក្នុងបឹងព្រះពន្លៃ ខួបប្រាំងវស្សា ។ ពួកយើងច្រើនគ្រួសាររស់នៅទីនោះយ៉ាងយូរ ទាំងអរទាំងភ័យ ។ អរព្រោះជាកន្លែងដែលឆ្ងាយពីស្នូរកាំភ្លើង ។ ភ័យព្រោះមានការគំរាមកំហែងពីប្រធានសហករណ៍ថ្មីដែលតែងនិយាយដូចគ្នានឹងប្រធានសហករណ៍នៅអមលាំងដែរថា "ត្រូវវែងរកមាសទឹកដប់..." ។ ពួកយើងទាំងអស់គ្នា ដែលភៀសខ្លួនពីអង្គភាពនានា មកពីភ្នំពេញ ច្រើនគ្រួសារត្រូវចុះធ្វើការជាមួយពួកគេឯងនៅសហករណ៍នោះដែរ។ គឺនៅពេលនោះហើយដែលបង **សយ** និងខ្ញុំដឹងថាពួកយើងក្លាយ

ទៅជាប្រជាជនថ្មី ចូលមកសស់នៅក្នុងសហករណ៍នោះ ។ បងសយបាន ណែនាំកូនទាំងអស់គ្នាថា " មិត្តទាំងអស់ មិត្តត្រូវយល់ថាឥឡូវយើងទាំងអស់គ្នា ត្រូវប្រឹងរស់ដោយខ្លួនឯង បដិវត្តន៍លែងគ្រប់គ្រងពួកយើងតទៅទៀតហើយ ។ អញ្ចឹងហើយ មិត្តៗត្រូវមើលគេឯង គេរស់បែបណា យើងត្រូវសម្របខ្លួន ដូចគេដែរហើយ។ មិត្តត្រូវគិតទៅលើក្រុមគ្រួសារយើង ឈប់គិតពីបដិវត្តន៍អ្វីទៀតទៅ..." ។ តាមការទូន្មានរបស់បង**សយ** ពីមួយថ្ងៃទៅមួយថ្ងៃ កូនស្រីៗរបស់យើងប្តូរចិត្តគំនិតលែងមានទឹកចិត្តមោះមុតទៀតហើយ។ គេធ្វើអ្វីៗទាំងអស់ដើម្បីក្រុមគ្រួសារយើង ដូចជាចាប់ផ្តើមហ៊ានទៅរួចបេះ បោចដំណាំដាំដុះរបស់សហករណ៍ ហ៊ានដើរហើរពីកន្លែងមួយទៅកន្លែងមួយទៀត ... ។ គេតម្រូវឲ្យយើងទៅគាស់គល់ឈើដើម្បីធ្វើចំការជារៀងរាល់ថ្ងៃ តែគេផ្តល់អាហារឲ្យមិនគ្រប់គ្រាន់សោះ ។ ការហេវហត់ខ្លាំងគួបផ្សំនឹងកង្វះការហូបចុកធ្វើឲ្យយើងដើរទៅរកបេះបោចហូបស្លឹកឈើ ស្លឹកព្រៃតែពាស ។ ការញាំផ្តេសផ្តាសនោះធ្វើឲ្យខ្ញុំឈឺពោះ ពេញមួយយប់ហើយពេលខ្ញុំទៅ សុំគេសម្រាកគេនិយាយប្រាស់ឆ្អេះឲ្យថា " យ៉ាងម៉េច ? គ្រាន់តែចុះ គាស់គល់ ឈើបានតែ ៤-៥ថ្ងៃ បាក់អាចម៍ បាក់នោមទៅហើយហ្អី ? " ។ ខ្ញុំនៅស្ងៀម ហើយប្រឹងញញឹម តែបេះដូងរបស់ខ្ញុំឡើងស្ងួតអស់រលីង ។ គេក៏ឲ្យខ្ញុំឈប់ទាំងមិនសប្បាយចិត្ត ។ ក្រោយមកគេឲ្យខ្ញុំទៅដឹកជញ្ជូនស្រូវ នៅដំណាក់កន្សែងដែលជាឃ្លាំងស្រូវរបស់សហករណ៍ដើម្បីទៅលាក់ទុកនៅកន្លែងផ្សេងឆ្ងាយពីមាត់ផ្លូវ។ ទៅបានតែមួយយប់គេឲ្យពួកខ្ញុំត្រឡប់មកវិញដោយសារមានសភាពការណ៍ប្រែប្រួល។ ខ្ញុំបែកបង**សយ** គ្រាន់តែមួយយប់សោះ ពេលមកដល់សហករណ៍វិញ ខ្ញុំភ្ញាក់ព្រើតព្រោះខ្ញុំ មើលប្តីខ្ញុំស្ទើរតែមិនស្គាល់ ដោយសារគាត់មានជំងឺរាគ មួលពេញមួយយប់ ស្លេកស្លក់ប្រៀប ដូចអាសុភ។ ប្តីខ្ញុំបាននិយាយប្រាប់ថា កុំតែបានថ្នាំមួយគ្រាប់ ដែលមិត្តប៊ូ (នៅមន្ទីរក-២៩ ជាមួយគ្នាកាលពីមុន) បានឲ្យកុំអីគាត់ប្រហែលជាកាន់ តែដាបទៅៗ មិនដឹងទៅជាយ៉ាងណាទេ!។

នៅយប់អាធាត្រមួយនោះ មានលឺសំលេងអ្វីអែរនៅក្បែររោងបាយ ។ ប្ដីខ្ញុំចេញទៅមើលឃើញគេកំពុងវះគោដែលដួលស្លាប់ក្រោយពីអូសរទេះមកដល់សហាករណ៍ភ្លាម ។ ប្ដីខ្ញុំ និង ខ្ញុំ ស្រងោចក្នុងចិត្ត ហើយនិយាយជាមួយគ្នាថា " មិនមែនតែមនុស្សទេដែលត្រូវគេបង្ខំឲ្យធ្វើការច្រើនហួសកម្លាំងនោះ សូម្បីតែសត្វពាហនៈក៏ត្រូវគេប្រើធ្វើការដល់យប់អាធ្រាត្រ គ្មានស្គាល់ពេលវេលា ប្រើរហូតដល់ដួលស្លាប់នៅនឹងកន្លែងតែម្ដង " ។ បងសយរកកាំបិត ដើម្បីសុំគេចូលជួយវះគោនោះ ។ ក្រោយមក គេយកសាច់ទៅទុកមួយអន្លើ ហើយគេដកតែគ្រឿងក្នុងយកទៅចំអិន ហើយចែកឲ្យអ្នកធ្វើគោនោះ ហូបទាំងយប់នោះតែម្ដង ។ ប្ដីខ្ញុំមិនបានហូបជាមួយពួកគេទេ គាត់សុំគេ យកមកញ៉ាំនៅរោង ។ មកដល់រោងវិញ បងសយបានហុចបញ្ចប់មួយដែលរុំ ដោយស្លឹកត្បែង ក្នុងនោះមានគ្រឿងក្នុងគោ ប្រហែលជា ១០ ចំណិត មកអោយខ្ញុំញ៉ាំ ។ គាត់តឿនឲ្យខ្ញុំហូបភ្លាមៗ ទាន់វានៅក្ដៅទើបឆ្ងាញ់ ។ មែនវាឆ្ងាញ់ណាស់ មានរស់ជាតិផ្អែម ។ ពីរថ្ងៃក្រោយមកនៅលើម្រាមដៃ ស្ដាំរបស់ខ្ញុំ(នាងដៃ) មានលេចចេញកន្ទួលពណ៌ក្រហមមួយធ្វើឲ្យខ្ញុំរមាស់អេះមិនចេះឈប់ ។ ចាប់ពីពេលនោះមកម្រាមដៃខ្ញុំចាប់ផ្ដើមហើមៗយ៉ាងលឿនទៅដល់កដៃ ឡើងទៅកែងដៃដល់ស្មា។ តែក្នុងរយៈពេល២ ថ្ងៃប៉ុណ្ណោះ ដៃស្ដាំទាំងមូលរបស់ខ្ញុំឡើង ហើមជិតប៉ុនភ្លៅ ។ ម្រាមទាំង៥ ហើមឡើងក្រញ៉ាងប្រៀបបាននឹងដៃខ្មោចលង់ទឹក ដែលកំពុងហើមពេញបន្ទុក ។ វាមិនបានធ្វើឲ្យខ្ញុំឈឺចាប់អ្វីឡើយ ក្រៅពីមានអារម្មណ៍ថាធ្ងន់ពិបាកធ្វើចលនាប៉ុណ្ណោះ។ ជាការពិត ខ្ញុំមានការភ័យខ្លាចណាស់ពេលឃើញស្ថានភាពបែបនោះ ព្រោះមិនដឹងជាខ្ញុំកើតមានជំងឺអ្វីឡើយ ។ អ្នកដែលបានឃើញសភាពការណ៍នោះ គេបាននិយាយថា ដៃខ្ញុំត្រូវកើតពិសហើយ ត្រូវតែទៅរកគ្រូខ្មែរស្ដោះ ដែលនៅក្នុងសហាករណ៍បឹងព្រះពន្លៃនោះដែរ ។ ខ្ញុំត្រូវដើរទៅរកជួបគ្រូស្ដោះនោះ ។ គាត់នៅខ្ទមដែលឆ្ងាយអំពីរោងស្នាក់នៅរបស់ខ្ញុំ ។ ខ្ញុំពុំអាចដើរបានច្រើនជំហានទេ ពីព្រោះហាក់ដូចជាមានកាំបិតមក ចាក់ខ្វាស់នៅនឹងចង្កេះ ដូចនេះដើរបានតែ ៤-៥

ពំហានខ្ញុំត្រូវឈប់ម្តង ។ ខ្ញុំបានជួបគ្រូស្តោះនោះ គាត់មានវ័យចំណាស់ហើយ ។ ខ្ញុំជម្រាបគាត់អំពីរោគសញ្ញានៃជំងឺរបស់ខ្ញុំ ។ លោកតាពិនិត្យហើយប្រាប់ខ្ញុំថា " មិត្តឯងកើតពិសហើយ គឺពិស មហាមេឃ មហាដាល "។ គាត់បន្តទៀតថា "ចៅ ឯងត្រូវមើលខ្លួនឲ្យមែនទែន ពីព្រោះមានម្នាក់នោះគេបានកើតជំងឺដូច មិត្តឯងអញ្ចឹងដែរ ហើយបានតែ ១១ថ្ងៃ គេក៏ស្លាប់ទៅ... ចុះចៅឯង ចាប់ឈឺប៉ុន្មានថ្ងៃហើយ? "។ ខ្ញុំឆ្លើយថាមកដល់ថ្ងៃនេះគឺជាថ្ងៃទី៧ហើយ ។ គាត់ក៏ប្រាប់ឲ្យរកថ្នាំសម្រាប់ព្យាបាល ក្នុងនោះគាត់ឲ្យរកសំបកស្លែង មើមក្តួច មើមប្រង់ មើមក្តាតហោរា និងថ្នាំខ្លាំង (ថ្នាំជក់ )។ ខ្ញុំនាំពាក្យនេះមកប្រាប់ប្តីខ្ញុំ ។ គ្រាន់តែឮភ្លាម គាត់ដឹងថាគ្រឿងផ្សំទាំងអស់នោះសុទ្ធតែជាគ្រឿងពុល ។ ខ្ញុំខ្លាចណាស់ ក៏ប៉ុន្តែអ្នកស្រុកអ្នកភូមិ គេនិយាយប្រាប់វិញថា គេយកគ្រឿងពុលទៅបន្សាបជាតិពិស ។ ខ្ញុំគ្មាន ជម្រើសទេ ពីព្រោះបើតាមសំដីតាគ្រូស្តោះ គឺខ្ញុំនៅមានពេលតែ ៣ ឬ ៤ ថ្ងៃ ទៀតតែប៉ុណ្ណោះ ខ្ញុំនឹងត្រូវលាចាកលោកនេះទៅហើយ...។ ប្តីខ្ញុំស្វះស្វា សុំឲ្យគេជួយរកគ្រឿងផ្សំទាំងអស់នោះ ។ ជាសំណាង ដែលគ្រឿងផ្សំទាំង អស់នោះមិនពិបាករកទេ នៅតាមភូមិ តាមភ្នំ ដែលពួកយើងរស់នៅនោះ ។ ពេលព្រលប់នៃថ្ងៃទី ៨ ទើបយើងរកគ្រឿងផ្សំទាំងអស់នោះបានគ្រប់មុខ ។ កូនខ្ញុំម្នាក់ៗ ផ្លាស់ប្តូរគ្នាដុសថ្នាំនោះឲ្យខ្ញុំផឹក ដុសបានកន្លះត្រលោក ខ្ញុំផឹកម្តងៗ ។ ដៃរបស់កូនខ្ញុំ ដែលកាន់មើមថ្នាំដុសឡើងក្រហម ហើយរមាស់ព្រោះប៉ះនឹងគ្រឿងថ្នាំពុលទាំងនោះ ។ ដោយឡែកមាត់របស់ខ្ញុំ ដែលផឹកថ្នាំដុសស្ទើររាល់ម៉ោង ឥតមានទទួលផលវិបាកអ្វីទាំងអស់ ។ នៅព្រឹកព្រលឹមថ្ងៃទី ១០ គឺ ២ ថ្ងៃក្រោយពីខ្ញុំបានផឹកថ្នាំផ្សំនោះ ខ្ញុំក្រោកពីសម្រាកសម្លឹងមើលដៃរបស់ខ្ញុំ... ឃើញមានផ្ទត់ជ្រួញៗ ៣-៤ នៅលើគន្លាក់ដៃ ជាប់និងស្នា ។ បង **សយ** ជួយពិនិត្យ និងប៉ាន់ស្មានថា " ដូចជាស្រកហើម"។ មែនវាស្រក ! ស្រកលឿនដូចកាលចាប់ហើមដែរ ។ ពេលកំពុងស្រកស្បែកដៃរបស់ខ្ញុំចាប់ផ្តើមចេញពងពេលប៉ោង ពាសពេញ ដូចពងនៃស្បែក រលាក

ភ្លើងអញ្ចឹង មានតូច ល្អិត មានធំប៉ុនមេដៃ ធំប៉ុនមេជើង ។

សកម្មភាពនៅលើខ្នងទំនប់ មានយ៉ាងមមាញឹក ដោយមានមនុស្ស ដើរទាំងហ្វូងៗ និងទាំងជួរៗ កាន់និងស្ពាយឥវ៉ាន់សំពីងសំពោង ធ្វើដំណើរ ឆ្ពោះទៅជើងភ្នំអូរ៉ាល់ ។ ពេលនោះកូនរបស់ខ្ញុំម្នាក់បានឃើញក្រុមយុវជន ស្លៀកពាក់ខោអាវខ្មៅ ដើរជាជួរទៅជាមួយគេនោះដែរ ។ កូនស្រីខ្ញុំមើល ពីខាងជើងទំនប់ទៅឃើញយុវជនម្នាក់រាងខ្ពស់ស្រឡះ ហើយគេគិតថា ប្រហែលជាបងប្រុស វិន្តរបស់គេហើយ ។ គេស្រែកហៅ និងរត់ដេញតាម នៅជើងទំនប់ដើម្បីឲ្យយុវជននោះឈប់ ។ ក៏ប៉ុន្តែពុំមាននរណាម្នាក់ ងាកមក មើលម្ចាស់សំឡេងនោះឡើយ ។ ដោយដំណើររបស់គេ បែបរួតរះ ក្រុម នោះក៏ដើរលឿនផុត ដែលកូនខ្ញុំពុំអាចដេញតាមទាន់ឡើយ ។ គេមកប្រាប់ ដំណឹងនេះឲ្យខ្ញុំ និងបងសយដឹង ។ ក៏ប៉ុន្តែយើងពុំអាចស៊ើបសួរឲ្យបានដឹង ច្បាស់លាស់អំពីក្រុមនោះទៅទីណាឡើយ ។ ប៉ុន្មានថ្ងៃមុននេះ បង **សយ** បានទៅទាក់ទងនឹង " មិត្តចែម " ដែលជាយុវជននៅក្នុងជួរដែរនោះ ដើម្បីចង់ដឹងអំពីព័ត៌មានរបស់ក្រុមឃោសនាការ ។ មិត្តចែមបាននិយាយ ប្រាប់ថា គេឲ្យយុវជនៗទៅចូលរួមក្នុងកងដឹកជញ្ជូន (ជញ្ជូនស្បៀង និង សំភារៈខ្លះៗ ទៅលាក់ទុកឲ្យឆ្ងាយពីផ្លូវឡាន ) ។ ក្នុងកងដឹកជញ្ជូននោះ ក៏មានមិត្តវិន្តទៅជាមួយផងដែរ ។ មិត្តចែមបន្តទៀតថា " លឺ គេ វាកង នោះបានត្រូវគ្រាប់ផ្លោងរបស់កងទ័ពយួនផ្លោងមកចំ ហើយគេមិនដឹងអ្វីត ទៅទៀតទេ ថាតើមាននរណាខ្លះត្រូវស្លាប់ និងនរណាខ្លះដែលបានគេចផុត អំពីស្លាប់នោះឡើយ " ។ គ្រួសារខ្ញុំទាំងអស់គ្នាក្តុកក្តួលចិត្ត នៅពេលដែលលឺ ដំណឹងនេះ ក៏ប៉ុន្តែនៅមានកូនចិត្តមួយសង្ឃឹមថា កូនខ្ញុំអាចរួចផុតអំពីគ្រាប់ ផ្លោងនោះ ។ អញ្ចឹងហើយបានជានៅពេលដែលឃើញ ពួកយុវជនដើរ នៅលើខ្នងទំនប់ យើងនឹកគិតស្មានថាប្រហែលជាមានវាសនា បានជួបកូន វិន្តហើយ ។

ខ្ញុំនៅពុំទាន់ដើរបានស្រួល ឈានបានតែ ៤-៥ ជំហាន ដូចរោមមាន

កាំបិតមកចាក់ខ្លាស់នៅឡើយ ។ គឺនៅពេលនោះហើយ ដែលខ្ញុំដឹងច្បាស់ថា ទាំងប្ដីខ្ញុំក្ដី ទាំងកូនស្រីទាំង ៥របស់ខ្ញុំក្ដី គេសុីស្លាប់រស់ជាមួយខ្ញុំដែរ ពីព្រោះ កាលណោះ កងទ័ពវៀតណាមបានវាយមកដល់សហករណ៍ពិណាក់កន្សែងហើយ ( ប្រហែល ១០ គីឡូពីសហករណ៍បឹងព្រះពន្លៃ ) ហើយកំពុងធ្វើដំណើរមកសហករណ៍ខ្ញុំ ។ ពួកប្រជាជនមូលដ្ឋានគេរត់បាត់រស់តាំងពីយប់ លឺថាពួកគេ ភាគច្រើនរត់ឡើងភ្នំ អ្នកដ៏ទៃទៀតរត់ជាបន្តបន្ទាប់ ដល់ពេលរសៀលនៅសល់ តែគ្រួសាររបស់ខ្ញុំមួយប៉ុណ្ណោះ ។ ពួកយើងក៏ត្រូវតែចាកចេញពីសហករណ៍នេះដែរ ពីព្រោះស្នូរកាំភ្លើងតូចធំ នៅតែលាន់ឮក្ដុងក្ដាំង ហើយពួកយើងកំពុង បិតនៅជាប់នឹងទំនប់ដែលមានផ្លូវឡានបើកបរនៅលើខ្នងទំនប់នោះឯង ។ យើងនាំគ្នាជញ្ជូនឥវ៉ាន់ផ្ទាល់ខ្លួនបន្តិចបន្តួច និងជួយគ្រាហ៍ខ្ញុំដើរទៅដល់ជើង ទំនប់បម្រុងឆ្លងទៅពួនក្នុងព្រៃក្បែរជើងទំនប់ម្ខាងទៀត ។ ក្រោយពីជញ្ជូន ឥវ៉ាន់ទៅដាក់នៅម្ខាងទំនប់រួចហើយ ទាំងកូនៗ ទាំងប្ដីខ្ញុំ មកជួយគ្រាហ៍ខ្ញុំ ឡើងទំនប់ ។ ខ្ញុំប្រឹងទប់ខ្លួនកុំឲ្យរអិលធ្លាក់។ ទាំងកម្លាំងទាញ កម្លាំងរុញ នៅតែទប់ខ្ញុំមិនជាប់ព្រោះណាមួយខ្ញុំគ្មានកម្លាំងទាល់តែសោះ ណាមួយទៀតទំនប់នោះខ្ពស់ណាស់ និងចោតថែមទៀត ។ ខ្ញុំបានប្រាប់បង**សយ** និងកូនៗរបស់ខ្ញុំឲ្យរត់ទៅមុនទៅ ទុកឲ្យខ្ញុំដើរតិចៗតាមក្រោយ តែពួកគេទាំងអស់គ្នាមិនព្រមទេ ។ បងសយនិយាយថា "បើនៅយើងនៅទាំងអស់គ្នា បើទៅយើងទៅទាំងអស់គ្នា " ។ ពេលនោះកូនខ្ញុំម្នាក់ឲ្យយោបល់ថា ដាក់ខ្ញុំក្នុងអង្រឹងរួចយកស្នែងមកសែងទៅ។ បងសយនិយាយតបថា រៀបចំអង្រឹងមិនទាន់សភាពការណ៍ទេ ។ គាត់បញ្ជាឲ្យកូនៗ ធ្វើតាមគាត់វិញ ។ គាត់លើកខ្ញុំបីហើយឲ្យកូនម្នាក់ៗជួយរុញគាត់ពីក្រោយ កូន២នាក់នៅសងខាង ខ្លួនគាត់ឲ្យជួយទប់ព្រោះគាត់គ្មានដៃទប់ខ្លួនពេលវារឡើងចំណោតទំនប់ ។ យើងអាចឆ្លងឡើងទំនប់បានហើយៗទៅកំបាំងខ្លួន នៅក្នុងព្រៃក្បែរៗទំនប់នោះ រហូតដល់ព្រលប់ស្ងាត់ស្នូរគ្រាប់កាំភ្លើង។ ភាពស្ងាត់ជ្រងំបានធ្វើឲ្យគ្រួសាររបស់ខ្ញុំ

រងា ភ័យខ្លាចទ្វេឡើងៗ ក៏សម្រេចវិលមកសម្រាកនៅខ្ទមក្នុងសហករណ៍វិញ ។ ឥតមានហេតុការណ៍អ្វីកើតឡើងទេនៅក្នុងយប់នោះ ។ យើងចេញដំណើរនៅពេលជិតភ្លឺដែលផ្ទៃមេឃនៅងងឹតនៅឡើយ គឺចេញទៅកន្លែងណាដែលនៅឆ្ងាយពីទំនប់ ។

នៅតាមផ្លូវ យើងប្រមូលស្បៀងបានជាច្រើនដែលគេបោះបង់ចោល។ យើងបានមកដល់លាជ ហើយឆ្លងទៅត្រើយម្ខាងទៀត ដែលមានខ្ទមចាំចំការ នៅតាមបណ្តោយមាត់ស្ទឹង ។ យើងជួបអ្នកភៀសខ្លួនដូចពួកយើងចំនួន ៤–៥ គ្រួសារដែរ ។ ពួកគេស្នាក់នៅក្នុងខ្ទមក្បែរៗគ្នា ក្នុងនោះមានមិត្តរ៉ា និងគ្រួសារគេមួយគ្រួដែរ ។ បងសយគិតថាគាត់ចង់រស់នៅទីនោះរហូត ព្រោះថានៅតាមដងស្ទឹង " លាជ " ដីល្បប់ ល្បាយខ្សាច់ លាតសន្ធឹងពីមាត់ស្ទឹងទៅដល់ជើងភ្នំ ។ អ្នកភូមិធ្វើចំការដាំបន្លែសព្វបែបយ៉ាងនៅតាមបណ្តោយមាត់ស្ទឹងនោះ ។ ម្យ៉ាងទៀត ទឹកស្ទឹងក៏សំបូរត្រី ដែរអាចរស់នៅបានយ៉ាងស្រួល ។ អញ្ចឹងហើយបានជាគាត់គិតថាចង់រស់នៅទីនោះរហូត ជាប្រជាជនសមញ្ញ ដូចគេដូចឯងនៅទីនោះ ។ ខ្ញុំដឹងចិត្តបង **សយ** ច្បាស់ គាត់ស្រឡាញ់ទីកន្លែងណាដែលមានទឹក គាត់ចូលចិត្តហែលទឹក ពូកែជ្រមុជក្នុងទឹក ហើយជ្រមុជបានយូរទៀតផង ។ គាត់ប្រាកដជាសប្បាយនឹងរស់នៅទីនោះហើយ ។

| | | |
|---|---|---|
| – ក្រោមមេឃទឹកភ្លៀង | យើងខំជៀសវាង | មិនឲ្យទទឹក |
| ទោះប្រើប្រដាប់ | ការពារសន្ទឹក | ភ្លៀងខ្លាំងជះទឹក |
| | ជោកជាំពេញប្រាណ ។ | |
| – ខន្តីអំណត់ | ការងារម៉ត់ចត់ | ព្យាយាមប្រមាណ |
| ប្រមើលកិច្ចការ | គួរធ្វើគួរខាន | មិនឲ្យជាប់ដាន |
| | ជាជនអប្រិយ ។ | |

# វគ្គទី ៦

## ក្រោមនយោបាយមុខពីរ

កងទ័ពវៀតណាមបានវាយមកដល់សហករណ៍លាជហើយៗបោះទីតាំងនៅទីនោះ ។ មានពេលល្ងាចមួយនោះ ពួកកងទ័ពវៀតណាមដែលកាន់កាប់សហករណ៍លាជ បានបោកគ្រាប់បែកក្នុងទឹកស្ទឹងដើម្បីចាប់ត្រី ។ ត្រីងាប់ផ្ងារពោះ អណ្តែតពេញស្ទឹង ។ គេប្រមូលត្រីតូច ត្រីធំ បានពេញមួយស្បោងធំ ហើយក៏ចេញបាត់ទៅ។ បងសយ ស្លៀកខោខ្លី លោតទឹកព្រោង មុជបាត់មួយសន្ទុះ ងើបមកវិញលើកត្រីឆ្លាំងធំមួយ គ្រវែងមកលើគោក ហើយស្រែកប្រាប់កូនៗ ដែលនៅឈរមើល ឲ្យទៅយកកន្ត្រកមកឲ្យគាត់ ។ គាត់មុជលើកទី ២ ងើបមកវិញបានត្រីធំៗពេញកន្ត្រក ។ គាត់ហែលមកច្រាំងឲ្យកូនចាក់ត្រីនោះចូលទៅក្នុងធុង ដោយប្រាប់ថា " នៅមានទៀត "។ លើកទី ៣ គាត់ចាប់បានត្រីខ្លះទៀត និងកន្ធាយមួយ មកចាក់ចូលក្នុងធុងទៀត ។ គាត់ចាប់បានត្រីជិតពេញធុង ។ គាត់និយាយយ៉ាងសប្បាយចិត្តថា " ពួកអាអស់ហ្នឹង វាអត់ដឹងទេ ត្រីដែលងាប់ហើយអណ្តែតគឺត្រីតូចៗ ឯត្រីធំៗ វានៅក្រោម គ្រាន់តែស្រេងល់ ធ្លាក់ទៅនៅឯបាតស្ទឹងឯណោះ ។ ពុកគ្រាន់តែពរនៅតាមចន្លោះថ្ម តាមដីក្រឡុក ចាប់បានត្រីធំៗទាំងនេះឯង " ។ មិត្ត រ៉ា ឃើញកូនខ្ញុំយួរធុង យួរកន្ត្រកត្រី គេស្រែកឡើងថា " អុំឆេងបានត្រីច្រើនណាស់អ៊ើយៗ "។ អ្នកខ្ទមជិតខាងរត់មកមើលសប្បាយជាមួយគ្នា ។ យើងចែកឲ្យពួកគេម្នាក់ត្រីមួយៗ ដោយមិនមានលាក់បំពួនសម្រាប់តែគ្រួសារឯងឡើយ ។

ពួកយើងមិនហ៊ានរស់នៅក្នុងទីដាច់ស្រយាលនោះតទៅទៀតទេ ព្រោះពួកទ័ពវៀតណាមតែងដើរក្រវែលខ្ទមរបស់ពួកយើង ។ គេបកស្បូវ

ព័ត៌មាន សូរប្រវត្តិរូបជាញឹកញាប់ ហើយជាពិសេសគេឧស្សាហ៍សួរឈ្មោះកូនស្រីៗរបស់ខ្ញុំ ធ្វើឲ្យបងសយព្រួយបារម្ភ ។ គាត់បានប្រាប់កូនៗឲ្យឆ្លើយថា ពួកនាងមានអាយុ៣០-៤០ ឆ្នាំ ហើយមានប្ដីអស់ហើយៗប្ដីនោះស្លាប់អស់ហើយ ថាពួកនាងជាស្រីមេម៉ាយ...។ បន្ទាប់មកយើងក៏សម្រេចចាកចេញពីលាជ ព្រោះខ្លាចមានបញ្ហាអ្វីកើតឡើង ។ យើងធ្វើដំណើរបន្តឆ្ពោះទៅកាន់ទីប្រជុំជន ខេត្តពោធិសាត់វិញ ដើម្បីបន្តធ្វើដំណើរចូលក្រុងភ្នំពេញ ។ យើង មានឥវ៉ាន់កាន់តែច្រើនហើយ ដោយប្រមូលបានពីកន្លែងនេះបន្តិច កន្លែងនោះបន្តិច ដែលជាឧបករណ៍សម្រាប់កាប់គាស់ដាំដុះ និងគ្រាប់ពូជដំណាំមួយចំនួន ដូចជា គ្រាប់ស្ពៃ ត្រសក់ត្រឡាច ឃ្លោក ល្ពៅ ប៉េងប៉ោះ រនោង...។ បងសយរៀបចំធ្វើរទេះ អូសព្រោះយើងមានក្របី១ក្បាល ដែលកូនស្រីធំ របស់ខ្ញុំរើសបាន នៅពេលនាងទៅបេះបន្លែ ។ រទេះរបស់យើងពុំ អាចអូសបានឆ្ងាយទេពីព្រោះយើងប្រើខ្នងកង់ធ្វើជាកង់រទេះ អូសបានចម្ងាយ ប្រហែលជា ១០០ ម៉ែត្រខ្នងកង់វៀច ត្រូវបញ្ឈប់ដើម្បីជួសជុលកែតម្រូវ ។

នៅតាមផ្លូវយើងជួបនឹងព្រឹត្តិហេតុច្រើន ។ មានការឆ្មក់វាយគ្នារវាងពួកទ័ពខ្មែរក្រហម និងពួកទ័ពវៀតណាម ។ មានការប្លន់អីវ៉ាន់របស់អ្នកភៀសខ្លួន ដោយពួកសមាសភាពក្លែងបន្លំ ។ រទេះរបស់យើងក៏ត្រូវជួបនឹងពួកស្រវឹង ស្រា ៣-៤ នាក់មកស្ទាក់ ហើយសំឡុតយកក្របីរបស់យើងបាត់ដែរ(សំណាង ដែរបើក្របីនោះនៅមាន យើងមុខជាត្រូវដើរពីពោធិសាត់ទៅភ្នំពេញ ដោយចំណាយពេលយ៉ាងតិចក៏មួយខែដែរ )។ ខ្ញុំចាប់ផ្ដើមនឹកគិតអំពីបញ្ហា វាសនាអនាគតរបស់សង្គមខ្មែរយើងទៀតហើយ ក្រោយជួបប្រទះនឹងសភាពការណ៍អំបាញ់មិញនេះ ។ ឃើញមានវត្តមានកងទ័ពវៀតណាមចូលជ្រៅមកស្រុកភូមិ ចុងកាត់មាត់ញកររបស់ខ្មែរយើង ឃើញសកម្មភាពទប់ទល់របស់កងទ័ពព្រៃខ្មែរក្រហម និងឃើញការឆ្លៀតឱកាសរបស់ពពួកសមាសភាពអាក្រក់ ដែលដើរគំរាមកំហែងប្រជាជន ឆក់ប្លន់

ទ្រព្យសម្បត្តិរបស់ប្រជាជន... ហើយក៏នឹងអាចមានកើតបញ្ហារពាក្រក់រពាក្រីផ្សេងៗទៀតដែរហើយមើលទៅ ។

នៅតាមផ្លូវ យើងឃើញមានតែឡានកងទ័ពវៀតណាមបើកចេញចូលជាញឹកញាប់ ហើយក៏មិនដែលបានឃើញឡានទ័ពខ្មែរយើង ដែលលឺគេហៅថា " កងទ័ពរណសិរ្សរំដោះជាតិ " ម្ដងណាឡើយ ហ៊ឺស! គួរឲ្យឆ្ងល់មែន...តើតទៅទៀតស្រុកខ្មែរយើងនឹងស្ថិតនៅក្នុងស្ថានភាពនយោបាយបែបណាទៅហ្ន៎? កូនស្រីទី ៣ និងទី ៤ មិនចង់ធ្វើដំណើរដោយជើងតទៅទៀតទេ ដោយសារមានអីវ៉ាន់ច្រើន ហើយធ្ងន់ផង ពិបាកទូល រែក និងស្ពាយ ។ នាងប្រាប់ទៅឪពុកនាងថា " ពូ សុំឡានគេជិះទៅ! " ។ បង **សយ** ឆ្លើយតបថា " ពួកវាម៉េចនឹងឲ្យយើងជិះ " ។ កូនទីបីតបវិញ ថា " ចុះបើខ្ញុំសុំឡានគេជិះបាន អញ្ចឹងតើពូព្រមជិះឡានទេ " ។ គាត់ ឆ្លើយយល់ព្រម " អ៊ុស " ។ កូនស្រីពីរនាក់របស់ខ្ញុំ ដែលមានវ័យក្មេង ហើយស្អាតដែរនោះ ទៅឈរចាំនៅមាត់ផ្លូវ ឃើញឡានកងទ័ពវៀតណាមបរចេញទៅពោធិ៍សាត់ គេក៏បក់ដៃសុំឡានជិះ ។ ឡានក៏ឈប់ឯក់ កូនខ្ញុំ ស្រែកប្រកូកហៅ " ពូ–ម៉ែង! មក គេឲ្យពួកយើងជិះឡានហើយ " ។ ពេលនោះមិនត្រឹមតែគ្រួសារខ្ញុំមួយប៉ុណ្ណោះទេដែលរត់ប្រញាយមកឡើងឡាន អ្នកដំណើរតាមផ្លូវផ្សេងទៀត ក៏រត់ប្រសាចឡើងឡានដែរ ធ្វើឲ្យអ្នកបើកបរឡាននោះលាន់មាត់ថា " ចយអើយ! " ដោយមានទឹកមុខ ក្រម៉ូវ ។

ឡាននាំពួកយើងមកដល់កាច់ជ្រុងផ្លូវជាតិលេខ ៥ ក្នុងទីរួមខេត្តពោធិ៍សាត់ ហើយក៏ឈប់ឲ្យពួកយើងចុះ ។ កូនស្រីខ្ញុំទាំងពីរដែលទើបចេះពាក្យវៀតណាមមួយម៉ាត់ ពីរម៉ាត់នោះ បានសម្ដែងការគួរសមទៅអ្នកបើកបរថា " កាំអើនៗ អាន់អើយ " ធ្វើឲ្យអ្នកបរបើកនោះសប្បាយចិត្តបន្តិចឡើងវិញ ។

នៅតាមផ្លូវជាតិលេខ ៥ យើងបានឃើញប្រជាជនច្រើនកកកុញ ។

គេដើរទាំងក្រុមៗ មានក្មេងមានចាស់ ខ្លះដើរទៅទិសខាងកើត(ចូលភ្នំពេញ ) តែភាគច្រើនគេទៅទិសខាងលិច ។ ប្ដីខ្ញុំបានជួបមិត្តម្នាក់ដែលនិយាយអន្ទងគាត់ឲ្យរួមដំណើរទៅលិចជាមួយ ។ តែប្ដីខ្ញុំប្រាប់គេវិញថា គាត់ចង់ទៅរកបងប្អូនគាត់ ម្យ៉ាងទៀតគាត់មានកូនសុទ្ធតែស្រីៗ ហើយក៏អត់មានមាសប្រាក់ជាប់នឹងខ្លួនសម្រាប់ការធ្វើដំណើរដែរ ។ មិត្តគាត់បាននិយាយកាត់ថា "មិន អីទេបើនិយាយពីបញ្ហាសោហ៊ុយធ្វើដំណើរ ព្រោះយើងមាននៅសល់មាសពេជ្រខ្លះៗដែរ សយឯងកុំបារម្ភ យើងចែកគ្នារស់ទៅ..."។ ប្ដីខ្ញុំនិយាយអរគុណចំពោះមិត្តគាត់ ហើយប្រាប់ថា " លន់ឯងទៅមុនចុះ ខ្ញុំនឹងទៅតាមក្រោយ..." ។ និយាយសំណេះសំណាលគ្នារួច យើងក៏បែកផ្លូវគ្នា ។ គ្រួសារខ្ញុំត្រូវរកកន្លែងឈប់សម្រាក ដើម្បីទាក់ទងរកឡានធ្វើដំណើរទៅភ្នំពេញ ។ យើងឃើញមានឡានកងទ័ពវៀតណាមបើកបរទៅមក ខ្វាត់ខ្វែង ទៅលិច ទៅកើត ទៅជើង ទៅត្បូង មានផ្ទុកពួកទ័ព ផ្ទុកគ្រឿងសព្វាវុធ និងជួនកាលឃើញមានប្រជាជនជិះផងដែរ ។

ព្រឹកស្អែកឡើង ឃើញមានឡានមួយឈប់នៅលើចញ្ចើមថ្នល់ គ្មានមនុស្សជិះ ក្បាលបែរទៅទិសខាងកើត ហើយមានមនុស្សរត់ប្រសេកប្រសាច ទៅតោងរបាំងក្រោយ តែត្រូវទាហានម្នាក់មកដេញ " ឌី! ឌី! " ។ នៅក្រោមដើមឈើក្បែរឡានឈប់នោះ ឃើញមានមនុស្សឈរពេមទាហានម្នាក់ទៀត ។ ប្ដីខ្ញុំដើរតម្រង់ទៅទីនោះ តែជួបស្ត្រីម្នាក់ដែលទើបចេញពីហ្វូង អ្នកចោមរោម មានទឹកមុខញញឹមញញែម ។ ស្ត្រីនោះនិយាយប្រាប់ប្ដីខ្ញុំថា គេព្រមឲ្យយើងជិះឡានទៅកំពង់ឆ្នាំងហើយ តែត្រូវឲ្យអីៗខ្លះដល់គេ។ ប្ដីខ្ញុំយល់ការណ៍ក៏ដកចិញ្ចៀនដាំត្បូងកណ្ដៀងមួយវង់របស់ខ្ញុំពីកូនដៃរបស់គាត់ទៅបង្ហាញគេៗងក់ក្បាលព្រមឲ្យពួកយើងឡើងឡាន។ ចំណែកឯអ្នកផ្សេង ក៏ឆ្លៀតឱកាសប្រតេងប្រតោងឡើងឡានជាមួយដែរ ហើយក៏មានអ្នកខ្លះទៀត ឡើងមិនទាន់គ្រប់គ្នា ក៏លោតចុះវិញ ដូលច្រងាប់ច្រងិល ព្រោះខ្លាចបែកគ្នា...។ រីឯរូបខ្ញុំវិញ ដែលមិនទាន់ជាស្រួលបួល

នៅប្រើឈើច្រត់ ជាជំនួយ និងដៃស្ដាំនៅចងព្យួរនឹងកនៅឡើយ ក៏ឡើង ឡានមិនទាន់គេដែរ ។ ម៉ាស៊ីនឡានចាប់រោទ៍ ប្រុងចេញដំណើរ ។ ប្ដីខ្ញុំ និងកូនស្រែក " មីងៗ ឆាប់ឡើង ឡើងឡានភ្លាមមក " ។ ពេលនោះខ្ញុំ ខំយកដៃឆ្វេង ចាប់ទ្វារឡាន ខាងមុខ ដោយស្រែកថា " ចុងទូយៗ "( មាន ន័យថាប្ដីខ្ញុំៗ ) ។ ពេលនោះប្ដីខ្ញុំ និងកូនម្នាក់ ចាប់ទាញដៃ ម្នាក់ចាប់ក្រោម ឃ្លៀកខ្ញុំ ទាញមួយទំហឹង ដើម្បីអូសខ្ញុំឡើងឡាន ។ ខ្ញុំមិនទាន់រកកន្លែង អង្គុយបានផង រំពេចនោះឡានក៏ស្ទុះវ៉ឺ ចេញដំណើរធ្វើឲ្យខ្ញុំដួលត្រែតទៅ លើគេឯង ។ អង្គុយបានមួយភ្លែត ខ្ញុំហាក់ដូចជាមានអារម្មណ៍ថា ជើងខ្ញុំ ស្ពឹក នៅគន្លាក់ជង្គង់ ។ ខ្ញុំក៏សើយសំពត់ជាឱបខ្មៅ មើលតើវាមានកើតអ្វី ទៅដែរ? ស្រាប់តែខ្ញុំភ្ញាក់ព្រើត ព្រោះនៅគន្លាក់ជង្គង់ សាច់ខ្ញុំត្រូវដាច់រយះ យ៉ាងធំ ហើយហូរឈាមឥតឈប់ ។ ភ្លាមនោះខ្ញុំភ័យ ហើយចាប់ផ្ដើមមាន អារម្មណ៍កាន់តែឈឺចុកចាប់ ។ មនុស្សម្នាក់ៗនៅលើឡានជួយភ័យត្រប់ៗ គ្នា ព្រោះវាជារបួសមួយ ដាច់សាច់មួយដុំធំ គេសួរខ្ញុំថាកើតអីហ្នឹង? ។ ខ្ញុំក៏អត់ដឹងដែរ តែបើគិត មើលទៅប្រហែលជានៅពេលបង**សយ** និងកូនខ្ញុំ ចាប់អូសទាញខ្ញុំឡើងឡាន ពេលនោះហើយប្រហែលជាជើងរបស់ខ្ញុំត្រូវ ទាក់នឹងដែកអ្វីមួយនៅជិតទ្វារឡាន ធ្វើឲ្យដាច់សាច់រយះធំយ៉ាងនេះ ។ ឃើញសភាពការណ៍នេះ បង**សយ** ប្រាស់ប្រាល សួរទៅអ្នករួមដំណើរជា មួយដើម្បីសុំឲ្យគេជួយខ្ញុំ ។ មានស្ត្រីរួមដំណើរម្នាក់យកថ្នាំជក់ផ្សើមជា មួយទឹក ហើយយកមកបិទលើមុខរបួស ដើម្បីជួយឲ្យសាច់នោះវាស្ពឹក ហើយប្រហែលជាអាចជួយឃាត់ឈាមកុំឲ្យហូរផងដែរក៏មិនដឹង ព្រោះ ឈាមអន់ហូរជាងមុន ។ ប្ដីខ្ញុំហែកក្រមាចាស់ មួយចំរៀក មករុំលើមុខរបួស ព័ទ្ធជុំវិញជង្គង់តែម្ដង ។ ហ៊ឹស! ខ្ញុំអើយ ដូចជាពិបាកជាងគេអ្វីម្ល៉េះហ្ន៎!!...។

ឡានដែលដឹកពួកយើងទាំងអស់គ្នានោះ មិនបានចូលទៅដល់ក្រុង កំពង់ឆ្នាំងនោះទេ ។ គេបញ្ឈប់ឡាននៅជាយក្រុង ហើយបង្ខំឲ្យយើងចុះ ។ ដូច្នេះពួកយើងត្រូវធ្វើដំណើរដោយជើងបន្តទៅទៀត ។ ចំពោះរូបខ្ញុំ ដែល

ពិការទាំងដៃ ហើយឥឡូវពិការទាំងជើងផងនោះ ពុំអាចដើរួចបានឡើយ។ យើង បានសុំរទេះគោជនកៀសខ្លួនម្នាក់ ដែលធ្វើដំណើរទៅក្រុងកំពង់ឆ្នាំងដែរនោះ ជិះទៅជាមួយ ។ ដោយឃើញខ្ញុំមានការពិបាកក្នុងការធ្វើដំណើរបែបនេះ គេក៏អនុញ្ញាតឲ្យខ្ញុំជិះ ។ ពួកកូនខ្ញុំ ប្ដីខ្ញុំ រែកផង ទូលផង ស្ពាយផង ខំប្រឹងដើរឲ្យលឿន ទាន់ខ្ញុំដែលជិះរទេះ ។ ទៅដល់ក្បែរសាលារៀនមួយ យើងក៏ចូលទៅរកកន្លែងសម្រាក ។ យើងស្នាក់នៅក្នុងទីរួមខេត្តកំពង់ឆ្នាំងជាច្រើនថ្ងៃ ពីព្រោះយើងពេញចិត្តនឹងទីនោះ ដោយសារមានអ្វីៗច្រើនសម្រាប់បំប៉នសុខភាព ដែលទ្រុឌទ្រោមយ៉ាងខ្លាំង អស់ពេលជាយូរមកហើយ ។ រាល់ៗព្រឹក ប្ដីខ្ញុំនិងកូន យួរចង់អង្ករដើម្បីទៅដូរយកត្រី បន្លែនិងចំណីអាហារ ផ្សេងៗទៀតមកធ្វើម្ហូប ។ ដោយនៅផ្សារលើនៃខេត្តកំពង់ឆ្នាំង សំបូរទៅដោយលៀស ដែលពួកយើងចូលចិត្ត យើងដូរក្ទុងមួយថ្ងៃៗបានលៀស ១០-២០ កំប៉ុង ដោយចំណាយអង្ករអស់ត្រឹម ៤-៥ កំប៉ុងប៉ុណ្ណោះ ។ យើងឥតភ័យព្រួយនឹងខ្វះអង្ករទេ ពីព្រោះនៅតាមផ្លូវដែលយើងចេញពីបឹងព្រះពន្លៃមក យើងដើរកាត់សហករណ៍ជាច្រើន ដែលមានអង្ករពោរពាស ។ ឲ្យតែយើងមានកំលាំងច្រើន យើងអាចយកអង្ករបានច្រើនការុងក៏បាន ។ នៅកំពង់ឆ្នាំង តែ ១០ ថ្ងៃ លៀសដែលយើងហូបអស់ចោលសំបកចាក់ពេញ ត្រង់សេ ដែលគេជីកក្នុងពេលធ្វើសង្គ្រាម ។

ទោះបីនៅកំពង់ឆ្នាំង យើងទទួលបាននូវការហូបចុក គ្រប់គ្រាន់ក៏ពិតមែនតែយើងពុំអាចនៅទីនោះយូរតទៅទៀតដែរ ។ យើងត្រូវរកមធ្យោបាយបន្តដំណើរចូលក្រុងភ្នំពេញហើយ ។ យើងបានទៅទាក់ទងរកឡាន ដើម្បីធ្វើដំណើរ ។ យើងជួបនឹងស្ត្រីចំណាស់ម្នាក់បែបកូនចៅចិន ចេះនិយាយភាសាវៀតណាម ដែលមានបំណងទៅភ្នំពេញដែរ ។ គាត់ប្រាប់យើងថាគាត់ទាក់ទងគេបានហើយៗសន្យាថាព្រមឲ្យខ្សែដៃទម្ងន់បីជី ជាការដោះដូរជាមួយថ្លៃធ្វើដំណើរ ។ គ្រួសារខ្ញុំក៏បានធ្វើដូចគ្នានេះដែរ ពីព្រោះយើងពុំអាចដើរទៅ ដល់ភ្នំពេញបានឡើយ ។ ឡានចេញដំណើរហើយ...

ប្រហែលជាពីរម៉ោងក្រោយមក ឡានក៏បានមកដល់គីឡូលេខ ៦ ។ គឺនៅទីនេះហើយ ដែលជនភៀសខ្លួននៅក្នុងឡានទាំងអស់ត្រូវចុះ ពីព្រោះគេពុំទាន់អនុញ្ញាតឲ្យជនភៀសខ្លួន ចូលទៅក្នុងក្រុងនៅឡើយ ។ យើងទាំងអស់គ្នាកំពុងរើអីវ៉ាន់ រៀបចំចុះពីឡាន ក៏ប៉ុន្តែស្ត្រីកូនចៅចិនម្នាក់នោះដែលចុះពីឡានមុនយើងបន្តិច បានទៅនិយាយជាមួយអ្នកបើកបរជាភាសាវៀតណាម រួចបានឡើងមកប្រាប់គ្រួសារគេវិញថា " គេព្រមជូនយើងទៅដល់បែកចានហើយ " (ឃុំបែកចានឋិតនៅលើផ្លូវជាតិលេខ ៤ ចំងាយប្រហែលជាង ២៥ គីឡូម៉ែត្រ ពីក្រុងភ្នំពេញ ) ។ ពួកខ្ញុំដែលកំពុងទាញឥវ៉ាន់ប្រុងចុះពីលើឡានដែរ ក៏ផ្អាក ដំណើរ ហើយសុំឲ្យអាចែនោះជួយប្រាប់គេអនុញ្ញាតឲ្យពួកខ្ញុំចូលទៅដល់ក្រុងផង ។ គាត់និយាយថា " ចែឯងធ្វើដូចមិនដឹងទៅ បើចង់ចុះនៅទីណា ចាំប្រាប់ឲ្យឡានឈប់ទៅ " ។ ឡានចាប់បរទៅមុខ ក្រោយពេលដែលអ្នកជិះមួយចំនួនចុះអស់ នៅសល់ប្រហែលជាង ១០ នាក់ប៉ុណ្ណោះ គឺមានតែគ្រួសារខ្ញុំ និងគ្រួសារចែនៅបែកចាននេះឯង ។

មកដល់មុខសកលវិទ្យាល័យភ្នំពេញ យើងសុំចុះនៅទីនោះ ។ ពេលជិតព្រលប់ទៅហើយ យើងរកកន្លែងដាំបាយ និងសម្រាកពេលយប់ ។ ផ្ទះនៅតាមផ្លូវសហភាពសូវៀតម្តុំនោះ ឥតទាន់មានមនុស្សចូលមកនៅនៅឡើយទេ នៅក្នុងខែ ៥ នេះ ។ យើងសម្រាកជាបណ្តោះអាសន្នមួយយប់នៅផ្ទះល្វែងមួយ ហើយព្រឹកស្អែកឡើង ទើបប្តីខ្ញុំទៅដើររកមើលផ្ទះចាស់របស់ខ្ញុំនៅម្តុំ អាងទឹកស្តាដអូឡាំពិក ជាមួយកូនស្រីទី ៤ ដើម្បីមានបំណងចង់ទៅរស់នៅទីនោះវិញ ។ ពេលត្រឡប់មកវិញ គាត់ប្រាប់ខ្ញុំថា " យើងត្រូវផ្លូវទៅនៅផ្ទះមួយនៅជិតនេះសិនហើយ គឺនៅម្តុំខាងជើងសាលាសន្ធរម៉ុក " ។

" ចុះម៉េចមិនទៅផ្ទះយើងវិញ? " គាត់ប្រាប់ទៀតថា គាត់ឥតបានចូលទៅដល់ម្តុំផ្ទះចាស់នោះទេ ព្រោះគេដេញមិនឲ្យចូល ។ យើងក៏រៀប

ចំដូរកន្លែងទៅនៅផ្ទះ ដែលគាត់បានជ្រើសរើសនោះ ។ គឺទីកន្លែងនោះហើយ ដែលគ្រួសារខ្ញុំបន្តការស្នាក់នៅជារៀងរហូតមកដល់សព្វថ្ងៃ ហើយឥឡូវវាក៏ ក្លាយទៅជាកម្មសិទ្ធិរបស់ខ្ញុំទៅហើយដែរ ។ បងសយជ្រើសរើសរស់នៅម្តុំនោះ ព្រោះណាមួយជិតសាលាកូនរៀនផង និងអាចរកស៊ីលក់ដូរបានផង ។ បង**សយ**ជ្រើសយកផ្ទះតូចមួយមានពីរបន្ទប់ សង់កំពស់ ស្មើកខ្ពស់ពីដី មានភ្លើងអគ្គីសនី មានទឹកម៉ាស៊ីន ជាពិសេសមានដីទំនេរដល់ទៅពីរឡូតិ៍ជាប់គ្នា (ឡូតិ៍ទំហំ ២០ x ៣០ ) អាចដាំបន្លែបង្ការបានច្រើន ។ វាត្រូវនឹងបំណងរបស់យើងហើយ ។ យើងមានចបកាប់ ចបជីក ផ្លែចបពូថៅតូច ពូថៅធំ និងគ្រាប់ពូជ...។ បងសយតែងនិយាយជាញឹកញាប់ថាចង់រស់នៅជាប្រជាជនសមញ្ញ មិនចង់ធ្វើជាមន្ត្រីរាជការ ឬជាអ្នកនយោបាយ អ្វីទៀតទេ វាឆ្អែតចិត្តពេកហើយ ! ។

បី បួនថ្ងៃក្រោយមក មានលោកគ្រូម្នាក់ដែលធ្លាប់ចូលរួមធ្វើមិទិញ នៅ " ហ្សាក់ប៉េដា " ជាមួយគ្នា បានប្រាប់ខ្ញុំថា " លោករដ្ឋមន្ត្រីក្រសួងអប់រំចង់ជួបបងឯង និងបងប្រុស " ។ រំលងប៉ុន្មានថ្ងៃក្រោយមក ខ្ញុំក៏ទៅជួបលោករដ្ឋមន្ត្រីនៅក្រសួងអប់រំ ដែលស្ថិតនៅមុខវត្តប្រយូរវង្ស ព្រោះខ្ញុំធ្លាប់ស្គាល់គាត់ កាលនៅរៀនសាស្ត្រាចារ្យមុខវិជ្ជារូប-គីមីជាមួយគ្នា គឺលោករដ្ឋមន្ត្រី **ចាន់ វ៉េន** ។ លោករាក់ទាក់យ៉ាងខ្លាំង ស្វាគមន៍ខ្ញុំឲ្យចូលធ្វើការវិញ... ហើយក៏ផ្តាំខ្ញុំថា លោកក៏ចង់ជួបផ្ទាល់នឹងប្តីខ្ញុំដែរ ។ មួយសប្តាហ៍ ក្រោយមកប្តីខ្ញុំក៏ព្រមទៅជួបគាត់ តាមការអង្វររបស់ខ្ញុំ ។ ពេលជួបមានការសន្ទនាគ្នាយ៉ាងច្រើន លើបញ្ហាក្នុងរបបខ្មែរក្រហម លើបញ្ហារំដោះភ្នំពេញ និងជាពិសេស បញ្ហាកងទ័ពវៀតណាមនៅកម្ពុជាតែម្តង ។ លោករដ្ឋមន្ត្រីបាននិយាយតបវិញថា " បងធ្លាប់យល់អំពីរបបអន្តរជាតិវណ្ណៈអធន ហើយតើបើវៀតណាមគេមានអ្វី យើងក៏អាចមានអ្វីនោះដែរ បានសេចក្តីថា បើវៀតណាមមានឡានជិះ ខ្មែរយើងក៏មានឡានជិះ បើគេមានកង់ជិះ យើងក៏មានដែរ... មែនទេ? " ។ ប្តីខ្ញុំជ្រួញចិញ្ចើម រួចក៏ឆ្លើយតបវិញថា មិន

ព្រោកដជាបែបនឹងទេ ។ ការចរចាគ្នាមានរយៈពេលមួយសន្ទុះធំដែរ តែក៏នៅមិនទាន់ចុះសម្រុងគ្នានៅឡើយ ។ ប្ដីខ្ញុំនិយាយបញ្ចប់ថា " បើអញ្ចឹងមិនថ្វីទេ ចាំខ្ញុំទៅគិតគូរជាមួយប្រពន្ធកូនសិន " ។ មុនពេលគាត់លាចេញត្រឡប់មកផ្ទះវិញ លោករដ្ឋមន្ត្រីបាននិយាយសន្យាជាច្រើន ដើម្បីទាក់ទាញឲ្យបងសយចូលមករួមចំណែកធ្វើការដឹកនាំនៅក្នុងវិស័យអប់រំ សម័យនោះជាមួយគាត់ ដូចជាផ្ដល់ឋានៈ តួនាទី និងលំនៅដ្ឋានដ៏សមរម្យមួយ ឲ្យគ្រួសារខ្ញុំ ។ មកដល់ផ្ទះវិញ បង**សយ**បានរាយរ៉ាប់អំពីការសន្ទនានោះ ប្រាប់ដល់ខ្ញុំ ហើយធ្វើសេចក្ដីសន្និដ្ឋានថា " ខ្ញុំមិនយល់ដូចលោករដ្ឋមន្ត្រី នោះទេ ពីព្រោះខ្ញុំយល់ច្បាស់អំពីធាតុពិតរបស់ពួកវៀតណាម ដោយយោលទៅលើប្រវត្តិនៅក្នុងអតីតកាលផង ការតស៊ូរំដោះឥណ្ឌូចិនអំពីពួកអាណានិគមនិយមបារាំងផង និងជាពិសេសការចូលមករំដោះតំបន់ខ្លះនៃប្រទេសខ្មែរយើង ( ឆ្នាំ ១៩៧០ ) ជាមួយពួកខ្មែរក្រហមផង ។ ពួកគេតែងតែយកប្រៀបចំណេញ លើខ្មែរយើងជារៀងរហូតមក ។ ដូច្នេះខ្ញុំយល់ថាការមកជួយរំដោះប្រទេស ខ្មែរយើងពីពួកខ្មែរក្រហមក្នុងពេលនេះ ពិតជាស្ថិតនៅក្នុងមហិច្ឆិតាចង់បានចំណេញអ្វីមួយពីខ្មែរយើងជាមិនខាន " ។ អញ្ចឹងហើយបានជាគាត់ធ្វើសោះអង្គើយ ចំពោះការអំពាវនាវហៅចូលទៅធ្វើការអំពីលោករដ្ឋមន្ត្រីក្រសួងអប់រំនោះ ។ ទោះបីលោកសន្យាផ្ដល់បុណ្យសក្តិប៉ុនណាក៏ដោយ ក៏បង**សយ**ឥតរំភើប ឬក៏ចង់ប្ដូរគោលគំនិតរបស់គាត់ដែរ ។

ដោយឆ្អែតនឹងបញ្ហានយោបាយ និងការងារក្នុងរដ្ឋការ បង**សយ**ក្ដី ខ្ញុំក្ដីបានសម្រេចចិត្ត ប្ដូររបៀបរស់នៅ ទៅតាមបែបប្រជាជនសមញ្ញ គឺរកស៊ីលក់ដូរនៅតាមផ្សារដើម្បីចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ ។ ដំបូង កូនស្រីរបស់ខ្ញុំលក់ទឹកកកឈូសនៅមុខសាលាសន្ធរម៉ុក ។ កូនស្រីខ្លះៗ ទៀតលក់របស់កំប៉ិកកំប៉ុកនៅតាមចិញ្ចើមថ្នល់ ។ គាប់ជួនពេលនោះ គេឲ្យអ្នកលក់ដូរនៅតាមចិញ្ចើមថ្នល់ដូរទៅលក់នៅក្នុង " ការ៉ាសតាបុល " ដែលនៅក្រោយសាលាសន្ធរម៉ុកវិញ ។ ខ្ញុំលក់សារុងពុម្ព ក្រណាត់ និងឥវ៉ាន់ ចាប់ហួយ

ខ្លះៗ។ កូនខ្ញុំរែរទេះលក់ទឹកកកឈូសពីមុខសាលា មកលក់នៅក្នុងផ្សារថ្មីនេះដែរ ។ រាល់ពេលព្រឹក បងសយតែងតែជិះកង់ទៅដឹកស្ករត្នោត មកឲ្យកូនធ្វើទឹកស្ករ ដាក់ទឹកកកកូត ។ សល់ពេលគាត់តែងទៅផ្សារ ផ្សេងៗទៀត នៅទួលទំពូង និងនៅផ្សារអំពៅ (មានតែផ្សារធំពីរនេះទេ ដែលបើកលក់នៅពេលនោះ)។ គាត់ទិញចាន កាំបិត កន្ត្រៃ សោរចាស់ៗ និងគ្រឿងផ្សំសម្លមានស្ករស ខ្ទឹម ម្រេច មកទុកឲ្យខ្ញុំដាក់លក់ ។ គាត់ធ្វើសកម្មភាពបែបនេះរៀងរាល់ថ្ងៃ ។ គ្រួសារខ្ញុំរកបានចំណូលច្រើនគួរសមដែរ គឺក្នុងមួយថ្ងៃៗរកបានអង្ករពីរ–បី ការុង (បើដូរជាមាស បានប្រហែល ២–៣ ជីដែរ) ។

ដំណឹងដ៏ក្រៀមក្រំមួយបានលេចលឺដល់គ្រួសារខ្ញុំ ព្រោះបងសយក្នុងពេលដើរទិញឥវ៉ាន់ បានជួបនឹងបងជីដូនមួយខ្ញុំម្នាក់ ដែលសួររកខ្ញុំ ។ បង**សយ** ប្រាប់គាត់ថា ខ្ញុំនៅផ្ទះឯមុខសាលាសន្ធរម៉ុក ។ ចែឡាង ( បងជីដូនមួយនោះ ) បានលាន់មាត់ប្រាប់បងសយថា " អូ! បើអញ្ចឹង គ្រួសារពូឈុំមិន ទាន់ដាច់ពូជទេ គឺនៅសល់អាហ៊ុចម្នាក់ដែរ " ។ បង **សយ** មិនយល់សោះថា ចែឡាងចង់និយាយថាម៉េច ។ ជាបន្ទាន់នោះ **ចែឡាង** បាននិយាយប្រាប់អំពីមរណៈភាពយ៉ាងខ្លោចផ្សារបស់ម៉ែ ឪ និងបងប្អូនកូនក្មួយខ្ញុំ ដែលត្រូវពួកខ្មែរក្រហម យកទៅសម្លាប់គ្មានសល់នរណាម្នាក់ឡើយ សូម្បីតែឪពុក ម្ដាយ ចាស់ជរា និងកូនង៉ារបស់ក្មួយខ្ញុំ ក៏គេឥតទុកឲ្យរស់រានមានជីវិតដែរ ។ ប្ដីខ្ញុំនឹកសង្វេគក្នុងចិត្ត រួចសួរនាំអំពីទីកន្លែងស្នាក់នៅរបស់គាត់ ដើម្បីឲ្យខ្ញុំទៅសាកសួរនាំអំពីរឿងដ៏សោកសៅនេះដោយផ្ទាល់ ។ ដំណឹងនេះ បានធ្វើឲ្យខ្ញុំបាត់បង់អស់នូវសតិស្មារតីប្រៀបបាននឹងវត្ថុមួយដែលគ្មានវិញ្ញាណ ។ ខ្ញុំយំ ខ្ញុំសោកសង្រេងក្ដុកក្ដួលក្នុងចិត្តយ៉ាងក្រៃលែង ។ ការបាត់បង់ជីវិតដ៏ មានតម្លៃទាំងអស់នោះ ចំពោះខ្ញុំវាតែងមកញាំញីជីវិតខ្ញុំ ជារៀងរាល់ថ្ងៃ ខែ ឆ្នាំ រហូតមកទល់សព្វថ្ងៃនេះ ។

| | |
|---|---|
| – អ្វីដែលខ្ញុំនឹក គិតថា "ស្តាយ" | ពីក្មេងរៀងអាយ ដល់សព្វថ្ងៃ |
| គឺការបាត់បង់ ពុកម៉ែថ្លៃ | ដែលគេប្រល័យ ទាំងគ្រួសារ ។ |
| – "ស្តាយ"ព្រោះឥតបានដឹងទំនង | ដំណើរដើមទង នៃសង្ខារ |
| "ស្តាយ" ព្រោះឥតបានគតវេទិតា | "ស្តាយ"ពេលវេលា គ្មានត្រឡប់ ។ |

ចាប់ពីពេលនោះមក ព័ត៌មានស្ដីអំពីការស្លាប់របស់ញាតិមិត្ត និងអ្នកដែលខ្ញុំធ្លាប់ស្គាល់បានលេចលឺជាបន្តបន្ទាប់ដែរ ។ ដោយឡែក បងសយគាត់នៅមានកិច្ចការសំខាន់ និងចាំបាច់ដែលត្រូវធ្វើ គឺទៅរកបងប្អូនរបស់គាត់ដែរ ។ អញ្ចឹងហើយការផ្តល់ព័ត៌មានទៅឲ្យលោករដ្ឋមន្ត្រីក្រសួងអប់រំក៏ត្រូវពន្យារពេលពីមួយថ្ងៃទៅមួយថ្ងៃ រហូតដល់ពេលមួយនោះ គេប្រាប់ថាឃើញលោកមកសាលាសន្ធរម៉ុក ជួបនឹងលោកនាយកសាលា(ស៊ឹម ស្វាម៉ា) ពីរ–បី ដងដែរ ។ ពេលមកម្ដងៗ លោករដ្ឋមន្ត្រីតែងឈរសម្លឹងទៅទិសខាងជើងសាលា ហើយចង្អុលទៅផ្ទះដែលខ្ញុំរស់នៅ គឺនៅលើផ្លូវក្រោយទល់មុខក្លោងទ្វារខាងជើងសាលានោះ។ ខ្ញុំឥតបានចាប់អារម្មណ៍នឹងព័ត៌មានទាំងអស់នោះទេ ។

បងសយត្រូវធ្វើដំណើរទៅខេត្តសៀមរាប ដើម្បីសាកសួរព័ត៌មានពីបងប្អូនគាត់ អស់រយៈពេលប្រហែលមួយសប្តាហ៍ ។ គាត់ក៏អស់សង្ឃឹមក្រៃលែងដែរ ។ បងៗរបស់គាត់ ដូចជា បងស្រី **ពីន សេន** និងគ្រួសារស្លាប់ទាំងអស់គ្នា បងស្រី **ពីន សាន** និងកូន ២ នាក់ បង **ពីន ស៊ាន** ហៅពីប្អូន **ពីន គីមស៊ា** និងភរិយា ព្រមទាំងកូន ២ នាក់ ប្អូន **ពីន គីមសួរ** និងកូនទាំង ៤ នាក់ ព្រមទាំងក្មួយៗ បានស្លាប់ទាំងគ្រួ ក្នុងនោះមាន **ស៊ាន អាន** និងភរិយា **ទ្រាំ សៀង** ដែលជាក្មួយផងដែរ ។ បងសយបានត្រឡប់

មកដល់ភ្នំពេញវិញ ជិតព្រលប់ទៅហើយ ។ បងសយបានរៀបរាប់អំពីរឿងរ៉ាវទាំងនោះប្រាប់ខ្ញុំ។ ខ្ញុំក៏ចូលរួមសោកសង្រេងជាមួយគាត់ដែរ ព្រោះខ្ញុំក៏ស្រឡាញ់បងប្អូនរបស់គាត់ ដូចជាគ្រួសាររបស់ខ្ញុំអញ្ចឹងដែរ ។ ពួកគាត់ជាគ្រួសារល្អ ដែលចេះជួយគ្នាទៅវិញទៅមក គួរឲ្យគោរព និង ស្រឡាញ់ ។ ដើម្បីជួយបន្ធូរភាពតឹងតែងក្នុងអារម្មណ៍របស់បងសយ ខ្ញុំក៏បាននិយាយលួងលោមគាត់ថា "ទោះជាយ៉ាងណា ក៏បងមានសំណាងជាងខ្ញុំដែរ បងមាននៅសល់សាច់បង្កើតខ្លះ មានបងប្រុសមួយ បងស្រីមួយ និងកូនក្មួយបង្កើតសន្ធឹកដែរ មិនដូចខ្ញុំ ដែលបងប្អូនស្លាប់ ស្ទើរផុតពូជអស់នៅសល់តែខ្ញុំម្នាក់ឯង " ។

ព្រឹកឡើងគឺថ្ងៃបន្ទាប់(ថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៧៩) បងសយដឹកដៃកូនស្រីពៅ និងកាន់ថង់អង្ករទៅរកទិញនំប៉័ង ។ គ្រាន់តែចេញផុតពីច្រកមុខផ្ទះ មានមនុស្ស ២ នាក់ ស្ទុះចេញពីឡាន ដែលចតនៅលើផ្លូវកម្ពុជាក្រោមមកចាប់ក្រៀកគាត់ចងស្លាបសេក យកក្រណាត់ខ្មៅមកចង រុំមុខគាត់រួចរោក់គាត់បញ្ចូលឡាន ។ កូនស្រីពៅរបស់ខ្ញុំភ័យខ្លាំង ក៏ស្រែកយំ ព្រោះមិនដឹងថាមានរឿងអ្វីកើតឡើង ចំពោះឪពុករបស់នាង ។ សំឡេងស្រែកយំនោះក៏ធ្វើឲ្យអ្នកជិតខាងម្នាក់លឺ ហើយក៏រត់មកហៅកូនស្រីធំ របស់ខ្ញុំដើម្បីប្រាប់ពីព្រឹត្តិហេតុនោះ។ កូនស្រីធំខ្ញុំកន្ត្រាក់កង់ជិះតាមឡាន ដែលកំពុងពេទ៍ម៉ាស៊ីន មុនពេលបរចេញទៅ។ គឺជាឡាន(ម៉ែរសឺដេស) ពណ៌ខ្មៅមានលេខខាងចុងសូន្យសូន្យ។ឃើញតែប៉ុណ្ណឹងឡានបរលឿនតាមលែងទាន់ ទើបនាងត្រឡប់មកវិញ ឃើញប្អូនពៅរបស់នាងកំពុងឈរយំនៅឡើយ។ នាងទាញដៃប្អូនចូលក្នុងផ្ទះ រួចឡើងកង់ទៅប្រាប់ខ្ញុំដែលកំពុងរៀបឥវ៉ាន់សម្រាប់លក់នៅផ្សារតាបុលនោះ ។ ខ្ញុំស្រែកហៅម៉ែអាភ័ណ្ឌ (អ្នកលក់មាសនៅមុខរានរបស់ខ្ញុំ ) ឲ្យជួយទៅប្រាប់កូនលក់ទឹកកក មកសាឥវ៉ាន់ទុក ។ ចំណែកខ្ញុំរត់មកផ្ទះជាប្រញាប់ ។ មកដល់ផ្ទះ ខ្ញុំឃើញ មនុស្ស ៥-៦ នាក់ស្លៀកពាក់ខោអាវស៊ីវិល ឈរនៅក្បែរជណ្តើរផ្ទះ ។ ខ្ញុំមិនទាន់ទាំងបាន

សួរពួកគេថាអញ្ជើញមករកនរណា ឬមានការអ្វីដែរផង សំណួរចោទប្រកាន់មួយបានសំឡុតខ្ញុំយ៉ាងខ្លាំងថា " តើមីឯងឯងលាក់កាំភ្លើងនៅឯ ណា? " ។ ខ្ញុំបើកភ្នែកធំៗឥតប៉ប្រិច សំឡឹងចំទៅម្ចាស់សំណួរ ។ ណាមួយខ្ញុំមិនយល់នឹងសំណួរគេ ណាមួយទៀតខ្ញុំនៅតក់ស្លុតនឹងដំណឹងដែលកូនខ្ញុំទើបតែប្រាប់នៅឡើយ ។ ខ្ញុំតបយ៉ាងម៉ឺងម៉ាត់ថា " សុំលោកអញ្ជើញមើលទៅចុះ កុំថាឡើយកាំភ្លើងមួយដើម សូម្បីតែគ្រាប់កាំភ្លើងមួយគ្រាប់បើលោករកឃើញ លោកបាញ់ខ្ញុំចោលទៅចុះ..." ។ គេឥតនិយាយតបមកខ្ញុំវិញទេ គេហុតក្រដាសមួយសន្លឹកហុចឲ្យខ្ញុំអាន ដែលជាដីកាឆែកឆេរផ្ទះចុះហត្ថលេខាដោយ " សមមិត្តហុង " ។ ខ្ញុំឥតដឹងថា សមមិត្តហុងនោះជានរណាទេ មានឋានៈឬតួនាទី អ្វីក៏ឥតដឹងដែរ តែឃើញមានបោះត្រាចេញពីក្រសួងមហាផ្ទៃ ។ ការឆែកឆេបានធ្វើឡើងយ៉ាងឆាប់ ពីព្រោះផ្ទះខ្ញុំតូច គ្មានកន្លុកកន្លៀត គ្មានអីវ៉ាន់អីវ៉ាន់ច្រើន...។ ឆែកបណ្ដើរ គេជជីកសួរខ្ញុំបណ្ដើរ "តើប្ដីរបស់មីឯងឯង ធ្វើអ្វីនៅសម័យអាពត? "។ ខ្ញុំឆ្លើយតាមដំណើរការណ៍ តែគេនៅតែបង្ខំខ្ញុំឲ្យឆ្លើយត្រង់ថា ប្ដីខ្ញុំធ្វើកុងស៊ីយ៍នៅក្រសួងនេះ ក្រសួងនោះ។ តែខ្ញុំបដិសេធ ព្រោះពុំមែនជាការពិត " បើប្ដីខ្ញុំធ្វើកុងស៊ីយ៍មែនមុខវា គេមិនឲ្យគាត់នាំប្រពន្ធកូន ដើរសោត់អណ្ដែតបែបនេះទេ! ។ ការពិតទៅ គាត់ជាអ្នកក្នុងជួរដែលគេមិនទុកចិត្ត និងទុកចោល លែងនឹកនាតាំងពីក្រោយថ្ងៃ ១៧ មេសា មកម្ល៉េះ... " ។ ទោះបីជាខ្ញុំខំនិយាយការពិតប្រាប់គេយ៉ាងណាក៏ដោយ ក៏គេហាក់ដូចជាមិនយកចិត្តទុកដាក់នឹងសំដីទាំងនោះសោះ ។ ពួកគេរកឃើញម៉ាស៊ីនថតម៉ាកកាណុងមួយ ( វាតាំងថត លែងកើតទៅហើយ ) គេយកមកមើល ហើយយកទៅទុកមួយជុំឃើញ មានថ្នាំពេទ្យជាច្រើនកញ្ចប់ទៀត ហើយសួរថា " " មីឯងឯងយកថ្នាំនេះមកពីណា ហើយប្រុងយកទៅផ្គត់ផ្គង់នរណាគេដែរ? "។ ខ្ញុំឆ្លើយតាមហេតុការណ៍ពិត " គឺថ្នាំដែលខ្ញុំទិញពីក្មេងៗ ដែលដើរប្រមូលបានតាមផ្ទះតាមឃ្លាំងថ្នាំ ដែលនៅម្ដុំមន្ទីរផលិតថ្នាំ ។ ខ្ញុំទិញពីពួកគេនោះ ដើម្បីយកទៅលក់បន្តនៅផ្សារ " ។ គេនៅស្មៀមរមក៏ប្រមូលយកថ្នាំទាំងនោះ ព្រម

ទាំងម៉ាស៊ីនថតផងដែរ ។ បន្ទាប់មកគេក៏ចេញទៅវិញអស់ទៅ ។ខ្ញុំច្របាច់ច្រមុះ បន្តិចដែរ ពីព្រោះពួកគេឥតបានឆែកឃើញគ្រឿងអលង្ការ កំប៉ិចកំប៉ុករបស់ខ្ញុំ រួមទាំងមាសមួយចំនួន ដែលប្អូនថ្លៃរបស់បងសយ ( នាងស៊ីនលី) ផ្ញើទុក ដោយសារគេយកតាមខ្លួនមិនអស់ មុនពេលគេរត់ទៅជំរុំ ។ ពួកមហាផ្ទៃ ទៅបាត់មែន តែខ្ញុំនៅតែញ័រជើង ហើយរិតតែញ័រខ្លាំងថែមទៀត ព្រោះខ្ញុំ បានស្តាប់ការរៀបរាប់របស់កូនខ្ញុំ អំពីការចាប់ចងឪពុករបស់គេ ។ ខ្ញុំស្តាប់ ទាំងស្លុតស្មារតីពីព្រោះទិដ្ឋភាពបែបនោះ វាកាចសាហាវពេកណាស់ ប្រៀប ដូចជាការចាប់ចោរប្លន់ រឺឃាតករឃោរឃៅ ដែលកំពុងធ្វើសកម្មភាពកាប់ សម្លាប់មនុស្សយ៉ាងព្រៃផ្សៃ ។ តើប្តីខ្ញុំជាមនុស្សបែបនឹង ឬ បានជាត្រូវបាន គេចាប់ចងស្លាបសេក រុំមុខ រួចដាក់បញ្ចូលឡាន នៅចំពោះមុខកូនស្រីតូច ម្នាក់ដែលនៅមិនទាន់ដឹងក្តីនៅឡើយនោះ ? ។

តទៅទៀត ខ្ញុំមិនដឹងថាតើខ្ញុំត្រូវធ្វើអ្វីទៀតទេ ។ តែទោះជាយ៉ាងណា ក៏ខ្ញុំត្រូវដើរទៅស៊ើបសួរគេឯង ដើម្បីឲ្យដឹងថាតើក្រុមណាមកចាប់ប្តីខ្ញុំ ? តើគេយកគាត់ទៅទីណា? ហើយពីព្រោះអ្វី ។ល។ ខ្ញុំទៅផ្ទះសំពត់អាវ ប្រុង ទៅរកជួបគេ ។ ខ្ញុំនឹកឃើញមនុស្សម្នាក់ គឺក្មួយស្រីជីដូនមួយរបស់ខ្ញុំ ដែលប្តី នាងជាប្អូនធម៌របស់ជំនាញការវៀតណាមម្នាក់ ។ ខ្ញុំក៏ទៅទាក់ទងជាមួយ នាងនោះ ។ នាង (ខេន) រាក់ទាក់ទទួលខ្ញុំ និងធានាជួយខ្ញុំ ។ នាងបាន នាំខ្ញុំទៅជួប "សមមិត្តហុង" ( ឈ្មោះដែលខ្ញុំចាំ នៅក្នុងដីកាឆែកឆេ) នៅ ក្រសួងមហាផ្ទៃក្រោយវាំង ។ នាងខេន និងខ្ញុំនៅចាំអស់មួយព្រឹកធំ នៅ មាត់ជណ្តើរអគារខាងត្បូង ដែលគេប្រាប់ថា " បងហុង " នៅធ្វើការក្នុង បន្ទប់ជាន់ទីមួយនៃអគារនោះ ។ ចាំយ៉ាងយូរ នៅតែឥតបានជួបក៏សម្រេច ចិត្តមកផ្ទះវិញ ព្រោះឃ្លានបាយឡើងញ័រខ្លួន ។ ព្រឹកស្អែកឡើង យើងទាំង ពីរនាក់ទៅក្រសួងមហាផ្ទៃទៀត ។ គ្រាន់តែឃើញយើង ប្រុងចូលទៅប៉ុស្តិ៍ យាម គេស្រែកដេញថា " ឌី! ឌី! " ។ ក្មួយស្រីខ្ញុំនិយាយតបវិញថា " ខ្ញុំមករកជួបបងហុង " ។ អ្នកយាមម្នាក់ ទៀតដែលជាជនជាតិខ្មែរបានសម្លឹង

បើលយើងហាក់ដូចជាចង់និយាយអ្វីប្រាប់ ។ ក៏ប៉ុន្តែឆ្មាំទ្វារវៀតណាម ស្រែកគំហកមកទៀតថា ឌី! ឌី! ដោយធ្វើដៃជាសញ្ញាដេញ ។ យើងពុំអាចនៅរួសតទៅទៀតទេ ត្រូវតែដើរចេញ ។ ក្រោយមកមានមិត្តនារីរបស់ខ្ញុំម្នាក់ដែលបានដឹងរឿងនេះដែរ ក៏នាំខ្ញុំទៅជួបនឹងប្រពន្ធសមមិត្ត **ហុង** ដែលគេធ្លាប់ស្គាល់ ។ ផ្ទះសមមិត្តហុងនោះ ស្ថិតនៅលើផ្លូវពេងជ័រ ក្បែរវាំង ។ អ្នកស្រីប្រពន្ធសមមិត្ត ហុង ទទួលពួកយើងស្តាប់យើងនិយាយរហូតដោយឥតមានឆ្លើយតប អ្វីក្រៅពីពាក្យថា " ចាំ ចាំ " ។ នៅទីបញ្ចប់ អ្នកស្រីបាននិយាយថា " មិនអីទេ ចាំខ្ញុំសួរបង **ហុង** ឲ្យ " ។ ចាប់ពីពេលនោះមកខ្ញុំរង់ចាំដំណឹង ក៏ប៉ុន្តែស្ងាត់ឈឹង ទោះបីខ្ញុំព្យាយាមសុំទៅជួបអ្នកស្រីនោះម្តងពីរដងទៀត ក៏គេមិនព្រមឲ្យជួបដែរ ដោយយកលេសថាគាត់ឥតនៅផ្ទះ។ ខ្ញុំនៅតែស្វះស្វែង ស៊ើបសួររកព័ត៌មានដើម្បីឲ្យដឹងថាគេចាប់ប្តីខ្ញុំយកទៅណា ហើយតើគាត់រស់ ឬ ស្លាប់ ។ តាមរយៈប្តីនាង **ខេន** គេប្រាប់ខ្ញុំថាបងធម៌របស់គេដែលជា ជំនាញការវៀតណាមនោះ បានប្រាប់ឲ្យខ្ញុំទៅជួបលោករដ្ឋមន្ត្រីក្រសួងអប់រំទៅ ។ ខ្ញុំក៏ធ្វើតាមការណែនាំ ។ នៅពេលទៅជួបជាមួយលោករដ្ឋមន្ត្រី លោកនិយាយបែបសោះអង្គើយថា ពុំអាចជួយអ្វីដល់ខ្ញុំបានទេ ។ ប្រហែលជាមួយអាទិត្យក្រោយមក មានភ្នាក់ងារសង្កាត់ទំកល្អក់ម្នាក់យកសំបុត្រតូចមួយ សរសេរដោយដៃសុំអញ្ជើញខ្ញុំទៅសាលាក្រុងដើម្បីសួរចម្លើយ ។ បងប្អូនខ្ញុំ ម្នាក់ដែលធ្វើការនៅសង្កាត់ដែរនោះ មានការបារម្ភជួសខ្ញុំ ព្រោះគេយល់ថា ប្រហែលជាខ្ញុំត្រូវគេចាប់ទៀតហើយ។ គេឲ្យយោបល់ថា គួរឲ្យបងប្អូនណាម្នាក់ជូនខ្ញុំទៅ ហើយនៅចាំរហូតដល់ឃើញខ្ញុំចេញមកវិញ ។ នៅទីនោះ មានវៀតណាមពីរនាក់ (ម្នាក់ចេះខ្មែរ និយាយប៉ៃឡាំ និងខ្មែរម្នាក់ទៀតជាមន្ត្រីក្រសួងមហាផ្ទៃ គេហៅឈ្មោះថា ស–ម **សេន**) បានអង្គុយរង់ចាំក្នុងបន្ទប់សួរចម្លើយខ្ញុំនោះ ជាស្រេច ។ ដំបូងគេ សួរអំពីប្រវត្តិរូបរបស់ខ្ញុំ តាំងពីក្មេងរហូតដល់សព្វថ្ងៃ ។ សួរវេចខ្ចីរ គ្មានចន្លោះ ហើយខ្ញុំក៏ឥតមានការលាក់លៀមអ្វីដែរ ។

រហូតដល់ម៉ោង ១២ ថ្ងៃ ត្រង់ ទើបវៀតណាមដែលជាអ្នកចោទសំណួរ និយាយប្រាប់វៀតណាមម្នាក់ទៀតថា "ឲ្យគាត់ទៅហូបបាយសិនចុះ ចាំម៉ោង ២ រសៀល យើងធ្វើការបន្តទៀត "។ ខ្ញុំត្រូវបានគេដោះលែងហើយ ។ កូនស្រីទី ៤ របស់ខ្ញុំ ដែលបានចាំខ្ញុំ តាំងពីម៉ោង ៧ ព្រឹក ស្ទុះហោ មកទទួលខ្ញុំនៅមាត់ជណ្ដើរ ហើយសួរយ៉ាងតក់ក្រហល់ថា " មេចទៅម៉ែ? គេមានសំឡុតម៉ែ ឬធ្វើបាបអ្វីទេ? " ខ្ញុំញញឹមស្ងួតរកគេ ដោយនិយាយបន្លប់ថា "ឥតមានអីទេ! មកទៅផ្ទះ ម៉ែឃ្លានបាយហើយ " ។ នាងទៅទាញកង់កញ្ចាស់ ដែលផ្អែកនឹងសរសេរឆ្ងាយពីមាត់ជណ្ដើរ ហើយឌុបខ្ញុំយ៉ាងញញាក់ញញ័រ វេដៃចង្កូតម្ដងទៅឆ្វេង ម្ដងទៅស្ដាំ ធ្វើឲ្យខ្ញុំលោតចុះពីកង់ ម្ដងពីរដងទំរាំដល់ផ្ទះ ។ ម៉ោង២រសៀល ខ្ញុំត្រូវចូលខ្លួនទៅឲ្យគេសួរទៀតហើយ ។ លើកនេះ គេឲ្យខ្ញុំរាយការណ៍ពីប្រវត្តិរូបប្ដីខ្ញុំអំពីសកម្មភាពរបស់គាត់តាំងពីដើមរៀងមក ។ ចំពោះប្រវត្តិរូបបង**សយ** ខ្ញុំដឹងបានខ្លះៗតាមរយៈបងប្អូនគាត់ ។ ចំពោះ សកម្មភាពផ្សេងៗវិញ ខ្ញុំឥតបានដឹងអ្វីក្រៅពីរឿងគាត់ធ្លាប់សរសេរកាសែត ធ្លាប់បង្រៀនសិស្សតែប៉ុណ្ណោះទេ ។ ទោះបីគេប្រឹងជជីកសួរយ៉ាងណាក៏ពួកគេឥតបានទទួលចម្លើយអ្វីពីខ្ញុំដែរ ព្រោះខ្ញុំឥតដឹងអ្វីមែន ។ ម៉ោង ៥ រសៀល ហើយគេក៏បញ្ចប់ការសួរចម្លើយ តែខ្ញុំក៏បានធ្វើសំណូមពរមួយទៅគេវិញដែរ គឺសួររកប្ដីខ្ញុំ តែគេបានសម្លឹងមុខខ្ញុំគួរឲ្យខ្លាច ដោយពោលពាក្យកំបុតកំបុយជាភាសាវៀតណាម ដែលខ្ញុំស្គាល់ពាក្យមួយម៉ាត់ថា " ខុងបៀតៗ " ហើយ ស.ម. **សេន** និយាយប្រាប់ខ្ញុំថា "កុំសួរលោកៗឥតដឹងទេៗ " គេឲ្យខ្ញុំមកផ្ទះវិញហើយ ។ ខ្ញុំហេវហត់ខ្លាំងណាស់ ។ សេចក្ដីក្លាហានដែលខ្ញុំ មានតាំងពីពេលចូលសាលាក្រុងដំបូង រហូតដល់ពេលរសៀល ជាពិសេសក្នុងពេលដែលត្រូវគេកំពុងសួរចម្លើយ ឥលូវសេចក្ដីក្លាហាននោះបែរជាចុះខ្សោយជាលំដាប់ ធ្វើឲ្យសេចក្ដីអស់សង្ឃឹមមកគ្របសង្កត់លើសតិអារម្មណ៍របស់ខ្ញុំយ៉ាងពេញទំហឹង ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំត្រូវតែបន្ត

ការស៊ើបសួររកប្តីខ្ញុំតទៅទៀតដែរ ។ ខ្ញុំបានប្រើមធ្យោបាយផ្សេងៗជាច្រើន ដូចជាប្រើលុយកាក់ឲ្យគេជាសគុណ ប្រើវត្ថុជាជំនូន ជាកាដូ ។ល។ ការបាត់ស្វាត់ដំណឹងចេះតែបន្លាយពីមួយខែទៅមួយខែ ។ នៅក្នុងគ្រួសារយើងទទួលនូវភាពស្មុគស្មាញយ៉ាងច្រើន ដូចជា មានចោរចូលក្នុងផ្ទះ មកលួចកង់ មានការគំរាមកំហែងរបស់ប្រធានក្រុម ដើម្បីយកដីឡូតិ៍ ដែលប្តីខ្ញុំតែងរៀបន្លែបង្ការ និងជាពិសេសចំណូលតិច ពុំអាចទប់ទល់នឹងចំណាយក្នុងគ្រួសារបាន ព្រោះកូនខ្ញុំបីនាក់ត្រូវចូលសាលារៀនបន្ត ។ កូនស្រីទីមួយត្រូវទៅរៀនគួរពិសេសថ្នាក់បញ្ចប់ ដើម្បីត្រៀមប្រឡងចូលមហាវិទ្យាល័យ ។ កូន ទីបួនរៀនបន្តនៅវិទ្យាល័យ និងកូនពៅ រៀននៅបឋមសិក្សា ។ សល់តែកូនពីរនាក់ដែលមិនចង់រៀនបន្ត នៅជួយរកស៊ី ដើម្បីចិញ្ចឹមគ្រួសារ ។ គឺក្នុងស្ថានភាពបែបនេះហើយ បានជាខ្ញុំប្តូរចិត្ត សុំចូលធ្វើការវិញ ។ ខ្ញុំទៅក្រសួងអប់រំដើម្បីបំពេញបែបបទសុំចូលធ្វើគ្រូ ។ ខ្ញុំជួបមិត្តភក្តិ ដែលធ្លាប់រៀននៅសកលវិទ្យាល័យភ្នំពេញ ជាច្រើនគ្នាមានលោក **សរ ភាគុន** មានលោក **ជ័យ ជេន**... ។ លោក **ជ័យ ជេន** ក្នុងពេលនោះ មានតំណែងជានាយកវិទ្យាល័យបាក់ទូក បានដករូបថតមួយសន្លឹកមកបង្ហាញខ្ញុំ ។ គឺរូបថតនិស្សិតបរិញ្ញាឆ្នាំ ១៩៧០ ដែលមានរូបខ្ញុំនៅទីនោះដែរ ។ មួយអាទិត្យក្រោយមកប្រធានការិយាល័យ បានឲ្យខ្ញុំទៅជួប ហើយឲ្យខ្ញុំទៅធ្វើការនៅសាលាវិក្រិត្យការ ព្រោះជាកន្លែងដែលខ្ញុំធ្លាប់បង្រៀនពួកគ្រូៗក្នុងសម័យមុន ។ ក៏ប៉ុន្តែខ្ញុំមិនទទួល ដោយហេតុថាផ្ទះខ្ញុំនៅជិតសាលាសន្ធរម៉ុក ហើយ កូនខ្ញុំក៏រៀននៅសាលាសន្ធរម៉ុកដែរ ។ ខ្ញុំទទូចទៅបង្រៀននៅសាលា " សន្ធរម៉ុក " វិញ តាមសំណូមពរដែលខ្ញុំបានចុះនៅក្នុងពាក្យសុំ ។ បន្ទាប់មកគេក៏ព្រម ហើយបញ្ជូនឈ្មោះខ្ញុំទៅមន្ទីរអប់រំក្រុងភ្នំពេញ ។ សុំបញ្ជាក់ថាសម័យនោះ នៅតាមក្រសួងសុទ្ធតែមានជំនាញការវៀតណាម នៅអែបដែរ ជាក់ស្តែងនៅពេលដែលឈ្មោះរបស់ខ្ញុំ បានផ្ញើទៅដល់មន្ទីរអប់រំក្រុងហើយ គេធ្វើការប្រជុំសម្រេច ដោយយល់ព្រមឲ្យខ្ញុំទៅធ្វើការនៅសាលា

សន្ទរម៉ុក ។ គេក៏ឲ្យខ្ញុំទៅបង្រៀននៅមធ្យមសិក្សាថ្នាក់ទី ៦(ថ្នាក់ដំបូង) ។ ខ្ញុំហួសចិត្តបន្តិចដែរ ពីព្រោះមានកូនសិស្សខ្ញុំខ្លះ មានត្រឹមតែឌីប្លូមទេ តែគេបែរជាឲ្យទៅបង្រៀននៅថ្នាក់ទី៧ ទី៨ ឯណោះ ។ ចុះចំណែកខ្ញុំ ដែលជាសាស្ត្រាចារ្យ ទុតិយភូមិ មកបង្រៀនសិស្សថ្នាក់ទី ៦ ហ្នឹង សមដែរ ឬទេ ? ណ្ហើយ! អ្វីដែលខ្ញុំត្រូវការ គឺទប់ទល់កុំឲ្យគេរករឿងចាប់ ចងទៀតបានហើយ។ ដូច្នេះចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៨០ ខ្ញុំនៅបង្រៀនក្នុងវិទ្យាល័យសន្ទរម៉ុករហូតមក ដោយគេឲ្យបង្រៀន ផ្នែកអក្សរ– សាស្ត្រ ថ្នាក់ទី ៦ បាន ២ ឆ្នាំ ក្រោយមក ថ្នាក់ទី ៨ ( ថ្នាក់ឌីប្លូម ) ១ ឆ្នាំ និងថ្នាក់ទី ១២ ( ថ្នាក់បាក់ឌុប ) រហូត ។

ក្នុងការបំពេញការងារបង្រៀននោះ ខ្ញុំខំប្រឹងប្រែងយ៉ាងពេញទំហឹង ។ ខ្ញុំចងក្រងមេរៀនទុកជាឯកសារជំនួយដល់គ្រូៗដ៏ទៃទៀត ។ ខ្ញុំតែងសៀវភៅ " តែងសេចក្តី " សម្រាប់ថ្នាក់ទី៨ និងសម្រាប់ថ្នាក់ទី១២ ដែលមានក្របរូប " ស្លាបមាន់ " ជាសញ្ញាសម្រាប់ជួយក្នុងការធ្វើតែងសេចក្តីដល់សិស្សៗ ។ ខ្ញុំត្រូវបានគេចាត់តាំងជាគ្រូបច្ចេកទេសផ្នែកអក្សរសាស្ត្រ ប្រចាំសាលា រួចជាប្រធានក្រុមបច្ចេកទេសប្រចាំរដ្ឋធានីទៀត ។ ថ្ងៃមួយ លោកគ្រូម្នាក់ដែលធ្លាប់និយាយលេងជាមួយខ្ញុំ បាននិយាយប្រាប់ខ្ញុំដោយភ្ញាក់មាត់ថា " " អូ៎ អ្នកគ្រូឥតដឹងទេ កាលដែលគេឲ្យអ្នកគ្រូផ្លាស់ចូលសន្ទរម៉ុក គេបានធ្វើការប្រជុំ ហើយសម្រេចបញ្ជូនអ្នកគ្រូឲ្យទៅបង្រៀននៅបឋមសិក្សា ។ កុំតែបានលោកនាយក **សុម៉ា** ជជែកវែកញែកកុំអីអ្នកគ្រូត្រូវទៅបង្រៀនកូនក្មេង ថ្នាក់ ក–ខ ឯណោះ ពីព្រោះជំនាញការវៀតណាមយល់ថាត្រូវធ្វើអញ្ចឹង ដើម្បីកុំឲ្យអ្នកគ្រូប្រើឥទ្ធិពលទៅលើសិស្សធំៗ " ។ ខ្ញុំបានតបទៅលោកគ្រូនោះវិញថា " " ខ្ញុំយល់ហើយ ។ ពួកគេនោះឥតខ្វល់អំពីគុណភាពនៃការសិក្សាអប់រំទេ គេគិតតែអំពីរឿងនយោបាយ ។ ប្រសិនបើគេនោះជាខ្មែរវិញ គេមុខជារកគ្រូដែលមានសមត្ថភាពត្រឹមត្រូវ មកបង្រៀនតាមកំរិតសិស្សនៃថ្នាក់នីមួយៗ គឺគេមិនខ្ជះខ្ជាយធនធានមនុស្សឡើយ " ។ គិតដល់បញ្ហានេះ

ខ្ញុំយល់ច្បាស់ថាប្រទេសខ្មែរយើងក្នុងសម័យនោះ កំពុងស្ថិតនៅក្រោមនយោបាយរបស់មនុស្សពីរក្រុម ដែលមានផលប្រយោជន៍ផ្សេងគ្នា ក្រោមនយោបាយមុខពីរ ដែលប្រទាញប្រទង់គ្នា។ តើអ្នកឈ្នះគឺពួកក្រុមណា ពួកវណ្ណៈសិរ្ស? ឬពួកវៀតណាមដែលមក "ជួយ" ដឹកនាំ និង គ្រប់គ្រងសង្គមខ្មែរក្នុងសម័យកាលនោះ? ។

ពីរឆ្នាំកន្លងផុតទៅ! ខ្ញុំនៅតែមិនបានដំណឹងពីប្តីខ្ញុំសោះ មិនដឹងថាតើគាត់នៅរស់ ឬគេយកទៅសម្លាប់បាត់ទៅហើយក៏មិនដឹង ។ ក្មួយស្រីឧស្សាហ៍ ដែលជាកូនរបស់ប្អូនថ្លៃខ្ញុំ (ស៊ា) ដែលប្រឡងជាប់ឌីប្លូមហើយៗ ក៏ត្រូវបន្តរៀននៅមធ្យមសិក្សាកំរិត ២ បានមកស្នាក់នៅជាមួយនឹងខ្ញុំ ។ សមាជិកគ្រួសារយើងមានកូន និងក្មួយស្រីៗ នៅលីវទាំងអស់ ។ ទាំងកូនខ្ញុំទាំងក្មួយស្រីខ្ញុំ បានចូលរួមជួយគ្នាទៅវិញទៅមកក្នុងការដេរខោអាវរយដើម្បីបានកម្រៃយកមកផ្គត់ផ្គង់គ្រួសារ ។ យើងមានម៉ាស៊ីនដេរតែមួយទេ យើងផ្លាស់គ្នាដេរ ។ ម្នាក់ឡើង ម្នាក់ជួយបត់ ម្នាក់ទៀតជួយផិត ជួយកាត់ព្រុយខោអាវ... យើងម្នាក់ៗជួយដេររហូតដល់យប់ជ្រៅ ធ្វើឲ្យគេទាំងនោះងោកងុយ ។ ដើម្បីបន្លប់ ខ្ញុំក៏ធានាអានសៀវភៅរឿងប្រលោមលោកជាភាសាបារាំង ហើយបកប្រែឲ្យគេស្តាប់ ។ ក្មួយស្រីរបស់ខ្ញុំចូលចិត្តស្តាប់រឿងទាំងនោះណាស់ ពីព្រោះជារឿងរបស់អ្នកនិពន្ធល្បីៗដូចជាអ្នកនិពន្ធដេល្លីជាដើម ។ ដោយមើលឃើញថារបររកស៊ីដេរខោអាវរយនេះ វាយ៉ាប់យ៉ឺន ហើយរកបានកម្រៃតិចតួចពេកយើងក៏សម្រេចចិត្តទិញកន្លែងលក់ខោអាវរាយ មួយនៅផ្សារអូឡាំពិកតំលៃ២ជីកន្លះមាស ។ កូនស្រីច្បងរបស់ខ្ញុំត្រូវប្តូរអាជីពពីលក់ទឹកកកឈូស មកលក់ខោអាវរយវិញ ហើយនាងក៏សុំទៅរៀនផងដែរ ។ អញ្ចឹងហើយកូនទាំងអស់ ព្រមទាំងក្មួយ ពេលទំនេរពីកិច្ចការសាលាតែងទៅជួយប្អូនគ្នាលក់នៅផ្សារ ។

នៅក្នុងឆ្នាំនោះដែរ កូនទីពីររបស់ខ្ញុំបែកគំនិតមួយទៀតហើយសម្រេចចិត្តចុះទៅរកស៊ីរត់ពន្ធ ដឹកឥវ៉ាន់ពីកំពង់សោមមកលក់នៅភ្នំពេញ ។ ក្រោ

ពេលធ្វើដំណើរចុះឡើងៗ មានពេលមួយនោះនាងបានជួបគ្រោះថ្នាក់ចោរប្លន់ឡាន បាញ់ត្រូវជើងទាំងសងខាង ធ្លុះពីជើងម្ខាងទៅម្ខាងទៀត ហើយបៀមគ្រាប់នៅជើងទី ២ នោះ ។ ការព្យាបាលមានភាពលំបាកច្រើនណាស់ គឺខ្វះតាំងពីថ្នាំចាក់បង្ការតេតាណូស ខ្វះតាំងពីឈាមបញ្ចូលឲ្យអ្នកជំងឺក្រោយពេលវះកាត់ ខ្វះសេរ៉ូម ថ្នាំផ្សះ... ក្នុងមន្ទីរពេទ្យ (ពេទ្យលោកសង្ឃ)។ គេតម្រូវឲ្យរកថ្នាំទាំងនោះ មកប្រើប្រាស់ម្រាប់ខ្លួនឯងផ្ទាល់ ព្រោះនៅមន្ទីរពេទ្យ សូម្បីតែសំឡី អាល់កុល ថ្នាំក្រហម ក៏មិនសំបូរដែរ ។ កូនស្រីខ្ញុំត្រូវសម្រាកនៅក្នុងមន្ទីរពេទ្យអស់រយៈពេលជាងមួយខែ ទើបសុំចេញមកបន្តការព្យាបាលនៅផ្ទះវិញ ។

រឿងមួយទៀត ដែលធ្វើឲ្យខ្ញុំមានកង្វល់ ហើយចងចាំជារឿងរហូត គឺបញ្ហាកំណែនប្រជាជនទៅ “ក៥” ។ ប្រហែលជា ៤-៥ ខែក្រោយមក មេដប់ខ្នង(ប្រធានក្រុម) បានមកកត់ឈ្មោះកូនរបស់ខ្ញុំម្នាក់នោះទៅក៥ ជាមួយគេ ព្រោះវាជាផែនការរបស់រដ្ឋអំណាចក្រុង ។ សូមបញ្ជាក់ថា គេកំណត់ឲ្យមនុស្សម្នាក់ក្នុងមួយគ្រួសារចេញទៅធ្វើកំណែន ។ គេជ្រើសរើសកូនដាដែលជាកូនស្រីទីពីរ ព្រោះកូនស្រីទីមួយរបស់ខ្ញុំស្វិតជើង កូនស្រីទីបីរបស់ខ្ញុំបានរៀបការចេញទៅនៅខាងប្តីគេបាត់ ឯកូនស្រីទីបួនទៅរៀន ហើយកូនស្រីពៅនៅមិនទាន់ពេញវ័យនៅឡើយ ។ អញ្ចឹងហើយ គេចាត់ឈ្មោះកូនស្រីទីពីរឲ្យទៅ ក៥ នោះ ។ កាលនោះខ្ញុំមិនដឹងថា ក៥ នោះជាកម្មវិធីអ្វីទេ តែជាសំណាងល្អដោយប្អូនថ្លៃរបស់ខ្ញុំម្នាក់ដែលធ្វើការនៅមន្ទីររៀបចំសំណង់ក្រុង (ប្អូនជិន) បានមកជួបរួចឲ្យយោបល់ថា “បង! កុំឲ្យក្មួយដាទៅ ក ៥ អី ព្រោះកន្លែងដែលគេបញ្ជូនប្រជាជនទៅកាប់ព្រៃនោះគឺជាតំបន់ដែលខ្មែរក្រហមកាន់កាប់ សំបូរមីន និងជាតំបន់មាន គើតជំងឺគ្រុនចាញ់... គួរបងរកវិធីយ៉ាងណាបញ្ចៀសកុំឲ្យទៅក៥ឲ្យសោះ ។ ប្អូនថ្លៃបាននិយាយបន្ថែមទៀតថាចំពោះរូបគាត់ក៏ជាប់ឈ្មោះទៅ ក៥ ដែរ តែគាត់ជាបុរស ហើយគ្រាន់តែជាអ្នកមើលកិច្ចការតូចតាចប៉ុណ្ណោះ ។ ខ្ញុំត្រូវកើត

ទុក្ខទៀតហើយ ។ រឿងមួយមិនទាន់បានដោះស្រាយផង លេចរឿងថ្មីមួយទៀត...។ អ្នកខ្លះបានឲ្យយោបល់ ថាទៅអង្វរមេដប់ខ្ទង រួចទៅប្រធានមណ្ឌល ឬទៅមេ៥០ ខ្ទង ។ ខ្ញុំបានសាកល្បងអស់ហើយ គេថាឲ្យនារីទៅក៥មិនមែនឲ្យទៅកាប់ព្រៃឯណាគឺឲ្យទៅជួយការងារខាងចង្ក្រានឆ្នាំង...។

ខ្ញុំហួសចិត្ត ព្រោះគិតថាខ្ញុំបានបែកពីប្ដីរបស់ខ្ញុំកាលពីមុន ក៏ដូចជាពេលនោះដែរ ហើយមិនមានដំណឹង ថាតើគាត់នៅទីណាមានសុខទុក្ខយ៉ាងម៉េចដែរ ។ តើឥឡូវគេប្បីឲ្យកូនស្រីរបស់ខ្ញុំបែកចេញពីក្រុម គ្រួសារទៀតឬ ? តើគេមានអាណិតដល់ជីវិតរបស់គ្រួសាររបស់យើងទេ នៅពេលដែលឃើញ ស្ត្រីមេម៉ាយម្នាក់មានកូនសុទ្ធតែស្រី ហើយត្រូវគេមកបំបែកយើងទៀត ហើយជាពិសេសនាងទើបតែចេញពីមន្ទីរពេទ្យបានប៉ុន្មានខែប៉ុណ្ណោះ ។ ពេលនោះខ្ញុំ នឹកឃើញមធ្យោបាយមួយគឺធ្វើសំបុត្រពេទ្យបញ្ជាក់អសមត្ថភាព ព្រោះជើងកូននេះធ្លាប់ត្រូវគ្រាប់ពិការអស់ជាច្រើនខែទើបដើររួច ។ ដោយមានអន្តរាគមន៍អំពីបងប្អូនខ្ញុំម្នាក់ធ្វើការនៅមន្ទីរពេទ្យក្រុងខ្ញុំក៏បានសំបុត្រពេទ្យនេះយកទៅឲ្យគេ ។ មេដប់ខ្ទងមិនទទួល ហើយឲ្យខ្ញុំយកទៅឲ្យប្រធានមណ្ឌលដែលជាអ្នកអនុវត្តកម្មវិធីកំណែននេះ ។ ថ្ងៃឡើងឡានពួកប្រជាជនជាប់កំណែន ត្រូវគេហៅឈ្មោះឡើងឡានម្នាក់ម្ដងៗ ។ ដល់ឈ្មោះ កូនស្រីខ្ញុំ " **ពីង សិន្ថា** " ខ្ញុំក៏ហុចសំបុត្រពេទ្យឲ្យគេ ។ ប្រធានមណ្ឌលជ្រួញចិញ្ចើម ហើយនិយាយបែបមួរម៉ៅថា " នៅដើរបានទេតើ ? "។ ខ្ញុំឥតហ៊ាននិយាយអ្វីច្រើនទេ គ្រាន់តែនិយាយតិចៗថា " ចាំ តែជើងវានៅឈឺនៅឡើយ... " ។ គេងាកមុខចេញ ហើយមួយសន្ទុះក្រោយមកគេក៏ចោលពាក្យថា " អញ្ចឹងចាំលើកក្រោយចុះ " ។ ខ្ញុំអរគុណគេ តែអន់ចិត្តខ្លាំងមែនទែន ព្រោះយល់ថា ក៥ ធ្វើឲ្យព្រៃខ្មែរវិនាស ធ្វើឲ្យប្រជាជនកំណែនពិការ ឬស្លាប់ដោយគ្រាប់មីនបង្កប់ និងឈឺ ឬស្លាប់ ដោយសារជំងឺគ្រុនចាញ់ ។ល។ ជាក់ស្ដែងប្អូនថ្លៃរបស់ខ្ញុំដែលបានទៅ ក ៥ ក្នុងពេលនោះដែរ ទៅបានតែមួយអាទិត្យ ចាប់ឈឺគ្រុនញាក់រហូតដល់ត្រូវគេបញ្ជូន

មកផ្ទះវិញ ហើយបាក់កម្លាំងរហូតទល់សព្វថ្ងៃ ។

រំលងជាច្រើនខែមក មានស្ត្រីម្នាក់ដែលប្ដីគាត់ជាក្រុម " ចលនាព្រលឹងខ្មែរ " ជាប់គុកនៅតេ៣ បានមកជួបកូនស្រីខ្ញុំ ហើយសួរថា " នាងមានឪពុកជាប់នៅគុកតេ៣ មែនទេ ? ឥឡូវគាត់បានឲ្យខ្ញុំមកប្រាប់នាងថាគាត់ជាប់ឃុំឃាំងនៅទីនោះ "។ រួចអ្នកស្រីបានរៀបរាប់ពីដំណើរដែលគាត់បានជួបនឹងឪពុករបស់កូនស្រីខ្ញុំ ថានៅពេលដែលអ្នកស្រីទៅសួរសុខទុក្ខប្ដីនៅគុកតេ៣ ពេលនោះគាត់ឃើញតា (បងសយ) កំពុងរុញរទេះដឹកកំទេចអិដ្ឋចេញក្រៅកំផែងគុក ហើយលួចមកដើរក្បែរគាត់ និងនិយាយផ្ដាំឲ្យគាត់ជួយមករកឈ្មោះកូនស្រីដែលនៅលក់ទឹកកកនៅមុខសាលាសន្ធម៉ុកឈ្មោះ " សិទ្ធិ " ដោយបញ្ជាក់បន្ថែមទៀតថា : " បើនាងភ្លេចឈ្មោះកូនខ្ញុំ ពេលដែលនាងលើកក្រាសសិតសក់ទៅនោះនាងអាចនឹកឃើញឈ្មោះកូនរបស់ខ្ញុំហើយ "។ អ្នកស្រីនិយាយចប់សើចតិចៗ ហើយលាន់មាត់ថា " ក្រោយពីត្រឡប់មកដល់ផ្ទះវិញ មីងពិតជាភ្លេចបណ្ដាំរបស់តាមែន តែនៅព្រឹកមិញនេះ នៅពេលមីងឆ្លុះកញ្ចក់សិតសក់ ស្រាប់តែនឹកឃើញឈ្មោះនាង និងបណ្ដាំតា ក៏ស្ទុះមករកនាងភ្លាមតែម្ដង..."។ គ្រាន់តែដឹងដំណឹងភ្លាមកូនស្រីធំរត់មកផ្ទះ ប្រាប់ខ្ញុំថាពុករបស់គេនៅក្នុងគុក "តេ ៣ "។ ភ្លាមនោះខ្ញុំទៅទាក់ ទងអ្នកស្រីនោះ(ប្រពន្ធពូស៊ុ ) ដើម្បីសួរនាំអំពីមធ្យោបាយសុំជួបគ្រួសារដែលនៅជាប់ក្នុងពន្ធនាគារនោះ ។ ដំបូងខ្ញុំទាក់ទងបានត្រឹមតែផ្ញើឥវ៉ាន់មួយកន្ត្រក ក្នុងមួយខែប៉ុណ្ណោះ ទៅឲ្យបងសយតាមរយៈប្រធានគុក ។ ខ្ញុំធ្វើរបៀបនេះអស់រយៈពេលពីរឆ្នាំ ក្រោយមកទើបគេអនុញ្ញាតឲ្យខ្ញុំអាចទៅសួរសុខទុក្ខប្ដីខ្ញុំបាន ។ ខ្ញុំរៀបចំឥវ៉ាន់សព្វគ្រប់ មានកាពិជាវ ត្រីងៀត ផាត់ប្រហុកគ្រឿង និង មានស្ករគ្រាប់ ដំណាប់ចេក ដំណាប់ស្វាយ ដាក់ចង់វុំក្រដាសពីរបីជាន់ និង នំប៉ុង ៣–៤... ញាត់ចូលក្នុងកន្ត្រកមួយធំល្មម ។

ជាធម្មតា អ្នកដែលទៅសុំជួបគ្រួសារត្រូវមានសំបុត្រអនុញ្ញាតពីប្រធានគុកតេ៣ ជាមុនសិន ។ គេឲ្យទៅអង្គុយក្នុងរោងមួយ នៅក្រៅកំផែងគុកដើម្បី

រង់ចាំ ហើយមិនអនុញ្ញាតឲ្យឈរ ឬអើតមើលទៅក្នុងតាមទ្វារចេញចូលបាន ឡើយ ។ កូនស្រីពៅរបស់ខ្ញុំ ដោយសារនាងចង់ជួបឪពុករបស់នាងខ្លាំង ពេក គេក៏លបទៅលួចអើតមើលតាមចំរឹងទ្វារ ត្រូវពួកវៀតណាម ដែលបណ្ដើរអ្នកទោសចេញពីក្នុងមកស្រែកគំហកឲ្យហើយលើកដៃធ្វើ សញ្ញា " អារក " ធ្វើឲ្យនាងភ័យ រត់យ៉ាងលឿនចេញពីទីនោះភ្លាម ។ កាយវិការបែបនេះ បញ្ជាក់នូវភាពកាចសាហាវណាស់! មែនទេ ?...។ ពិរុទ្ធជនចេញមកជាបន្តបន្ទាប់ ដោយមានឆ្មាំគុកពីរនាក់មកជាមួយ ម្នាក់ ជាជនជាតិខ្មែរ ម្នាក់ជាជនជាតិវៀតណាម ។ ពេលទៅជួបបងសយលើក ដំបូងខ្ញុំនិងកូនៗ រង់ចាំគាត់ទាំងអន្ទះសាហេតុអ្វីបានជាក្រឃើញគាត់ចេញ មកម្ល៉េះ ។ ពេលគាត់ចូល ដល់មាត់ទ្វារបន្ទប់ ក៏ខ្ញុំឥតចាប់អារម្មណ៍ដែរ ទាល់តែកូនខ្ញុំស្រែកថា " ពុកៗៗ " ទើបខ្ញុំដឹងថានោះជាបងសយហើយ។ ខ្ញុំមើលគាត់មិនស្គាល់ទេ ព្រោះអីរូបកាយរបស់គាត់ពេលនោះមិនសូវជាស្គម ខ្លាំងមែនតែស្លេកស្លាំងខ្លាំងណាស់ ហើយកាត់សក់ខ្លីរះអស់ជើងសក់ក្រោម ឃើញតែស្បែកក្បាលឡើងត្រមែង ប្រៀបបាននឹងមនុស្សចាស់ជរា ដែល ឈឺរ៉ាំរ៉ៃរាប់ខែមកហើយ ។ ពេលជួបគ្នាដំបូងនេះ ទាំងខ្ញុំក្ដី ទាំងបងសយ យើងស្ទើរតែរកពាក្យ អ្វីនិយាយមិនបាន ព្រោះវាអួលដើមករៀងៗខ្លួន ។ តែបង**សយ** ខំប្រឹងរកពាក្យមកនិយាយ ដើម្បីបន្លប់អារម្មណ៍ " ម៉េចទៅកូន ចៅយើងសុខសប្បាយទាំងអស់គ្នាទេឬ? " ខ្ញុំឆ្លើយមិនចេញគ្រាន់តែងក់ ក្បាលជំនួសចម្លើយ ។ សូវបានតែប៉ុណ្ណឹង គាត់ក៏ប្ដូរនិយាយរឿងផ្សេងវិញ គឺប្រាប់អំពីឥវ៉ាន់ដែលខ្ញុំ ត្រូវធ្វើឲ្យគាត់លើកក្រោយៗទៀត ។ យើងមិនបាន និយាយគ្នាយូរទេ ព្រោះគេកំណត់ឲ្យជួបតែប្រាំនាទីប៉ុណ្ណោះ ហើយក្នុងពេល ជួបនោះ ឆ្មាំទាំងពីរនាក់នៅអង្គុយជាប់ជាមួយយើងរហូត ទាល់តែរស់ ម៉ោង ។ ខ្មែរជាអ្នកស្ដាប់ ហើយបកប្រែឲពួកវៀតណាមជាអ្នកកត់ត្រា...។ ការជួបគ្នាក្នុងលើកដំបូង ក្រោយពេលបែកគ្នាអស់រយៈពេលជិតបីឆ្នាំនេះ បានធ្វើឲ្យខ្ញុំធូរស្រាលក្នុងចិត្តបន្តិចហើយដែរ ក៏ប៉ុន្តែអារម្មណ៍របស់ខ្ញុំតែតែ

នឹកស្រងោចលន្លោចចិត្តអាណិតប្ដីខ្ញុំ ដែលធ្លាប់រឹងប៉ឹង ហើយឥឡូវបែរជាបាត់បង់ថាមពល និងភាពសង្ហាក្លាហានអស់រលីង...។

| | | |
|---|---|---|
| - គិតសព្វគ្រប់ទៅ | មនុស្សសត្វរស់នៅ | មានកាយសម្បទា |
| ស្រស់ស្រាយប្រឹមប្រិយ | សាច់ឈាមភ្លឺថ្លា | មានហូបគ្រប់គ្រា |
| | មានញាតិជុំជិត ។ | |
| - បើរស់ក្នុងឃ្នាប | គុកកម្មចាំគាប | សេរីបំបិទ |
| ទារុណផ្លូវកាយ | បង្ក្រាបផ្លូវចិត្ត | អារម្មណ៍ក្រៀមស្វិត |
| | ស្រពោនព្រលឹង ។ | |

ខ្ញុំបានជួបគាត់ហើយ ជួនកាលមួយដងក្នុងមួយខែ ជួនកាលមួយដងក្នុងពីរខែអាស្រ័យទៅតាមសំបុត្រអនុញ្ញាតពីប្រធានគុក ។ ជាការពិបាកក្រៃលែង ដើម្បីសុំលិខិតនោះ ពីព្រោះលោកមេគុកជាប់រវល់ជាប់ប្រជុំ ឬជាប់ចុះបេសកកម្មទៅទស្សនៈកិច្ច ។ល។ ខ្ញុំអាសូរប្ដីខ្ញុំណាស់ ពេលគាត់ចេញមកជួបម្ដងៗគាត់តែងកាន់ស្ករគ្រាប់ ៣-៤ គ្រាប់ មកផ្ញើកូនស្រីពៅគាត់។ គាត់ធ្វើអញ្ចឹង ដើម្បីរក្សាមនោសញ្ចេតនាឪពុក-កូន ឲ្យនៅមានជានិច្ច ធ្វើឲ្យខ្ញុំគិតថា ត្រូវតែរកមធ្យោបាយជួយគាត់ឲ្យឆាប់រួចចេញពីពន្ធនាគារ ។

ក្នុងអំឡុងពេលនោះ ផ្ទះខ្ញុំមានសមាជិកមករស់នៅបន្ថែមទៀតហើយ គឺក្មួយរបស់ប្ដីខ្ញុំដែលត្រូវមករៀនខាងសាស្ត្រាចារ្យ និងបងប្អូនរបស់គេមួយចំនួនមកស្នាក់នៅជាមួយ ( នាង**ចន្ថា** **ក្មួយរ៉ើន** **ក្មួយពៅ**) ។ ហើយក៏មានក្មួយស្រីមេម៉ាយម្នាក់ទៀត ( នាង **ឡាំ ស៊ើម** ) ដែលមានកូនប្រសារធ្វើប៉ូលីសនៅតាខ្មៅ ដែលមានទំនាស់ក្នុងគ្រួសារក៏ សុំមកសង់ខ្ទមនៅក្នុងដីភូមិរបស់ខ្ញុំដែរ ។ ដីឡូតិ៍ យើងកាន់តែមានមនុស្សមកនៅច្រើនគ្នា ដែលវាជាការមួយធ្វើឲ្យខ្ញុំនិងកូនចៅកក់ក្ដៅច្រើនដែរ ។ យើងរស់នៅជុំគ្នាបីគ្រួសារ

ឥតមានកករល្អក់សោះ។ ប៉ុន្តែអារម្មណ៍ខ្វល់ខ្វាយរបស់យើងទាំងអស់គ្នា ចំពោះជីវិតរបស់ប្ដីខ្ញុំ របស់ឪពុកកូនខ្ញុំ និងមារបស់ក្មួយៗខ្ញុំតែងជិតជាប់ជាប្រចាំក្នុងចិត្តរៀងៗខ្លួន ។

កូនស្រីទីពីររបស់ខ្ញុំ ដែលធ្លាប់រកស៊ីរត់ពន្ធឥវ៉ាន់ពីកំពង់សោម មកភ្នំពេញ គេប្រាប់ខ្ញុំថា គេស្គាល់ប្រពន្ធថៅកែធំម្នាក់ នៅក្រុងកំពង់សោម ហើយសុំគេឲ្យជួយធ្វើអន្តរាគមន៍ ។ អ្នកស្រីនោះបានដឹងអំពីរឿងឪពុករបស់កូនខ្ញុំ ហើយក៏ទៅនិយាយនឹងប្ដីគាត់ឲ្យជួយ ព្រោះថៅកែនោះស្គាល់ជំនាញការនៅក្រសួងមហាផ្ទៃ ។ គាត់នាំខ្ញុំទៅជួបជំនាញការនោះនៅផ្ទះមួយត្រង់កាច់ជ្រុងផ្លូវចំការមន និងផ្លូវប៉ូកគោ ( ជាអតីតផ្ទះលោកវិស្វករ "**ចាន់ ម៉ុច**" មិត្តភក្តិរបស់បងសយ ) ។

បួន–ដប់ ថ្ងៃក្រោយមក មន្ទីរអប់រំភ្នំពេញបានហៅខ្ញុំឲ្យចូលទៅមន្ទីរ ដោយដាក់កម្មវត្ថុថា "ជួបនឹងមន្ត្រីក្រសួងមហាផ្ទៃ" ។ ក្នុងពេលជួបនោះ មានមន្ត្រីវៀតណាមពីរនាក់ និងមន្ត្រីខ្មែរម្នាក់ជាអ្នកបកប្រែ ។ គេសួរអំពីជីវប្រវត្តិរបស់ខ្ញុំ ហើយគេសង្កត់ច្រើនទៅលើបញ្ហាកូនប្រុសរបស់ខ្ញុំ ដែលបាត់ខ្លួននោះ ដោយចោទថាកូនខ្ញុំជាយោធាខ្មែរក្រហម ។ ខ្ញុំបដិសេធដាច់អហង្កា ពីព្រោះវាមិនមែនជាការពិត ។ ខ្ញុំក៏បានរៀបរាប់អំពីរឿងដែលខ្ញុំបានដឹងតាមរយៈមិត្តចែមឲ្យគេស្ដាប់ ។ គេក៏នៅស្ងៀម...។

ក្រោយជំនួបនោះបន្តិចមក មានអ្នកជាប់គុកម្នាក់ដែលត្រូវបានគេដោះលែងឲ្យមានសេរីភាព បាននាំដំណឹងមកប្រាប់ខ្ញុំថា " អ៊ុំសយក៏មានឈ្មោះបានចេញដែរ ប្រហែលល្ងាចនេះ ឬថ្ងៃស្អែក ត្រូវចេញពីពន្ធនាគារហើយ "។ ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំង រីឯកូនខ្ញុំគេក៏បានគិតគ្នាធ្វើម្ហូបអ្វីខ្លះ ដើម្បីរង់ចាំទទួលពុករបស់គេ ។ យើងរៀបចំម្ហូបដែលបងសយចូលចិត្តញ៉ាំ មានត្រីអាំង ជ្រក់មមាញ សម្លជី... ។ យើងចាំដល់ពេលល្ងាច... ចាំ ដល់ស្អែក... ឥតឃើញគាត់ចេញមកទេ ។ ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំបានទៅចាំនៅតេត

ជួបអ្នកធ្វើការពីរនាក់ដើរចេញមក ហើយខ្ញុំសួរគេៗថា " ប៉ុន្មានថ្ងៃមុននេះ មានឈ្មោះគាត់មែន តែឥឡូវធ្លាក់លើផ្កាកសិន " ។ ខ្ញុំចង់ជជីក សួរច្រើន សំណួរណាស់ តែគេដើរបណ្តើរ និយាយបណ្តើរ ដោយមិនចង់និយាយ ច្រើនជាមួយខ្ញុំ ។ គេនិយាយតែពាក្យដដែលៗ " ខ្ញុំឥតដឹងដែរៗ " ។ អស់ សង្ឃឹមហើយ ខ្ញុំត្រូវបន្តរង់ចាំតទៅទៀត ។

| | | |
|---|---|---|
| – មិនសមសោះឡើយ | មេឃស្រឡះហើយ | ពុំគួរគេប្បី |
| មានមនុស្សលោភលន់ | បុគ្គលក្រាស់ក្រៃ | យកគាប់ម្ចាស់ថ្មី |
| | វាយការណ៍គ្នាឯង ។ | |
| – ព្រោះតែយសសក្តិ | ហ៊ានក្បត់មិត្តភក្តិ | ញុះញង់បង្វែង |
| ចាប់ចងញាត់គុក | ខ្មែរជាតិសាសន៍ឯង | គ្រប់គ្នាចំបែង |
| | ព្រាត់សារលោហិត ។ | |

# វគ្គទី ៧

## ជីវិតចុងក្រោយ

បីឆ្នាំកន្លងទៅហើយ ចូលឆ្នាំទីបួន ទីប្រាំ ទីប្រាំមួយ កូនស្រីរបស់ខ្ញុំបីនាក់ បានរៀបការហើយដោយឥតមានឪពុកចូលរួម ។ ក៏ប៉ុន្តែ ជាសំណាងរបស់ខ្ញុំ ដោយមានប្អូនស្រី ប្អូនប្រុសមួយចំនួន ដែលជាកូនរបស់ឪពុកបង្កើតរបស់ខ្ញុំ " **ឈី ហាក់** " បានមកជួយខ្ញុំ នៅពេលប្រារព្ធពិធីអ្វីៗ នៅក្នុងគ្រួសារ ។ ប្អូនស្រី " **ឈី នារី** " និងប្តីរបស់គេ " **ជេត ជិន** " តែងតាំងខ្លួនជាមេបា ក្នុងពិធីមង្គលការរបស់កូនខ្ញុំ ជំនួសខ្ញុំជាស្ត្រីដែលប្តីព្រាត់ ។ ខ្ញុំសូមសំដែងការគោរពដ៏ស្មោះ ចំពោះប្អូនៗទាំងនោះ ដែលផ្តល់សេចក្តីសង្ឃឹមដល់ខ្ញុំក្រោយពេលដែលបងប្អូនពោះមួយរបស់ខ្ញុំ ត្រូវបានស្លាប់អស់នៅក្នុងសម័យខ្មែរក្រហម ។



ខ្ញុំគ្រប់គ្រងគ្រួសារតែម្នាក់ឯង ដោយប្រាក់ខែដ៏តិច តួចតួបផ្សំ នឹងប្រាក់បានមកពីការលក់ខោអាវរយរបស់កូនខ្ញុំ និងតម្លៃលក់សៀវភៅតែងសេចក្តីដែលខ្ញុំសរសេរនោះ។ នឹកដល់រឿងនិពន្ធសៀវភៅខ្ញុំដូចជាហួសចិត្តនឹងលោកនាយកសាលាដែលហៅខ្ញុំទៅព្រមាន ។ បញ្ហាទី១ លោកចោទ ថាខ្ញុំនិយាយបញ្ឆិតបញ្ឆៀងឲ្យថ្នាក់ដឹកនាំ ។ ខ្ញុំបានលើកពាក្យសុភាសិតមកធ្វើអត្ថាធិប្បាយថា " ទំពាំងស្នងឫស្សី " មិនប្រដៅត្រឹមតែយុវជនឲ្យស្គាល់តួនាទីរបស់ខ្លួនជាអ្នកស្នងសង្គមនៅអនាគតប៉ុណ្ណោះទេ តែពាក្យភាសិតនេះ ក៏ចង់ពញ្ញាក់ស្មារតីរបស់មនុស្សចាស់ផងដែរថាការប្រព្រឹត្តិរបស់ខ្លួនមានឥទ្ធិពលជះទៅលើក្មេងៗខ្លាំងណាស់ប្រៀបដូចដើមឫស្សីដែលដុះវៀចក្ងិចក្ងក់ ឬ ពុកស្អុយនៅក្នុងគុម្ពឫស្សីពុំអាចឲ្យទំពាំងដែលដុះចេញមកបានធំធាត់ល្អបានដែរ...។ បញ្ហារិះគន់មួយទៀតនៅត្រង់ការលើកឧទាហរណ៍ របស់ខ្ញុំដែលសរសើរ "ពាលី" ជាស្តេចដែលស្រលាញ់ប្រជារាស្ត្ររបស់ខ្លួនមិនសុខចិត្តប្រគល់ទ័ពស្វារបស់ខ្លួនឲ្យព្រះរាមយកទៅច្បាំងជាមួយក្រុងរាពណ៍នៅក្រុងលង្កា ដើម្បីយកព្រះនាងសីតាមកវិញ ។ ពាលីសុខចិត្តស្លាប់ដោយសារព្រះរាម ។ ក៏ប៉ុន្តែលោកនាយកបែរជាយល់ថា "មិនសរសើរនរណា ទៅសរសើរអាស្តេចស្វាទៅវិញ"។ លោកបានបង្ខំខ្ញុំកែសម្រួលឡើងវិញ...។ នេះគ្រាន់តែជាឧទាហរណ៍ដកស្រង់ចេញពីអក្សរសិល្ប៍សោះ បែរជាលោកមានទស្សនៈចង្អៀតចង្អល់ទៅហើយ ។ ការពិតខ្ញុំយល់ថា ក្រុងពាលីជាស្តេចល្អ មានឧត្តមគតិស្រលាញ់ប្រជារាស្ត្រដោយមិនសុខចិត្តលក់ប្រជាជនឲ្យទៅច្បាំងដើម្បីបុព្វហេតុបរទេស (ព្រះរាម)។ ម្យ៉ាងទៀត "ចរិតសកល" របស់ពាលីមួយទៀតឋិតនៅត្រង់ការពលីជីវិតរបស់គាត់ ដោយសុខចិត្តឲ្យសរព្រះរាមមកទំលុះទ្រូងគាត់ទៅចុះ ព្រោះថាប្រសិនបើគាត់យកសរនោះគ្រវាត់ទៅចក្កវាល វានឹងធ្វើឲ្យចក្កវាលទាំងមូលឆេះរលាយ...។ នេះគឺពិតជាបុគ្គលដ៏ប្រសើរក្រៃលែងគ្មានអ្នកប្រដូចដែលគួរសរសើរ និងគោរព ។ ក៏ប៉ុន្តែចំពោះខ្ញុំពេលនោះគ្មានជម្រើស

ទេ ។ ខ្ញុំត្រូវបង្ខំចិត្តបំពេញបំណងរបស់គេហើយព្រោះខ្លាចគេមិនឲ្យចេញ ក្រោយ ។

ចប់ឆ្នាំទី ៩ ចូលដល់ឆ្នាំទី ១០ ហើយ ដែលប្តីខ្ញុំនៅជាប់ក្នុងគុក តេ៣ នៅឡើយ ។ ថ្ងៃមួយមានលោកម្នាក់ ដែលខ្ញុំធ្លាប់មានទំនាក់ទំនងក្នុងការ ត៉ដេតូររឿងប្តីរបស់ខ្ញុំ បានមកជួបនឹងខ្ញុំម្តងទៀត ដោយប្រាប់ថា គាត់អាច ជួយប្តីខ្ញុំឲ្យឆាប់បានចេញពីមន្ទីរឃុំឃាំង ។ ចំពោះសោហ៊ុយ សោដា គឺគ្រាន់ តែជូនគេបន្តិចបន្តួច ជាការអរគុណតែប៉ុណ្ណោះបានហើយ ។ ខ្ញុំពុំសូវជា សង្ឃឹមប៉ុន្មានទេ ព្រោះមានរឿងបែបនេះជាច្រើនលើកច្រើនគ្រាមកហើយ។ យ៉ាងណាមិញមានព្រឹត្តិការណ៍មួយដែលធ្វើឲ្យខ្ញុំនឹកសង្ឃឹមថាមុខជាមានការ ដោះលែងអ្នកទោសនយោបាយខ្លះៗជាមិនខានពីព្រោះចំបាំងក្នុងស្រុក រវាងក្រុមខ្មែរក្រហម, ក្រុមរណសិរ្សសង្គ្រោះជាតិ (ដឹកនាំដោយសម្តេច សីហនុ និង លោក សឺន សាន ) និងពួករដ្ឋកម្ពុជាប្រជាមានិត ( គាំទ្រ ដោយកងទ័ពវៀតណាម) កំពុងរៀបចំចរចាបង្រួបបង្រួមគ្នា ធ្វើសន្និសិទ្ធនៅ ទីក្រុងបារីស ដើម្បីបញ្ចប់ការវិវាទរបស់ពួកក្រុមត្រីភាគីនោះ ។ បងថ្លៃស្រី របស់ប្តីខ្ញុំ (បងថន) ដែលរស់នៅជុំជាមួយយើងដែលទើបមកពីសៀមរាប បាននិយាយថា " គួរតែឲ្យគេគិតគូរទៅចុះ ហើយចាំបងជួយចេញខ្លះៗ "។ ពីរថ្ងៃក្រោយមកប្រហែលជាម៉ោង១០ ព្រឹក( ថ្ងៃទី ២១ ខែវិច្ឆិកាឆ្នាំ ១៩៨៨ ) ក្មួយស្រីខ្ញុំបានស្រែកហៅខ្ញុំថា " គឺមៗ ! គូមកដល់ ហើយៗ! " ។ ខ្ញុំស្ទុះ ចេញពីផ្ទះ ចុះពីកាំជណ្តើរតម្រង់ទៅច្រកចូលព្រមគ្នានឹងបងថ្លៃខ្ញុំដែលស្ទុះ ចេញដែរ ។ បងថ្លៃខ្ញុំរាំងដៃមិនទាន់ឲ្យប្តីខ្ញុំចូលដោយ បន្លឺថា " គូ រាំ! ឈរនៅ ត្រង់ហ្នឹងសិនហើយ "។ គាត់ប្រញាប់ប្រញាល់ត្រឡប់ចូលទៅក្នុងរោងបាយ ផ្ទះរបស់កូនគាត់ រួចកាន់អង្ករមួយកំប៉ុងចេញមក។ គាត់បាចអង្ករលើលងខ្លួន ប្តីខ្ញុំដោយនិយាយថា " ខ្មោចបិសាច! ចូរឯងយកអង្ករនេះទៅហើយកុំមក តាមយាយីគូសាយទៀត! មួយ ពីរ បី ជីៗ ! ទៅៗ " ។ ខ្ញុំឈរស្រឡាំង

កាំងព្រោះឥតបានដឹងមុនថាត្រូវធ្វើ ពិធីបែបហ្នឹងឡើយ ហើយនៅតែឈរ ភាំងទៀតព្រោះរកពាក្យអ្វីនិយាយមិនចេញ ។ កូនស្រីពៅរបស់ខ្ញុំអរណាស់ រត់ត្រេទៅហៅបងៗរបស់គេនៅលើផ្ទះឲ្យចុះមកទទួលពុក ។ បង **សយ** ញញឹមញញែមដាក់យើងទាំងអស់គ្នា ដោយទឹកចិត្តសប្បាយរីករាយ ក្រៃលែង ។ យើងរៀបរាប់អំពីសុខទុក្ខនៅក្នុងគ្រួសារក្នុងរយៈពេលជិត ១០ ឆ្នាំ ដែលគាត់ឥតបាននៅជាមួយ ។ ក្នុងនោះមានបងប្រុសម្នាក់ដែលនៅ រស់ក្រោយសម័យប៉ុលពតគឺ បង **ឌី សេ** ឥឡូវស្លាប់ហើយ ។ បងថ្លៃម្នាក់ ទៀតគឺបង **យ៉ាន់ ឡុយ** ក៏ស្លាប់ដែរ ដូច្នេះបងបង្កើតរបស់បងសយនៅសល់ តែបងស្រីទីបី ( បង **ពិន ឃួរ** ) ម្នាក់ទេ ដែលនៅរស់ ។ ក្រៅពីនេះ ក៏មាន ដំណឹងល្អខ្លះដែរដូចជា កូនស្រីទីបី ( នាង **ឡុំ** ) ព្រមទាំងក្មួយ ឧស្សាហ៍ ក្មួយ **ចេនា** ក្មួយ **ពីន** ក្មួយ **ពៅ** ក្មួយ **ម៉ាច់** និងចៅៗ ប៉ុន្មាននាក់ ទៀតបានទៅដល់សហរដ្ឋអាមេរិកអស់ហើយ ។ សំណួរសួរគ្នាទៅវិញ ទៅមកមានច្រើនមិនចេះអស់ ។ ក៏ប៉ុន្តែភាគច្រើនគឺខ្ញុំជាអ្នកនិយាយរៀបរាប់ អំពីការលំបាកវេទនារបស់ខ្ញុំ...ប្រាប់គាត់ ។ ការលំបាកក្នុងការស៊ើបសួរ ដំណឹងអំពីការចាប់ចង ការបាត់ខ្លួន និងការទាក់ទងសុំជួបគាត់ម្តងៗ ។ ឯការឈឺចាប់ គឺការគាបសង្កត់អំពីមេដប់ខ្នង មេ៥០ខ្នង ពីមន្ត្រីសង្កាត់ ខ័ណ្ឌ ជាដើម ។ ចំណែករឿងមួយទៀតដែលធ្វើឲ្យខ្ញុំឈឺចាប់ ខ្លាំងដែរនោះ គឺការ ប្រមាថមើលងាយអំពីថ្នាក់ដឹកនាំនៃក្រសួងអប់រំនេះ តែម្តងដូចជាការ បញ្ចុះឋានៈរបស់ខ្ញុំ ឲ្យទៅបង្រៀនថ្នាក់ទាប ដកតួនាទីខ្ញុំជាប្រធានក្រុម បច្ចេកទេសប្រចាំសាលា ដកតួនាទីខ្ញុំពីប្រធាននារី ដោយយកលេស ឥតសមហេតុផលទាល់តែសោះ ។ ចំពោះបុគ្គលិកគ្រូបង្រៀនមួយចំនួន ដែលធ្វើការជាមួយគ្នាទៀតសោត ក៏គេហាក់ដូចជារើសអើងជាមួយខ្ញុំ ខ្លះដែរ។ គេមិនសូវហ៊ាននិយាយស្តីជាមួយខ្ញុំ ហើយពេលប្រជុំការងារម្តងៗ ក៏គេច្រើនតែអង្គុយឃ្លាតឆ្ងាយពីខ្ញុំជានិច្ច។ ហើយខ្ញុំនៅតែមិនអស់ចិត្តដោយ

សារ " គេ " មិនព្រមប្រាប់ឲ្យក្រុមគ្រួសារបានដឹងថាតើគេចាប់បងសយ ដោយមូលហេតុអ្វី ? តើចាប់គាត់ឃុំនៅកន្លែងណា ? នេះប្រសិនបើគាត់មិនឡាត លួចទៅឱ្យប្រាប់ប្រពន្ធពូស៊ុំ នោះយើងមិនដឹងថាគាត់នៅទីណាជារៀងរហូតឬអ្វី?...។ បង **សយ** នៅស្ងៀមមួយសន្ទុះ រួចតបប្រាប់មកខ្ញុំវិញថា "មែនហើយ ខ្លួនពិតជាលំបាកមែន! ចំណែកឯខ្ញុំវិញ ខ្ញុំលំបាកច្រើនរយដង លើសនេះទៅទៀតដោយសារទារុណកម្មនៅក្នុងគុកគេ ៣ នោះ ។ វាមានការវេទនាស្ទើរតែមិនអាចជឿបានថា គេអាចធ្វើអំពើទាំងអស់នោះដាក់ចំពោះមនុស្សលោកបាន..."។ គាត់រៀបរាប់ពីការជាប់ឃុំឃាំងក្នុងគុកងងឹតក្នុងទ្រុងតូចមួយដែលពុំអាចសន្ធូកជើងបានត្រង់ ងងឹតស្លុបពុំមានខ្យល់គ្រប់គ្រាន់សម្រាបដកដង្ហើម ពេលខ្លះគាត់រកក្រដាសបានមួយសន្លឹកមកមូរ ហើយសិកតាមប្រហោង ដែលគេប្រើសម្រាប់ហុចបាយទឹកដើម្បីស្រូបយកខ្យល់អាកាសពីខាងក្រៅ។ គាត់ប្រាប់បន្ថែមទៀតថា គាត់នៅបន្ទប់ងងឹតនោះរាប់ខែ បត់ដៃបត់ជើងនៅនឹងកន្លែងរាប់អាទិត្យពុំដែលឃើញពន្លឺថ្ងៃ។នៅពេលគេឲ្យចេញទៅងូតទឹកម្តងៗ ពេលនោះភ្នែកគាត់ស្រវាំងនឹងពន្លឺថ្ងៃ ជើងដើរមិនរួច ដូច្នេះគាត់ត្រូវវារចេញ ។ រួចពីបន្ទប់ងងឹតគាត់ត្រូវគេឲ្យចេញទៅនៅបន្ទប់រួម ដែលមានអ្នកទោសគ្រប់ប្រភេទដេកតម្រៀបគ្នាប្រហែលជាសាម-សែសិបនាក់ ជើងជាប់ខ្នោះទាំងយប់ទាំងថ្ងៃ។ គាត់នៅក្នុងបន្ទប់រួមរហូត ជាប់ខ្នោះជើងរហូត ។ ដំបូងជាប់ជើងទាំងសងខាងខ្វែងគ្នា ក្រោយមកជាប់ជើងត្រង់គ្នាវិញ និងក្រោយមកទៀតជាប់ខ្នោះតែពេលយប់។ លុះដល់ចុងឆ្នាំ ១៩៨៨(ពីរ-បីខែមុនបានចេញ ពីពន្ធនាគារទើបគាត់រួចពីការដាក់ខ្នោះជើងទាំងសងខាងមកនៅសល់ដាក់ខ្នោះតែជើងម្ខាងប៉ុណ្ណោះ)។ ខ្ញុំសួរបន្តពីបញ្ហាហូបចុក ។ គាត់ឆ្លើយយ៉ាងខ្លីថា " ក្នុងគុកងងឹត គាត់មានតែបាយ១ដុំពំនូក និងអំបិលគ្រួស៤-៥គ្រាប់ ប៉ុណ្ណោះជាអាហារប្រចាំថ្ងៃ។ ក្រោយពីមកនៅរួមជាមួយគេឯង មានបាយ ម្ហូប តែមិន

ដែលឆ្អែតមិនដែលដឹងថាឆ្ងាញ់ព្រោះមានតែសម្លត្រកួនបង់អំបិល បង់ម្ទេស យូរៗស្រង់ឃើញកូនត្រីចង្វា១មានទាំងស្រកាឥតវះពោះ"។ គាត់បញ្ឈប់លែងឲ្យខ្ញុំសួរតទៅទៀត ។ ខ្ញុំស្តាប់គាត់និយាយទាំងខ្លោចផ្សាក្នុងចិត្ត តែគាត់និយាយបែបធ្វើហី ទំនងមិនចង់ឲ្យខ្ញុំរំលឹករឿងនោះច្រើន ហើយពិបាកចិត្តទៅលើអ្វីដែលជារឿងកន្លងផុតទៅហើយ។ ក៏ប៉ុន្តែខ្ញុំមានបញ្ហាច្រើនដែលចង់ដឹង។ ខ្ញុំក៏បង្វែរសំណួរដោយសួរគាត់ថា " តើពួកគេនោះធ្លាប់បង្ខំបងឲ្យសារភាព ឬស៊ីញែអ្វីទេ? " គាត់ឆ្លើយថា " មានពីរ បីដងដែរ ដូចជាឲ្យគាត់សារភាពថាក្នុងសម័យប៉ុលពត ធ្លាប់ធ្វើកុងស៊ីយ៍ ហើយឲ្យគាត់សុំទោស និងឲ្យប្តេជ្ញាស្មោះត្រង់ចំពោះបដិវត្តន៍ថ្មីនេះ..."។ គាត់បញ្ជាក់ថែមទៀតថា គាត់ឥតព្រមធ្វើតាមគេទេ ឥតស៊ីញែអ្វីទាំងអស់ ទោះបីគេសន្យាថានឹងដោះលែងគាត់ក៏ដោយ។ ខ្ញុំជឿពាក្យសម្តីរបស់គាត់ ព្រោះខ្ញុំស្គាល់ចរិតគាត់ច្បាស់ណាស់ ។ បងសយធ្លាប់ទទួល ការបញ្ចុះបញ្ចូលអំពីអ្នកមានអំណាចដែលចង់អូសទាញគាត់ឲ្យចូលរួមធ្វើនេះធ្វើនោះជាមួយពួកគេ ។ គេប្រើផ្ទាក់សព្វបែបយ៉ាង មានការផ្តល់លាភសក្ការៈផ្សេងៗរហូតដល់ឋានៈតួនាទីធំដុំថែមទៀត តួយ៉ាងដូចជា កាលគាត់ធ្វើចាងហ្វាងកាសែត "ឯកភាព " គាត់បានចូលរួមជាមួយគណៈប្រតិភូទៅធ្វើទស្សនៈកិច្ចនៅប្រទេសសង្គមនិយមជាច្រើន ហើយពេលត្រលប់មកវិញ ប្រធានគណៈប្រតិភូដែលជានាយករដ្ឋមន្ត្រី បានហៅគាត់ឲ្យចូលរួមការងារនៅក្រសួងអប់រំ ( ថ្នាក់រដ្ឋមន្ត្រី ) ។ នៅក្រោយរដ្ឋប្រហារ ( ១៩៧០ ) ប្អូនប្រុស របស់លោកឧត្តមសេនីយ **លន់ ណុល** ដែលជាមិត្តរួមថ្នាក់របស់គាត់ ក៏បានអន្ទងហៅគាត់ឲ្យចូលក្នុងជួរគណៈរដ្ឋមន្ត្រីផងដែរ ។ ក៏ប៉ុន្តែបង **សយ** បដិសេធរហូត ព្រោះគាត់យល់ច្បាស់នូវធាតុពិតរបស់ថ្នាក់ដឹកនាំកំពូលនៅសម័យនោះ ដែលភាគច្រើនដឹកនាំប្រទេសតាមមហិច្ឆិតាផ្ទាល់ខ្លួន ឥតខ្វល់ខ្វាយ នឹងសុខទុក្ខរបស់ប្រជាពលរដ្ឋឡើយ ។ ដោយមានជំហរបែបនេះហើយបានជា

ជីវិតរបស់គាត់ និងគ្រួសារតែងជួបប្រទះនឹងវិបត្តិឥតស្រាកស្រាន្ត ពីព្រោះគេចាត់ទុកគាត់ថាប្រឆាំងនឹងគេ ដូចជាត្រូវគេចាប់បង្ខាំង ចាប់ដាក់គុករហូតដល់ការគំរាមកំហែងដល់អាយុជីវិត គួរឲ្យខ្លាចថែមទៀត ។ ចំពោះប្ដីខ្ញុំ គាត់មិនដែលបញ្ចេញអាការរំភើបសប្បាយ ភ្លើតភ្លើន ឬរំជើបរំជួលម្ដងណាឡើយ ទោះបីនៅចំពោះស្ថានភាពល្អ ឬ អាក្រក់ក៏ដោយ ។ មានបុគ្គលខ្លះដែលធ្លាប់ស្គាល់គាត់ អ្នកខ្លះវាយតម្លៃថា បង**ពិនសយ** ជាមនុស្សដែលមានគុណសម្បត្តិខ្ពស់ មានទស្សនៈវិស័យច្បាស់លាស់ រក្សាឧត្ដមគតិខ្ជាប់ខ្ជួនកម្ររកមនុស្សប្រដូច ។ ទន្ទឹមនឹងនោះដែរ ក៏មានបុគ្គលខ្លះរិះគន់គាត់ដែរថាគាត់ល្ងង់ណាស់ ខ្លះថា គាត់ចូលស្ទឹងមិនតាមបត់ រហូតដល់មានខ្លះថាគាត់ភ្លើថែមទៀត ។ ខ្ញុំឆ្ងល់ថា ហេតុអីក៏មានការវាយតម្លៃផ្ទុយគ្នាខ្លាំងម្ល៉េះ ? ដំបូងខ្ញុំនឹកអន់ចិត្តខ្លះដែរ តែខ្ញុំគិតថាការវាយតម្លៃអ្វីក៏ដោយ វាពុំអាចដូចគ្នាបានទេ គឺវាអាស្រ័យតាមនិស្ស័យរបស់មនុស្ស ឬទស្សនៈវិស័យប្លែកៗរបស់សង្គម ។ ចំពោះរូបខ្ញុំវិញ ខ្ញុំយល់ថាជំហររបស់បងសយក្នុងគ្រានោះដែលមិនព្រមសារភាព សុខចិត្តទ្រាំដេកក្នុងគុកតទៅទៀត គឺជាឧត្ដមគតិរបស់គាត់ គឺមិនក្បត់ឧត្ដមគតិរបស់ខ្លួន ដែលខ្ញុំចាត់ទុកថាជាគុណសម្បត្តិដ៏ធំធេងរបស់គាត់ទៅវិញទេ ។

ម្យ៉ាងទៀតដោយមាននិស្ស័យជាអ្នកនយោបាយ បង **សយ** ឥតបោះបង់ការងារនេះឡើយ ។ គាត់តាមដានព្រឹត្តិការណ៍ក្នុងប្រទេសក្រៅប្រទេសជាប់ជានិច្ច។ គាត់ចូលចិត្តជជែកលែងជាមួយមិត្តភ័ក្ត ជាមួយក្រុមបញ្ញវន្តក្មេងៗ លើបញ្ហានយោបាយក្នុងស្រុក ( សម័យការចរចានៅទីក្រុងប៉ារីស រវាងពួកត្រីភាគគី ) ។ មិនតែប៉ុណ្ណោះ បង **សយ** បានចូលរួមជួយរៀបចំគណៈបក្សនយោបាយថ្មីដែលប្រុងនឹងបង្កើតតាមសំណូមពររបស់ក្រុម បញ្ញវន្តក្មេងៗ ក្នុងនោះមានក្មួយខ្ញុំម្នាក់ដែលជាកូនរបស់ប្អូនស្រីខ្ញុំ ( លីនារី ) ឈ្មោះ **ជេត ជួនតារាធុង** ជាអ្នកមកធ្វើទំនាក់ទំនងផ្ទាល់ជាមួយនឹង

គាត់ ។ គឺគណបក្ស " ជាតិខ្មែរ " ក្រោយមកដូរឈ្មោះជាគណបក្ស " សមរង្ស៊ីវិញ " ។ គណៈបក្សនេះចាប់បដិសន្ធិក្រោយការបោះឆ្នោត១៩៩៣។ តាំងពីពេល នោះមក បង**សយ** នៅជួយកិច្ចការរបស់គណបក្សនេះក្នុងនាមជាទីប្រឹក្សារហូតមក ។ ការចូលរួមក្នុងឆាកនយោបាយនាពេលនោះ គឺជាឆន្ទៈស្រលាញ់ ស្រុកទេសរបស់គាត់តែប៉ុណ្ណោះ ។ គាត់ចង់ឃើញមុខមាត់ថ្មីរបស់សង្គមខ្មែរ ដែលមានអ្នកដឹកនាំល្អ ដែលបម្រើផលប្រយោជន៍ឲ្យប្រជាពលរដ្ឋ ។ គាត់ពុំដែលមានបំណងចង់បានតួនាទី ឬឋានៈអ្វីទេ។ ជាក់ស្តែងរឿងមួយ ដែលខ្ញុំចាំមិនភ្លេចគឺ លោក **យឹម សុខា** ដែលជាអគ្គលេខាគណបក្ស ( ឥឡូវគាត់ស្លាប់ទៅហើយ) បានមកសុំយោបល់អំពីបង **សយ** លើបញ្ហាបង្កើតស្ថាប័ន " ព្រឹទ្ធសភា "។ បង **សយ** យល់ថាគឺជាការខ្ជះខ្ជាយមនុស្ស និងថវិកា មិនគួរឲ្យមានទេ...។ លោក **យឹម សុខា** មកសុំយោបល់ ហើយក៏ចង់ឲ្យគាត់ចូលទៅកាន់ព្រឹទ្ធសភាផងដែរ តែបង **សយ** បដិសេធ ព្រោះគាត់យល់ថា " ឥតបានផលប្រយោជន៍ " ។ ចរិតរឹងត្អឹងរបស់ បង **សយ** គឺជាជំហរស្រឡាញ់ " ហេតុផល " ឥតប្រែប្រួល ។ ជំហរបែបនេះហើយដែលធ្វើឲ្យគាត់មានចក្ខុវិស័យទូលំទូលាយ ។ គាត់តែងធ្វើការសម្រេចអ្វីមួយដោយឈរលើការត្រិះរិះពិចារណាល្អិតល្អន់ ។ ម្ល៉ោះហើយគាត់ និយាយអ្វីឬធ្វើអ្វីក៏ដោយមិនសូវខុសទេ ។ គ្រួសារគាត់ក្តី កូនចៅនិង ប្រូខ្ញុំក្តី តែងឲ្យតំលៃគាត់ថា " **ជាមនុស្សត្រូវគេ** " ដែលនិយាយត្រូវយល់ត្រូវទាយទុកជាមុនត្រូវមិនសូវខុស ។ មនុស្សបែបបង**សយ** គួរ.ណាស់តែត្រូវបានគេរាប់អាន និងឲ្យតំលៃ ។ ក៏ប៉ុន្តែផ្ទុយទៅវិញ គាត់ បែរជាទទួលទុក្ខទោសក្នុងគ្រប់ជំនាន់នៃសង្គម ។

---

យើងបានរស់នៅជួបជុំគ្នាវិញហើយ...ខ្ញុំទៅធ្វើការដូចធម្មតា(បង្រៀន នៅសាលារដ្ឋផង និងបង្រៀនគួរបន្ថែមផង)។ បងសយនៅផ្ទះ ក៏ឥតទំនេរដៃដែរ (ជានិស្ស័យរបស់គាត់)។ គាត់ជួសជុលផ្ទះបាយដែលពុកក្តារជញ្ជាំង ក្តារក្រាល ធ្លាក់បាក់បែក ជូរទទឹកដែលធ្លុះធ្លាយ ហូរ ទឹកចូលក្នុងផ្ទះពេលភ្លៀងធ្លាក់មកម្តងៗ ។ គាត់កាប់កាយដីនៅចំហៀងផ្ទះ ដាំបន្លែបង្ការ មានដើមជន្លង់ ដើមបាសឡាវតាមរបងផ្ទះ គ្រាន់បានបេះស្លឹកធ្វើជាបន្លែ ។ គាត់មានដាំទំពាំងបាយជូ (ទើបរៀនដាំ) ដាំផ្កាសម្រាប់លំអរលំនៅដ្ឋានដែរ។

ក្រោយពីពេលនោះបន្តិចមក រវាងឆ្នាំ ១៩៩០ មានអង្គការក្រៅរដ្ឋាភិបាលមួយ (អង្គការម៉ារីណុល ដែលបើកសាលាបង្ហាត់បង្រៀនជនពិការ មានទីតាំងនៅគៀនឃ្លាំង) បានមកសុំឲ្យខ្ញុំទៅជួយធ្វើការក្រៅម៉ោង នៅក្នុងអង្គការនោះ ។ ពេលខ្ញុំទៅធ្វើការម្តងៗ គឺបងសយនេះឯង ជាអ្នកជិះម៉ូតូឌុបខ្ញុំ ជូនទៅមកជានិច្ច ។ ម៉ូតូត្រូវចុះឆ្លងដរ ព្រោះស្ពានជ្រោយចង្វា នៅពុំទាន់បានគេសង់ឡើងវិញនៅឡើយ ក្រោយពីត្រូវកំទេចដាច់ដោយពួក យៀកកុង ក្នុងសម័យលន់ណុល ។ រាល់ពេលដែលខ្ញុំចូលទៅក្នុងបន្ទប់ធ្វើការបាត់ បងសយតែងជិះម៉ូតូទៅមើលភូមិស្រុកគៀនឃ្លាំង ទៅព្រែកលាបដែលភាគច្រើនប្រជាជននៅទីនោះ ប្រកបរបរដាំបន្លែ ។ គាត់ចូលចិត្តសួរនាំអំពីការរកស៊ី ការរស់នៅរបស់អ្នកភូមិស្រុកនោះ ។ ទំនាក់ទំនងញឹកញាប់របស់គាត់ជាមួយអ្នកស្រុកគៀនឃ្លាំង បានធ្វើឲ្យមានការរាប់អានគ្នាទៅវិញទៅមក ។ គឺនៅពេលនោះហើយ ដែលបងសយបានទាក់ទងទិញដី បានពីរ-បីកន្លែង ក្នុងតំលៃថោកៗ គឺពីរ-បីជី ក្នុងមួយប្លង់ដីតែប៉ុណ្ណោះ ។

នៅឆ្នាំ ១៩៩១ ក្រសួងអប់រំបានចេញប្រកាសឲ្យបុគ្គលិកនារីដែលមានអាយុពី ៥០ ឆ្នាំឡើងទៅត្រូវចូលនិវត្តន៍ ។ ពេលនោះខ្ញុំមានអាយុបាន ៥៤ ឆ្នាំហើយៗត្រូវចូលនិវត្តន៍តាមការកំណត់ ( ២៣ ធ្នូ ១៩៩១ ) ។ ដោយឆ្នាំសិក្សាមិនទាន់ចប់ ដូច្នេះខ្ញុំត្រូវនៅបង្រៀនបន្តរហូតដល់ចប់ឆ្នាំសិក្សា ។

រឿងមួយដែលធ្វើឲ្យខ្ញុំមិនសប្បាយចិត្តនោះ គឺគ្រាន់តែខ្ញុំមានឈ្មោះជាគ្រូចូលនិវត្តន៍ភ្លាម គេមិនសូវឲ្យតម្លៃតែម្តង ដូចជាមិនមានឈ្មោះចាត់តាំងជាមេប្រយោគក្នុងពេលប្រលង " បាក់ឌុប " ដែលកាលពីឆ្នាំមុនៗ ខ្ញុំតែងត្រូវបានគេចាត់តាំងជាប្រធានកំណែផ្នែកអក្សរសាស្ត្រស្ទើររាល់លើក ។ រាល់ពេលដែលគេត្រូវការគ្រូទៅបង្រៀនថ្នាក់អក្សរសាស្ត្រ គេតែងពោលពាក្យថា " មានតែអ្នកគ្រូទេទើបស័ក្តិសម " ដូចជាទៅបង្រៀនគ្រូបឋម ដើម្បីដំឡើងក៏តែជាសាស្ត្រាចារ្យក្នុងវគ្គខ្លី ដែលមានរយៈពេលមួយខែទៅពីរខែ ហើយរៀនបីវគ្គទើបចប់ ទៅបង្រៀនប្រធានមន្ទីរអប់រំខេត្តមួយចំនួន ដើម្បីឲ្យមានកម្រិតខ្ពស់ស្មើនឹងថ្នាក់សាស្ត្រាចារ្យ (វគ្គ ៩ ខែ នៅក្នុងមជ្ឈមណ្ឌលកូឡាបទី៣ ) ជាដើម ។ កាលនោះ អ្នកខ្លះអាយុដល់ទៅជាង ៦០ ឆ្នាំទៅហើយ នៅតែបន្តធ្វើការនៅក្នុងមន្ទីរ ឬ ក្រសួងដដែលដោយគេចាត់ទុកថាជាមន្ត្រីចាំបាច់។ ខ្ញុំតែងគិតថា "នេះគឺជារឿងប្រកាន់បក្សពួក " ឬ និយាយឲ្យខ្លីគឺ " អយុត្តិធម៌... " តែម្តង ។

ក្រោយពេលចូលនិវត្តន៍ ខ្ញុំមានឱកាសច្រើនដើម្បីទៅធ្វើការពេញម៉ោងនៅអង្គការជនពិការគៀនឃ្លាំង គឺអង្គការជប៉ុន AAR នៅកម្ពុជា (ដែលបន្តការងាររបស់អង្គការម៉ារីណុល ) ។ ខ្ញុំតែងចុះទៅរកជនពិការ នៅតាមខេត្តមួយចំនួន ដើម្បីឲ្យគេមករៀន (រៀនទាំងផ្នែកអក្សរផង និងរៀនទាំងផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈផង ) ។ ដំបូងខ្ញុំមានតួនាទីជាប្រធានផ្នែកអប់រំ រួចបន្ទាប់មកកាន់ផ្នែករដ្ឋបាល ។ ហើយនៅឆ្នាំ ១៩៩៧ ក៏ក្លាយទៅជាប្រធានប្រតិបត្តិនៃអង្គការនោះ ។

ដោយខ្ញុំបានចូលប្រឡូកក្នុងកិច្ចការនយោបាយ ជាមួយគណបក្សសម រង្ស៊ី ផងដែរ ហើយនៅអណត្តិឆ្នាំទី ២ ខ្ញុំបានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌលក្រុងភ្នំពេញ ពេលនោះខ្ញុំត្រូវទទួលការគំរាមកំហែងជាច្រើន ដែលជាហេតុធ្វើឲ្យខ្ញុំដើរចេញពីអង្គការជនពិការ (គ្រប់

អង្គការទាំងអស់ ត្រូវស្ថិតនៅក្រោមក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ) ។ ដូចនេះខ្ញុំបានធ្វើការនៅក្នុងអង្គការ AAR-J រយៈពេល ៧ ឆ្នាំ និង Mary Knoll រយៈពេល ២ ឆ្នាំ សរុប ៩ ឆ្នាំ ។

ក្រោយមកខ្ញុំបានចូលសរុបធ្វើការនៅក្នុងគណបក្ស **សម រង្ស៊ី** ជាគណៈកម្មាធិការនាយក ។ ខ្ញុំធ្លាប់បានចុះទៅបង្រៀនផ្នែកយេនឌ័រនៅតាមខេត្ត ក្រុងជាច្រើន ធ្លាប់បានធ្វើជានិពន្ធនាយកនៃព្រឹត្តិប័ត្រ "ចលនាស្ត្រី" របស់គណបក្ស **សម រង្ស៊ី** ។ នៅឆ្នាំ ២០០៣ ខ្ញុំត្រូវបានជាប់ឆ្នោតជាសមាជិក ក្រុមប្រឹក្សាឃុំ–សង្កាត់ មានតួនាទីជាចៅសង្កាត់នៅសង្កាត់ទឹកល្អក់ទី ១ ខ័ណ្ឌ ទួលគោក ។ ដំបូងខ្ញុំមានមោទនភាព និងពេញចិត្តយ៉ាងខ្លាំងនឹងតួនាទីនេះ ព្រោះខ្ញុំចង់រៀបចំសង្កាត់ទឹកល្អក់ទី ១ ដែលជាសង្កាត់ខ្ញុំរស់នៅសព្វថ្ងៃ ឲ្យទៅជាសង្កាត់គំរូ ដើម្បីឲ្យប្រជាជនគ្រប់ជាន់ថ្នាក់ទាំងអ្នកតូច អ្នកធំ ទាំងអ្នកក្រ អ្នកមាន មានលទ្ធភាពប៉ុនគ្នា ក្នុងការជួបប្រាស្រ័យទាក់ទង នឹងរដ្ឋអំណាចមូលដ្ឋាន។ បំណងសំខាន់មួយទៀតគឺរៀបចំអភិវឌ្ឍន៍សង្កាត់ នេះលើវិស័យច្បាប់ និងវិស័យសង្គមកិច្ច បានសេចក្តីថាប្រកាន់យុត្តិធម៌តាមផ្លូវច្បាប់ និងយុត្តិធម៌សង្គមឲ្យបានប្រសើរដូចជាប្រទេសជឿនលឿននៅលើពិភពលោក ។ ក៏ប៉ុន្តែ បំណងរបស់ខ្ញុំពុំអាចទៅដល់គោលដៅបានឡើយ ដោយមានមូលហេតុច្រើនយ៉ាង ។ ម៉្យាងសមាជិកក្រុមប្រឹក្សាសង្កាត់មកពីគណបក្សកាន់អំណាចបង្កការលំបាកសព្វបែបយ៉ាង ម៉្យាងទៀតសមាជិកក្នុងគណបក្សឯងផ្ទាល់ក៏ធ្វើការមិនពេញដៃពេញជើង ។ ពិបាកបន្ទោសដែរ ព្រោះ ប្រាក់ខែឧបត្ថម្ភតិចតួច គឺ ៨ ម៉ឺនរៀល ស្មើនឹង $ ២០ ក្នុងមួយខែប៉ុណ្ណោះ ។ អញ្ចឹងហើយម្នាក់ៗត្រូវតែឆ្លៀតរកក្រៅ ។ ហើយក៏ប្រហែលជាកំហុសរបស់ខ្ញុំដែរ ដែលកាលណោះឈ្មោះបោះឆ្នោត ខ្ញុំទទួលលំដាប់លេខ ១ ក្នុងបញ្ជីបេក្ខជនមែន តែខ្ញុំសន្យាថា បើជាប់ជាចៅសង្កាត់ ខ្ញុំធ្វើតែមួយរយៈទេ ខ្ញុំនឹងប្រគល់តួនាទីនេះទៅ

ឲ្យអ្នកលំដាប់ទី ២ ។ លើសពីនេះទៅទៀត ការសន្យា របស់គណបក្ស **សម រង្ស៊ី** ថានឹងជួយក្នុងការគ្រប់គ្រងសង្កាត់នេះឲ្យទៅជាសង្កាត់គំរូ ពីព្រោះជាសង្កាត់ដែលមានស្ត្រីជាចៅសង្កាត់តែមួយនៅក្រុងភ្នំពេញ តែបែរជាមិនបានជួយអ្វីទាំងអស់។ រយៈពេលជាងមួយឆ្នាំដែល ខ្ញុំធ្វើការនៅសង្កាត់ទឹកល្អក់ទី ១ ខ្ញុំពុំដែលឃើញតំណាងរាស្ត្រ ឬថ្នាក់ដឹកនាំរបស់គណបក្សណាម្នាក់មកមើល ឬសួរនាំអ្វីសោះឡើយ។ ខ្ញុំក៏សម្រេចចិត្ត លាលែង បោះបង់តួនាទីចៅសង្កាត់ (នៅខែ ឧសភា ឆ្នាំ ២០០៤) នេះទៅ ។ រីឯការចូលរួមក្នុងគណបក្សនយោបាយ **សម រង្ស៊ី** ក៏ខ្ញុំបានបន្ថយសកម្មភាពដែរ ដោយឃើញមានការប្រទាញប្រទង់ ដណ្តើមតួនាទីគ្នាក្នុងការយកលំដាប់ល្អ ក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតំណាងរាស្ត្រ ។

ចាប់ពីពេលនោះមក ខ្ញុំមានពេលទំនេរច្រើន សម្រាប់ការគ្រប់គ្រងសាលា ( គូ ) របស់ខ្ញុំ " សាលា នគរភ្នំ " ដែលកាន់តែរីកកើនឡើង និងផ្តល់កម្រៃច្រើនគួរសមសម្រាប់រស់ ។ គ្រួសារយើងក្នុងពេលនោះ ធូរធារហើយ ព្រោះពុំសូវមានបន្ទុកច្រើន ។ កូនរបស់យើងទាំងបីបានបញ្ចប់ ការសិក្សានៅមហាវិទ្យាល័យ ( នាងសិទ្ធិការ្យ រៀនចប់សាលាតិចណូ ជាវិស្វករផ្នែកអគ្គីសនី – នាងធុតិមា រៀនចប់សាលាពេទ្យជាវេជ្ជបណ្ឌិត ហើយនាងវ៉ាន់លឿនរៀនចប់សាលាតិចណូ ជាវិស្វករគីមីចំណីអាហារ) ។ ចំណែកឯកូនពីរនាក់ទៀត ម្នាក់ (នាងឡុំ កូនស្រីទី៣) ទៅអាមេរិក តាំងពីឆ្នាំ ១៩៨៤ និង ( នាងដា ) កូនស្រីទីពីរគេមានរបររកស៊ីត្រឹមត្រូវ ហើយប្តីរបស់នាងក៏មានបើកកន្លែងជួសជុលឡាន ព្រោះគេមានជំនាញក្នុងគ្រឿងម៉ាស៊ីន( ជានិស្សិតមកពីសូវៀត ) ហើយក្រោយមកគេបានចេញទៅរស់នៅឯប្រទេសអូស្ត្រាលីទាំងគ្រួសារដែរ ។ អាស្រ័យហេតុនេះហើយបាន ជាខ្ញុំឥតសូវខ្វល់ខ្វាយពីបញ្ហាចាយវាយប៉ុន្មានទេ ។ ក៏ប៉ុន្តែចំពោះប្តីខ្ញុំវិញ ថ្វីត្បិតតែគាត់មិនដែលបន្ទុចបង្អាក់ខ្ញុំមែន តែគាត់នៅតែមិនចូលចិត្តចំណាយ លើរបស់ណា

ដែលគាត់គិតថាអត់ប្រយោជន៍ដែរ ។ ទោះជាយ៉ាងនេះក្តី ក៏ម្តងម្កាលគាត់ព្រមធ្វើតាមខ្ញុំដែរ ដូចជាពេលខ្ញុំបបួលគាត់ទៅលេងតាមខេត្តនានា ក្នុងប្រទេស ( កែប កំពង់សោម កោះកុង ក្រចេះ ស្ទឹងត្រែង ) ឬទៅប្រទេសក្រៅជាដើម គាត់ព្រមទៅជាមួយផងដែរ។

គួរឲ្យសោកស្តាយ និងអាណិតប្តីខ្ញុំណាស់ ដែលបំណងធំរបស់គាត់គឺចង់ទៅលេងអូស្ត្រាលី ជួបនឹងក្មួយប្រុសគាត់ ( ជី គីលីន ) និងកូនស្រីទីពីររបស់គាត់ ដែលបានទៅរស់នៅអូស្ត្រាលី ៤–៥ ឆ្នាំមក ហើយតែពុំទាន់បានសម្រេចនៅឡើយ ។ គាត់ក៏ធ្លាប់មានបំណងចង់ជូនខ្ញុំទៅមើលមហាកំផែង ទៅមើលទូរអេសហ្វែល ក៏ពុំទាន់បានទៅដែរ ដោយគាត់មានការលំបាកក្នុងការធ្វើដំណើរ ។ នៅមានសំណាងមួយដែរ ព្រោះគាត់បានទៅលេងប្រទេសអាមេរិកពីរដង ។ កូនស្រីគាត់២ នាក់ និងមានក្មួយ ( កូនបងប្រុសទី ១ បងប្រុសទី ២ និងកូនប្អូនប្រុសបន្ទាប់របស់គាត់ ) ច្រើននាក់ទៀត នៅទីនោះ។ នៅពេលដែលគាត់ទៅលេងនៅសហរដ្ឋអាមេរិកលើកទីមួយនាឆ្នាំ ១៩៩៨ គាត់សប្បាយមែនទែន ពីព្រោះបំណងរបស់គាត់ដែលចង់ស្គាល់សហរដ្ឋអាមេរិកបានសម្រេចហើយ ។ បំណងមួយទៀតដែលគាត់ ចង់ជួបក្មួយប្រុសរបស់គាត់(**ពីង គីង៉ាត**) ដែលគាត់ធ្លាប់ស្រឡាញ់ និងធ្លាប់បញ្ជិះនៅលើស្មា នាំដើរលេងកាលក្មួយនៅក្មេង ដែលកាលនោះគាត់នៅលីវ ហើយស្នាក់នៅជាមួយប្អូន " **ស៊ា** " របស់គាត់ ។ គាត់ក៏មានបំណងទៅលេងក្មួយស្រី ក្មួយប្រុសដទៃទៀត ដែលបែកពីគាត់តាំងពីឆ្នាំ ១៩៧០ មកម្លេះ។ នៅពេលមកដល់រដ្ឋកាលីហ្វ័រនីញ៉ា ក្មួយគាត់ម្នាក់ ( នាង **ឈន់** និង ប្តីនាង **ម៉េង អៀង** )បាននាំគាត់ទៅមើលទំនប់វារីអគ្គិសនីដ៏ធំមួយគឺទំនប់ Hoover Dam ដែលធ្វើឲ្យគាត់នឹកឃើញដល់ការស្រមៃរបស់គាត់កាលនៅក្មេងពេលគាត់នៅរៀនបឋមសិក្សា ។ តាមរយៈការសិក្សាភូមិសាស្ត្រ ស្រុកខ្មែរ ថាមានកន្លែងទឹកធ្លាក់ដ៏ធំមួយនៅតាមដងទន្លេមេគង្គត្រង់

ព្រំប្រទល់កម្ពុជា–ឡាវ គឺ "ល្បាក់ខោន " ។ គាត់មានបំណងចង់ធ្វើវារីអគ្គីសនីនៅ "ល្បាក់ខោន " ក្នុងខេត្តស្ទឹងត្រែងនោះ ដើម្បីយកភ្លើងមកផ្គត់ផ្គង់នៅទូទាំងប្រទេសខ្មែរតែម្តង ។ អាស្រ័យហេតុដូចនេះហើយ បានជាពេលដែលគាត់ទទួលអាហារូបករណ៍ ទៅបន្តការសិក្សានៅប្រទេសបារាំង(ឆ្នាំ១៩៤៨)គាត់បានជ្រើសរើសយកមុខវិជ្ជាខាងវារីអគ្គីសនីនេះឯង..។


ល្បាក់ខោន

រឿងមួយទៀតដែលគាត់ចង់ស្គាល់ និងចង់ឃើញដោយផ្ទាល់នឹងភ្នែក ហើយដែលគាត់ស្រឡាញ់តាំងពីគាត់នៅក្មេងដែរនោះគឺ " ស្ពានមាស " នៅក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ។ គាត់តែងនឹកស្រមៃគិតថា ដល់គាត់ធំឡើង គាត់ចង់ឲ្យស្រុកខ្មែរ មានស្ពានដ៏ល្អប្រណីតបែបនេះ ដើម្បីឲ្យប្រជាជនធ្វើដំណើរបានងាយស្រួលឆ្លងកាត់ទន្លេមេគង្គ ។ ការស្រមៃនេះឯង ហើយដែលធ្វើឲ្យគាត់ចង់មកឃើញដោយផ្ទាល់ ។ ក្នុងពេលឆ្លងកាត់ " ស្ពានមាស "និងការដើរទស្សនា នាកន្លែងដាក់តាំងលក់វត្ថុអនុស្សាវរីយ៍នៃស្ពាននេះ គាត់រំភើប និងមានការចាប់ អារម្មណ៍ច្រើន ។

បង **សយ** ប្រាប់ឲ្យខ្ញុំទិញរូបថតស្ពាននៅសាន់ហ្វ្រាន់ស៊ីស្កូសន្លឹកធំមួយសន្លឹក ។ ដូចដឹងស្រាប់ហើយ គាត់ជាមនុស្សសន្សំសំចៃ មិនងាយចំណាយលុយទិញរបស់របរផ្ដេសផ្ដាសឡើយ ហើយរូបភាពនោះទៀតសោត វាមានតម្លៃថ្លៃគួរសមដែរ " ១៥០ " ។ តែគាត់នៅតែហ៊ានចំណាយប្រាក់ទិញ សរបញ្ជាក់ថា គាត់ពិតជាស្រឡាញ់សំណង់ស្ពានទំនើបរបស់ប្រទេសជឿនលឿនមែន ដើម្បីយកគំនិតមកអភិវឌ្ឍន៍ស្រុកទេសរបស់គាត់។ នៅពេលទៅដល់ស្រុកខ្មែរ គាត់យករូបថតនោះ ដាក់តាំងនៅជញ្ជាំង ក្បែរតុដែលគាត់តែង អង្គុយអានកាសែត ឬសរសេរអ្វីផ្សេងៗ ។ បំណងនេះក៏បានសម្រេច នៅពេលដែលគាត់មកលេងសហរដ្ឋអាមេរិក លើកទីពីរនៅឆ្នាំ ២០០២ ដើម្បីចូលរួម ក្នុងពិធីមង្គលការរបស់កូនស្រីពៅគាត់ផង ។




រាល់ពេលដែលយើងមកលេងនៅអាមេរិក កូនគាត់ក្ដី និងក្មួយៗ ដែលរស់នៅតាមបណ្ដារដ្ឋផ្សេងៗក្ដី ( អូរិហ្គិន កាលី និងនៅ តិចសាស តែងទទួលយើងយ៉ាងរាក់ទាក់ ហើយចាត់ទុកយើងដូចជាឪពុកម្ដាយបង្កើត

របស់ពួកគេអញ្ចឹងដែរ។ ខ្ញុំសូមថ្លែងអំណរគុណដល់ពួកគេទាំងអស់នោះយ៉ាងកក់ក្ដៅបំផុត ។

នៅឆ្នាំ ២០០៧ គាត់មានជំងឺ កើតដុំគ្រួសក្នុងប្រមាត់ដែលពេទ្យតម្រូវឲ្យគាត់វះកាត់ ។ កូនៗសុំឲ្យគាត់ទៅវះនៅអាមេរិកវិញ ព្រោះពេទ្យគេល្អជាង អាចមានការទុកចិត្តបានច្រើន ព្រោះគាត់មានអាយុជាង ៨០ ឆ្នាំទៅហើយ ។ លើកទី ៣ ហើយដែលគាត់មកអាមេរិក ។ គឺគាត់ត្រូវទៅឲ្យពេទ្យពិនិត្យដើម្បីវះយកគ្រួសក្នុងប្រមាត់ ។ តែពេលចូលដល់មន្ទីរពេទ្យ គេបែរជារកឃើញថាមានជំងឺផ្សេងទៅវិញ នោះគឺសរសៃឈាមចេញពីបេះដូងចំនួន៤ បានស្ទៀត។ គ្រូពេទ្យថាគ្រួសក្នុងប្រមាត់ មិនមែនជាបញ្ហាធ្ងន់ធ្ងរអ្វីទេ ហើយអ្វីដែលចាំបាច់ត្រូវធ្វើការវះកាត់ជាបន្ទាន់ គឺបញ្ហាបេះដូងដែលមានសរសៃស្ទៀតទៅវិញ ។ ដំបូងយើងទាំងអស់គ្នាស្ទាក់ស្ទើរ ព្រោះបញ្ហាថ្លៃពេទ្យដែលយើងធ្លាប់លឺគេនិយាយថា ការវះកាត់របៀបនេះត្រូវចំណាយប្រាក់អស់ជាង ១០ ម៉ឺនដុល្លារឯណោះ ប្រសិនបើយើងគ្មានអ៊ីនស្វ៊ីននោះ ។ ជាសំណាងល្អ លោកវេជ្ជបណ្ឌិតជំនាញខាងវះកាត់បេះដូង Dr. Gary Ott នៅមន្ទីរពេទ្យប្រ៊ូវីដង់( Providence ) បាននិយាយប្រាប់ យើងថា" "បើព្រមវះកាត់ឥឡូវ គាត់នឹងរះឲ្យព្រោះមានសង្ឃឹមច្រើនតែបើចាំ២ ខែទៀតគាត់មិនធានាឲ្យទេ..."។ យើងគ្មានជម្រើសឡើយ ណាជំងឺរបស់គាត់ចូលដល់ដំណាក់កាលអាសន្ន ណាមួយទៀតភាពមនុស្សធម៌ និងសប្បុរសធម៌របស់លោកវេជ្ជបណ្ឌិត Gary Ott ដែលបន្ថែម ថា " " គាត់សុខចិត្តវះកាត់ឲ្យដោយមិនគិតថ្លៃទេ ព្រោះព្រះបានបង្កើតរូប គាត់មកដើម្បីជួយដល់មនុស្សលោក " ។ ដោយមានការជួយគាំទ្រពីក្រុម គ្រួសារទាំងអស់គ្នាសូម្បីតែក្មួយ **កុសល** (កូនប្រុសប្អូនស៊ា ដែលជាក្មួយ សំណប់ចិត្តម្នាក់របស់គាត់ ) ដែលជាប់ការងាររវល់យ៉ាងមម៉ាញឹក ក៏ជិះយន្ត ហោះមកជួបដើម្បីជួយលើកទឹកចិត្តគាត់ និងបង្ហាញនូវភាពជួយគាំទ្រដល់ យើងទាំង

អស់គ្នា ហើយក៏មាន អ្នកស្រី ឡយនន ពេទ្យជនជាតិអាមេរិក ( មិត្តភក្តិរបស់កូនពិន ) មកជួយគាំទ្រដល់ពួកយើង ។ ជាមួយគ្នានេះមានការនិយាយលើកទឹកចិត្តតាមទូរស័ព្ទក៏មានច្រើនដែរ ដូចជាលោកសុណា នៅក្រុង Boston នាង ទូច (កូនស្រីរបស់ជន្លងខ្ញុំ) នៅក្រុង Lowel ជាដើម ។ ទាំងក្រុមគ្រួសារ ទាំងសាម៉ីខ្លួន ក៏សម្រេចចិត្តទទួលការវះកាត់ (វះកាត់ដោយ By Pass)។ ការវះកាត់នេះធ្វើឡើងអស់រយៈពេលជាង ៦ ម៉ោង បានទទួលជោគជ័យហើយ ។ យើងទាំងអស់គ្នារីករាយសប្បាយរីករាយឥតឧបមា ។

ដោយឡែកខ្លួនខ្ញុំដែលជួយកំដរគាត់នៅឯមន្ទីរពេទ្យជាមួយកូន និងក្មួយៗបានតែ ២-៣ ថ្ងៃប៉ុណ្ណោះ បែរជាមិនស្រួលខ្លួន ទៅជាក្ដៅរងាជាប់រហូតទាល់តែដល់ពេលគាត់ចេញពីមន្ទីរពេទ្យមកវិញ ។ ឥឡូវវាត្រូវដល់វេនខ្ញុំទៅពិនិត្យពេទ្យម្ដងវិញហើយ ឃើញថាជំងឺជរបស់ខ្ញុំក៏ចាប់ផ្ដើមមកញាំញី តែមិនសូវមើលឃើញធ្ងន់ធ្ងរប៉ុន្មានទេ ។ ដោយឡែកចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំស្មានដឹងថាប្រាកដជាមានជំងឺអ្វីប្លែកជាក់ជាមិនខាន ពីព្រោះខ្ញុំដើរក៏មិនស្រួលអង្គុយក៏មិនបាន ពេលប្រែខ្លួនឡើងក៏ឈឺចុកចាប់... ។ គឺក្នុងពេលនោះ ហើយដែលតម្រូវឲ្យខ្ញុំដើរដោយពឹងលើឈើច្រត់ ។

យើងបានត្រឡប់មកស្រុកខ្មែរវិញហើយ ។ បង**សយ** ក្រោយពីវះកាត់បេះដូងហើយ គាត់ដូចជាមានសុខភាពល្អជាងមុនច្រើន អាចដើរមើលថ្នាក់រៀនពីបន្ទប់មួយទៅបន្ទប់មួយ ឡើងពីជាន់មួយទៅជាន់មួយទៀតនៃអាគារផ្ទះល្វែងរបស់យើង។ គាត់អាចឡើងរហូតដល់ទៅជាន់ទី ៤ បានដោយឥតឃើញថាហត់សោះ។ ផ្ទុយពីខ្ញុំដែលអាចដើរក្រឡឹងបានត្រឹមតែជុំវិញបន្ទប់ផ្ទាល់ដីប៉ុណ្ណោះ។ លើសពីនេះ ជំងឺជង្គង់របស់ខ្ញុំចេះតែរើរបិតពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំស្រកស្រុតចុះទម្ងន់ស្គមទៅៗ ។ ខ្ញុំបានទទួលការ

ព្យាបាលម្តងថាឈឺនេះ ម្តងថាឈឺនោះ តាមអ្វីដែលពេទ្យវិនិច្ឆ័យរោគ។ តែខ្ញុំឥតបានធូរស្រាលឡើយ ។ គ្រួសារខ្ញុំក៏សម្រេចចិត្តនាំខ្ញុំទៅព្យាបាលជំងឺនៅប្រទេសវៀតណាម តាមយោបល់របស់អ្នកជិតខាងផង និងគ្រូដែលមកបង្រៀននៅសាលា " នគរភ្នំ " របស់ខ្ញុំផង ។ គេថាពេទ្យនៅ វៀតណាមពូកែណាស់ ! ។ កូនស្រីទី៤ របស់ខ្ញុំ ព្រមទាំងប្តីរបស់គេដែលជាវេជ្ជបណ្ឌិតទាំងពីរនាក់ បានជូនដំណើរខ្ញុំទៅពេទ្យនៅវៀតណាម និងនៅតាមដានជំងឺនិងនៅកំដរខ្ញុំរហូត ។ ខ្ញុំបានចូលសម្រាកពេទ្យអស់ ៤ កន្លែង ។ ខ្ញុំត្រូវបានគេបញ្ជូនចេញពីមន្ទីរពេទ្យមួយឲ្យទៅព្យាបាលនៅមន្ទីរពេទ្យមួយ ហើយទីបញ្ចប់ខ្ញុំត្រូវគេឲ្យទៅមន្ទីរពេទ្យ "ចារ៉យ" ដែលខ្មែរយើងនិយមទៅពិនិត្យជំងឺនៅទីនោះ ។ នៅក្នុងមន្ទីរពេទ្យចុងក្រោយនេះបានតែ ៣ថ្ងៃ ប៉ុណ្ណោះខ្ញុំក៏សុំគេចេញ ព្រោះខ្ញុំគ្មានឃើញអ្វីដែលគួរឲ្យសង្ឃឹមឡើយ ។ ខ្ញុំព្យាបាលនៅវៀតណាមអស់ជាងមួយខែ ។ ជំងឺរបស់ខ្ញុំកាន់តែដាបទៅ ។ ខ្ញុំចុះស្គមខ្លាំង កជើងប៉ុនកដៃ កដៃប៉ុនកវែក មានតែស្បែកដណ្តប់ឆ្អឹង ។ អំប៊ុយឡង់ដឹកខ្ញុំមកផ្ទះវិញ ។ កូនខ្ញុំព្រមទាំងបុគ្គលិកធ្វើការនៅសាលាឈររង់ចាំត្រៀបត្រា ។ គេបីខ្ញុំចុះពីឡាន សិស្សសាលាដែលឈរនៅតាមយ៉រថ្នាក់រៀនសម្លឹងមកមើលឡានទាំងអស់គ្នា ដោយដណ្តឹងសួរគ្នាអំពីហេតុការណ៍ពីអ្នកដែលគេបីចុះពីឡាន ។ អ្នកខ្លះថាប្រហែលជាបងប្អូនអុំម្ចាស់ផ្ទះ អ្នកខ្លះថាយាយនោះឈឺមកពីជនបទដើម្បីរកពេទ្យព្យាបាល ។ ល ។ មែន ! គេមើលខ្ញុំលែងស្គាល់ហើយ ព្រោះខ្ញុំបង់រូបបង់ឆោមអស់ប្រៀបបាននឹងអសុភទៅហើយ ។ ពេលខ្ញុំចូលដល់ក្នុងផ្ទះ គេដាក់ខ្ញុំនៅលើគ្រែ ។ ប្តីខ្ញុំស្ទុះមកអោបខ្ញុំដោយភាពក្តុកក្តួល រហូតដល់លឺសូរដង្ហក់ អស់មួយសន្ទុះធំ ។ តាំងពីពេលនោះមក ខ្លួនខ្ញុំត្រូវនៅលើគ្រែ ទាំងពេលបាយទឹក ទាំងពេលបត់ដៃបត់ជើង អស់រយៈពេលជាច្រើនខែ ។ ចៅប្រុសរបស់ប្តីខ្ញុំម្នាក់ដែលបានរៀនចប់ផ្នែកវេជ្ជសាស្ត្រនៅប្រទេសបារាំង ( **ស៊ាន មេត្តា** ហៅមិច ) បានមក

តាមដានជំងឺរបស់ខ្ញុំ ហើយឲ្យយោបល់ថា " ម៉ា! ម៉ាត្រូវបញ្ឈប់ពិសាស្ត្រវិញ ទាំងអស់នោះទៅ ម៉ាគួរបំប៉នចំណីអាហារ និងធ្វើចលនាដៃជើងឲ្យបានច្រើន និងទៀងទាត់វិញ "។ ខ្ញុំក៏ធ្វើតាមការណែនាំរបស់ចៅ មិច។ កូនស្រី ដុកទ័រ របស់ខ្ញុំ និងប្ដីគេដែលជាពេទ្យដែរនោះ តែងមកពិនិត្យសុខភាពរបស់ខ្ញុំ ព្រឹកល្ងាចៗរាល់ថ្ងៃ ។ ដោយមានការជួយជ្រោមជ្រែងពីគេរាល់គ្នាទាំងនោះ និងអ្នកថែទាំផ្ទាល់របស់ខ្ញុំផង សុខភាពរបស់ខ្ញុំបានប្រសើរពីមួយថ្ងៃ ពីដេកស្ដឹកនៅលើគ្រែ ទៅជាអាចអង្គុយបាននៅលើរទេះ អាចឈរបាន ដោយមានអ្នកជួយទប់ អាចឈានជើងបានដោយមានអ្នកជួយគ្រាហ៍ រហូត ដល់អាចដើរបានម្នាក់ឯង...រហូតមក ។

ក្រោយពេលដែលខ្ញុំបានជាសះស្បើយអំពីជំងឺធ្ងន់ធ្ងរនេះមក ខ្ញុំហាក់ ដូចជាមនុស្សថ្មីម្នាក់ ដែលមានចរិតខុសប្លែកពីមុនៗ ច្រើនមែនទែន ។ ខ្ញុំ លែងចង់តែងខ្លួន លាបម្សៅ លាបក្រែម ស្លៀកពាក់ខោអាវល្អៗ ទាន់ សម័យ... ដែលកាលពីមុនកន្លងមក ពេលចេញពីផ្ទះម្ដងៗ ខ្ញុំត្រូវចំណាយ ពេលយ៉ាងតិចកន្លះម៉ោង សម្រាប់តុបតែងកាយ ។ ផ្ទុយទៅវិញ ក្នុងពេល នេះ ខ្ញុំអត់ខ្វល់ពីបញ្ហាទាំងអស់នោះទាល់តែសោះ រហូតដល់ពេលខ្លះ ខ្ញុំមានអារម្មណ៍ខ្មាសគេទៅវិញ ពេលខ្ញុំទៅចូលរួមក្នុងពិធីអ្វីមួយ បើខ្ញុំស្លៀក ពាក់ល្អ តែងកាយបែបអភិជាតា (ស្ត្រីនៃត្រកូលខ្ពស់) នោះ ។ ក្នុងការរស់នៅ ប្រចាំថ្ងៃរបស់ខ្ញុំ ក៏មានការខុសប្លែកខ្លះៗដែរ ដូចជាខ្ញុំចង់ឃើញអ្វីដែល សម្រាប់ប្រើប្រាស់ជារបស់ល្អសម្អាតត្រឹមត្រូវ ហើយអ្វីដែលខ្ញុំញ៉ាំក៏ជារបស់ មានអនាម័យគឺឥតសំដៅលើវត្ថុប្រណិតអ្វីឡើយ ។ ការរើសអើងចំពោះវត្ថុ ទាំងនោះបានធ្វើឲ្យប្ដីខ្ញុំលាន់មាត់ថា " ខ្លួនឥឡូវម៉េចក៏ដូររើច្រើនប្លែះខុស ប្លែកពីមុនអញ្ចឹង? "។ ខ្ញុំយល់ចិត្តគាត់ គឺគាត់ចង់រិះគន់ខ្ញុំថា ឥឡូវខ្ញុំប្រែពាក្យ ហើយ ។ ខ្ញុំតមាត់ជាមួយគាត់ ដោយសួរគាត់វិញថា " តើអ្វីដែលខ្ញុំបាន ធ្វើដូចសព្វថ្ងៃនេះ រអ៊ូរទាំតែពីរឿងស្អាត រឿងកង្វះអនាម័យ គឺជារឿងអាក្រក់

មែនទេ? " ។ គាត់ឥតឆ្លើយ តែខ្ញុំនិយាយបន្តទៀតថា " បើវាអាក្រក់ បើវាធ្វើឲ្យខាតបង់ ឬជាការបំផ្លិចបំផ្លាញនោះ អញ្ចឹងខ្ញុំសូមសារភាពថាខ្ញុំពិតជាខុស ខ្ញុំពិតជាប្រែធាតុមែន... ក៏ប៉ុន្តែបើអ្វីៗដែលខ្ញុំបានធ្វើវាល្អ វាប្រសើរ នោះគឺខ្ញុំបានទទួលការវិវត្តន៍ពីអាក្រក់មកល្អហើយមែនទេ ? គួរតែបងឯងសរសើរខ្ញុំទៅវិញ " ។ បងសយនៅតែរក្សាភាពស្ងៀមស្ងាត់ឥតតបត ហើយក៏ដើរចេញយ៉ាងព្រងើយ ។ ខ្ញុំឥតខឹងនឹងគាត់ទេ ព្រោះខ្ញុំស្គាល់ចរិតរបស់គាត់ច្បាស់ណាស់ ។ គាត់ពុំមែនជាមនុស្សចេះបញ្ចើចបញ្ចើនរណាទេ ។ ប្រសិនបើគេនិយាយខុស គាត់តែងជួយកំណែតម្រង់ ហើយបើគាត់យល់ស្រប គាត់នៅស្ងៀមបែបនឹងឯង ។ ក្រោយទំនាស់ពាក្យសំដីនោះបន្តិចមក ខ្ញុំបានធ្វើការវិភាគខ្លះៗអំពីបម្រែបម្រួលចរិតលក្ខណៈរបស់មនុស្ស ។ បងសយបានមើលឃើញថាខ្ញុំប្រែប្រួលចរិត ។ មែន!ខ្ញុំដូរមែន ពីព្រោះពេលឈឺធ្ងន់ជិតស្លាប់ខ្ញុំអស់សង្ឃឹម ភ័យខ្លាចមច្ចុរាជខ្លាំងណាស់។ តែសំណាងហើយអាយុមិនទាន់អស់អាចជៀសផុតពីស្លាប់...។ គឺនៅពេលដែលខ្ញុំបានធូរស្រាលមួយថ្ងៃបន្តិចៗខ្ញុំតែងនឹកគិតពិចារណា លើអាយុសង្ខារបស់មនុស្សសត្វលោក ឃើញថាអ្វីក៏មិនប្រសើរជាងមានជីវិតប្រកបដោយសុខភាពដែរ ។ ភាពហ៊ឺហា ភាពរើសអើងគ្រប់សព្វបែបយ៉ាងសុទ្ធតែជាឧបសគ្គ ធ្វើឲ្យបាត់បង់នូវភាពស្ងប់ស្ងាត់ ជំរុញភ្លើងលោភៈ (លោភៈ – ទោសៈ– មោហៈ–រាគៈ ) ឲ្យផុតពេលវាលក្នុងសតិអារម្មណ៍ រួមរិត សង្កត់ខ្លួនប្រាណឲ្យទ្រុឌទ្រោម បាត់បង់សេចក្ដីសុខ...។ ទន្ទឹមនឹងការផ្លាស់ប្ដូរចិត្តគំនិតនេះ ខ្ញុំក៏បានប្រមើលមើលឃើញទៀតថា មនុស្សណាក៏តែងទទួលការប្រែប្រួលចរិតដែរ។ ជួនកាលគេប្រែពីល្អទៅអាក្រក់ (ចំពោះមនុស្សដែលចូលក្នុងសង្គមបរិយាកាសអាក្រក់ដែលមានភាគច្រើន ព្រោះវាធ្វើឲ្យអ្នកចំណូលថ្មីនោះសប្បាយភ្លើតភ្លើន) ។ ក៏ប៉ុន្តែ បើគេកែពីអាក្រក់ទៅល្អវិញនោះក៏មានដែរ តែចំនួនតិច ។ ខ្ញុំតែងគិតថា ចំពោះករណីក្រោយនេះ យើង

ពិតជាអាចជំរុញមនុស្សឲ្យទទួលការកែប្រែពីចរិតមិនល្អទៅជាចរិតល្អវិញបាន។ បញ្ហានេះ វាអាស្រ័យទៅលើសង្គមបរិយាកាសយ៉ាងពិតប្រាកដ។ យើងចង់បានមនុស្សល្អ ជាពលរដ្ឋល្អ គឺត្រូវរៀបចំសណ្តាប់ធ្នាប់នៅក្នុងសង្គមឲ្យបានល្អ។ គឺសង្គមត្រូវមានច្បាប់ មានការអនុវត្តន៍ច្បាប់ និងការដាក់ពិន័យក្នុងករណី មិនគោរពច្បាប់...។ មនុស្សត្រូវតែស្ថិតនៅក្រោមសំណាញ់ច្បាប់ ពុំអាចងាករេបានឡើយ ហើយត្រូវតែឋិតនៅក្នុងរបត់សង្គមជាដរាប ។ ឧទាហរណ៍ដូចជានៅក្នុងប្រទេសជឿនលឿនដែលពលរដ្ឋរបស់គេ គឺជាពលរដ្ឋល្អចេះគោរពច្បាប់របស់រដ្ឋ គឺដោយសារអ្នកដឹកនាំរបស់គេ ក៏គោរពច្បាប់ អនុវត្តច្បាប់ក្នុងស្មារតីបម្រើផលប្រយោជន៍ចំពោះពលរដ្ឋរបស់គេដែរ។ អ្នកដឹកនាំល្អ គឺជាមនុស្សមានសមត្ថភាពពូកែទាំងផ្លូវគំនិត និងផ្លូវចិត្តក៏ល្អបរិសុទ្ធ (ក្បាលល្អ + បេះដូងល្អ ) ។ គិតដល់បញ្ហានេះ ខ្ញុំមិនអស់សង្ឃឹមនឹងមនុស្សខ្មែរ ដែលគេតែង និយាយថាមាន-ហ្សែន-ជាមនុស្សបុគ្គលនិយមនោះទេ ។ មនុស្សខ្មែរ ក៏ដូចជាជាតិសាសន៍នានាដែរ អាចកែប្រែចរិតបានគ្រប់ពេលវេលា អាស្រ័យទៅលើបម្រែបម្រួលនៃរបត់សង្គម គឺសង្គមបរិយាកាសនេះតែម្តង ពីព្រោះគេពុំអាចដើរខុសផ្លូវដែលច្បាប់បានកំណត់ឲ្យមនុស្សអនុវត្តគ្រប់ៗគ្នានោះឡើយ ។

ឆ្នាំ ២០០៩ ខ្ញុំនិងប្តីខ្ញុំ ត្រូវបានកូនពៅធានាឲ្យមករស់នៅសហរដ្ឋអាមេរិក ។ យើងបានសិទ្ធិរស់នៅជាអចិន្ត្រៃយហើយ ។ យើងមកដល់អាមេរិកបានមួយអាទិត្យ ប្តីខ្ញុំធ្លាក់ខ្លួនឈឺ ( ដូលប៉ះក្បាលធ្វើឲ្យកកសរសៃឈាមក្នុងខួរក្បាល ) ដែលតម្រូវឲ្យមានការវះកាត់ ។ ក៏ប៉ុន្តែ ដោយសារភាពទ្រុឌទ្រោមរបស់គាត់ គាត់ពុំអាចទទួលការដាក់ថ្នាំសន្លប់បានទេ មិនថាទាំងនៅមន្ទីរពេទ្យក្រុង Salem មិនថាទាំងមន្ទីរពេទ្យនៅ St.Vincent ក៏ពេទ្យគេមិនអាចធ្វើការវះកាត់ឲ្យគាត់បានដែរ ។ គេតម្រូវឲ្យយកគាត់មកព្យាបាលនៅផ្ទះវិញ រង់ចាំពេលវេលាដ៏សមរម្យ សម្រាប់ជីវិតចុងក្រោយរបស់គាត់ ។

គេបានឲ្យពេទ្យនៅតាមស្រុក ( County ) មកជួយព្យាបាលរៀងរាល់ថ្ងៃ ព្រមទាំងឧបត្ថម្ភថ្នាំសង្កូវសព្វយ៉ាងដែលចាំបាច់។ នេះគឺជាការយកចិត្តទុកដាក់យ៉ាងពេញទំហឹងរបស់រដ្ឋាភិបាលនៃសហរដ្ឋអាមេរិកចំពោះអ្នកជំងឺទូទៅដោយឥតរើសមុខ ។ ក៏ប៉ុន្តែ ទោះបីស្ថានភាពជំងឺរបស់បងសយ ចូលដល់ដំណាក់ការនេះហើយក៏ដោយ ក៏ពួកយើងទាំងអស់គ្នានៅតែខំប្រឹងប្រែងថែទាំ និងព្យាបាលជំងឺរបស់គាត់ឲ្យអស់លទ្ធភាពដែរ ។ យើងផ្លាស់ប្តូរគ្នាមកជួយថែរក្សាគាត់ ( ក្មួយគំនិត នាងឧស្សាហ៍ នាងរចនា (៣) ក្មួយឡុង នាងដានី (នាងស្រី) ទាំងប្តី ទាំងប្រពន្ធជារៀងរាល់ថ្ងៃ ។ ក្រៅពីនេះ ក្មួយនៅរដ្ឋតិចសាស់ ( ក្មួយ ចន្ថា ក្មួយពីន ) កូនដានៅប្រទេសអូស្ត្រាលី កូនប្រសារ (វឌ្ឍនៈ) មកពីស្រុកខ្មែរ ក៏មកលើកទឹកចិត្តគាត់ដែរ។ បងសយតែងសម្លឹងមើលគេទាំងអស់នោះដោយទឹកមុខញញឹម តែគាត់មិនដែលនិយាយសួរសុខទុក្ខជាមួយពួកគេនោះឡើយ គ្រាន់តែឆ្លើយមួយម៉ាត់ពីរម៉ាត់ នៅពេលដែលគេសួរគាត់ថា " ឪ-ពុក ស្គាល់ខ្ញុំទេ? ចាំខ្ញុំបានទេ? "។ ជូនកាលគាត់ឆ្លើយត្រូវ ជូនកាលគាត់ឆ្លើយខុស បញ្ជាក់ថាគាត់បានបាត់បង់ការចងចាំអស់ច្រើនហើយ ។ តែអ្វីដែលគាត់តែងរំលឹកនិងនិយាយឈ្មោះជាច្រើនដង ច្រើនសារនោះគឺឈ្មោះប្អូនប្រុសរបស់គាត់ "គឹមស៊ា" ដែលបាត់បង់ជីវិតក្នុងសម័យខ្មែរក្រហម។ នេះមកពីអារម្មណ៍របស់គាត់នៅចងចាំអនុស្សាវរីយ៍នៃយុវវ័យរបស់គាត់ជាមួយប្អូន គឺ ៖ស៊ា របស់គាត់កាលនៅវត្តដំណាក់ក្នុងកុដិលោកគ្រូ "មហាឆាន់ " និងក្រោយមកទៀត ពេលគាត់ទាំងពីរនាក់ មករៀនជាមួយគ្នានៅភ្នំពេញ គាត់ទាំងពីរនាក់បងប្អូនមកស្នាក់នៅផ្ទះ " គ្រូចិក" ដែលកាលនោះអ្នកទាំងពីរបានជួបប្រទះនឹងបញ្ហាលំបាកៗជាច្រើនដែលគាត់ពុំអាចបំភ្លេចបាន និយាយរួមគឺគាត់ទាំងពីរមានអនុស្សាវរីយកំសត់ៗ ជាមួយគ្នាជាច្រើន ។

ទោះបីជាខំប្រឹងយ៉ាងណាក៏ដោយ ជំងឺរបស់គាត់កាន់តែដាបទៅៗ

គឺគាត់លែងចង់និយាយស្តី លែងចង់លេបបាយ លេបទឹក លែងស្គាល់កូនចៅហើយ គាត់ទទូចឲ្យនាំគាត់ទៅស្រុកខ្មែរវិញ។ យើងត្រូវតែបំពេញសំណូមពររបស់គាត់ហើយ ។ យើងសង្ឃឹមថាគាត់នឹងសប្បាយចិត្តរាចធ្វើឲ្យជំងឺរបស់គាត់បានធូរស្រាលបន្តិច ព្រោះម្យ៉ាងស្រុកខ្មែរគឺជាស្រុកកំណើតរបស់គាត់ជាស្រុកមួយដែលគាត់ស្រឡាញ់ជាងអ្វីៗទាំងអស់។ គាត់មានអនុស្សាវរីយ៍ល្អៗច្រើន និងមានមោទនភាពយ៉ាងក្រៃលែងដែលរស់នៅក្នុងនាមជាកុលបុត្រខ្មែរ លើទឹកដីដ៏ស្រស់ប្រិមប្រិយ៍នេះ។ ពេលយើងនាំគាត់ត្រឡប់មកស្រុកខ្មែរវិញ ក៏ឥតឃើញមានអ្វីប្រសើរឡើយ ទោះបីជាយើងទាំងអស់គ្នា ជាកូនជាចៅ ជាក្មួយ បានខំប្រឹងប្រែងព្យាបាលថែទាំ និងបំប៉នគាត់អស់ រយៈពេលជាច្រើនខែមកហើយក៏ដោយ ។

គួរឲ្យសង្វេគណាស់! លក្ខណៈសម្បត្តិដ៏ឧត្តុង្គឧត្តមដែលគាត់ធ្លាប់មានពីមុនមក ឥឡូវធ្លាក់ចុះស្ទើរបាត់បង់ ។ ឈ្មោះដែលអ្នកស្រុក និងគ្រួសាររបស់គាត់តែងហៅ " គឹមសាយ " ដែលមានន័យថា " តោមាស " គឺរាស័ក្តសមនឹងលក្ខណៈសម្បត្តិរបស់គាត់ដែលរឹងប៉ឹង ក្លាហាន និងមានឆន្ទៈមោះមុត ។ បើនិយាយអំពីសីលធម៌រស់នៅវិញ គាត់ជាមនុស្សឧស្សាហ៍ព្យាយាម អំណត់ និងទៀងត្រង់ ស្រឡាញ់ការរីកចម្រើនប្រកបដោយទស្សនៈវិស័យសេរីភាព និងយុត្តិធម៌ ។ លើសពីនេះទៅទៀត គាត់មានការចេះដឹងច្រើនទាំងក្នុងវិស័យអក្សរសាស្ត្រ និងក្នុងវិស័យវិទ្យាសាស្ត្រសង្គមដែលអ្នកនៅជាប់ក្នុងគុកគេ ៣ ជាមួយគាត់ តែងហៅគាត់ថា "គារចនានុក្រម" ។ តែក្នុងគ្រានេះ "តោមាស" បានក្លាយទៅជា "តោចាស់ អង្គុយក្តី" គ្មានព្រលឹងពុំអាចធ្វើចលនាអ្វីបានមានតែដង្ហើមចេញចូល និង បើកមាត់លេបអាហារដែលគេបញ្ចុកឲ្យតែប៉ុណ្ណោះ។ ពេលមានញាតិមិត្តមកសួរសុខទុក្ខ គាត់អាចញញឹមទទួលគេបានម្តងម្កាល តែគាត់ប្រឡំព្រោះគេហៅតស្ទូម្បីតែកូនបង្កើតរបស់គាត់ដែលនៅជាប់ជាមួយគាត់ក៏គាត់ចាំមុខ

ឈ្មោះដែរ ។ គឺមានតែរូបខ្ញុំមួយទេ ដែលគាត់ថាឈ្មោះមិនដែលខុស " គឺម៉ីង គឺប្រពន្ធ " (គាត់ធ្លាប់ហៅខ្ញុំថា "ម៉ីង " តាំងពីក្នុងសម័យប៉ុលពតមកម្ល៉េះ ) ។

យើងទាំងអស់គ្នា អាសូរគាត់ណាស់! ព្រោះជីវិតរបស់លោកតា **ពិន សយ** ឥតបានទទួលការព្រោសប្រណីអំពីធម្មជាតិឡើយ ។ គាត់បានលាចាក លោកយើងនេះ យ៉ាងស្ងប់ស្ងាត់ នៅម៉ោងប្រហែលជា ៤ ភ្លឺ នាថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១០ ចោលយើងទាំងអស់គ្នាទៅហើយ ដោយឥតបានផ្ដាំផ្ញើអ្វីមួយម៉ាត់សោះឡើយ ។ យើងតម្កល់សពគាត់ចំនួន ៥ថ្ងៃ តាមបែបពុទ្ធសាសនាផង តាមបែបចិនសែផង ដើម្បីឲ្យកូនចៅញាតិសន្ដាន និងមិត្តភក្តិ នៅជិតនៅឆ្ងាយមកជុំគ្នា ដើម្បីប្រារព្ធពិធីបុណ្យ និងចូលរួមរំលែកទុក្ខក្នុងឱកាសនោះដែរ ។



សពរបស់លោកតា ត្រូវយកទៅបញ្ចុះនៅ វត្តខ្វរ ក្នុងឃុំ ព្រែកលាប ស្រុកមុខកំពូល។ ឡានដង្ហែសពបានមកតម្រៀបគ្នា នៅតាមបណ្ដោយផ្លូវលំ (ផ្លូវលេខ១២២ សង្កាត់ទឹកល្អក់ទី១) តាំងពីព្រលឹមស្រាងៗ រង់ចាំពិធីកែលសពដង្ហែទៅបញ្ចុះ ។ សំឡេងភ្លេងខែកបន្លឺ ឡើងយ៉ាងលន្លង់លន្លោចលាយឡំនឹងសំឡេងស្រែកទ្រហោយំរបស់កូន ចៅដែលនឹកស្រណោចចិត្តត្បិតព្រលឹងដ៏ឧត្ដុង្គឧត្តមមួយកំពុងរៀបចំចេញចាកចោលពួកយើងហើយ...។ ឡានស៊ីរ៉ែនបើកផ្លូវរបស់តម្រួតចរាចរ ចាប់ចេញដំណើរនៅម៉ោង ៧ ព្រឹក ។ ឡានតម្កល់មឈូសអមដោយម៉ូតូធំ ពណ៌ស៤ គ្រឿងក៏ចេញដំណើរឆ្ពោះទៅព្រែកលាបឆ្លងស្ពានជ្រោយចង្វា ដោយរួតរះជៀសវាងការស្ទះផ្លូវដែលចរាចរកំពុងមមាញឹក។ ភ្លេងពិណពាទ្យបន្លឺសូរស័ព្ទគួរឲ្យរន្ធត់មែន តែពុំអាចប្រជែងជាមួយសំឡេងភ្លេងខែកដែលកំពុងចូលជ្រៅក្នុងចិត្តរបស់អ្នកដង្ហែក្បួនសពបានឡើយ ។

ក្បួនដង្ហែសព បានចូលទៅដល់វត្តខ្វរតម្រង់ទៅចេតិយមួយដែលសង់បែរមុខទៅរកទន្លេមេគង្គ ហើយនៅស្ដាំដៃជាប់នឹងមាត់ព្រែកដែលហូរតាមបណ្ដោយក្បែរនឹងរបងវត្ត ។ ទីតាំងចេតិយនេះ ត្រូវបានបងសយជ្រើសរើសដោយផ្ទាល់ទៅតាមនិស្ស័យរបស់គាត់ដែលស្រឡាញ់កន្លែងមាត់ទឹកមានជំនោរខ្យល់ទន្លេ...។ ចេតិយនេះបង **សយ** បានជ្រើសរើសប្លង់ និងក្បូរក្បាច់រចនាដោយផ្ទាល់ ទុកតាំងពីបួន-ប្រាំឆ្នាំកន្លងមកហើយ។ ក្រោយពេលដង្កល់សពចូលទៅក្នុងចេតិយ វិយោគកថាដ៏ក្រៀមក្រំ ស្រណោះអាឡោះអាល័យអានដោយកូនស្រីទី ៤ របស់លោកតា **គឺ សយ** ធ្វើឲ្យអ្នកចូលរួមក្នុងពិធីបញ្ចុះសពរបស់លោកតា ចុះចាញ់នឹងមនោសញ្ចេតនាក្ដុកក្ដួលហើយស្រក់ទឹកភ្នែកស្ទើរគ្រប់ៗគ្នា ។ សំឡេងអួលអាក់ញ័រៗដាច់ៗរបស់កូនស្រីទី៤ និងស្នូរយំដង្ហក់របស់កូន ចៅ បានជះតាមប្រដាប់បំពងសំឡេងឧឃោសនសព្ទ លាន់ឮរំពងពេញផ្ទៃវត្តទាំងមូល ។

យើងបានត្រឡប់មកលំនៅឋានវិញទាំងក្ដីសោកសៅ។ ខ្ញុំហេងហាង ក្នុងចិត្តក្រៃលែង ហើយក៏មិនចង់ចូលក្នុងផ្ទះភ្លាមដែរ ។ ខ្ញុំឈរសំឡឹង ទៅក្នុងផ្ទះ... ស្រាប់តែអនុស្សាវរីយ៍ដ៏សន្ធឹកសន្ធាប់នៃកម្រងជីវិតរបស់ខ្ញុំ និង គាត់បានផុសមកជាបន្តបន្ទាប់...។ ទេ! ខ្ញុំមិនចង់រំលឹកវាទេ! តែចំណុច ខ្លះ វាបង្ខំខ្ញុំជាពិសេសព្រឹត្តិការណ៍ថ្មីៗនេះ ដូចជានៅយប់ចុងក្រោយនៃជីវិត របស់គាត់ ។ គាត់សម្រាកនៅលើគ្រែអ្នកជំងឺក្បែរគ្រែរបស់ខ្ញុំ ហើយនៅ វេលាម៉ោង ៣ ភ្លឺ ខ្ញុំតែងងើបទៅសួរនាំគាត់ រួចផ្លាស់ខោកន្ទបឲ្យគាត់ ឃើញ ថាគាត់នៅមានដង្ហើមចេញចូលដូចធម្មតា តែប្រហែលជា ២ ម៉ោងក្រោយ មកកូនស្រីរបស់ខ្ញុំដែលធ្វើពេទ្យស្រែកហៅខ្ញុំថា " ម៉ែៗ! ពុកបានធ្វើដំណើរ ទៅហើយ!"។ ខ្ញុំស្ទុះងើបឡើងទាំងមមឹងមមាំងរួចស្រែកដាស់កូនចៅ ។ យើងទ្រហោយំទាំងអស់គ្នា...។ ខ្ញុំសម្លឹងទៅកន្លែងតម្កល់មឈូសដែលមាន ចងសាណាហ៊ា ( រាំងនន ) និងបដាព័ទ្ធជុំវិញឃើញនៅលើគំរបមឈូស ពាសទៅដោយផ្កាពណ៌សលៀងតម្រៀបជាគោមក្បាច់ ទម្លាក់រំយោល ផ្កាម្លិះ ព័ទ្ធជុំវិញមឈូសដែលអបទៅដោយកំរងផ្កាចងជា Crown មានចារិតអក្សរ ពណ៌សលើក្រណាត់ខ្មៅថា "អនិច្ចំ ទុក្ខំ អនត្តា " , "កើត ចាស់ ឈឺ ស្លាប់ " និង "ជាតិ ជរា ព្យាធិ មរណៈ"។ គួរោនផ្កាទាំងនោះបញ្ជូន មកពីអង្គការក្នុងស្រុក ( អង្គការដែលកូនស្រី ជុតិមាធ្វើការ ) និងមកពី អង្គការនៅសហរដ្ឋអាមេរិក ( ដែលកូនស្រីលៀនធ្វើការ ) ពីដន្លងខ្ញុំ និង សិស្សចាស់ៗរបស់ខ្ញុំផងដែរ ។ គេសម្ដែងនូវការចូលរួមមរណៈទុក្ខចំពោះ លោកតា និង ដើម្បីផ្ដល់ភាពកក់ក្ដៅដល់ជីវិតរបស់គ្រួសារខ្ញុំតទៅទៀត ។ ខ្ញុំឈរភ្លឹកអស់រយៈពេលយ៉ាងយូរ ទាល់តែកូនរបស់ខ្ញុំចាប់ទាញដៃខ្ញុំឲ្យចូល ក្នុងផ្ទះរកកន្លែងអង្គុយសម្រាក ពីព្រោះគេឃើញខ្ញុំកំពុងឋិតនៅក្នុងអារម្មណ៍ វិលវល់ និងក្នុងក្ដីស្រមៃដែលគ្មានព្រំដែន...។ មែន! ជីវិតមិនទៀង មែន ហើយ ត្រូវតែមានទីបញ្ចប់ដូចនេះឯង ។

ខ្ញុំអង្គុយតែម្នាក់ឯងយ៉ាងស្ងៀមស្ងាត់។ ខ្ញុំប្រមើលគិតលើជីវិតបច្ចុប្បន្ន និងអនាគតរបស់ខ្ញុំ។ ខ្ញុំឃើញច្បាស់ហើយ ! ខ្ញុំដកដង្ហើមយ៉ាងវែង ដើម្បីបន្ធូរភាពតានតឹង...។

ក្នុងជីវិតរបស់ខ្ញុំ ខ្ញុំបានជួបប្រទះនឹងរឿងល្អ រឿងអាក្រក់ ដូចជីវិតរបស់មនុស្សសត្វលោកទូទៅដ៏ទៃៗទៀតដែរ។ ក៏ប៉ុន្តែ អ្វីដែលធ្វើឲ្យខ្ញុំនឹកគិតថាជារឿងមិនធម្មតានោះគឺ " ក្នុងមួយជីវិតរបស់ខ្ញុំនេះ ឃើញតែការព្រាត់ប្រាស...។ តែសំណាងដែរ "ជួបហើយទើបព្រាត់ព្រាត់ ហើយទើបជួបៗៗ។ តើឥឡូវការព្រាត់របស់យើងក្នុងគ្រានេះ យ៉ាងម៉េចដែរ? – យើងលែងបានជួបគ្នាជារឿងរហូតហើយ! "។ គ្រាន់តែគិតដល់ត្រង់នេះ ភ្លាមទឹកភ្នែករលីងរលោងក៏បានមកដក់ក្នុងរង្វង់ភ្នែករបស់ខ្ញុំភ្លាមដែរ តែ វាក៏មិនព្រមហូរចេញធ្លាក់ចុះមកក្រោមទេ ពីព្រោះខ្ញុំហាក់ដូចជាលឺសម្លេងមួយមកនិយាយខ្សិបដាក់ត្រចៀកខ្ញុំថា: " កុំតូចចិត្តថ្វីនឹងការព្រាត់ប្រាស របស់អ្នកក្នុងពេលនេះ អ្នកនឹងបានជួបគ្នាវិញ ក្នុងពេលដែលអ្នកក្លាយទៅជាដី ហើយដីរបស់អ្នកទាំងពីរនឹងរលាយចូលគ្នាសម្រាប់ទុកឲ្យកូនចៅ និងមនុស្សម្នា ទូទៅដែលមានជីវិតរស់អាចពឹងពាក់ស្នាក់អាស្រ័យនៅ ជាតំណៗ តរៀងទៅ! "។

ខ្ញុំមានអារម្មណ៍ធូរស្រាលបន្តិចហើយ។ ខ្ញុំត្រូវខំប្រឹងរស់ៗដើម្បីរង់ចាំថ្ងៃខែ ឆ្នាំ ដែលធម្មជាតិលែងផ្តល់ការប្រោសសន្តោសប្រណីដល់ជីវិតដ៏កំសត់របស់ខ្ញុំ ហើយក៏ជាឱកាសដ៏សំខាន់មួយដែរសម្រាប់ឲ្យខ្ញុំបានតាមមើល កូនចៅ ញាតិផៅ ក្នុងស្មារតីជួយតម្រែតម្រង់ការប្រព្រឹត្តិរបស់គេឲ្យដើរទៅតាមគន្លងសីលធម៌បរិសុទ្ធនិងជាពិសេសមើលដំណើរឆ្ពោះទៅនៃប្រទេសខ្ញុំ។ នេះគឺជាឆន្ទៈដ៏មោះមុតរបស់ប្តីខ្ញុំ តាំងពីពេលគាត់នៅរស់ហើយក៏ជាចេតនារបស់ខ្ញុំដែរដែលចង់ឃើញភាពរីកចំរើននៃសង្គមខ្មែរដែលខ្ញុំសង្ឃឹមថានឹងមាន មុខមាត់ថ្មី ស្រស់ភ្លឺថ្លា ជាមិនខាន...។

## កំណាព្យ

- ជីវិតប្រសើរ គ្មានអ្វីគ្រាន់បើ ស្មើសុខភាពល្អ
  ប្រាជ្ញាឆ្លាតវៃ ក្នុងកាយបវរ ថាមពលពេញពោរ
  ឈ្នះគ្រប់ឧបសគ្គ ។
- ថ្វីត្បិតជីវិត មិនទៀងមែនពិត តាំងចិត្តជឿជាក់
  ទៅតាមដំណើរ ធម្មជាតិគួសឆ្លាក់ មនុស្សត្រូវពឹងពាក់
  លើទង្វើល្អ ។
- មួយ -កសាងខ្លួន បំពាក់ខ្ជាប់ខ្លួន ខ្លួនជាជំហរ
  ពីរ -អភិវឌ្ឍន៍ សង្គមស្មោះសរ បី-ចែកបន្ត
  រស់សុខអវសាន ។

សូមវិញ្ញាណក្ខន្ធរបស់បង **ពីន សយ** ដែលត្រូវជាប្តី ជាលោកឪពុក ជាឪពុកមា ជាជីតា បានទៅកាន់សុគតិភព! និងសូមឲ្យព្រលឹងដ៏ពិសិដ្ឋរបស់បងមកសណ្ឋិតនៅជាប់ក្នុងសណ្តានចិត្តរបស់កូនចៅទាំងអស់ក្នុងការកសាងខ្លួន ក្នុងការកសាងអនាគតសង្គមជាតិរបស់យើងតរៀងទៅ ៕

# ចប់

ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ជាទិវាខួបមរណភាព៣ឆ្នាំ

របស់បង **តឹខ សយ** ។ ខ្ញុំនិងកូន ក្មួយព្រមទាំងក្រុមគ្រួសារត្រកូល "**តឹខ**"



ទាំងអស់បានធ្វើពិធីសម្ពោធអាគារសម្ភព "**តឹខ ឃួត**" និងដាក់ប្រគល់

ជូនមណ្ឌលសុខភាពពួក ក្នុងស្រុកពួក ខេត្តសៀមរាប ដើម្បីឧទ្ទិស

ដល់វិញ្ញាណក្ខន្ធ បង **តឹខ សយ** ផង និងជាការរំលឹកគុណដល់មាតាបិតា

បង **តឹខ សយ** " លោកតា **តឹខ ឌី** និងលោកយាយ **ឃួត**" ដែលធ្លាប់

បានសាងសង់អាគារមន្ទីរពេទ្យនៅទីនោះជូនប្រជាជនក្នុងភូមិឃុំគាត់ ។